ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍បូកសរុប
## ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## ប្រចាំឆ្នាំ២០២១ និងទិសដៅការងារសម្រាប់ឆ្នាំ២០២២





ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

**រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០២២**

# មាតិកា


**I- សេចក្តីផ្តើម** ........ 1

**II- គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០** ........ 5

**III- លទ្ធផលជារួម** ........ 7

១.ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ ........ 8

២. កំណើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម ........ 9

៣. សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម ........ 9

៤.ស្ថានភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្ម ........ 10

**V- លទ្ធផលតាមអនុវិស័យ** ........ 10

១.បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច ........ 10

២.ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........ 30

៣.លទ្ធផលនៃការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម ........ 48

៤.លទ្ធផលនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ ........ 52

៥.លទ្ធផលនៃការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ........ 57

**VI- បញ្ហាប្រឈម** ........ 100

**VII- ទិសដៅអនុវត្ត** ........ 101

១. ផែនការជំរុញផលិតកម្មដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម ........ 101

២. ផែនការបង្កើនផលិតកម្មដំណាំកៅស៊ូ ........ 103

៣. ផែនការកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ........ 104

៤. ផែនការជំរុញការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍន៍វារីវប្បកម្ម ........ 105

៥. ផែនការជំរុញការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ ........ 106

**VIII- សេចក្តីសន្និដ្ឋាន** ........ 107

**តារាងឧបសម្ព័ន្ធ**

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០២១
# និងទិសដៅអនុវត្តឆ្នាំ២០២២

## I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ហើយវិស័យនេះបាន និងកំពុងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ធានាបាននូវសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបន្តជំរុញការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិ-ធុរកិច្ច ការលើកកម្ពស់ផលិតកម្មសត្វនិងសុខភាពសត្វ ការគ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍន៍វារីវប្បកម្ម ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ រួមទាំងការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ជាពិសេស ក្នុងកាលៈទេសៈដែលប្រទេសជាតិយើងកំពុងទទួលរងនូវហានិភ័យពីវិបត្តិជាសាកលនៃជំងឺឆ្លងកូវីដ-១៩នេះ។

ជាកត្តាសត្យានុម័ត "សន្តិភាព" គឺជាបុរេលក្ខខណ្ឌដ៏ចម្បង និងសំខាន់បំផុតសម្រាប់កសាងខឿនសេដ្ឋកិច្ច និងអភិវឌ្ឍសង្គមជាតិ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវវិធានការគោលនយោបាយនានាសំដៅធានានូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលមានភាពអនុគ្រោះសម្រាប់សកម្មភាពផុសផុលនៃការវិនិយោគ និងធុរកិច្ចក្នុងគ្រប់វិស័យ។ សេដ្ឋកិច្ចជាតិបានរីកធំធាត់យ៉ាងឆាប់រហ័ស ហើយរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាក៏កំពុងផ្លាស់ប្តូរពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលពឹងផ្អែកជាសំខាន់លើវិស័យឧស្សាហកម្ម និងសេវាកម្មវិញក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤។

ក្នុងឆ្នាំ២០២១នេះ ជំងឺកូវីដ-១៩ បានបន្តឆ្លងរាលដាលដល់ស្ទើរគ្រប់ប្រទេស នៅលើសាកលលោក ជាមួយនឹងភាពមិនប្រាកដប្រជាកាន់តែខ្ពស់ តាមរយៈការបំប្លែងខ្លួនជាប្រភេទវីរុសកូវីដ-១៩ថ្មីជាច្រើន ជាពិសេសមេរោគបំប្លែងថ្មី ដែលតា និងអូមីក្រុង ដែលមានលទ្ធភាពចម្លងកាន់តែខ្ពស់ និងអាចបង្កគ្រោះថ្នាក់ដល់អាយុជីវិតប្រជាជនកាន់តែខ្លាំងក្លាជាងមុន។ ជាមួយនឹងបញ្ហាប្រឈមនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកការចាក់វ៉ាក់សាំងជាវិធានការយុទ្ធសាស្ត្រគន្លឹះ ដើម្បីកាត់បន្ថយករណីឆ្លង និងឈឺធ្ងន់ និងពិសេសសំដៅឈានទៅសម្រេចបានភាពស៊ាំសហគមន៍ ដែលជាកត្តាជំរុញក្នុងការធានានូវការវិលត្រឡប់ឱ្យបានឆាប់រហ័សទៅរក "**ប្រក្រតីភាពថ្មី**" នៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជាទូទៅ និងកិច្ចដំណើរការនៃសង្គម-សេដ្ឋកិច្ច។

ផ្អែកតាមការវាយតម្លៃ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងអាចមានកំណើនក្នុងអត្រា៤% ដែលជាសញ្ញាមួយទ្រទ្រង់ដល់ការងើបឡើងវិញនៃសកម្មភាពពាណិជ្ជកម្ម-ធុរកិច្ចក្នុងស្រុក និងកំណើនវិជ្ជមាននៃសេដ្ឋកិច្ចសកល ក៏ដូចជាការកើនឡើងនូវតម្រូវការខាងក្រៅ ពិសេសការប្រើប្រាស់និងការវិនិយោគឯកជន ដែលជាលទ្ធផលនៃ (១).ការដាក់ចេញគោលនយោបាយគាំទ្រនៅតាមបណ្តាប្រទេសនានា (២).ការរំពឹងទុកនៃការងើបឡើងវិញជាបណ្តើរៗ

នៃសកម្មភាពសេដ្ឋកិច្ចដែលជំរុញដោយការចែកចាយ និងការចាក់វ៉ាក់សាំងបានកាន់តែទូលំទូលាយ និង(៣).ការសម្របខ្លួនរបស់ប្រជាជន និងអាជីវកម្មទៅនឹងវិបត្តិជំងឺកូវីដ-១៩។

តាមការវាយតម្លៃរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ**" ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាអាចនឹងសម្រេចបានអត្រាកំណើនត្រឹមតែ៣%ប៉ុណ្ណោះនៅក្នុងឆ្នាំ២០២១នេះ ដោយសារការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍បាន និងកំពុងបន្ទច់បង្អាក់យ៉ាងខ្លាំងដល់សកម្មភាពពាណិជ្ជកម្ម ដែលធ្វើឱ្យវិស័យទេសចរណ៍ វិស័យលក់ដុំ-លក់រាយ ដែលជាសកម្មភាពប្រើប្រាស់ក្នុងស្រុក វិស័យសំណង់ និងអចលនទ្រព្យបន្តធ្លាក់ចុះយ៉ាងគំហុក។

ដោយឡែក សម្រាប់ឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងសម្រេចបានក្នុងអត្រា ៥,៦% ដោយសារការសម្របខ្លួនបានទៅនឹង "**ប្រក្រតីភាពថ្មី**" ព្រមទាំងភាពធូរស្រាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ បន្ទាប់ពីការចាក់វ៉ាក់សាំងត្រូវបានអនុវត្តយ៉ាងទូលំទូលាយពេញផ្ទៃប្រទេស ដែលបានជួយជំរុញការងើបឡើងវិញសន្សឹមៗនៃវិស័យ និងអនុវិស័យជំរុញកំណើនសំខាន់ៗ ជាមួយនឹងភាពល្អប្រសើរឡើងវិញនៃកំណើសេដ្ឋកិច្ចសកល និងការងើបឡើងវិញសន្សឹមៗនៃរំហូរមនុស្ស និងរំហូរទុនវិនិយោគ ស្របពេលដែលការរីករាលដាលនៃជំងឺកូវីដ-១៩ ត្រូវបានរំពឹងថានឹងអាចគ្រប់គ្រងបាន។ ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចកម្ពុជាក៏បន្តប្រឈមនឹងហានិភ័យពីកត្តាខាងក្រៅ និងក្នុងប្រទេសផងដែរ ដែលទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជាបន្តត្រៀមខ្លួនប្រកបដោយស្មារតីប្រុងប្រយ័ត្ន បុរេសកម្ម និងបត់បែនខ្ពស់ក្នុងការរៀបចំ និងដាក់ចេញនូវគោលនយោបាយ និងវិធានការអន្តរាគមន៍ដើម្បីឆ្លើយតប និងសម្របតាមការវិវឌ្ឍនៃវិបត្តិឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ស្ថិតក្នុងកាលៈទេសៈដែលយើងកំពុងទទួលរងនូវបញ្ហាប្រឈមពីវិបត្តិនៃជំងឺកូវីដ-១៩នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអង្គភាពជំនាញជាសេនាធិការ បានខិតខំបំពេញកាតព្វកិច្ចចំពោះមុខនេះ សំដៅគាំទ្រ និងចូលរួមដោះស្រាយបញ្ហាជីវភាពប្រជាជនដែលបានជួបប្រទះក្នុងវិបត្តិនេះ និងបានប្រឹងប្រែងយ៉ាងសកម្មថែមទៀត ដើម្បី "ប្រែក្លាយកសិកម្មកម្ពុជា ជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព សំដៅបង្កើនប្រាក់ចំណូលគ្រួសារកសិករ" តាមអភិក្រមប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបយថាផល ឈានទៅរកដំណាក់កាលថ្មីដែលផ្តោតលើប្រពលវប្បកម្ម ព្រមទាំងលើកកម្ពស់ពិពិធភាវូបនីយកម្មដំណាំដែលមានសក្តានុពល មានផលចំណេញខ្ពស់ និងមានតម្រូវការទីផ្សារ រួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម។

ជាមួយគ្នានេះដែរ ក្រសួងបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនទៀតរួមមាន៖ ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធគាំទ្រដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនគុណភាពនៃការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ជំរុញការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំ និងធន់នឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ការអនុវត្តកសិកម្មតាមកិច្ចសន្យា ព្រមទាំងការកសាង និងពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាលើការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្របក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងគោលដៅរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិ-ពាណិជ្ជកម្ម និងការបង្កើនចំណូលថវិកាជាតិ។ គួរកត់សម្គាល់ថា ផលិតកម្មដំណាំស្រូវ និងដំណាំកសិឧស្សាហកម្មមានការវិវឌ្ឍឈានឡើងជាលំដាប់ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការជាតិនិងអន្តរជាតិនានា រដ្ឋបាលថ្នាក់ក្រោមជាតិ និង

ការចូលរួមយ៉ាងសកម្មពីប្រជាកសិករ ជាពិសេសការប្តូរទម្លាប់ពីការផលិតសម្រាប់ហូបចុកមកជាការផលិតសម្រាប់ពាណិជ្ជកម្ម និងការនាំចេញ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តធ្វើការណែនាំដល់គ្រប់អង្គភាពក្រោមឱវាទដែលពាក់ព័ន្ធ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ នៅក្នុងរដូវវស្សាឆ្នាំ២០២១ ឱ្យអនុវត្តនូវវិធានការចាំបាច់មួយចំនួនសំដៅជំរុញការអភិវឌ្ឍដំណាំស្រូវ ដំណាំសាកវប្បកម្មនិងដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ដោយលើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាព ដើម្បីផ្គត់ផ្គង់តម្រូវការប្រើប្រាស់របស់កសិករ និងទីផ្សារក្នុងស្រុក តាមរយៈការប្រើប្រាស់ពូជដំណាំមានគុណភាព ការធ្វើពិពិធកម្មប្រភេទដំណាំ ការអនុវត្តបង្កំបច្ចេកទេសទំនើប ការលើកកម្ពស់ការអនុវត្តកសិកម្មល្អ និងការផ្តល់សេវាបច្ចេកទេសកសិកម្មថ្មី និងបច្ចេកវិទ្យាវៃឆ្លាតធន់នឹងអាកាសធាតុដល់កសិករ និងសហគមន៍កសិកម្ម ពិសេសការត្រៀមបម្រុងគ្រាប់ពូជដំណាំក្រោមក្របខ័ណ្ឌប្រព័ន្ធស្បៀងបម្រុងកម្ពុជាសម្រាប់ចែកជូនដល់កសិករ ដើម្បីស្តារផលិតកម្មដំណាំគ្រប់ប្រភេទនៅតាមតំបន់ដែលរងគ្រោះដោយសារកត្តាធម្មជាតិនៅរដូវវស្សា។

ចំពោះអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ក្រសួងបានជំរុញការចិញ្ចឹមសត្វ ទាំងលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម សំដៅធានាការផ្គត់ផ្គង់សាច់ និងផលិតផលសត្វមានគុណភាព អនាម័យ និងសុវត្ថិភាព សម្រាប់បំពេញតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ ដោយបានបំផុស និងលើកទឹកចិត្តដល់ប្រជាកសិករដែលចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យបង្កើនផលិតកម្មសត្វប្រកបដោយប្រសិទ្ធភាព។ លើសពីនេះ ក្រសួងបានជំរុញក្រុមហ៊ុនចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យបង្កើនទុនវិនិយោគបន្ថែមទៀតក្នុងការពង្រីកកសិដ្ឋានចិញ្ចឹមសត្វ និងបង្កើនផលិតកម្មសត្វ ព្រមទាំងបានជំរុញឱ្យក្រុមហ៊ុនផលិតចំណីសត្វបង្កើនទុនសម្រាប់ការទិញវត្ថុធាតុដើមក្នុងស្រុក ដើម្បីបង្កើនការផលិតចំណីសត្វ ធានានូវគុណភាព សុវត្ថិភាព និងមានតម្លៃសមស្រប។ ជាមួយគ្នានេះ ក្រសួងបានជំរុញសមាគមចិញ្ចឹមសត្វឱ្យបន្តកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល រៀបចំផែនការផលិតកម្មសត្វស្របតាមវិធានជីវសុវត្ថិភាព ឬគោលការណ៍ណែនាំស្តីពីការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) ដើម្បីធានាបានការផ្គត់ផ្គង់សត្វ និងសាច់ សម្រាប់បម្រើដល់ការប្រើប្រាស់ក្នុងស្រុក។ ជាងនេះទៅទៀត ដើម្បីការពារផលិតកម្មចិញ្ចឹមជ្រូកក្នុងស្រុក និងរក្សាតម្លៃសមស្របសម្រាប់អ្នកផលិតនិងអ្នកហូបចុក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអនុសាសន៍របស់សម្តេចជាពិសេសក្នុងបរិបទកូវីដ-១៩ បានកំហិតការនាំចូលជ្រូករស់ពីប្រទេសជិតខាង ដែលយុទ្ធសាស្ត្រនេះធ្វើឱ្យការចិញ្ចឹមក្នុងស្រុកបានផុសផុល និងឆ្លើយតបទៅនឹងកង្វះខាតកន្លងមក។

ទន្ទឹមនឹងនេះដែរ ក្រសួងបានបន្តជំរុញការអភិវឌ្ឍវារីវប្បកម្មគ្រប់រូបភាពដល់ប្រជាកសិករ និងអ្នកវិនិយោគផ្នែកនេះ ដើម្បីធានាបាននូវការផ្គត់ផ្គង់ត្រី កាត់បន្ថយការនាំចូល រក្សាបានតុល្យភាពតម្លៃទីផ្សារ ព្រមទាំងធានាបាននូវគុណភាព និងសុវត្ថិភាពដល់អ្នកបរិភោគ បង្កើនការផលិតកូនត្រីពូជឱ្យបានគ្រប់គ្រាន់ ដើម្បីចែកចាយដល់កសិករនៅតំបន់ដែលមានសក្តានុពលក្នុងការធ្វើវារីវប្បកម្ម ផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងធនធានហិរញ្ញវត្ថុដល់សហគមន៍នេសាទ ដើម្បីបង្កើនប្រាក់ចំណូលបន្ថែមក្នុងការធ្វើវារីវប្បកម្ម។

ក្រសួងបានបន្តជំរុញឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ធ្វើការណែនាំដល់ប្រជាកសិករ និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងខ្សែច្រវាក់ផលិតកម្មកសិកម្មឱ្យត្រៀមលក្ខណៈក្នុងការបង្កបង្កើនផល ដើម្បីបង្កើនផលិតកម្មស្បៀងគ្រប់ប្រភេទប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងត្រូវសម្របសម្រួលសហការជាមួយអាជ្ញាធរមូលដ្ឋាន ពិនិត្យនិងកំណត់តំបន់មានប្រភពទឹក ឬតំបន់ដែលមានស្ថានភាពអំណោយផលនៅក្នុងមូលដ្ឋាន ជាពិសេសសម្របសម្រួលស្វែងរកលទ្ធភាពផ្គត់ផ្គង់ទឹក សម្រាប់ជំរុញផលិតកម្មដំណាំរដូវវស្សាឱ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ជាមួយគ្នានេះដែរ ក្រសួងបានជំរុញឱ្យមន្ទីរត្រូវធ្វើជាអន្តរការីជំរុញសកម្ម និងមានប្រសិទ្ធភាពក្នុងការភ្ជាប់ទំនាក់

ទំនងរវាងអ្នកផលិតជាមួយនឹងអ្នកប្រមូលទិញ តាមយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីធានាការផ្គត់ផ្គង់ និងថ្លៃកសិផលសមរម្យ។

ពាក់ព័ន្ធនឹងការគ្រប់គ្រងគម្រោង ក្រសួងបានស្នើឱ្យអង្គភាពអនុវត្តគម្រោងអភិវឌ្ឍន៍កសិកម្ម និងអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង ឱ្យជំរុញការអនុវត្តផែនការសកម្មភាពដែលបានអនុម័តរួច ដើម្បីបង្កើនផលិតកម្មស្បៀងអាហារ (បន្លែ ផ្លែឈើ ត្រី សាច់) សម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការហូបចុកក្នុងប្រទេសឱ្យបានគ្រប់គ្រាន់ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩នេះ។

ទាំងនេះគឺបានឆ្លុះបញ្ចាំងឱ្យឃើញថា ស្ថាប័នជាច្រើន ទាំងរដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍បាននិងកំពុងផ្តល់សេវាកម្ម ដើម្បីបង្កើនចំណេះដឹងនិងចំណេះធ្វើដល់កសិករនៅមូលដ្ឋាន ហើយកសិករភាគច្រើនបានទទួលយកនូវបទពិសោធន៍ និងទេពកោសល្យទាំងអស់នេះយកទៅអនុវត្តប្រកបដោយភាពឧស្សាហ៍ព្យាយាម និងគំនិតច្នៃប្រឌិតដោយទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់នៅក្នុងតំបន់ជាច្រើន ទៅតាមអនុវិស័យនីមួយៗ។ ដោយឡែកវិស័យឯកជនបានតម្រង់ទិសការផលិតឆ្ពោះទៅរកទីផ្សារនាំចេញ តាមរយៈការអនុវត្តគោលការណ៍ផលិតកម្មកសិកម្មតាមកិច្ចសន្យា ការបង្កើនសមត្ថភាពកែច្នៃ ធានាបានទាំងគុណភាព និងបរិមាណ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ ពិសេសការនាំចេញអង្ករសរីរាង្គ ចេកអំបូងលឿង ស្វាយកែវរមៀត ម្រេច ដំឡូងមី និងផលិតផលកសិកម្មសំខាន់ៗដ៏ទៃទៀតមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់។

ជាក់ស្តែងក្នុង ឆ្នាំ២០២១កន្លងទៅនេះ តម្លៃផលិតផលកសិកម្មសរុបមានទំហំ ១៨ ពាន់លានដុល្លារអាមេរិក កើនប្រមាណជាង ៤៣% ធៀបទៅនឹងតម្លៃផលិតផលកសិកម្មសរុបក្នុងឆ្នាំ២០២០ ក្នុងនោះ តម្លៃផលិតផលសរុបផ្នែកដំណាំមានទំហំ ១០,៥៣ពាន់លានដុល្លារអាមេរិក តម្លៃផលិតផលសរុបផ្នែកផលិតកម្មសត្វមានទំហំ ៥,១ ពាន់លានដុល្លារអាមេរិក តម្លៃផលិតផលផ្នែកជលផលមានទំហំ ១,៧៣ពាន់លានដុល្លារអាមេរិក តម្លៃផលិតផលផ្នែកព្រៃឈើមានទំហំជាង ៧៨,៦៣លានដុល្លារអាមេរិក និងតម្លៃផលិតផលសរុបផ្នែកកៅស៊ូមានទំហំជាង ៦១០លានដុល្លារអាមេរិក។ ដោយឡែក តម្លៃនៃការនាំចេញផលិតផលកសិកម្មសរុបសម្រាប់ឆ្នាំ២០២១ មានទំហំជាង ៥ ពាន់លានដុល្លារអាមេរិក ដែលមានកំណើន ២៥% ធៀបទៅនឹងការនាំផលិតផលកសិកម្មឆ្នាំ២០២០។

ការកែទម្រង់ស៊ីជម្រៅអនុវិស័យជលផលត្រូវបន្តបានអនុវត្តយ៉ាងសកម្ម។ កំណែទម្រង់នេះ បានធ្វើឱ្យប្រជាជនទូទៅ ជាពិសេសអ្នកប្រកបរបរនេសាទជាលក្ខណៈគ្រួសារ អាចធ្វើអាជីវកម្មបានទូលំទូលាយជាងមុន។ រហូតមកដល់ពេលនេះ យើងបានបង្កើតសហគមន៍នេសាទចំនួន៥១៦ ដើម្បីគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព តាមរយៈការអនុវត្តទិសស្លោក **“សហគមន៍នេសាទ គ្មានបទល្មើស”** ក្នុងគោលបំណងពង្រឹងសហគមន៍នេសាទឱ្យបានរឹងមាំ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមគ្រប់គ្រង ថែរក្សាការពារធនធានជលផលឱ្យបានគង់វង្ស និងការទាក់ទាញពីភ្ញៀវទេសចរផងដែរ។ ការធ្វើវារីវប្បកម្ម ពិសេសការចិញ្ចឹមបង្កង ត្រីរ៉ស់ ត្រីឆ្ពោ និងពពួកត្រីដែលមានតម្លៃទីផ្សារខ្ពស់ ទាំងជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្មត្រូវបានអនុវត្តយ៉ាងសកម្ម ហើយបានរួមចំណែកដល់ការបង្កើនប្រាក់ចំណូលក្នុងគ្រួសារ។

ជាក់ស្តែង នៅដើមខែធ្នូ ឆ្នាំ២០២១ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំពេញបេសកកម្មជាមួយក្រុមការងារអន្តរក្រសួងដែលដឹកនាំដោយ ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចុះមកពិនិត្យ និងចាត់វិធានការបង្ក្រាបការទន្ទ្រានដីរដ្ឋក្នុងដែនព្រៃលិចទឹកនៅតំបន់បឹងទន្លេសាបស្ថិតក្នុងខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ និងខេត្តសៀមរាប។ ជាលទ្ធផល ដីព្រៃលិចទឹកជុំវិញបឹងទន្លេសាបត្រូវបានដកហូត ប្រជាពលរដ្ឋចំនួន១៤ ៦៥៦ គ្រួសារ បានស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋទំហំ៦១ ១៦១.៧៦ហិកតា និងបានដាំកូនឈើព្រៃលិចទឹកចំនួន៤២ ២៣៥ដើម ឬស្សីចំនួន៨ ៤៤៩ដើម កូនត្នោតចំនួន៣៣៩ដើម និងគ្រាប់ត្នោតចំនួន២៤២ ២០៥គ្រាប់។ ទន្ទឹមនឹងនេះ វិធានការ

មួយចំនួនក៏ត្រូវបានដាក់ឱ្យអនុវត្ត រួមមាន៖ (១). ជូនរដ្ឋបាលខេត្តចេញលិខិតណែនាំដល់អាជ្ញាធរស្រុក ឃុំ បញ្ឈប់ការពិនិត្យបញ្ជាក់លើលិខិតសុំកាន់កាប់ដី និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីក្នុងដែនព្រៃលិចទឹក ព្រមទាំងចេញលិខិតបដិសេធលើរាល់លិខិតដែលបានចេញរួចពីពេលមុន (២). ចាត់វិធានការបញ្ឈប់ការចូលទន្ទ្រានដីដែនព្រៃលិចទឹកបន្តទៀត ធ្វើអត្តសញ្ញាណអ្នកដែលបានចូលទន្ទ្រានដើម្បីធ្វើការដកហូតដី និងចាត់វិធានការតាមផ្លូវច្បាប់ ដោយត្រូវកសាងអង្គហេតុ និងដាក់បណ្តឹងអាជ្ញាទៅតុលាការ (៣). ទន្ទឹមនឹងវិធានការផ្លូវច្បាប់ ជនល្មើសត្រូវដាំដើមឈើឡើងវិញលើផ្ទៃដីដែលបានទន្ទ្រាន (៤).កងកម្លាំងមានសមត្ថកិច្ច ត្រូវចាត់កម្លាំងចុះល្បាតតាមគោលដៅ ដើម្បីទប់ស្កាត់ការទន្ទ្រានដីព្រៃលិចទឹក និងអនុវត្តវិធានការច្បាប់ (៥). ដាំបង្គោលព្រំដែនព្រៃលិចទឹកដែលខ្វះ និងដែលបានដួលរលំ និងដាក់ពាក្យសុំចុះបញ្ជីដីរដ្ឋនូវដីព្រៃលិចទឹកតំបន់ទន្លេសាប (៦). ចំពោះប្រជាពលរដ្ឋដែលបានដាំដំណាំ ពិសេសដំណាំស្រូវ គឺទុកពេលឱ្យប្រមូលផល រួចស្នើឱ្យធ្វើលិខិតប្រគល់ដីព្រៃលិចទឹកជូនរដ្ឋវិញ (៧). ត្រូវដាំដើមឈើឡើងវិញ និងផ្តល់អាទិភាពលើការដាំដើមឫស្សីក្នុងតំបន់ព្រៃលិចទឹក។

ចំពោះការកែទម្រង់វិស័យព្រៃឈើ ក្រសួងបានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសពង្រឹងការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹង ព្រមទាំងសម្រេចបាននូវលទ្ធផលមួយចំនួនផងដែរ។ ជាការកត់សម្គាល់ ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា ឃើញថាទទួលបានប្រសិទ្ធភាពជាងមុន។ បន្ថែមលើសពីនេះ ក្រសួងក៏បានចូលរួមអនុវត្តយ៉ាងសកម្មជាមួយគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅទប់ស្កាត់ និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ឈើ ការនាំចេញឈើខុសច្បាប់ និងបទល្មើសនានានៅទូទាំងប្រទេស។ ទន្ទឹមនឹងនេះ ក្រសួងក៏សូមវាយតម្លៃខ្ពស់ចំពោះកិច្ចសហការល្អ និងការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានជលផល និងព្រៃឈើប្រកបដោយនិរន្តរភាពក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ជាពិសេសការបង្ក្រាបបទល្មើសតាមគ្រប់រូបភាពឱ្យទទួលបានលទ្ធផលល្អប្រសើរ ទោះបីនៅមានបញ្ហាខ្លះៗក៏ដោយ ពិសេសការរំខានពីការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។

## II- គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០

រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យរយៈពេលវែង ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាក៏មានមហិច្ឆិតាក្នុងការធ្វើទំនើបកម្មវិស័យកសិកម្ម ដើម្បីឱ្យវិស័យនេះកាន់តែមានភាពប្រកួតប្រជែង មានបរិយាប័ន្ន និងធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព។

គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០ ត្រូវបានរៀបចំ និងពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដោយបានផ្តល់នូវការតម្រង់ទិសយ៉ាងទូលំទូលាយ និងមុតស្រួច ដើម្បីអភិវឌ្ឍន៍វិស័យនេះ សម្រាប់ក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានារួមគ្នាអនុវត្ត។ គោលនយោបាយនេះបានដាក់ចេញនូវផ្នែកសំខាន់ៗចំនួន ៤ គឺ៖ (១) ការធ្វើទំនើបកម្ម និងពាណិជ្ជូបនីយកម្មក្នុងខ្សែច្រវាក់តម្លៃកសិកម្ម (២) ការវិនិយោគសាធារណៈ និងឯកជនក្នុងវិស័យកសិកម្ម (៣) កំណើនប្រកបដោយចីរភាព និងការបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និង (៤) ការកែទម្រង់ស្ថាប័ន និងបញ្ហាអន្តរវិស័យ។

គោលនយោបាយនេះមានគោលបំណងជំរុញកំណើនកសិកម្មប្រកបដោយភាពប្រកួតប្រជែង និងបរិយាប័ន្ន ដែលផ្តល់នូវផលិតផលមានគុណភាពខ្ពស់ មានសុវត្ថិភាព និងអាហារូបត្ថម្ភ សម្រាប់បំពេញសេចក្តីត្រូវការក្នុងស្រុក

និងការនាំចេញ ដោយត្រូវគិតគូរខ្ពស់ដល់ការគ្រប់គ្រងដីធ្លី ទឹក ធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។ ដើម្បីសម្រេចបាននូវគោលបំណងនេះ គោលដៅជាយុទ្ធសាស្ត្រចំនួន ៤ ត្រូវបានកំណត់ និងដាក់ឱ្យអនុវត្ត រួមមាន៖

(ទី១) លើកកម្ពស់ខ្សែច្រវាក់ផលិតកម្មកសិកម្មប្រកបដោយភាពប្រកួតប្រជែង។

(ទី២) បង្កើនការគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ឥណទាន និងការសម្រួលកសិ-ពាណិជ្ជកម្ម។

(ទី៣) បង្កើនការគ្រប់គ្រងធនធានដីកសិកម្ម ព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព។

(ទី៤) ពង្រឹងអភិបាលកិច្ច និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម។

ចំណុចសំខាន់នៃគោលនយោបាយនេះ គឺផ្តោតលើយុទ្ធសាស្ត្របង្កើនផលិតភាព និងជំរុញកំណើនកសិកម្ម សំដៅពង្រីកការនាំចេញផលិតផលកសិកម្ម ព្រមទាំងការសម្របសម្រួល និងការផ្លាស់ប្តូរទៅជាប្រព័ន្ធស្បៀងអាហារទំនើប និងប្រកបដោយនិរន្តរភាព។ ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មត្រូវបានសម្រួលឱ្យស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជាឆ្នាំ២០៣០ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ផែនការអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រប្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣។ ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ផែនការមេវិស័យកសិកម្មឆ្នាំ២០៣០ ក៏នឹងត្រូវបានរៀបចំជាបន្តទៀត ដោយត្រូវបង្ហាញយ៉ាងលម្អិត និងជាក់លាក់នូវសកម្មភាពគោលនយោបាយសម្រាប់អនុវត្ត។

យុទ្ធសាស្ត្រដែលបានរៀបរាប់ខាងលើ គឺផ្តោតសំខាន់លើការរៀបចំ និងការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាក់លាក់មួយ ដោយផ្អែកលើយន្តការសហការជិតស្និទ្ធ និងសម្របសម្រួលដើម្បីធានាការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មរហូតដល់ឆ្នាំ២០៣០ ប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មត្រូវការថវិកាពីប្រភពសំខាន់បីគឺ ថវិកាជាតិ ថវិកាដៃគូអភិវឌ្ឍន៍ និងការវិនិយោគរបស់វិស័យឯកជន។ ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវបន្តដាក់ចេញនូវកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពអាទិភាពសំខាន់ៗ សំដៅធ្វើការវិភាជន៍ថវិកាជាតិ និងថវិកាដែលបានមកពីដៃគូអភិវឌ្ឍន៍ឱ្យបានសមស្រប ឆ្លើយតបទៅនឹងសូចនាករកំណត់ក្នុងគោលនយោបាយនេះ។ ជាមួយគ្នានេះ ក្រសួងនិងស្ថាប័នពាក់ព័ន្ធត្រូវបង្កើតគម្រោងលម្អិតដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគសាធារណៈ (PIP) ផែនការរំកិលបីឆ្នាំ ដោយអនុលោមតាមសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលដើម្បីលើកកម្ពស់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយប្រសិទ្ធភាព។ ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយជោគជ័យ ក៏នឹងអាស្រ័យលើស្ថានការណ៍ក្នុងតំបន់ និងពិភពលោក ក៏ដូចជាសភាពការណ៍ក្នុងប្រទេស ដែលអាចជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលទៅលើដំណើរការនៃការធ្វើទំនើបកម្មកសិកម្ម ការប្រកួតប្រជែងកសិ-ពាណិជ្ជកម្ម ផលិតភាពនៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី និងកម្រិតនៃការវិនិយោគឯកជន។ ក្របខ័ណ្ឌនៃយន្តការពិនិត្យតាមដាន និងវាយតម្លៃនឹងត្រូវបានអនុវត្តនៅគ្រប់កម្រិតទាំងអស់នៅក្នុងកិច្ចការនេះ។ ការប្តេជ្ញាយ៉ាងមុតមាំក្នុងការសម្របសម្រួល និងអនុវត្តគឺជាមូលដ្ឋាននៃជោគជ័យ ដោយត្រូវប្រែក្លាយផែនការសកម្មភាពជាលក្ខណៈគោលនយោបាយដែលមានក្នុងគោលនយោបាយនេះ ឱ្យទៅជាការអនុវត្តជាក់ស្តែង តាមរយៈការខិតខំបង្កើន និងប្រើប្រាស់ធនធានក្នុងស្រុក ព្រមទាំងកៀរគរធនធានពីបណ្តាដៃគូអភិវឌ្ឍន៍ និងវិស័យឯកជននានា ក៏ដូចជាការធ្វើសមាហរណកម្មឱ្យគ្រប់តួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់ ចូលរួមអនុវត្តគោលនយោបាយនេះឱ្យសម្រេចបាននូវសមិទ្ធផលប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់។

## III- លទ្ធផលជារួម

នៅក្នុងឆ្នាំ២០២១នេះ ទឹកភ្លៀងបានចាប់ផ្តើមធ្លាក់យឺតជាងរដូវវស្សាឆ្នាំមុន និងមានកូនរដូវប្រាំងកើតឡើងនៅតាមបណ្តាខេត្តមួយចំនួន ពិសេសមានគ្រោះរាំងស្ងួតក្នុងអំឡុងខែសីហានិងដើមខែកញ្ញា និងជាចុងក្រោយគឺគ្រោះទឹកជំនន់បានកើតមានក្នុងអំឡុងខែតុលា ដែលបានបង្កការលំបាកដល់ដំណើរការបង្កបង្កើនផលដំណាំ។

មកទល់ពេលនេះ ជំងឺកូវីដ-១៩ បាននិងកំពុងរីករាលដាលនៅទូទាំងសកលលោក និងបានធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់សេដ្ឋកិច្ច សង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ជាមួយនឹងការខិតខំស្តារឡើងវិញនូវវិស័យបម្រើឱ្យសេដ្ឋកិច្ច វិស័យកសិកម្មបានឈរនៅក្នុងអាទិភាពមួយខ្ពស់ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ពិសេសពាក់ព័ន្ធនឹងការបង្កើនស្បៀងអាហារ អង្ករ ត្រីសាច់ឱ្យបានគ្រប់គ្រាន់ និងនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។ ផ្អែកលើកត្តាសត្យានុម័តនិងអត្តនោម័ត និងអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** លើវិធានការត្រៀមបម្រុងស្បៀងអាហារសម្រាប់ប្រជាពលរដ្ឋ ក្នុងស្ថានភាពដែលមានផលប៉ះពាល់ជាសកលបង្កដោយជំងឺកូវីដ-១៩ ការជំរុញអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ត្រូវបានវាយតម្លៃថាបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។ ក្នុងបរិការណ៍នេះ យុទ្ធនាការជាទ្រង់ទ្រាយធំក្នុងការបំផុសប្រជាកសិករនៅតាមមូលដ្ឋាន ដែលមានសក្តានុពលផលិតកម្មកសិកម្ម ឱ្យធ្វើការដាំដុះដំណាំស្បៀង ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ស្របតាមវិធានការបច្ចេកទេសកសិកម្មទំនើបត្រូវបានរៀបចំធ្វើយ៉ាងផុលផុស។ ជាមួយគ្នានេះ សន្ទុះនៃការអនុវត្តផែនការសកម្មភាពចាំបាច់ក្នុងស្ថានភាពបន្ទាន់ជាការឆ្លើយតប ដើម្បីបង្កើនផលិតកម្មស្បៀងប្រកបដោយគុណភាព និងសុវត្ថិភាព សំដៅរួមចំណែកបង្កើននូវឱកាសការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋនៅជនបទ ក៏ដូចជាពលករដែលបានត្រឡប់ពីបរទេសវិញ ក៏ត្រូវបានអនុវត្តយ៉ាងល្អប្រសើរ។ ម៉្យាងវិញទៀត សកម្មភាពឆ្លើយតបបន្ទាន់ក្នុងបណ្តាគម្រោងដែលកំពុងអនុវត្តក៏ត្រូវបានជំរុញយ៉ាងខ្លាំងក្លា ដើម្បីរួមចំណែកជួយដោះស្រាយបញ្ហាប្រឈមរបស់កសិករ ពិសេសបញ្ហាទឹកដោយការប្រើប្រព័ន្ធសន្សំសំចៃទឹក ការជួយជីកនិងស្តារស្រះ ត្រពាំង និងអណ្តូងជាដើម ការអប់រំបណ្តុះបណ្តាលកសិករណែនាំផ្សព្វផ្សាយអំពីបច្ចេកទេស ការអនុវត្តកសិកម្មល្អ និងការធ្វើហិរញ្ញប្បទានដល់ប្រជាកសិករតាមគ្រប់រូបភាព សំដៅដល់ការបង្កើតកសិដ្ឋានថ្មីៗ ព្រមទាំងគាំទ្រ និងពង្រីកទំហំផលិតកម្មស្បៀងដែលឆាប់ផ្តល់ផល។ល។

លើសពីនេះទៀត ការចិញ្ចឹមសត្វដើម្បីធានាការផ្គត់ផ្គង់សាច់ និងផលិតផលសត្វ សម្រាប់បំពេញតម្រូវការហូបចុករបស់ប្រជាពលរដ្ឋ ត្រូវបានវាយតម្លៃថាអនុវត្តបានល្អប្រសើរជាមួយនឹងការរៀបចំយុទ្ធនាការបំផុសដល់ប្រជាកសិករដែលចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ឱ្យបង្កើនការចិញ្ចឹមសត្វដែលមានវដ្តផលិតកម្មខ្លី និងដោះស្រាយបានទាន់ពេលវេលា បញ្ហាសន្តិសុខស្បៀងត្រូវបានធ្វើយ៉ាងយកចិត្តទុកដាក់ខ្ពស់។ បន្ថែមពីនេះ ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វថ្មីៗរបស់កសិករត្រូវបានពិនិត្យឃើញថាមានការកើនឡើងគួរឱ្យកត់សម្គាល់ និងក្រុមហ៊ុនឯកជនក៏ត្រូវបានជំរុញឱ្យមានការចិញ្ចឹមសត្វក្នុងទ្រង់ទ្រាយធំបន្ថែមទៀត ដើម្បីបម្រើសេចក្តីត្រូវការសាច់ក្នុងប្រទេស និងកាត់បន្ថយការនាំចូល។

ដើម្បីធានាបាននូវការផ្គត់ផ្គង់ត្រីសម្រាប់ប្រើប្រាស់ក្នុងស្រុក រក្សាបានតុល្យភាពតម្លៃទីផ្សារ ដែលរួមចំណែកធានាបាននូវសន្តិសុខស្បៀងគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋកម្ពុជា រដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត បានធ្វើយុទ្ធនាការទ្រង់ទ្រាយធំក្នុងការចុះជំរុញការអភិវឌ្ឍវារីវប្បកម្មតាមគ្រប់រូបភាពដល់ប្រជាកសិករ និងអ្នកវិនិយោគផ្នែកនេះ ដោយបានសហការជាមួយដៃគូអភិវឌ្ឍន៍ ព្រមទាំងបានលើកទឹកចិត្តដល់ការចិញ្ចឹមត្រីដែលមានវដ្តផលិតកម្មខ្លី ដូចជាការចិញ្ចឹមត្រីអណ្តែង កង្កែបនៅក្នុងតង់ផ្លាស្ទិក និងប្រភេទត្រីមួយចំនួនទៀតដែលមិនប្រើទុនវិនិយោគច្រើន ទីតាំងធំ និងទឹកច្រើន តែផ្តល់នូវផលល្អនិងឆាប់រហ័ស។

គ្រប់អង្គភាពជំនាញ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត បានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពខ្ពស់នូវធនធានដែលទទួលបានពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ក្នុងការបង្កើនយុទ្ធនាការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មនេះ។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម សំដៅជំរុញលើកកម្ពស់ផលិតភាពកសិកម្ម ទាំងបរិមាណនិងគុណភាព ដោយធានាបានសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល ក៏ដូចជាការគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយចីរភាព។

## ១. ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ

ក្នុងឆ្នាំ២០២១នេះ វិស័យកសិកម្មបានចូលរួមចំណែកប្រមាណ២៤,៤% (គិតតាមថ្លៃបច្ចុប្បន្ន) នៃផលិតផលសរុបក្នុងស្រុក។ ដោយឡែក វិស័យឧស្សាហកម្មបានរួមចំណែកប្រមាណ៣៨,៥% និងវិស័យសេវាកម្មប្រមាណ៣៧%។ ការកើនឬថយចុះនូវចំណែកនៃការចូលរួមរបស់វិស័យកសិកម្ម គឺអាស្រ័យទៅនឹងការរីកលូតលាស់នៃផ្នែកពីរសំខាន់ផ្សេងទៀតក្នុងវិស័យសេដ្ឋកិច្ច (វិស័យឧស្សាហកម្ម សំណង់ និងវិស័យសេវាកម្ម) ដែលជាការកត់សម្គាល់នាពេលកន្លងមក ការចូលរួមចំណែករបស់វិស័យកសិកម្មមានការប្រែប្រួលថយចុះពី២៤,៩% ដល់២៤,៤% ក្នុងចន្លោះឆ្នាំ២០១៧-២០២១។

**ក្រាហ្វិកទី១៖ ការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិ**




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២១

ទោះជាការចូលរួមចំណែករបស់វិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ យ៉ាងនេះក្តី ក៏តម្លៃបន្ថែមសរុប (គិតតាមតម្លៃបច្ចុប្បន្ន) នៃវិស័យកសិកម្ម (Agricultural Gross Value Added-GVA) គឺមានការកើនឡើងជារៀងរាល់ឆ្នាំ។ តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មបានកើនពី ១៨ ៩៩៩ ពាន់លានរៀលនៅឆ្នាំ២០១២ ដល់ ២០ ៩៨៦ពាន់លានរៀលនៅឆ្នាំ២០១៧ និងបានបន្តកើនដល់ ២៤ ៧៥៥ពាន់លានរៀលនៅឆ្នាំ២០២១។

### ក្រាហ្វិកទី២៖ កំណើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២១

## ២. កំណើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម

កំណើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម (Agricultural Gross Value Added- GVA) មានការប្រែប្រួលជាមធ្យមក្នុងចន្លោះពី៣%ទៅ៤% ក្នុងរយៈពេលពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ ដែលនេះជាសញ្ញាមួយវិជ្ជមានរបស់វិស័យក្នុងការចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជា។ ស្របពេលដែលប្រទេសកម្ពុជា ក៏ដូចជាបណ្តាប្រទេសនានាលើសាកលលោក បានជួបប្រទះនឹងការរីករាលដាលជំងឺកូវីដ-១៩ វិស័យកសិកម្មនៅតែរក្សាបាននូវកំណើននៃតម្លៃបន្ថែមវិជ្ជមានក្នុងរង្វង់ ៤,៧% ក្នុងឆ្នាំ២០២១នេះ។

### ក្រាហ្វិកទី៣៖ កំណើនតម្លៃបន្ថែមសរុបនៃវិស័យកសិកម្ម (តម្លៃបច្ចុប្បន្ន) ឆ្នាំ២០១២-២០២១




## ៣. សមាសភាគនៃអនុវិស័យក្នុងវិស័យកសិកម្ម

នៅឆ្នាំ២០២១នេះ ការចូលរួមចំណែកនៃអនុវិស័យក្នុងផលិតផលក្នុងស្រុកសរុបរបស់វិស័យកសិកម្ម រួមមាន៖ ផ្នែកដំណាំ៥៧,៤% ផ្នែកកៅស៊ូ៥,៧% ផ្នែកផលិតកម្មសត្វ១១,៤% ផ្នែកជលផល២៤,៤% និងផ្នែកព្រៃឈើ៧,៤%។ ជាការកត់សម្គាល់ផ្នែកដំណាំ និងជលផល គឺជាកម្លាំងចលករនាំមុខក្នុងវិស័យកសិកម្ម (ការចូលរួមចំណែកច្រើនជាងគេក្នុងវិស័យទាំងមូល)។ រីឯផលិតកម្មសត្វ ក៏ជាមុខព្រួញសំខាន់មួយទៀតក្នុងការផ្គត់ផ្គង់តម្រូវការសាច់ក្នុងស្រុកនិងបម្រើឱ្យការនាំចេញ ដែលផ្នែកទាំងនេះត្រូវជំរុញអភិវឌ្ឍឱ្យបានខ្លាំងក្លាផងដែរ។

ក្រាហ្វិកទី៤៖ ការចូលរួមចំណែករបស់អនុវិស័យកសិកម្ម (%)




ប្រភព៖ ក្រសួងផែនការឆ្នាំ២០២១

### ៤. ស្ថានភាពកម្លាំងពលកម្មក្នុងវិស័យកសិកម្ម

អត្រាកម្លាំងពលកម្មកសិកម្មធៀបនឹងពលកម្មសរុបបានបន្តធ្លាក់ចុះពី ៤១,៥% នាឆ្នាំ២០១៥ មកត្រឹម ៣៥,៥% នៅឆ្នាំ២០២០។ យន្តូបនីយកម្មកសិកម្មបានចូលមកជំនួសការបាត់បង់កម្លាំងពលកម្មកសិកម្ម ដោយក្នុងឆ្នាំ២០២០នេះ ការប្រើប្រាស់គ្រឿងយន្តកសិកម្មសម្រាប់ការងាររៀបចំដីស្រែមានជាង៩៩% និងការប្រមូលផលស្រូវដោយគ្រឿងយន្តមានប្រមាណ៨៥%។

**តារាង៖ ប្រៀបធៀបកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច**

| កម្លាំងពលកម្ម (ពាន់នាក់) | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៥ | | | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០២០ | | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | បុរស | សរុប | ស្ត្រី | បុរស |
| ចំនួនពលកម្មសរុប | ៨ ៣៥២ | ៤ ០២៩ | ៤ ៣២២ | ៨ ៨០៥ | ៤ ៣១៨ | ៤ ៤៨៧ |
| កសិកម្ម (%) | ៤១,៥ | ៤៣,៩ | ៣៩,៤ | ៣៥,៥ | ៣៨,០ | ៣៣,០ |
| ឧស្សាហកម្ម (%) | ២៥,៥ | ២៤,៨ | ២៦,១ | ២៦,១ | ២៤,២ | ២៧,៩ |
| សេវាកម្ម (%) | ៣៣,០ | ៣១,៣ | ៣៤,៥ | ៣៨,៤ | ៣៧,៨ | ៣៩,១ |
| សរុប (%) | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

ប្រភព៖ ក្រសួងផែនការឆ្នាំ២០២០ (អង្កេតសេដ្ឋកិច្ចសង្គមកិច្ច)

## V- លទ្ធផលតាមអនុវិស័យ

### ១. បង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្ម និងកសិធុរកិច្ច

#### ក. ផលិតកម្មដំណាំស្រូវ

ក្នុងឆ្នាំ២០២១នេះ ផ្ទៃដីដាំដុះដំណាំស្រូវសរុបទូទាំងប្រទេស សម្រេចបានចំនួន ៣,៥៥លានហិកតា ស្មើនឹង ១១៦%នៃផែនការ ក្នុងនោះស្រូវរដូវប្រាំងមានចំនួន ០,៦៥លានហិកតា និងស្រូវរដូវវស្សាមានចំនួន ២,៩០លានហិកតា ដែលផ្ទៃដីដាំដុះសរុបនេះ កើនឡើងចំនួន ៤,៤១% ធៀបនឹងផ្ទៃដីដាំដុះសរុបនៅឆ្នាំ២០២០។ ផ្ទៃដីប្រមូល

ផលសរុបមានចំនួន ៣,៥០លានហិកតា ក្នុងនោះស្រូវរដូវប្រាំងមានចំនួន ០,៦៥លានហិកតា និងស្រូវរដូវវស្សា ចំនួន ២,៨៥លានហិកតា។ បរិមាណផលស្រូវសរុបទទួលបានចំនួន ១២,២១លានតោន ក្នុងនោះ បរិមាណផលស្រូវរដូវប្រាំងទទួលបាន ២,៩៣លានតោន និងបរិមាណផលស្រូវរដូវវស្សា ទទួលបាន ៩,២៨លានតោន ដែលបរិមាណផលស្រូវសរុបនេះ កើនឡើងចំនួន ១,២៧លានតោន ឬស្មើនឹង ១១,៦% ធៀបនឹងឆ្នាំ២០២០។ ទិន្នផលស្រូវមធ្យមប្រចាំឆ្នាំទទួលបាន ៣,៤៩០តោន/ហិកតា ក្នុងនោះ ទិន្នផលស្រូវប្រាំងទទួលបាន ៤,៥៣៤តោន/ហិកតា និងទិន្នផលស្រូវវស្សាទទួលបាន ៣,២៥៤តោន/ហិកតា។ ដោយឡែក ការភ្ជួររាស់ដោយគ្រឿងយន្តបនីយកម្មកសិកម្ម សម្រេចបានចំនួន៣,៥៦លានហិកតា ស្មើនឹង៩៩,៤២% និងដោយគោក្របីសម្រេចបាន ០,០២លានហិកតា ស្មើនឹង ០,៥៨% នៃផ្ទៃដីភ្ជួររាស់សរុប ចំនួន ៣,៥៨លានហិកតា។

**ក្រាហ្វិកទី៥៖ បង្ហាញពីកំណើនបរិមាណផល និងទិន្នផលនៃផលិតកម្មដំណាំស្រូវឆ្នាំ២០១៧-២០២១**




តាមរយៈលទ្ធផលសម្រេចបានខាងលើនេះបង្ហាញថា ស្ថានភាពផលិតកម្មដំណាំស្រូវនៅឆ្នាំ២០២១នេះ មានការកើនឡើងគួរឱ្យកត់សម្គាល់ សម្រាប់ការប្រើប្រាស់ក្នុងស្រុក និងការកែច្នៃនាំចេញ។

**ខ. ផលិតកម្មដំណាំសាកវប្បកម្ម**

នៅឆ្នាំ២០២១ ផ្ទៃដីដាំដុះដំណាំសាកវប្បកម្មសម្រេចបានចំនួន៣០៨ ៣៩០ហិកតា និងទទួលបានបរិមាណផលចំនួន៤ ៣៦៥ ៨៧៨តោន ក្នុងនោះផ្ទៃដីដុះដំណាំសាកវប្បកម្មរយៈពេលខ្លីសម្រេចបាន ៧៤ ៩០១ហិកតា ថយចុះចំនួន ៣០ ៤៥៥ហិកតា ស្មើនឹង២៩% ធៀបនឹងឆ្នាំ២០២០ (ដោយសារទិន្នន័យដំណាំសាកវប្បកម្មរយៈពេលខ្លីមួយចំនួនដូចជា ពោតស ដំឡូងជ្វា និងដំឡូងឈើ ត្រូវបានបញ្ចូលក្នុងដំណាំឧស្សាហកម្មរយៈពេលខ្លី)។ ចំពោះផ្ទៃដីប្រមូលផលសម្រេចបានចំនួន ៧៤ ៥៤២ហិកតា ដោយទទួលបានបរិមាណផលចំនួន ១ ១០៧ ៦១១តោន កើនឡើងចំនួន ៨៧ ៣៩៧តោន ស្មើនឹង ៨,៥៧% ធៀបនឹងឆ្នាំ២០២០ ។

ដោយឡែក ផ្ទៃដីដាំដុះដំណាំសាកវប្បកម្មរយៈពេលវែងសំខាន់ៗ រួមមាន ដំណាំចេក អនុវត្តសរុបបានចំនួន ៤៣ ៥៩៣ហិកតា និងទទួលបានបរិមាណផលសរុបចំនួន ៦១៥ ៩១២តោន (ក្នុងនោះ ចេកអំបូងលឿងមានចំនួន ១៤ ៨៨៦ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ២៦៣ ១៤២តោន) ដំណាំស្វាយ អនុវត្តសរុបបានចំនួន ១៥២ ០៧៣ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ២ ១៩៧ ២៦៥តោន ដំណាំម្រៀន/ម្រៀនប៉ៃលិន អនុវត្តសរុបបានចំនួន ១២ ៨៣៧ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ១៣១ ៤៩៨តោន ដំណាំទុរេន អនុវត្តសរុបបានចំនួន ៥ ៤៥២ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ៤៧ ៤៥០តោន និងដំណាំស្រកានាគ អនុវត្តសរុបបានចំនួន ២៩៣ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ២ ១៥៤តោន។

**ក្រាហ្វិកទី៦៖ បង្ហាញពីកំណើនផលិតកម្មដំណាំសាកវប្បកម្មឆ្នាំ២០១៧-២០២១**




### គ. ផលិតកម្មដំណាំឧស្សាហកម្ម

នៅឆ្នាំ២០២១ ផ្ទៃដីដំណាំឧស្សាកម្មសម្រេចបានចំនួន១ ៤៥៣ ៥៣០ហិកតា ផ្ទៃដីប្រមូលផលមានចំនួន ១ ៣០០ ៦៩០ហិកតា និងទទួលបានបរិមាណផលចំនួន១៩ ១៥៨ ៩៩៥តោន ក្នុងនោះផ្ទៃដីផលិតកម្មដំណាំឧស្សាហកម្មរយៈពេលខ្លីសម្រេចបានចំនួន ៩៦០ ៨០៧ហិកតា កើនឡើងចំនួន ៨៥ ៦៧៤ហិកតា ស្មើនឹង១០% ធៀបនឹងឆ្នាំ២០២០ ដោយទទួលបានបរិមាណផលចំនួន ១៥ ៦៩៤ ៨៧៨តោន។ ជាការកត់សម្គាល់ផ្ទៃដីដាំដុះដំណាំដំឡូងមីសម្រេចបានចំនួន ៧៣២ ៣២៨ហិកតា លើសឆ្នាំមុនចំនួន ១០៣ ៤៣៤ហិកតា ស្មើនឹង១៦% ដោយទទួលបានបរិមាណផលចំនួន ១៤ ៧២៨ ៥២០តោន ដំណាំពោតក្រហមបានចំនួន ១២៥ ០១២ហិកតា ថយចុះចំនួន ២៩ ៥៨៦ហិកតា ស្មើនឹង១៩% ដោយទទួលបានបរិមាណផលចំនួន ៦៩៩ ០៧៥តោន និងដំណាំអំពៅបានចំនួន ៤៦ ៩២៣ហិកតា កើនលើសឆ្នាំមុនចំនួន ៣០ ៩៣១ហិកតា ស្មើនឹង១៩៣% ដោយទទួលបានបរិមាណផលចំនួន ២ ៤២១ ៩៦៥តោន។

ដោយឡែក ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មរយៈពេលវែងសំខាន់ៗអនុវត្តបានចំនួន ៤៩២ ៧២៣ហិកតា ដោយទទួលបានបរិមាណផលសរុបប្រមាណ ៣ ៤៦៤ ១១៧តោន។ ដំណាំឧស្សាហកម្មរយៈពេលវែងសំខាន់ៗរួមមាន ដំណាំស្វាយចន្ទីអនុវត្តបាន ៤០៥ ៩៩១ហិកតា ដោយទទួលបានបរិមាណផលសរុប ៤៧២ ៦៣៦តោន ដំណាំម្រេចអនុវត្តបាន ៦ ៥៨៨ហិកតា ដោយទទួលបានបរិមាណផលសរុប ១៨ ៣៧៣តោន ដំណាំកាហ្វេអនុវត្តបាន ៣៩៨ហិកតា ដោយទទួលបានបរិមាណផលសរុប ៦៧៥តោន និងដំណាំដូងអនុវត្តបាន ១២ ៦២៧ហិកតា ដោយទទួលបានបរិមាណផល ១៩០ ៥២៤តោន។

**ក្រាហ្វិកទី៧៖ បង្ហាញពីស្ថានភាពផលិតកម្មដំណាំឧស្សាហកម្មរយៈពេលខ្លីឆ្នាំ២០១៧-២០២១**



### ឃ. ការលើកកម្ពស់គុណភាព សុវត្ថិភាព និងការនាំចេញផលិតផលដំណាំកសិកម្ម

កិច្ចខិតខំប្រឹងប្រែង ដើម្បីលើកកម្ពស់គុណភាព និងសុវត្ថិភាពស្បៀង កំពុងត្រូវបានយកចិត្តទុកដាក់យ៉ាងសកម្ម តាមរយៈការអនុវត្តប្រព័ន្ធផលិតកម្មធានាគុណភាព និងសុវត្ថិភាពស្បៀង មានដូចជា៖ ការអនុវត្តកសិកម្មល្អកម្ពុជាសម្រាប់បន្លែនិងផ្លែឈើ ការអនុវត្តប្រព័ន្ធធានាដោយមានការចូលរួម (Participatory Guarantee System -PGS) និងការអនុវត្តកសិកម្មសរីរាង្គ។ ក្រសួងបានចុះបញ្ជីជាចម្ការអនុវត្តកសិកម្មល្អកម្ពុជា ចំនួន១២៧ ចម្ការ/ កសិដ្ឋាន និងបានបំពាក់ប្រព័ន្ធ QR Code។

ការនាំចេញផលិតផលកសិកម្មសរុបសម្រេចបានចំនួន ១៥ ៣៩៥ ៧៦៩តោន ក្នុងនោះការនាំចេញផលិតផលកសិកម្មសរុបមានវិញ្ញាបនបត្រចំនួន ៧ ៩៨៤ ២៥២តោន។ ការនាំចេញកសិផលមានវិញ្ញាបនបត្រច្រើនជាងគេរួមមាន ស្រូវមានចំនួន ២ ១៨៧ ១៧៧តោន ចំណិតដំឡូងមីក្រៀមមានចំនួន ១ ៦៤៤ ៥៩២តោន ដំឡូងមីស្រស់មានចំនួន ១ ១០៤ ២២២តោន អង្ករមានចំនួន ៦១៧ ០៦៩តោន ផ្លែចេកស្រស់មានចំនួន ៤២៣ ១៦៩តោន ផ្លែស្វាយស្រស់មានចំនួន ២៤២ ៤៨៤តោន និងគ្រាប់ពោតមានចំនួន ២០១ ៥៨៩តោន។

ដោយឡែក ការនាំចេញអង្ករទាំង ៦១៧ ០៦៩តោននេះ គឺនាំចេញទៅប្រទេសចិនច្រើនជាងគេ បានចំនួន ៣០៩ ៧០៩តោន ស្មើនឹង ៥០,១៩% ទៅសហភាពអឺរ៉ុបបានចំនួន ១៥៥ ៧៧៣តោន ស្មើនឹង ២៥,២៤% ទៅប្រទេសក្នុងតំបន់អាស៊ាន បានចំនួន ៦៣ ១៦៥តោន ស្មើនឹង ១០,២៣% និងទៅប្រទេសផ្សេងៗទៀតបានចំនួន ៨៨ ៤២២តោន ស្មើនឹង ១៤,៣៤% នៃការនាំចេញអង្ករសរុប។ ប្រភេទអង្ករនាំចេញ រួមមាន អង្ករក្រអូបគ្រប់ប្រភេទចំនួន ៤៥៧ ៤១៥តោន អង្ករសចម្រុះចំនួន ១៤៩ ០៨០តោន និងអង្ករចំហុយចំនួន ១០ ៥៧៤តោន។

**ក្រាហ្វិកទី៨៖ ស្ថានភាពនៃការនាំចេញផលិតផលកសិកម្មសរុប និងការនាំចេញអង្ករផ្លូវការឆ្នាំ២០១៧-២០២១**




ក្រៅពីនេះ ក្រសួងបានធ្វើការចរចារបើកទីផ្សារនាំចេញផលិតផលកសិកម្មសំខាន់ៗ ដោយសម្រេចបាន៖ (១) ចុះហត្ថលេខាលើពិធីសារ ស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យ សម្រាប់ការនាំចេញផ្លែស្វាយស្រស់ទៅកាន់ប្រទេសចិន (២) បើកទីផ្សារជាមួយប្រទេសវៀតណាម ស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃការនាំចេញផ្លែក្រូចថ្លុងមៀន និងផ្លែខ្នុរ។

### ង. ការអភិវឌ្ឍន៍សហគមន៍កសិកម្ម

ក្នុងឆ្នាំ២០២១ សហគមន៍កសិកម្មចំនួន ១៧សហគមន៍ត្រូវបានបង្កើត ដោយនៅទូទាំងប្រទេស មានសហគមន៍កសិកម្មសរុបចំនួន ១ ២១៧សហគមន៍ ដែលមានម្ចាស់ភាគហ៊ុនសរុបចំនួន ១៥៥ ៨៥៩នាក់ ក្នុងនោះមានសមាជិកជាស្ត្រីចំនួន ៩៨ ៩០០នាក់ ស្មើនឹងប្រមាណ៦៤% នៃសមាជិកសរុប ប្រាក់ភាគហ៊ុនសរុបមានចំនួន ៥០ ២៧៩

លានរៀល (ស្មើនឹង១២,៥លានដុល្លារអាមេរិក) ដែលជាថវិកាផ្ទាល់របស់ប្រជាកសិករក្នុងការវិនិយោគក្នុងសហគមន៍កសិកម្មរបស់ខ្លួន និងដើមទុនសរុបមានចំនួន១០២ ៤៦៧លានរៀល (ស្មើនឹង២៥,៦លានដុល្លារអាមេរិក)។

ទន្ទឹមនឹងនេះ ក្រសួងបានសម្របសម្រួលចងក្រងសហគមន៍កសិកម្មឱ្យទៅជាសហភាពសហគមន៍កសិកម្ម បានចំនួន៥ ដែលរហូតមកដល់បច្ចុប្បន្ននេះបានចំនួនសរុប ១៥ ដែលមានសហគមន៍កសិកម្មជាសមាជិកចំនួន២៧៦ សហគមន៍កសិកម្ម មានភាគហ៊ុនសរុបចំនួន ១ ៧០៣ហ៊ុន ដែលមានប្រាក់ភាគហ៊ុនសរុបចំនួន ១ ៨០៩លានរៀល (ត្រូវជាប្រមាណ ៤៥២ពាន់ដុល្លារអាមេរិក) ដែលជាថវិកាផ្ទាល់របស់សហគមន៍កសិកម្ម វិនិយោគក្នុងសហភាពសហគមន៍កសិកម្មរបស់ខ្លួន និងដើមទុនសរុបមានចំនួន ៣ ៣៨៣ លានរៀល (ត្រូវជាប្រមាណ ៨៤៦ ពាន់ដុល្លារអាមេរិក)។ ក្រៅពីនេះ អគ្គនាយកដ្ឋានកសិកម្ម បានសម្របសម្រួលបង្កើត សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាបានចំនួន ០១ ដែលមានសហគមន៍កសិកម្ម និងសហភាពសហគមន៍កសិកម្មជាសមាជិក ដែលសម្ព័ន្ធសហគមន៍កសិកម្មនេះ ត្រូវបានចុះបញ្ជីនិងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ក្រាហ្វិកទី៩៖ ចំនួនសហគមន៍កសិកម្មឆ្នាំ២០០៣-២០២១**




### ច. ការគ្រប់គ្រង និងប្រើប្រាស់ធនធានដីកសិកម្ម

ក្នុងឆ្នាំ២០២១នេះ ក្រសួងបានធ្វើបច្ចុប្បន្នភាពផែនទីចំណាត់ថ្នាក់ដីដាំដុះដំណាំស្រូវ សិក្សាវាយតម្លៃបម្រែបម្រួលការប្រើប្រាស់ដីដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម ការសិក្សាពីជម្រើសបច្ចេកទេសកសិកម្មវៃឆ្លាតនឹងអាកាសធាតុ លើការគ្រប់គ្រងទឹកនិងដី ការសិក្សាផ្ទៀងផ្ទាត់ទិន្នន័យស្ថិតិដំណាំស្រូវតាមប្រព័ន្ធព័ត៌មានផ្កាយរណប និងបានផលិតផែនទីប្រព័ន្ធក្សេត្របរិស្ថានដំណាំស្រូវ (បច្ចេកវិទ្យា RIICE) ការចុះប្រមូលទិន្នន័យអំពីសេដ្ឋកិច្ចសង្គម បរិស្ថានសម្រាប់កំណត់តំបន់ដាំដុះកសិកម្ម និងវាយតម្លៃកម្រិតសាយភាយបច្ចេកទេសសម្រាប់គ្រប់គ្រងជីជាតិដី ការលើកកម្ពស់ការអនុវត្តល្អដើម្បីទប់ស្កាត់ឱនភាពដីនៅតំបន់ខ្ពង់រាប ការធ្វើផែនទីកំណត់តំបន់ដាំដុះកសិកម្ម ការផលិតផែនទីប្រភេទដីទូទាំងប្រទេសនិងសម្រាប់ខេត្តទាំង២៤ និងការស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្មអភិរក្ស។

**១. ការធ្វើបច្ចុប្បន្នភាពផែនទីចំណាត់ថ្នាក់ដីដាំដុះស្រូវ នៅខេត្តពោធិ៍សាត់**

ចំណាត់ថ្នាក់ដីដាំដុះស្រូវនៅខេត្តពោធិ៍សាត់ ត្រូវបានធ្វើបច្ចុប្បន្នភាព និងបែងចែកជា ០៩ ប្រភេទ (ឬក្រុមដី) (ប្រើប្រព័ន្ធធ្វើចំណាត់ដីសម្រាប់ផលិតកម្មដំណាំស្រូវនៅកម្ពុជា) ដែលមានផ្ទៃដីសរុប ១៩៨ ៦៥៩ ហ.ត ក្នុងនោះ

មាន ១.ក្រុមដីបាកាន (៣៨%) ២.ក្រុមដីក្បាលពោធិ៍ (៤%) ៣.ក្រុមដីកៀនស្វាយ (២%) ៤.ក្រុមដីក្រគរ ៩៨%) ៥.ក្រុមដីប្រទះឡាង (១២%) ៦.ក្រុមដីប្រទះឡាង/បាកាន (១៨%) ៧.ក្រុមដីព្រៃខ្មែរ (៣%) ៨.ក្រុមដីទួលសំរោង (១៥%) និង៩.ដីពុំទាន់ធ្វើអត្តសញ្ញាណ (១%)។

### ២. ការសិក្សាវាយតម្លៃបម្រែបម្រួលការប្រើប្រាស់ដីលើដំណាំស្រូវ នៅខេត្តសៀមរាប

លទ្ធផលនៃការសិក្សាបានបង្ហាញថា ពីឆ្នាំ២០០២ ដល់ឆ្នាំ២០២១ ផ្ទៃដីដាំដុះស្រូវក្នុងខេត្តសៀមរាបបានកើនឡើងចំនួន ៧១ ៧៥៧ ហ.ត (+២៦%)។ ជាមួយគ្នានេះដីចម្ការដំណាំក្រៅពីស្រូវក៏បានកើនឡើងយ៉ាងខ្លាំងផងដែរ (+២៤%) ហើយប្រភេទប្រើប្រាស់ដីផ្សេងទៀតក៏បានកើនឡើងដែរ។

**តារាងស្តីពីបម្រែបម្រួលនៃប្រភេទប្រើប្រាស់ដីកសិកម្មក្នុងខេត្តសៀមរាបឆ្នាំ២០០២-២០២១**

| ល.រ | ប្រភេទប្រើប្រាស់ដី | បម្រែបម្រួលផ្ទៃដី (ហ.ត) | | |
|---|---|---|---|---|
| | | ឆ្នាំ២០០២ | ឆ្នាំ២០២១ | បម្រែបម្រួល |
| ១ | ដីចម្ការដំណាំ | ៤២៩៥ | ១០៥៨៧៥ | ១០១៥៨០ |
| ២ | វាលស្រែ | ២៧៩០៦៥ | ៣៥០៨២២ | ៧១៧៥៧ |
| ៣ | ដីចម្ការកៅស៊ូ | 0 | ១១៤៥៩ | ១១៤៥៩ |
| ៤ | ដីចម្ការតាមភូមិនិងភូមិឋានប្រជាពលរដ្ឋ | ១៧៦៥៨ | ៤១១៥០ | ២៣៤៩២ |
| ៥ | ផ្ទៃទឹក | ១៥២០៨ | ១៨៤៩៧ | ៣២៩០ |
| **ផ្ទៃដី សរុប** | | **៣១៦២២៥** | **៥២៧៨០៣** | **២១១៥៧៨** |

### ៣. ការសិក្សាវាយតម្លៃបម្រែបម្រួលការប្រើប្រាស់ដីលើដំណាំកសិកម្ម នៅក្នុងខេត្តបាត់ដំបង

លទ្ធផលនៃការសិក្សាបានបង្ហាញថា ពីឆ្នាំ២០០២ ដល់ឆ្នាំ២០២១ ផ្ទៃដីដាំដុះកសិកម្មក្នុងខេត្តបាត់ដំបងបានកើនឡើងចំនួន ៤៧៥ ៤១២ ហ.ត (+១២៧%) ក្នុងនោះ ដីចម្ការដំណាំបានកើនឡើងចំនួន ២៦៥ ៤៤៣ ហ.ត ដីចម្ការឈើហូបផ្លែបានកើនឡើងចំនួន ៩៨៨ ហ.ត ដីស្រែបានកើនឡើងចំនួន ១៨៣ ៦៧៣ ហ.ត និងដីចម្ការតាមភូមិបានកើនឡើងចំនួន ២៧ ៦៥៥ ហ.ត។ ចំណែកឯកសិកម្មពនេរចរ ពុំមានវត្តមានទៀតឡើយ។

**តារាងស្តីពីបម្រែបម្រួលនៃប្រភេទប្រើប្រាស់ដីកសិកម្មក្នុងខេត្តបាត់ដំបង ឆ្នាំ២០០២-២០២១**

| ល.រ | ប្រភេទប្រើប្រាស់ដី | បម្រែបម្រួលផ្ទៃដី (ហ.ត) | | |
|---|---|---|---|---|
| | | ឆ្នាំ២០០២ | ឆ្នាំ២០២១ | បម្រែបម្រួល |
| ១ | ដីចម្ការដំណាំ | ៤៧៧៥៨ | ៣១៣២០១ | ២៦៥៤៤៣ |
| ២ | ដីចម្ការឈើហូបផ្លែ | ១៦៦ | ១១៥៤ | ៩៨៨ |
| ៣ | វាលស្រែ | ២៨០៤៩៤ | ៤៦៤១៦៧ | ១៨៣៦៧៣ |
| ៤ | ដីចម្ការកៅស៊ូ | 0 | 0 | 0 |
| ៥ | កសិកម្មពនេចរ | ៦៣៧២ | 0 | -៦៣៧២ |
| ៦ | ដីចម្ការតាមភូមិនិងភូមិឋានប្រជាពលរដ្ឋ | ៣៣៩៩៩ | ៦១៦៥៤ | ២៧៦៥៥ |
| ៧ | ផ្ទៃទឹក | ៦៦៧៦ | ១០៧០២ | ៤០២៦ |
| **ផ្ទៃដី សរុប** | | **៣៧៥៤៦៦** | **៨៥០៨៧៨** | **៤៧៥៤១២** |

### ៤. ការងារកំណត់តំបន់ដាំដុះកសិកម្ម

បានបំពេញកិច្ចប្រជុំគណៈកម្មាធិការកំណត់តំបន់ដាំដុះកសិកម្មស្តីពី វឌ្ឍនភាពការងារ និងទិសដៅសម្រាប់អនុវត្តបន្តដែលដឹកនាំដោយ ឯកឧត្តម តូច ប៊ុនហួរ រដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មាធិការកំណត់តំបន់ដាំដុះកសិកម្មកម្ពុជា។ បានប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី របាយការណ៍លទ្ធផលនៃការប្រមូលទិន្នន័យស្តីពីសេដ្ឋកិច្ចសង្គម និងបរិស្ថានសម្រាប់កំណត់តំបន់ដាំដុះកសិកម្មដែលមានអ្នកចូលរួមសរុបចំនួន២៥នាក់ (ស្ត្រី៥នាក់) នៅអគ្គនាយកដ្ឋានកសិកម្ម។ បានផលិតផែនទីសំខាន់មួយចំនួនរួមមាន៖ ផែនទីមេដើម្បីបែងចែកតំបន់កសិកម្ម ផែនទីប្រភេទដីទូទាំងប្រទេស និងសម្រាប់ខេត្តទាំង២៤ ផែនទីប្រភទនៃការប្រើប្រាស់ដីកសិកម្មទូទាំងប្រទេស ផែនទីតំបន់ដាំដុះស្រូវ និងប្រព័ន្ធក្បេត្របរិស្ថានដំណាំស្រូវ។ បាននិងកំពុងដំណើរការផលិតផែនទីតំបន់ដាំដុះដំណាំផ្សេងៗមានដូចជា ស្វាយ ស្វាយចន្ទី ដំឡូងមី ពោត ទុរេន មៀនប៉ៃលិនជាដើម។ បាននិងកំពុងដំណើរការវាយតម្លៃភាពសមស្របនៃដីសម្រាប់ដំណាំ ស្វាយ ស្វាយចន្ទី ដំឡូងមី ពោត ទុរេន ម្រេច កប្បាស និងល្ងៃ ដើម្បីធ្វើបច្ចុប្បន្នភាពផែនទីភាពសមស្របនៃដីសម្រាប់ដំណាំកសិកម្មសំខាន់ៗ។




ផែនទីមេកំណត់តំបន់អភិវឌ្ឍន៍កសិកម្មមាន ៤តំបន់ធំៗគឺ តំបន់ឆ្នេរ (Coastal Zone) តំបន់ទំនាបទន្លេមេគង្គក្រោម (Lower Mekong Plain Zone) តំបន់បឹងទន្លេសាប (Tonle Sap Lake Zone) និងតំបន់ខ្ពង់រាបទន្លេមេគង្គលើ (Upper Mekong Plateau Zone)។

### ឆ. ការពិសោធន៍ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម

- បានពិសោធស្រាវជ្រាវបច្ចេកទេសដាំដុះស្រូវពូជសែនក្រអូប០១ ដោយប្រើប្រាស់ឧបករណ៍ដាំគ្រាប់ (Eli seeder) នៅកសិដ្ឋានផលិតពូជស្រូវទួលសំរោង ខេត្តបាត់ដំបង។ ពិសោធន៍នេះមាន៤បថ្ម័យ គឺ T1. ដាំជាគុម្ពដោយឧបករណ៍នាំចូលពីប្រទេសថៃ កម្រិតគ្រាប់ពូជ ១០០គីឡូក្រាម/ហិកតា T2. ព្រោះគ្រាប់ដោយដៃតាមទម្លាប់

កសិករ កម្រិតគ្រាប់ពូជ១៥០គីឡូក្រាម/ហិកតា T3. ដាំគ្រាប់ស្ងួតដោយឧបករណ៍ថៃយើតនាំចូលពីប្រទេសថៃ កម្រិតគ្រាប់ពូជ១០០គីឡូក្រាម/ហិកតា និង T4.ដាំគ្រាប់សើមលើដីភក់ដោយឧបករណ៍ Eli Seeder ប្រើគ្រាប់ពូជក្នុងកម្រិត ១០០គីឡូក្រាម/ហិកតា។ តាមលទ្ធផលពិសោធន៍បង្ហាញថា បច្ច័យទី២ ទទួលបានទិន្នផលខ្ពស់ជាងគេគឺ ៤ ៨២៥គីឡូក្រាម/ហិកតា បន្ទាប់មកបច្ច័យទី៤គឺ ៤ ៧៩៩គីឡូក្រាម/ហិកតា បច្ច័យទី៣គឺ ៤ ៥០៧គីឡូក្រាម/ហិកតា និងបច្ច័យទី១ ទទួលបានទិន្នផលទាបជាងគេគឺ ៤ ២៩៥គីឡូក្រាម/ហិកតា

- បានធ្វើការពិសោធន៍ប្រៀបធៀបពូជពោតចំនួន ១០ពូជ ដែលធន់នឹងជំងឺឫសទៅលើទិន្នផល។ លទ្ធផលបង្ហាញពូជពោត Pionee-4554 ទទួលបានទិន្នផលខ្ពស់ជាងគេគឺ ៩,០៩តោន/ហិកតា បន្ទាប់គឺពូជ CHM01 ដែលជាពូជអ៊ីប្រ៊ីតលើកដំបូងរបស់កម្ពុជា ទទួលបានទិន្នផល ៩,០៧តោន/ហិកតា នៅពេលដែលពូជពោត CHM02 ដែលជាប្រភេទពូជពោតអ៊ីប្រ៊ីតទី២របស់កម្ពុជា ដែលគ្រោងនឹងបញ្ចេញក្នុងពេលឆាប់ៗទទួលបានទិន្នផល ៨,៣៨តោន/ហិកតា

**តារាង៖ បង្ហាញពីលទ្ធផលពិសោធន៍តាមដានទិន្នផលនៃពូជពោត CHM02 រយៈពេល៣ឆ្នាំកន្លងមក**

| Line | DS-2019 | WS-2020 | DS-2020 | WS-2021 | Mean |
|---|---|---|---|---|---|
| CHM01 | 9.05 | 8.91 | 9.09 | 9.23 | 9.07±0.13 |
| **CHM02** | **7.79** | **8.06** | **8.78** | **8.91** | **8.38±0.55** |
| Pacific- 99 | 8.51 | 8.33 | 8.64 | 8.87 | 8.58±0.23 |
| GT-709 | 8.19 | 8.42 | 8.55 | 8.46 | 8.40±0.15 |
| GT-822 | 8.28 | 8.33 | 8.69 | 8.82 | 8.53±0.27 |
| Pionee-4554 | 9.09 | 8.96 | 9.18 | 9.14 | 9.09±0.10 |
| SK-100 | 7.11 | 7.61 | 7.11 | 7.56 | 7.35±0.27 |
| CP-888 | 5.94 | 6.66 | 6.17 | 6.62 | 6.35±0.35 |
| LVN-10 | 6.44 | 6.71 | 6.39 | 6.71 | 6.56±0.17 |
| BT-7723 | 6.98 | 6.84 | 6.98 | 6.89 | 6.92±0.07 |
| Total Line | 10 | 10 | 10 | 10 | |
| Mean | 7.74±1.08 | 7.88±0.88 | 7.96±1.16 | 8.12±1.06 | |
| Maximum | 9.09 | 8.96 | 9.18 | 9.23 | |
| Minimum | 5.94 | 6.66 | 6.17 | 6.62 | |

- បានរចនាប្លង់ធុងប្រអប់ត្រជាក់ ( Cool Box ) សម្រាប់ដាក់បន្លែផ្លែឈើដោយប្រើកម្មវិធី Solid Work និងបន្តស្រាវជ្រាវ បច្ចេកទេសរចនាប្លង់នៃឧបករណ៍ផ្សេងៗ ដោយប្រើកម្មវិធី Solid Work
- បានពិសោធន៍ដាំដំណាំស្រោចស្រពដោយប្រព័ន្ធតំណក់ទឹក និងដាំដុះបន្លែលើទឹកប្រព័ន្ធ Hydroponic
- ពិសោធន៍ជីវប្រសិទ្ធិភាពថ្នាំកសិកម្មនៅទីវាល៖ ការងារពិសោធន៍ជីវប្រសិទ្ធភាពថ្នាំកសិកម្មនៅទីវាលនៃថ្នាំកសិកម្មពីក្រុមហ៊ុនលក់ ចែកចាយសម្ភារៈ និងថ្នាំកសិកម្មសរុបចំនួន៤៩២មុខរួមមាន៖ (១) ថ្នាំកម្ចាត់សត្វល្អិត១៩៧មុខ (២) ថ្នាំកម្ចាត់រុក្ខជាតិចង្រៃ១២៩មុខ (៣) ថ្នាំកម្ចាត់ជំងឺផ្សិត១២៤មុខ (៤) ថ្នាំជំរុញការលូតលាស់ ៤០មុខ និង(៥) ថ្នាំកម្ចាត់ខ្យងមាស០២មុខ។
- ពិសោធន៍ចិញ្ចឹមដង្កូវ FAW និង Cotcyra cephalonica ក្នុងបន្ទប់ពិសោធ៍ដើម្បីយកពងរបស់វា ឱ្យ Telenomus remus បន្តវដ្តជីវិត
- សិក្សាស្រាវជ្រាវលើការវិភាគគុណភាពគ្រាប់ពូជ និងមីក្រូសារពាង្គកាយក្នុងជីជីវសាស្ត្រ និងថ្នាំជីវសាស្ត្រ
- បានរៀបចំពិសោធន៍សម្តែងកម្មនៅទីវាលលើប្រភេទពូជដំណាំពោតនិងស្រូវដែលបានស្នើសុំបញ្ជាក់គុណភាព
- សិក្សាស្រាវជ្រាវប្រភេទពូជដំណាំទុរេន ចំនួន ២៤សួនក្នុងខេត្តចំនួន៣ ដំណាំម្រេច ចំនួន ១៤កន្លែងក្នុងខេត្តចំនួន៤ និងដំណាំមៀន ចំនួន ៧ខេត្ត។

### ជ. ការងារបណ្តុះបណ្តាលបច្ចេកទេសកសិកម្មក្នុងអនុវិស័យដំណាំ

ក្រសួងបានបណ្តុះបណ្តាល និងផ្ទេរបច្ចេកទេសដល់មន្ត្រីបច្ចេកទេសកសិកម្ម ក្រុមហ៊ុន ម្ចាស់កសិដ្ឋាន សហគមន៍កសិកម្ម កសិករគំរូ អំពីបច្ចេកទេសកសិកម្មថ្មីៗទំនើប ការគ្រប់គ្រងកសិដ្ឋាន ការត្រួតពិនិត្យគុណភាព ការចុះបញ្ជី ការបញ្ជាក់គុណភាពនិងការផលិតពូជដំណាំ បង្កំបច្ចេកទេសដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម វិធានការចម្រុះគ្រប់គ្រងនិងថែរក្សាជីជាតិដី កសិកម្មអភិរក្ស វិធានការចម្រុះគ្រប់គ្រងដំណាំ កសិកម្មវៃឆ្លាតនឹងអាកាសធាតុ ការអនុវត្តកសិកម្មល្អ ការអនុវត្តកសិកម្មសរីរាង្គ សុវត្ថិភាពនិងជីវសុវត្ថិភាពប្រើប្រាស់ថ្នាំកសិកម្ម វិធានការការពារដំណាំ អនាម័យនិងភូតគាមអនាម័យ ផលិតភាពនិងប្រសិទ្ធភាពក្នុងការប្រើប្រាស់គ្រឿងយន្តកសិកម្ម ប្រព័ន្ធបច្ចេកវិទ្យាស្រោចស្រពទំនើប ការគ្រប់គ្រងនិងធ្វើអាជីវកម្មក្នុងសហគមន៍កសិកម្ម និងការគ្រប់គ្រងស្ថិតិដំណាំ។

### ឈ.ការពង្រឹងសមត្ថភាពអង្គភាពនិងសេវាគាំទ្រ

ក្របខ័ណ្ឌយុទ្ធសាស្ត្រនិងបទដ្ឋានគតិយុត្តិនានា ត្រូវបានរៀបចំនិងដាក់ឱ្យប្រើប្រាស់សម្រាប់បម្រើឱ្យអនុវិស័យដំណាំកសិកម្មដែលរួមមាន៖ សេចក្តីសម្រេចស្តីពីការចាត់តាំងភ្នាក់ងារអធិការកិច្ចពូជដំណាំ ប្រកាសស្តីពីបែបបទនៃពិន័យអន្តរការណ៍និងតម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍ សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការបញ្ចេញប្រភេទពូជដំណាំ សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាពូជដំណាំ ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំនៅកម្ពុជា។ ដោយឡែក ក្របខ័ណ្ឌយុទ្ធសាស្ត្រនិងបទដ្ឋានគតិយុត្តិដែលកំពុងដំណើរការរៀបចំរួមមាន៖ សេចក្តីប្រកាសអន្តរក្រសួងស្តីពីការផ្តល់និតិសម្បទាជានគរបាលយុត្តិធម៌ សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការចាត់តាំងមន្ត្រីអធិការកិច្ចពូជដំណាំ សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ និងសេចក្តីព្រាងប្រកាសស្តីពីពីបែបបទនៃការពិន័យអន្តរការណ៍ និងតម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍ សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាគោលនយោបាយសហគមន៍កសិកម្ម សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍន៍សហគមន៍កសិកម្ម សេចក្តីព្រាងអនុក្រឹត្យស្តីពីការលើកទឹកចិត្តនិងសិទ្ធិអនុគ្រោះពន្ធរបស់រាជ-រដ្ឋាភិបាលចំពោះសគមន៍កសិកម្ម សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគគាមអនាម័យ។

### ញ. ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) ជាអង្គភាពជំនាញបានប្រមូលនិងអភិរក្សប្រភេទពូជដំណាំកសិកម្ម បង្កើតប្រភេទពូជដំណាំកសិកម្មថ្មីៗ ថែរក្សានូវគុណភាពគ្រាប់ពូជនៃប្រភេទពូជដំណាំដែលបានបញ្ចេញ រួមទាំងផ្សព្វផ្សាយនូវពូជទាំងនោះ និងវិធីសាស្ត្រសម្រិតសម្រាំងគ្រាប់ពូជស្រូវបែបកសិករ បច្ចេកវិទ្យាដាំដុះ គ្រប់គ្រងសារធាតុចិញ្ចឹមដំណាំនិងជីជាតិដី ការពារនិងកម្ចាត់សមាសភាពចង្រៃ ការងារមុនពេលនិងក្រោយពេលប្រមូលផល បណ្តុះបណ្តាលធនធានមនុស្ស រួមទាំងចងក្រងបោះពុម្ព និងផ្សព្វផ្សាយអត្ថបទវិទ្យាសាស្ត្រ សៀវភៅ ព្រមទាំងឯកសារបច្ចេកទេស ជូនដល់អ្នកពាក់ព័ន្ធនិងកសិករទូទាំងប្រទេស។ ជាក់ស្តែងក្នុងឆ្នាំ២០២១នេះ ការងារជាច្រើនត្រូវបានអនុវត្ត ហើយខាងក្រោមនេះគឺជាសមិទ្ធផលសំខាន់ៗ៖

**១- ការអភិរក្សប្រភេទពូជដំណាំកសិកម្ម និងដំណាំផ្សេងៗ៖** បានប្រមូលប្រភេទពូជដំណាំថ្មីៗបន្ថែមទៀតចំនួន ១៥ ប្រភេទ សរុបមានចំនួន ១០៦ សំណាកមករក្សាទុកក្នុងធនាគារពន្ធុរបស់វិទ្យាស្ថាន និងបន្តការអភិរក្សពូជដំណាំនៅក្នុងវិទ្យាស្ថានកាឌីបានចំនួន៣៩ប្រភេទ ដែលរួមមានស្រូវចំនួន ៦ ៧៧៦ បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣៨ ប្រភេទសរុបចំនួន ២ ៥១៧បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន ៩ ២៩៣បញ្ជីក/សំណាក។ បានដាំវាយតម្លៃនិង

កំណាត់លក្ខណៈលើដំណាំ ៥ មុខគឺ មេទ្បុងចំនួន ៥០ សំណាក ម្ទេសចំនួន ៥០ សំណាក ល្ពៅចំនួន ៣០ សំណាក ត្រប់ចំនួន ៤០ សំណាក និងដំឡូងជ្វាចំនួន ៣៦ សំណាក សរុបមានចំនួន ២០៦ សំណាក។

**២- ការងារបសិដ្ឋកម្មពូជស្រូវ៖** បានធ្វើពិសោធន៍ជ្រើសរើសស្រទ្បាយស្រូវ ល្ង សណ្តែកសៀង សណ្តែកបាយ ដំឡូងមី និងបំណាំបន្លែ ដែលមានទិន្នផលខ្ពស់ គុណភាពល្អ និងធន់នឹងការប្រែប្រួលអាកាសធាតុ ចំនួន៦១ប្រភេទ សរុបមានចំនួន ១៤៨ ពិសោធន៍ និងមាន ២ ៩២១ ស្រទ្បាយចូលរួម នៅក្នុងវិទ្យាស្ថានកាឌី ខេត្តព្រៃវែង ស្វាយរៀង កំពង់ធំ សៀមរាប បាត់ដំបង ឧត្តរមានជ័យ កំពង់ស្ពឺ តាកែវ និងកំពត។ បានធ្វើស្រែបង្ហាញលើពូជស្រូវ ៤៦ ពូជចំនួន ២បង្ហាញ ពូជស្រូវដំណើបស្បៃមង្គលចំនួន ៥០ បង្ហាញ ពូជសណ្តែកបាយចំនួន ១៥ បង្ហាញ ល្ងចំនួន ២០ បង្ហាញ ពូជឪឡឹករាជនីចំនួន ១៥ បង្ហាញ និងពូជប៉េងប៉ោះនាងពេជ្រចំនួន ១៥ បង្ហាញ សរុបទាំងអស់មានចំនួន ១១៧ បង្ហាញ នៅវិទ្យាស្ថានកាឌី ខេត្តកំពង់ធំ កំពង់ចាម ត្បូងឃ្មុំ ស្វាយរៀង និងខេត្តតាកែវ។

**៣- ពិសោធន៍ស្តីពីប្រសិទ្ធភាពនៃការប្រើប្រាស់ជី NPK ទៅលើការដុះលូតលាស់ និងទិន្នផលដំណាំដំឡូងមី៖** បានធ្វើឡើង នៅក្នុងឃុំរំដោះ ស្រុករវៀង ខេត្តព្រះវិហារ។ លទ្ធផលបឋមនៃពិសោធន៍បង្ហាញថា បច្ច័យប្រើប្រាស់ជីនីមួយៗពិតជាមាន ភាពខុសគ្នាតាមស្ថិតិវិទ្យា ដែលបង្ហាញពីឥទ្ធិពលទៅលើទិន្នផលមើមដំឡូងមីស្រស់ ដោយការប្រើជីអ៊ុយរ៉េចំនួន ៤៤គក្រ/ហត ជី១៥-១៥-១៥ចំនួន ១៣៣គក្រ/ហត និងជីប៉ូតាស្យូមក្លរួចំនួន ៣៣គ.ក្រ/ហត បានបង្កើនទិន្នផលមើមស្រស់ជាមធ្យមក្នុងរយៈពេលពីរឆ្នាំប្រមាណជា១៨%។ ហើយការដាក់ជីអ៊ុយរ៉េចំនួន ៨៨គក្រ/ហត ជី១៥-១៥-១៥ចំនួន ២៦៦គក្រ/ហត និងជីប៉ូតាស្យូមក្លរួចំនួន៦៦គក្រ/ហត បានជួយឲ្យទិន្នផលមើមស្រស់កើនបាន ៤០%។ ចំណែកឯការប្រើប្រាស់ជីខ្ពស់ក្នុងបរិមាណជីអ៊ុយរ៉េចំនួន ១៧៦គក្រ/ហត ជី១៥-១៥-១៥ ចំនួន៥៣២គក្រ/ហត និងជីប៉ូតាស្យូមក្លរួចំនួន ១៣២គក្រ/ហត ទទួលបានកំណើនទិន្នផលមើមស្រស់ ៥៧% ធៀបជាមួយការមិនប្រើប្រាស់ជី និងខ្ពស់ជាងគេក្នុងចំណោមកម្រិតប្រើប្រាស់ជីផ្សេងៗទៀត (តារាង ១)។

**តារាង៖ ទិន្នផលមធ្យម២ឆ្នាំនៃប្រើប្រាស់ជីក្នុងកម្រិតផ្សេងៗ**

| បរិមាណសារធាតុចិញ្ចឹម N-$P_2O_5$-$K_2O$ (គក្រ/ហត) | បរិមាណជី (គក្រ/ហត) | | | ទិន្នផលមើមស្រស់ (ត/ហត) | | មធ្យម |
|---|---|---|---|---|---|---|
| | ជីអ៊ុយរ៉េ | ១៥-១៥-១៥ | ប៉ូតាស្យូម | ២០២០ | ២០២១ | |
| 0 | 0 | 0 | 0 | ១៧,៤ | ១៨,០ | ១៧,៧ |
| 40-20-40 | ៤៤ | ១៣៣ | ៣៣ | ១៩,៦ | ២២,៣ | ២១,០ |
| 80-40-80 | ៨៨ | ២៦៦ | ៦៦ | ២២,០ | ២៧,៥ | ២៤,៨ |
| 160-80-160 | ១៧៦ | ៥៣២ | ១៣២ | ២៦,៩ | ២៨,៧ | ២៧,៨ |
| កម្រិតខុសគ្នាជាអត្ថន័យ ៥% | | | | ១,៤** | ១,២** | ១,៤** |

សំគាល់៖ ** មានភាពខុសគ្នាជាអត្ថន័យក្នុងកម្រិត១% ($p<0.01$)

**៤ -ឥទ្ធិពលរយៈពេលវែងនៃការប្រើប្រាស់ជី NPK និងជីលាមកគោទៅលើទិន្នផលស្រូវ៖** បានធ្វើឡើងនៅលើក្រុមដីប្រទះឡាង ស្ថិតនៅក្នុងវិទ្យាស្ថានកាឌី ចាប់តាំងពីឆ្នាំ២០១៦ដល់ឆ្នាំ២០២១នេះ ជាដំណាំទី១១ហើយ។ លទ្ធផលបឋមបង្ហាញថា ការមិនប្រើជីទទួលបានទិន្នផលទាបណាស់ពោលគឺប្រមាណជា១,២ត/ហតប៉ុណ្ណោះ ហើយការប្រើប្រាស់ជីលាមកគោក្នុងកម្រិត ៥ត/ហត បានបង្កើនទិន្នផលគ្រាប់ជិតពីរដងពោលគឺ ២,៣ត/ហ.ត។ ដោយឡែកការប្រើប្រាស់ជីគីមីតាមកម្រិតណែនាំរបស់វិទ្យាស្ថាន ១០០-៤០-៨០គក្រ/ហត ($N:P_2O_5:K_2O$) បានបង្កើនទិន្នផលខ្ពស់ដែលមាន

កំណើនរហូតដល់២០០%ធៀបជាមួយនឹងការដាំដុះស្រូវដោយមិនប្រើជី ប៉ុន្តែការប្រើប្រាស់ជីគីមីតាមកម្រិតណែនាំលាយជាមួយលាមកគោក្នុងបរិមាណ ៥ត/ហត បានបង្កើនទិន្នផលគ្រាប់ដែរ ប៉ុន្តែក្នុងកំណើនតិចតួចប៉ុណ្ណោះធៀបជាមួយការដាក់ជីគីមីក្នុងកម្រិតណែនាំតែឯង។ ក្នុងការដាំដុះរយៈពេល១១ដំណាំនេះ ការដាក់ជីតាមកម្រិតណែនាំរបស់វិទ្យាស្ថានដោយមាន ឬគ្មានបន្ថែមជីលាមកគោ នៅតែរក្សាបាននូវទិន្នផលគ្រាប់ខ្ពស់គួរឲ្យកត់សម្គាល់ (ក្រាហ្វិក ១)។

**ក្រាហ្វិក ១០៖ ប្រសិទ្ធភាពនៃការប្រើប្រាស់ជី NPK និងលាមកគោទៅលើទិន្នផលពូជស្រូវសែនពិដោរ**




**៥- អត្ថបទវិទ្យាសាស្ត្រនិងការដឹកនាំនិស្សិត៖** បានសរសេរនិងបោះពុម្ពអត្ថបទនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រអន្តរជាតិបានចំនួន១អត្ថបទ និងសៀវភៅបច្ចេកទេសស្តីពីសម្ញាកម្មពូជត្រសក់មេឡុង ( Melon Germplasm Catalog of Cambodia-I) ចំនួន១ និងបានដឹកនាំនិស្សិតសរសេរសារណាថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន៨នាក់ (នារី២នាក់ ស្មើនឹង ២៥%))។

**៦. ការអភិវឌ្ឍន៍ធនធានមនុស្សនិងផ្សព្វផ្សាយ៖** បានធ្វើទិវាស្រែចំនួន ១៧ លើក មានកសិករចូលរួម ៥៧២ នាក់ (ស្ត្រី ២៧០ នាក់ ស្មើនឹង ៤៧%) ជួបប្រជុំជាមួយកសិករចំនួន ៩ លើក មានកសិករចូលរួម ៣៥២ នាក់ (នារី ២១៧ នាក់ ស្មើនឹង ៦២%) វគ្គបណ្តុះបណ្តាលកសិករមានចំនួន ២៦ លើក មានកសិករចូលរួម ១ ១៤៦ នាក់ (នារី ៧០៤ នាក់ ស្មើនឹង ៦១%) និងវគ្គបណ្តុះបណ្តាលជំនាញនៅ CARDI ចំនួន ៨ លើក មានសិក្ខាកាមចូលរួម ១៣២ នាក់ (នារី ៣៧ នាក់ ស្មើនឹង ២៨ %)។ ថ្នាក់ដឹកនាំ មន្ត្រីនិងបុគ្គលិកក្រោមឱវាទវិទ្យាស្ថាន បានចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា និងកិច្ចប្រជុំនៅក្នុងប្រទេសដោយផ្ទាល់ និងតាមរយៈអនឡាញចំនួន ៦៤ លើក ដែលមានចំនួនអ្នកចូលរួមសរុប១៨៦នាក់ (នារី៥១នាក់ ស្មើនឹង ២៧%)។ ទន្ទឹមនឹងនេះមានមន្ត្រីសរុបចំនួន៤រូបទៀត បាននិងកំពុងបន្តការសិក្សាថ្នាក់បណ្ឌិតចំនួន២រូប និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន២រូប នៅប្រទេសកូរ៉េ និងចិន។ បានបោះពុម្ពឯកសារចំនួន ៣០ ១៨៣ ច្បាប់ និងបែងចែកឯកសារ ៦ ៥២៥ ច្បាប់។ ចំនួនអ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យារបស់ CARDI តាមរយៈគេហទំព័រ http://www.cardi.org.kh មានចំនួនសរុប ១ ៩៥១ ០១៨ នាក់ គិតជាមធ្យមចំនួន ៥ ៣៤៥ នាក់/ថ្ងៃ កើនលើសឆ្នាំ២០២០ ចំនួន១៦២នាក់/ថ្ងៃ (៣%)។ នៅក្នុងឆ្នាំ២០២១ វិទ្យាស្ថានបានផ្តល់ជូននូវគ្រាប់ពូជស្រូវសុទ្ធល្អដែលបញ្ចេញឲ្យប្រើប្រាស់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន ៨០០ គីឡូក្រាម ក្នុងនោះមានពូជស្រូវផ្ការំដួលចំនួន ៤៥៥ គីឡូក្រាម ពូជស្រូវផ្ការមៀតចំនួន ៦៥ គីឡូក្រាម ពូជស្រូវសែនពិដោរចំនួន ១៧០ គីឡូក្រាម និងពូជស្រូវខា១៥ចំនួន ១១០គីឡូក្រាម ដល់កសិករចំនួន ១៦០ គ្រួសារ

(៥ គ.ក្រ/គ្រួសារ) នៅខេត្តសៀមរាប តាកែវ និងព្រៃវែង។ វិទ្យាស្ថានបាន ផលិតគ្រាប់ពូជស្រូវសរុបចំនួន៨៨,៨៩ តោន និងបានលក់ជូនអតិថិជនចំនួន៣ ២៦៥គីឡូក្រាម។

## ដ. ការងារនីតិកម្មនិងគ្រប់គ្រងសម្ភារកសិកម្ម

### ១. ការផ្តល់លិខិតអនុញ្ញាតឱ្យនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម

ក្នុងការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ឱ្យទទួលបានប្រសិទ្ធិភាពខ្ពស់ក្នុងឆ្នាំ២០២១ កន្លងទៅនេះ ក្រសួងបានចេញលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនចំនួន ២៥២ ក្រុមហ៊ុន នាំចូលថ្នាំកសិកម្ម និងជីកសិកម្ម ក្នុងនោះរួមមាន ក្រុមហ៊ុននាំចូលថ្នាំកសិកម្ម មានចំនួន ៥៧ ក្រុមហ៊ុន ក្រុមហ៊ុននាំចូលជីកសិកម្ម មានចំនួន ១២០ ក្រុមហ៊ុន និង ក្រុមហ៊ុននាំចូលថ្នាំកសិកម្ម និងជីកសិកម្ម មានចំនួន ៧៥ ក្រុមហ៊ុន។

### ២. ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មៈ

ក្រសួងបានចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងបានផ្តល់សុពលភាព ផ្គត់ផ្គង់ ចែកចាយ ដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៨៧ ក្រុមហ៊ុន ក្នុងនោះថ្នាំកសិកម្មសរុបចំនួន ៨២៤មុខ ស្មើនឹង ២០ ៧៧២,៤១ តោន និងជីកសិកម្មសរុបចំនួន ៥៦០ មុខ ស្មើនឹង ២២៤ ៦០២,១២ តោន។ ទន្ទឹមនេះ ក្រសួងក៏បានចាត់ក្រុមការងារអធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម ចុះត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្ម បានចំនួន១៦ ខេត្ត ស្មើនឹង ២១ លើក ដោយត្រួតពិនិត្យដេប៉ូចំនួន ៧០ ដេប៉ូ និង ០១ មធ្យោបាយដឹកជញ្ជូន បានសម្រេចពិន័យអន្តរការណ៍ចំនួន ១៥ ករណី មានទឹកប្រាក់ចំនួន ៥១ ០០០ ០០០៛ និងពិន័យចំពោះក្រុមហ៊ុនពុំបានប្រកាសប្រតិវេទន៍ចំនួន ០៥ ក្រុមហ៊ុន ស្មើនឹង ០៥ ករណី មានទឹកប្រាក់ចំនួន ១១ ៥០០ ០០០៛ សរុបទឹកប្រាក់ពិន័យបានចំនួន ៦២ ៥០០ ០០០។

### ៣. ការអភិវឌ្ឍបទដ្ឋានគតិយុត្តៈ

ក្នុងឆ្នាំ២០២១កន្លងទៅនេះ ក្រសួងបានពិនិត្យសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗក្នុងវិស័យកសិកម្ម បានចំនួន ១០ ករណី។ បានពិនិត្យលើសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗក្រៅក្រសួងបានចំនួន ០២ ករណី។ បានជួយពិនិត្យ និងផ្តល់មតិលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗ បានចំនួន១៣ ករណី។ បានពិនិត្យ និងផ្តល់មតិលើសំណើសុំគោលការណ៍ផ្សព្វផ្សាយធ្វើសិក្ខាសាលាដល់អាជីវករថ្នាំកសិកម្ម និងជីកសិកម្ម និងកសិករអំពីរបៀប ប្រើប្រាស់ផលិតផលថ្នាំកសិកម្ម និងជីកសិកម្មប្រកបដោយសុវត្ថិភាពតាមរយៈស្ថានីយ៍វិទ្យុ និងទូរទស្សន៍នៅតាមបណ្តា រាជធានី-ខេត្តបានចំនួន ០៥ ក្រុមហ៊ុន។

## ៤. ការងារផ្សព្វផ្សាយ

ការផ្សព្វផ្សាយការងារនីតិកម្មកសិកម្មក្នុងឆ្នាំ២០២១កន្លងទៅនេះ ក្រសួងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "នីតិវិធី និងវិធានបច្ចេកទេសនៃការធ្វើពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្ម" នៅខេត្តបាត់ដំបង ដោយមានអ្នកចូលរួមពីមន្ត្រីនាយកដ្ឋាននីតិកម្មកសិកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តំណាងដៃគូអភិវឌ្ឍន៍មាន FAO, CAVAC, JICA និងតំណាងក្រុមហ៊ុនធ្វើពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្ម សរុបចំនួន ១២០ នាក់។ ក្រសួងបានសហការជាមួយកម្មវិធី CAVAC រៀបចំសិក្ខាសាលាស្តីពី "ការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធព័ត៌មាន QR-Code នៅលើស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្ម និងផ្សព្វផ្សាយខ្លឹមសារប្រកាសអន្តរក្រសួងស្តីពីគោលការណ៍ណែនាំអនុវត្តវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ការបោះចោលសំណល់ និងសំបកវេចខ្ចប់ថ្នាំកសិកម្ម" នៅតាមខេត្តគោលដៅចំនួន ៥ រួមមានខេត្តកំពត កំពង់ស្ពឺ កំពង់ធំ ឧត្តរមានជ័យ និងខេត្តមណ្ឌលគីរី មានសិក្ខាកាមចូលរួមសរុបចំនួន ១៥០នាក់ និងបានរៀបចំនៅរាជធានីភ្នំពេញដោយអញ្ជើញខេត្តគោលដៅចំនួន ៥ រាជធានី-ខេត្ត រួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល

ស្វាយរៀង ព្រៃវែង និងខេត្តកំពង់ចាម មានសិក្ខាកាមចំនួនសរុប ៣៦នាក់ ដែលអញ្ជើញមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត។ ទន្ទឹមនេះ បានក៏សហការជាមួយអង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (FAO) នៃអង្គការសហប្រជាជាតិ រៀបចំសិក្ខាសាលាស្តីពី"គោលការណ៍ណែនាំសម្រាប់ស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្ម និងគំរូស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្ម" នៅខេត្តតាកែវ និងខេត្តកំពត ដែលមានអ្នកចូលរួមសរុបចំនួន ៨០ នាក់។ បានសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត បើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករលក់ដុំ លក់រាយថ្នាំកសិកម្ម និងជីកសិកម្មតាមប្រព័ន្ធ Zoom បានចំនួន ០៥ខេត្ត ក្នុងនោះរួមមាន ខេត្តត្បូងឃ្មុំ ខេត្តសៀមរាប បន្ទាយមានជ័យ តាកែវ និងខេត្តបាត់ដំបង សរុបចំនួន ៣៥០នាក់។

## ៨. ការងារកសិ-ឧស្សាហកម្ម

### ១. ការរៀបចំលិខិតបទដ្ឋានគតិយុត្ត

- បានផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៩-២០៣០ ជូនដល់អង្គភាពពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍន៍នានា
- បានរៀបចំចេញជាសេចក្តីសម្រេច ស្តីពីការតែងតាំងមន្ត្រីអធិការកិច្ចសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម
- បាននិងកំពុងបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ផលិតកម្មកសិកម្មតាមកិច្ចសន្យា បានប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់នេះចំនួន១៨លើក ក្នុងនោះប្រជុំក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងច្បាប់នៃនាយកដ្ឋានកសិ-ឧស្សាហកម្មចំនួន ០៨លើក ប្រជុំក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងច្បាប់នៃក្រសួងកសិកម្មចំនួន ០៧លើក ប្រជុំគណៈកម្មការបច្ចេកទេសរៀបចំតាក់តែង ច្បាប់នៃក្រសួងកសិកម្មចំនួន០២លើក និងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ចំនួន០១លើក
- បានរៀបចំចេញជាប្រកាសរួមជាមួយអគ្គនាយកដ្ឋានកសិកម្ម ស្តីពី វិធានកសិកម្មសរីរាង្គកម្ពុជា និងរូបសញ្ញាជាតិ សម្រាប់អនុវត្តក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង
- បាននិងកំពុងរៀបចំគោលការណ៍ នីតិវិធីនិងបែបបទនៃការចេញវិញ្ញាបនបត្រផលិតផលសរីរាង្គកម្ពុជា តាមប្រកាសលេខ១៦៣ ស្តីពី វិធានកសិកម្មសរីរាង្គកម្ពុជា និងរូបសញ្ញាជាតិ សម្រាប់អនុវត្តន៍ក្នុងផលិតកម្ម និងការកែច្នៃបឋមដំណាំស្បៀង
- បានប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពី វិធានអនុវត្តន៍ HACCP និងស្លាកសញ្ញាសម្គាល់សម្រាប់ផលិតផលកសិកម្ម និងចំណីអាហារនៃផលិតផលកសិកម្ម
- បានប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានក្នុងការរៀបចំសេចក្តីព្រាងប្រកាស ស្តីពីវិធានអនុវត្តន៍អនាម័យល្អ (GHP) និងស្លាកសញ្ញាសម្គាល់សម្រាប់ផលិតផលកសិកម្ម និងចំណីអាហារនៃផលិតផលកសិកម្ម
- បានប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានក្នុងការរៀបចំសេចក្តីព្រាងប្រកាសស្តីពី នីតិវិធីនៃការស្នើសុំ និងចេញវិញ្ញាបនបត្របញ្ជាក់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ
- បានរៀបចំ និងចេញសេចក្តីសម្រេចស្តីពី ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់នាយកដ្ឋានកសិ-ឧស្សាហកម្ម។

### ២. ការងារកិច្ចសន្យាផលិតកម្មកសិកម្ម

ក្នុងឆ្នាំ២០២១នេះ ក្រសួងបានសម្របសម្រួល រៀបចំ និងផ្តល់ប្រឹក្សាយោបល់លើការងាររៀបចំកិច្ចសន្យាផលិតកម្មកសិកម្មជូនភាគីអ្នកទិញ និងភាគីអ្នកផលិត នៅទូទាំងប្រទេសសរុបចំនួន ៩២៨កិច្ចសន្យា។

## តារាងចំនួនកិច្ចសន្យាផលិតកម្មកសិកម្ម ក្នុងឆ្នាំ២០២១

| ល.រ | ខេត្ត | ចំនួនកិច្ចសន្យាផលិតកម្មកសិកម្ម |
|---|---|---|
| ១ | ខេត្តបន្ទាយមានជ័យ | ០៤កិច្ចសន្យា |
| ២ | ខេត្តកំពង់ឆ្នាំង | ២៦កិច្ចសន្យា |
| ៣ | ខេត្តកំពង់ស្ពឺ | ៤៨៤កិច្ចសន្យា |
| ៤ | ខេត្តកំពង់ធំ | ៣៦កិច្ចសន្យា |
| ៥ | ខេត្តក្រចេះ | ១១កិច្ចសន្យា |
| ៦ | ខេត្តមណ្ឌលគិរី | ១៤កិច្ចសន្យា |
| ៧ | ខេត្តព្រះវិហារ | ៤៣កិច្ចសន្យា |
| ៨ | ខេត្តព្រៃវែង | ០១កិច្ចសន្យា |
| ៩ | ខេត្តសៀមរាប | ០៥កិច្ចសន្យា |
| ១០ | ខេត្តព្រះសីហនុ | ១៩កិច្ចសន្យា |
| ១១ | ខេត្តស្ទឹងត្រែង | ៥៥កិច្ចសន្យា |
| ១២ | ខេត្តស្វាយរៀង | ០១កិច្ចសន្យា |
| ១៣ | ខេត្តប៉ៃលិន | ១៦កិច្ចសន្យា |
| ១៤ | ខេត្តឧត្តរមានជ័យ | ០៤កិច្ចសន្យា |
| ១៥ | ខេត្តត្បូងឃ្មុំ | ៤០កិច្ចសន្យា |
| ១៦ | ខេត្តពោធិ៍សាត់ | ៦៦កិច្ចសន្យា |
| ១៧ | ខេត្តបាត់ដំបង | ១៤កិច្ចសន្យា |
| ១៨ | ខេត្តកែប | ២១កិច្ចសន្យា |
| ១៩ | ខេត្តកណ្តាល | ២៨កិច្ចសន្យា |
| | **សរុប** | **៩២៨កិច្ចសន្យា** |

## ក្រាហ្វិកទី១១៖ ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា



### ៣. ការងារមន្ទីរពិសោធន៍

- បានធ្វើការវិភាគនូវកំហាប់អាសេនិច Aflatoxin សូដ្យូមក្លរួ ផេះ អត្រាសំណើម ប្រូតេអ៊ីន ជាតិសរសៃ ខ្លាញ់ កាល់ស្យូម ផូស្វ័រ ដែក និងបាក់តេរីបង្កគ្រោះថ្នាក់ (អ៊ីកូលី សាល់ម៉ូណេឡា Enterobacteriaceae ម៉ូល & ផ្សិត និង Total Plate Count) នៅក្នុងម្សៅត្រីមីជី ម្សៅត្រីកាល់ស្យូម ចំណីសត្វ គ្រាប់ស្វាយចន្ទីលីង ៤ ប្រភេទ ប្រេងសណ្តែកដី្កាយ ០៣ប្រភេទ និងជ្រក់ម្រេចខ្ចី។
- បានធ្វើការវិភាគនូវសមាសធាតុលោហៈធ្ងន់ ដូចជា អាសេនិច បារត និងសំណ នៅក្នុងសំណាកត្រីទឹកសាបចំនួន ១៤ ប្រភេទផ្សេងៗគ្នា ព្រមទាំងបាក់តេរីបង្កគ្រោះថ្នាក់ ដូចជាវត្តមានអ៊ីកូលី សាល់ម៉ូណេឡា និង Enterobacteriaceae ទៅលើផលិតផលនីមួយៗ
- បានធ្វើការវិភាគនូវសមាសធាតុគីមី ដូចជា ផេះ អត្រាសំណើម ប្រូតេអ៊ីន ជាតិសរសៃ កំហាប់អំបិល កាបូនអ៊ីដ្រាត និងថាមពល នៅក្នុងគ្រាប់ស្វាយចន្ទី ចំណីមាន់ចំនួន០៨ប្រភេទ និងសំបកស្វាយហាលស្ងួត
- បានធ្វើការវិភាគនូវសមាសធាតុគីមីដូចជា អត្រាសំណើម ផេះ សារធាតុរឹងសរុប (Total soluble Solid) អាស៊ីត pH និងបាក់តេរីបង្កគ្រោះថ្នាក់ (អ៊ីកូលី សាល់ម៉ូណេឡា ផ្សិត និងម៉ូល និង Total plate count) នៅក្នុងទឹកឃ្មុំ ខេត្តប៉ៃលិន
- បានធ្វើការវិភាគនូវសមាសធាតុគីមី ដូចជា ថាមពលប្រូតេអ៊ីន ជាតិសរសៃ ស្ករ ខ្លាញ់ អាស៊ីត pH កាល់ស្យូម សូដ្យូម ប៉ូតាស្យូម កាបូនអ៊ីដ្រាត ដែក ម៉ាញ៉េស្យូម អេតាណុល មេតាណុល និងបាក់តេរីបង្កគ្រោះថ្នាក់ (Total plate count, ផ្សិត និងម៉ូល) នៅក្នុងដំបែ សាយ៉បំពង និងហ្វីស៊ុបគោ
- បានធ្វើការវិភាគនូវសមាសធាតុលោហៈធ្ងន់អាសេនិច ម៉ង់ហ្គាណែស ទង់ដែង សូដ្យូម ប៉ូតាស្យូម ស័ង្កសី បារត សមាសធាតុគីមីផ្សេងទៀត ដូចជា pH ធាតុរឹងរលាយសរុប ភាពរឹងសរុប និងភាពប្រៃ នៅក្នុងទឹកម៉ាស៊ីន ទឹកចម្រោះ និងទឹកដាំពុះ
- បានធ្វើការវិភាគនូវលោហៈធ្ងន់ កំហាប់អាសេនិច នៅលើបន្លែស្រស់ ដែលត្រូវបានប្រមូលមកពីផ្សារចំនួន ៣ នៅរាជធានីភ្នំពេញ ដោយក្នុងមួយផ្សារយកបន្លែចំនួន ១០ ប្រភេទខុសៗគ្នា
- បានធ្វើការវិភាគរក ប្រូតេអ៊ីន នៅក្នុងអង្ករមួយចំនួនដែលមានប្រភេទខុសៗគ្នា និងម្សៅត្រី ចំនួន ០២ ប្រភេទ។

### ៤. ការងារកែច្នៃផលិតផលកសិកម្ម

- បានចុះទស្សនកិច្ចសិក្សាលើកសិធុរកិច្ចខ្នាតតូច និងមធ្យមនៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា (World Bank)
- បានចូលរួមអនុវត្តសកម្មភាពជាច្រើនជាមួយអង្គភាពសម្របសម្រួលគម្រោងពិពិធកម្មកសិកម្មកម្ពុជា និង ក្រុមការងារអ្នកផ្តល់សេវាបច្ចេកទេស(TSPs)
- បាននិងកំពុងសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីខេត្តក្នុងការប្រមូលទិន្នន័យសហគ្រាសកែច្នៃផលិតផលកសិកម្មខ្នាតតូច និងមធ្យម
- បានចូលរួមប្រជុំជាមួយ CDC ពាក់ព័ន្ធគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម
- បណ្តុះបណ្តាលបុគ្គលិកសិប្បកម្មកែច្នៃស្វាយចន្ទី ជ័យ សំបូរ អំពីបច្ចេកទេសកែច្នៃស្វាយចន្ទី ការអនុវត្តអនាម័យល្អ (GHP) ការអនុវត្តផលិតកម្មល្អ (GMP) និងប្រព័ន្ធគ្រប់គ្រងគុណភាព សុវត្ថិភាព HACCP
- សម្របសម្រួលក្នុងការងារស្នើសុំវិញ្ញាបនបត្រកែច្នៃ ស្វាយចន្ទីសរីរាង្គជូនសិប្បកម្មកែច្នៃស្វាយចន្ទី ជ័យ សំបូរ ជាលទ្ធផលសិប្បកម្មកែច្នៃស្វាយចន្ទីទទួលបានវិញ្ញាបនបត្រសរីរាង្គក្នុងការកែច្នៃ
- រៀបចំចងក្រងឯកសារក្នុងការស្នើសុំវិញ្ញាបនបត្រ GMP, HACCP បាននិងកំពុងរៀបចំនីតិវិធីនៃការចុះធ្វើអធិការកិច្ចសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម និងឯកសណ្ឋាន។

## ៣. ការបង្កើនផលិតភាពដំណាំកៅស៊ូ

### ១. ផ្ទៃដីដាំដុះកៅស៊ូ

នៅឆ្នាំ២០២១នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន៤០៤ ០៤៤ហិកតា បើធៀបទៅនឹងឆ្នាំ២០២០ ដែលមានចំនួន៤០៤ ១៦០ហិកតា គឺថយចុះចំនួន១១៦ហិកតា ស្មើនឹង-០,០៣%។ ការថយផ្ទៃដីនេះភាគច្រើនកើតមាននៅលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដោយក្រុមហ៊ុនមួយចំនួនបានផ្លាស់ប្តូរមុខដំណាំ ព្រោះដីមិនសមស្របនឹងដំណាំកៅស៊ូ និងក្រុមហ៊ុនមួយចំនួនទៀតគ្រប់គ្រងថែទាំកៅស៊ូមិនបានល្អ និងដោយសារភ្លើងឆេះនៅរដូវប្រាំង។ ផ្ទៃដីកៅស៊ូទាំងនេះត្រូវបានបែងចែកជា០២ផ្នែកគឺៈ ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម (ផ្ទៃដីអតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន២៤០ ៣៤៦ហិកតា ស្មើនឹង៥៩,៥% និងកៅស៊ូគ្រួសារមានចំនួន១៦៣ ៦៩៨ហិកតា ស្មើនឹង៤០,៥% នៃផ្ទៃដីកៅស៊ូសរុប (ក្រាហ្វិកទី១)។

**តារាងទី១៖ ផលិតកម្មកៅស៊ូ២០២០-២០២១**

| ល.រ | ផលិតកម្មកៅស៊ូ | ប្រភេទចម្ការកៅស៊ូ | ឯកតា | ២០២០ | ២០២១ | ២០២១/២០២០ (Δ%) |
|---|---|---|---|---|---|---|
| 1 | ផ្ទៃដីដាំកៅស៊ូសរុប | កសិឧស្សាហកម្ម | ពាន់ហ.ត. | ២៤៣,០ | ២៤៣,៣ | -១,១ |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត. | ១៦១,២ | ១៦៣,៧ | ១,៥ |
| | | **សរុប** | **ពាន់ហ.ត.** | ៤០៤,២ | ៤០៤,០ | -០,០៣ |
| 2 | ផ្ទៃដីចៀរជ័រ | កសិឧស្សាហកម្ម | ពាន់ហ.ត. | ១៤៣,៧ | ១៥៦,៩ | ១០,០ |
| | | កៅស៊ូគ្រួសារ | ពាន់ហ.ត. | ១៤៩,៨ | ១៥៣,៣ | ២,៣ |
| | | **សរុប** | **ពាន់ហ.ត.** | ២៩២,៥ | ៣១០,២ | ៦,១ |
| 3 | ផលិតផលកៅស៊ូ | កសិឧស្សាហកម្ម | ពាន់តោន | ១៦៣,៩ | ១៨៤,៦ | ១២,៦ |
| | | កៅស៊ូគ្រួសារ | ពាន់តោន | ១៨៥,៤ | ១៨៣,៤ | -១,១ |
| | | **សរុប** | **ពាន់តោន** | ៣៤៩,៣ | ៣៦៨,០ | ៥,៤ |

**ក្រាហ្វិកទី១២៖ ប្រភេទផ្ទៃដីចម្ការកៅស៊ូឆ្នាំ២០១៧-២០២១**




### ២. ការងារផលិតកម្ម

ឆ្នាំ២០២១ ផ្ទៃដីកៅស៊ូយកផលអនុវត្តបានចំនួន៣១០ ១៩៣ហិកតា ធៀបនឹងផ្ទៃដីកៅស៊ូចៀរឆ្នាំ២០២០

ដែលមានចំនួន២៩២ ៤៩៧ហិកតា គឺកើនឡើងចំនួន១៧ ៦៩៦ហិកតា ស្មើនឹង៦,១%(ក្រាហ្វិកទី១២)។ ផលិតផលកៅស៊ូសម្រេចបានចំនួន៣៦៨ ០០០តោន ធៀបនឹងឆ្នាំ២០២០ ដែលមានចំនួន៣៤៩ ៣០០តោន គឺកើនឡើងចំនួន ១៨ ៧០០តោន ស្មើនឹង៥,៤%(ក្រាហ្វិកទី៣)។ ទិន្នផលមធ្យមមានចំនួន១ ១៨៦គ.ក្រ/ហ.ត បើធៀបនឹងឆ្នាំ២០២០ ដែលមានចំនួន១ ១៩៤គ.ក្រ/ហ.ត គឺថយចុះចំនួន៨គ.ក្រ/ហ.ត ស្មើនឹង០,៨% ដោយសារផ្ទៃដីយកផលថ្មីកើនឡើងច្រើនក្នុងឆ្នាំ។

**ក្រាហ្វិកទី១៣៖ ផ្ទៃដីកៅស៊ូចៀរជ័រ ថែទាំ និងសរុប ឆ្នាំ២០១៧-២០២១**




### ៣. ការងារធុរកិច្ចកៅស៊ូ

នៅក្នុងឆ្នាំ២០២១នេះ ការនាំចេញកៅស៊ូមានចំនួន ៣៦៦ ៣០០តោន ស្មើនឹងទឹកប្រាក់ប្រមាណ ៦១០ ២៥៥ ៨០០ដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០២០ មានចំនួន៣៣៨ ៣០០តោន គិតជាទឹកប្រាក់សរុបចំនួន៤៦៧ ៥៨៤ ៣០២ដុល្លារអាមេរិក ដែលបរិមាណនាំចេញកើនឡើងប្រមាណចំនួន២៨ ០០០តោន ស្មើនឹង៨,៣% និងប្រាក់ចំណូលកើនប្រមាណ១៤២ ៦៧១ ៤៩៨ដុល្លារអាមេរិក ស្មើនឹង៣០,៥%។ តម្លៃកៅស៊ូនាំចេញជាមធ្យម ១ ៦៦៦ដុល្លារអាមេរិកក្នុងមួយតោន បើធៀបនឹងឆ្នាំ២០២០ ដែលតម្លៃមធ្យមស្មើនឹង ១ ៣៨២ ដុល្លារអាមេរិកក្នុងមួយតោន ឃើញថាមានការកើនឡើងចំនួន២៨៤ដុល្លារអាមេរិក ក្នុងមួយតោនត្រូវនឹង២០,៥%។ រីឯការនាំចេញឈើកៅស៊ូពីការកាប់ដើមកៅស៊ូចាស់ៗមានចំនួន៦ ២៩២ម៉ែត្រគូប គិតជាទឹកប្រាក់ចំនួន១ ៥១៥ ០១៤,៨៤ដុល្លារអាមេរិក។

**ក្រាហ្វិកទី១៤៖ ផលិតកម្មនិងការនាំចេញកៅស៊ូ ឆ្នាំ២០១៧ - ២០២១**



មកដល់ឆ្នាំ២០២១នេះ រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូនិងឈើកៅស៊ូមានចំនួនសរុប១៦៨កន្លែង។ បើធៀបនឹងឆ្នាំ២០២០ មានចំនួន១៦២កន្លែង កើនចំនួន០៦ ក្នុងនោះ រោងចក្រកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេស (TSR: TECHNICALLY SPECIFIED RUBBER) មានចំនួន៥០កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ (CL: CONCENTRATED LATEX) ចំនួន១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង (RSS: RIBBED SMOKED SHEET) សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ (ADS: AIR-DRIED SHEET) មានចំនួន១០០កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូ (RWF: RUBBER WOOD FACTORY) ចំនួន១៧កន្លែង (ក្រាហ្វិកទី៤) ក្នុងនោះមានរោងចក្រនិងសិប្បកម្មចំនួន៦០កន្លែងដែលបានផ្អាកដំណើរការ រួមមាន៖ រោងចក្រកែច្នៃកៅស៊ូធម្មជាតិបញ្ជាក់តាមលក្ខណៈបច្ចេកទេសចំនួន ១៥កន្លែង រោងចក្រកែច្នៃទឹកជ័រខាប់ចំនួន ១កន្លែង សិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយមានផ្សែង និងសិប្បកម្មកែច្នៃកៅស៊ូសន្លឹកសម្ងួតដោយខ្យល់ក្តៅ ចំនួន៣៩កន្លែង និងរោងចក្រកែច្នៃឈើកៅស៊ូចំនួន៥កន្លែង។ ការផ្អាកដំណើរការនេះ ដោយសារខ្វះវត្ថុធាតុដើម ដែលជាកៅស៊ូមិនទាន់កែច្នៃមួយចំនួនត្រូវបាននាំចេញក្រៅផ្លូវការ។ អត្រាគុណភាពល្អនៃកៅស៊ូកែច្នៃ (CSR L, CSR 5, CSR 10) ក្នុងឆ្នាំ២០២១ អនុវត្តបានចំនួន ៧៨,៥%។

**ក្រាហ្វិកទី១៥៖** រោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូឆ្នាំ២០១៧ -២០២១




### ៤. ការងារផែនការ ហិរញ្ញវត្ថុ

នៅក្នុងឆ្នាំ២០២១ ការប្រមូលចំណូលអនុវត្តបានចំនួន២ ០៨១ លានរៀល (៥០៨ ៨២៥ដុល្លារអាមេរិក) ក្នុងនោះរួមមាន៖ ការជួលដីក្រុមហ៊ុនទាំង០៧ មានចំនួន១ ៤០៩លានរៀល (៣៤៥ ៩៧២ដុល្លារអាមេរិក) ប្រាក់ពិន័យមានចំនួន៤៦ លានរៀល (១១ ៣០២ដុល្លារអាមេរិក) និងការជួលអចលនវត្ថុ (អសង្ហារឹម) ក្រុមហ៊ុន នីហរ័ណអាហរ័ណកៅស៊ូ មានចំនួន៦១៧ លានរៀល (១៥១ ៥៥០ដុល្លារអាមេរិក) និងបង់សំណៅសចំណាយបៀវត្សឆ្នាំ២០២០ ចំនួន៩លានរៀល ។ បើធៀបនឹងគោលដៅចំនួន ១ ៥២៤ លានរៀល (៣៧១ ៧០៧ដុល្លារអាមេរិក) មានការកើនឡើងចំនួន៥៥៧ លានរៀល ស្មើនឹង៣៦,៥៥%។ ការកើនឡើងនេះ ដោយសារ (១)ចម្ការកៅស៊ូចម្ការអណ្តូង និងចម្ការកៅស៊ូពាមជាំង បានបង់ថ្លៃឈ្នួលនិងប្រាក់ពិន័យពីឆ្នាំ២០២០ចូលមកឆ្នាំ២០២១ និង(២)ចម្ការកៅស៊ូឡាបានសៀក បានបង់ប្រាក់ឈ្នួលសម្រាប់ឆ្នាំ២០១៩និងឆ្នាំ២០២០ចូលមកឆ្នាំ២០២១។

### ៥. ការងារផ្សព្វផ្សាយនិងបណ្តុះបណ្តាល

- បានចុះបើកវគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយអំពីបច្ចេកទេសដាំដុះកៅស៊ូ ជំងឺនិងកក្កាចង្រៃលើដំណាំកៅស៊ូ បច្ចេកទេសយកផលទឹកជ័រ ការវិភាគសរីរទឹកជ័រ បច្ចេកទេសកែច្នៃ ទីផ្សារកៅស៊ូ បច្ចេកទេស

ចិញ្ចឹមឃ្មុំ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធអនុវិស័យកៅស៊ូ ដល់ប្រតិបត្តិករកៅស៊ូ បាន១៩វគ្គ ដោយមានអ្នកចូលរួម៧៩០នាក់។

- បានចុះបើកសិក្ខាសាលាស្ដីការវិវត្តកៅស៊ូធម្មជាតិ ដល់មន្ត្រីបង្គោលបានចំនួន១វគ្គ ដោយអ្នកចូលរួមសរុបចំនួន៣០នាក់ បានចុះពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ បានចំនួន០៤សហគមន៍ នៅខេត្តក្រចេះ មណ្ឌលគិរី រតនគិរី និងខេត្តសៀមរាប និងចូលរួមបណ្ដុះបណ្ដាលនិស្សិតនៅសាកលវិទ្យាល័យភូមិន្ទកសិកម្មនិងនៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាមលើជំនាញវិទ្យាសាស្ត្រកៅស៊ូ។

## ៦. ការងារពិសោធន៍ស្រាវជ្រាវកៅស៊ូ

- **ការងារដាំដុះនិងការពារ៖** ស្រង់និងវិភាគរួមមាន៖ (១)អភិវឌ្ឍន៍រុក្ខសម្ភារដាំដុះ (២)ការប្រើប្រាស់ជីលើកៅស៊ូមិនទាន់ផ្ដល់ផល និងកៅស៊ូផ្ដល់ផល (៣) ការធ្វើពិពិធកម្មដំណាំរួមផ្សំ និងរុក្ខជាតិព្រៃនៅចន្លោះរងកៅស៊ូ (៤) ដំណាំគម្របដី ផលិតកម្មជីវម៉ាស់ និងវិធានការគ្រប់គ្រងដំណាំគម្របដី (៥)ទំនាក់ទំនងរវាងការលូតលាស់និងទិន្នផលទៅនឹងអាកាសធាតុ ហើយនិងចង្វាក់ចៀរ d3, d4 (៦)ដង់ស៊ីតេដាំដុះដើមកៅស៊ូ (៧)ឥទ្ធិពលនៃការស្រោចស្រពលើការលូតលាស់និងទិន្នផលកៅស៊ូ។ អនុវត្តការងារបំបៅកូនកៅស៊ូសម្រាប់ដាំដុះឆ្នាំ២០២១ និងដាំជួសកៅស៊ូដាំឆ្នាំ២០១៩-២០២១ ដោយរៀបចំថ្នាលបណ្ដុះកូនកៅស៊ូឆ្នាំ២០២១លើផ្ទៃដី០.៣៥ហិកតា អនុវត្តការថែទាំដំណាំគ្របដីចំនួន៣ប្រភេទ (*Stylosanthes guianesis, Mucuna aterrinum, Puraria phaseoloides*) ដាក់ជីបំប៉នលើកូនកៅស៊ូមិនទាន់ផ្ដល់ផលចំនួន២លើក លើផ្ទៃដី៣៧.៧៥ហិកតា និងចម្ការពិសោធន៍ជីលើកៅស៊ូផ្ដល់ផលចំនួន៤ចម្ការលើផ្ទៃដី១៥,២០ហិកតា ព្រមទាំងបាញ់ថ្នាំការពារនិង ព្យាបាលជំងឺផ្កាកុលាបនៅតាមប្រគៀបមែកកៅស៊ូចាប់ពីអាយុ៤-១០ឆ្នាំ លើផ្ទៃដី១៦១,៦៦ហិកតា និង បានដាំកូនកៅស៊ូក្នុងឆ្នាំ២០២១ ចំនួន៩,៥ហិកតា។
- **ការងារស្រាវជ្រាវអំពីការបង្កាត់ពូជ៖** តាមដាន ស្រង់និងបញ្ចូលទិន្នន័យចម្ការពិសោធន៍ក្នុងនិងក្រៅស្ថានីយបានចំនួន២៣ចម្ការពិសោធន៍(ទំហំដើមកៅស៊ូ ទិន្នផលជ័រ មាឌឈើ និងជំងឺប្រផេះស Oidium) អនុវត្តការថែទាំច្បារពូជកៅស៊ូទំហំ ៨,៦០ហិកតា សម្រាប់បំរើដល់ការពិសោធស្រាវជ្រាវ។ ចុះអង្កេតការជ្រុះស្លឹក និងចេញផ្ការនៅច្បារបង្កាត់ពូជលើក្លូនកៅស៊ូចំនួន១៦។ ស្រាវជ្រាវនិងអភិវឌ្ឍន៍ធនធានសេនេទិច(genotype)កៅស៊ូលេចធ្លោចំនួន២០ ត្រូវបានជ្រើសរើសសម្រាប់ការបង្កើតចម្ការពិសោធន៍ទ្រង់ទ្រាយតូច និងបានដាំនៅចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយតូច ដោយធ្វើការប្រៀបធៀបជាមួយបណ្ដាក្លូនកសិណរួមមាន GT 1, PB 260, RRIM 600 និង PB 217។ ដាំពង្រីកកូនកៅស៊ូនៅក្នុងច្បារពូជសរុបបានចំនួន៧៧៩កូន។
- **ការងារស្រាវជ្រាវលើសរីរសាស្ត្រនិងការយកផលទឹកជ័រ៖** តាមដាន ស្រង់ បញ្ចូលទិន្នន័យគ្រប់ចម្ការពិសោធន៍ពី៖ (១) សក្ដានុពលទិន្នផល (d3, d4) និងប្រព័ន្ធចង្វាក់ចៀរធ្វើល (d4, d5, d6) (២)ការបើកមុខចៀរលើទំហំដើមខុសគ្នា (៣)ប្រសិទ្ធភាពនៃរបាំងការពារទឹកភ្លៀង នៅក្នុងស្ថានីយ៍ចំនួន១៣ និងក្រៅស្ថានីយចំនួន១ លើទិន្នន័យទំហំដើម ទិន្នផល និងជំងឺស្ងួតផ្ទាំងចៀរ (TPD) ។ យកសំណាកនិងវិភាគសរីរទឹកជ័រ ពីចម្ការពិសោធន៍នានាក្នុងនិងក្រៅស្ថានីយបានចំនួន២៩ចម្ការពិសោធន៍ ស្មើនឹង ១ ២៨០សំណាក។
- **ការងារផ្នែកមន្ទីរពិសោធន៍ជាតិយថាប្រភេទ៖** បានអនុវត្តការងាររួមមាន (១)ធ្វើតេស្តកៅស៊ូសន្លឹក (RSS) របស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា សរុបចំនួន ៧២សំណាក ដើម្បីពិនិត្យគុណភាព នៃការកែច្នៃតាមស្តង់ដាCSR (២)ចូលរួមធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍អន្តរជាតិក្នុងក្របខ័ណ្ឌ

សមាគមកៅស៊ូអន្តរជាតិ (IRA) ចំនួន២លើក(ទី១២៤និងទី១២៥) (៣)ធ្វើតេស្តប្រៀបធៀបក្នុងស្រុកជាមួយមន្ទីរសោធន៍មូលដ្ឋានលើកទី៦២ ចំនួន៤២សំណាក (៤)ចុះបញ្ជិកាទទួលស្គាល់និងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជាចំនួន៤ ក្នុងនោះ៖ រោងចក្រកែច្នៃកៅស៊ូ TSR ចំនួន១និងមន្ទីរពិសោធន៍ចំនួន៣ ( ៥)ធ្វើតេស្តកៅស៊ូដុំ (TSR) បាន៣ក្រុមហ៊ុន សរុបចំនួន១៦សំណាក។ ក្នុងពេលបច្ចុប្បន្នមានរោងចក្រកែច្នៃកៅស៊ូ TSR ចំនួន១៥ និងមន្ទីរពិសោធន៍ចំនួន៨ បានចុះបញ្ជិកាទទួលស្គាល់និងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជាពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា។

**៧. ការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្នែកកៅស៊ូ**

- ពិនិត្យ កែសម្រួលឡើងវិញ សេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ ស្របតាមការណែនាំរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សេចក្តីព្រាងច្បាប់នេះ មានគោលបំណងកំណត់ការគ្រប់គ្រងការស្រាវជ្រាវ និងការអភិវឌ្ឍ ដើម្បីធានានិរន្តរភាពនៃផលិតកម្មកៅស៊ូ ប្រកបដោយប្រសិទ្ធភាពខ្ពស់ រួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងរក្សានិរន្តរភាពបរិស្ថានធម្មជាតិ
- បានប្រជុំពិនិត្យសេចក្តីព្រាងសារាចរណែនាំ ស្តីពីវិធានការទប់ស្កាត់ការនាំចេញជ័រកៅស៊ូនិងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេស
- បានរៀបចំប្រកាស ស្តីពីនីតិវិធីនៃការស្នើសុំបង្កើតនិងដំណើរការរោងចក្រ សិប្បកម្មកែច្នៃកៅស៊ូ និងឈើកៅស៊ូ និងត្រូវបានចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានប្រជុំកែសម្រួលសេចក្តីព្រាងការកែសម្រួលតួនាទីភារៈកិច្ចរបស់អគ្គនាយកដ្ឋានកៅស៊ូ
- បានចុះពិនិត្យករណីក្រុមហ៊ុន អ៊ាន ម៉ាឌី គ្រុប ស្នើសុំចុះបញ្ជីដីរដ្ឋចំនួន១៧០០ហិកតា ស្រុករមាសហែក ខេត្តស្វាយរៀង
- បានចូលរួមក្នុងការទាញហេតុផលផ្ទាល់មាត់ ជាមួយប្រជាពលរដ្ឋចំនួន០៤គ្រួសារ ក្នុងការទាមទារដីនិងផ្ទះនៅក្រុមហ៊ុន ស៊ីហ្វរីសសស៍ (ខេមបូឌា) លីមីតធីត ស្រុកស្នួល ខេត្តក្រចេះ និងចុះពិនិត្យទំនាស់ដីធ្លីនៅក្រុមហ៊ុនចំការកៅស៊ូមេមត់។

**៨. ការងារសហប្រតិបត្តិការអន្តរជាតិ**

ឆ្នាំ២០២១នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈអគ្គនាយកដ្ឋានកៅស៊ូ បានចូលរួមក្នុងព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំរបស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ ANRPC កិច្ចប្រជុំជាមួយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD: Agence Française de Développement) បានចុះកិច្ចព្រមព្រៀងភាពជាដៃគូត្រីភាគី (Tripartite Partnership Agreement) គោលបំណងគឺការបង្កើតលក្ខណ្ឌនៃភាពជាដៃគូ រវាងទីភ្នាក់ងារអ្នកទទួលផលចុងក្រោយ និងដៃគូបច្ចេកទេស ដើម្បីប្រតិបត្តិសកម្មភាពស្រាវជ្រាវឧស្សាហកម្មកៅស៊ូនៅតំបន់អាស៊ីអាគ្នេយ៍ បានសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិស្រាវជ្រាវកសិកម្មសម្រាប់ការអភិវឌ្ឍ (CIRAD) លើការងារស្រាវជ្រាវផ្នែកក្សេត្រសាស្ត្រ បង្កាត់ពូជ ការយកផលទឹកជ័រនិងសរីរសាស្ត្រទឹកជ័រ និងប្រជុំពិនិត្យការចុះសិក្សាសមិទ្ធលទ្ធភាពរបស់គម្រោង FORSEA។ បានធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្មនៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការលើការងារស្រាវជ្រាវកៅស៊ូរួមគ្នា បានធ្វើបច្ចុប្បន្នភាពលើរបាយការណ៍ផែនការអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូនៅតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម បានសហការជាមួយអង្គការមូលនិធិសកលសម្រាប់ធម្មជាតិ (World Wide Fund for Nature) អង្គការ OXFAM អង្គការ WWF និង អង្គការ ONG FORUM លើការងារបច្ចេកទេស តាមរយៈវគ្គផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ

ការពង្រឹងសមត្ថភាពសហគមន៍កសិកម្មកៅស៊ូគ្រួសារ បច្ចេកទេសការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រកៅស៊ូ ការរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ និងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការប្រមូលផលទឹកជ័ររបស់កៅស៊ូគ្រួសារ និងពិនិត្យលើការរៀបចំរបាយការណ៍សិក្សាអំពីនិរន្តរភាពកៅស៊ូធម្មជាតិ និងចូលរួមកិច្ចប្រជុំតាមអនឡាញជាមួយក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ IRRDB អំពីជំងឺ *Pestalotiopsis leaf disease*។

## ២. ការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ

ផលិតកម្មសត្វមានសក្តានុពលក្នុងការរួមចំណែកបង្កើតការងារ សន្តិសុខស្បៀង អាហារូបត្ថម្ភ កំណើនសេដ្ឋកិច្ច និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។ អនុវិស័យនេះជាផ្នែកមួយសំខាន់សម្រាប់ទ្រទ្រង់ដល់វិស័យកសិកម្ម និងសេដ្ឋកិច្ចជាតិ។ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានដាក់បញ្ចូលវិស័យកសិកម្មក្នុងចតុកោណទី៤ មុំទី១ ចំណុចអាទិភាពទី៧ ចែងពីការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីលើកកម្ពស់ការចិញ្ចឹមសត្វឱ្យកាន់តែទូលំទូលាយថែមទៀត តាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយផ្អែកលើខ្សែច្រវាក់តម្លៃ និងដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍអនុវិស័យនេះ ជាមួយនឹងការគិតគូរដល់បញ្ហាសុវត្ថិភាពចំណីអាហារ និងកិច្ចដំណើរការប្រកួតប្រជែងទីផ្សារ ពិសេសការបន្ថយថ្លៃដើមផលិត និងអនាម័យសាច់។

ក្នុងឆ្នាំ២០២១ ផលិតកម្មសត្វមានការកើនឡើង ជាពិសេសការចិញ្ចឹមសត្វសម្រាប់ឧស្សាហកម្ម។ ជាក់ស្តែងសត្វចិញ្ចឹមសរុបបានកើនដល់៥៩,៩៦លានក្បាល គឺកើនលើសឆ្នាំ២០២០ ចំនួន១១,២% ដែលធ្វើឱ្យកម្ពុជាមានសមត្ថភាពផលិតសាច់សម្រាប់បម្រើតម្រូវការក្នុងស្រុកបានប្រមាណជាង២៦៩ពាន់តោន ឬស្មើនឹង៨៧% នៃតម្រូវការសាច់សរុបប្រមាណ៣១០ពាន់តោនក្នុងមួយឆ្នាំ។

ទន្ទឹមនឹងនេះ ក៏មានការត្រៀមលក្ខណៈបានល្អ និងយកចិត្តទុកដាក់ខ្ពស់លើការងារអង្កេតតាមដាន ស្រាវជ្រាវប្រភពចម្លងជំងឺ និងមានប្រព័ន្ធរាយការណ៍ស្ថានភាពសុខភាពសត្វជាប្រចាំ ក្នុងករណីមានផ្ទុះជំងឺឆ្លងត្រូវបានរកឃើញដោយត្រូវរាយការណ៍ឱ្យបានឆាប់រហ័ស និងបានចាត់វិធានការឆ្លើយតបទាន់ពេលវេលា។

### ២.១. លទ្ធផលនៃការជំរុញផលិតកម្មសត្វ

#### ២.១.១ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារក្នុងឆ្នាំ២០២១ មានចំនួនសរុប៣៦,៥៧លានក្បាល ក្នុងនោះមានគោចំនួន២,៩៥លានក្បាល ក្របីចំនួន៤៣២ពាន់ក្បាល ជ្រូកចំនួន១,២៥លានក្បាល បក្សីចំនួន៣១,៨៩លានក្បាល សេះចំនួន៣,៥៨ពាន់ក្បាល ចៀមចំនួន២,៤៩ពាន់ក្បាល ពពែចំនួន៤២,៥ពាន់ក្បាល និងដំរីចំនួន៤៩ក្បាល។

បើប្រៀបធៀបឆ្នាំ២០២០ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសរុបកើនឡើងចំនួន៤,៦% ក្នុងនោះគោកើនចំនួន៤,១% ក្របីកើនចំនួន២,១% គោ ក្របីកើនចំនួន៣,៩% ជ្រូកកើនចំនួន៩,៩% បក្សីកើនចំនួន៤,៤% សេះកើនចំនួន២០,៦% ចៀមកើនចំនួន១៦៤,១% និងពពែកើនចំនួន៤១,៨%។

**តារាងស្ថិតិផលិតកម្មសត្វលក្ខណៈគ្រួសារ ពីឆ្នាំ២០១៧-២០២១**

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀប (២០២១&២០២០) |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| ១ | គោ | ២ ៩៥១ ៣៥៩ | ២ ៩១៧ ៣០២ | ២ ៧៦៩ ៨៨៥ | ២ ៨៣៥ ៣៦០ | ២ ៩៥២ ៧៥១ | ៤,១% |
| ២ | ក្របី | ៥០៨ ៤៥៨ | ៥០០ ៧៧៨ | ៤៤៧ ១៦៧ | ៤២៣ ៦១៤ | ៤៣២ ៤០៩ | ២,១% |
| ៣ | គោ ក្របី | ៣ ៤៥៩ ៨១៧ | ៣ ៤១៨ ០៨០ | ៣ ២១៧ ០៥២ | ៣ ២៥៨ ៩៧៤ | ៣ ៣៨៥ ១៦០ | ៣,៩% |
| ៤ | កម្លាំងអូសទាញ | ៩៣៥ ២៣៩ | ៨៣៦ ៣០១ | ៧១៧ ៩០២ | ៦៤៨ ៧២៩ | ១៦១ ៥៥០ | -៧៥,១% |
| ៥ | ជ្រូក | ២ ៣៣១ ៥១២ | ១ ៩៣៤ ៩១៧ | ១ ០៣០ ៤៩៤ | ១ ១៣៧ ០៥៦ | ១ ២៥០ ១៦៧ | ៩,៩% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | បក្សី | ២៨ ៦៥២ ៤០៩ | ២៨ ៩៥៦ ៣៤២ | ២៧ ៧៦៣ ៤៧៩ | ៣០ ៥៥៣ ២៣៣ | ៣១ ៨៩១ ៩៥២ | ៤,៤% |
| ៧ | សេះ | ៥ ០៥៥ | ៤ ២០៧ | ៣ ៧៧១ | ២ ៩៧១ | ៣ ៥៨៣ | ២០,៦% |
| ៨ | ចៀម | ៤៦១ | ៤៥៩ | ៦៤៨ | ៩៤៤ | ២ ៤៩៣ | ១៦៤,១% |
| ៩ | ពពែ | ២៨ ៥៤២ | ២៥ ៧៤៧ | ២៧ ៧៤០ | ២៩ ៩៨១ | ៤២ ៥០៦ | ៤១,៨% |
| ១០ | ដំរី | ៦៣ | ៥៨ | ១៨ | ៥១ | ៤៩ | -៣,៩% |
| ១១ | ស្វា | | | ១៤៨ | ២១៩ | ១៦៦ | -២៤,២% |
| ១២ | ទន្សាយ | | | ១៨៥ | ៣១១ | ៥៤៦ | ៧៥,៦% |
| សរុប | | ៣៤ ៤៧៧ ៨៥៩ | ៣៤ ៣៣៩ ៨១០ | ៣២ ០៤៣ ៥៣៥ | ៣៤ ៩៨៣ ៧៤០ | ៣៦ ៥៧៦ ៦២២ | ៤,៦% |

### ក្រាហ្វិកទី១៦៖ ផលិតកម្មសត្វលក្ខណៈគ្រួសារឆ្នាំ២០១៧ -២០២១




## ២.១.២ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

សត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មក្នុងឆ្នាំ២០២១ មានចំនួនសរុប២៣,៣៨លានក្បាល ក្នុងនោះគោ ក្របីចំនួន១៤,៧៩ពាន់ក្បាល ជ្រូកចំនួន១,៧៦លានក្បាល បក្សីចំនួន២១,៥៣លានក្បាល ចៀមចំនួន១,៨ពាន់ក្បាល ពពែចំនួន១,០៥ពាន់ក្បាល និងស្វាចំនួន៦៨ពាន់ក្បាល។

បើប្រៀបធៀបឆ្នាំ២០២០ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មសរុបកើនឡើងចំនួន២៣,៦% ក្នុងនោះគោក្របីកើនចំនួន១០,២% ជ្រូកកើនចំនួន២៨,២% បក្សីកើនចំនួន២៣,០% ចៀមកើនចំនួន១៣០,៥% ពពែកើនចំនួន២៥១,៧% និងស្វាកើនចំនួន២៩៩,៨%។

### ស្ថិតិផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀប (២០២១&២០២០) |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| ១ | គោ | ២០ ៣៦៣ | ១១ ២៣២ | ៩ ៨៧៧ | ១៣ ២១៦ | ១៤ ៦៤៧ | ១០,៨% |
| ២ | ក្របី | ១៩៨ | ២១៧ | ២១៨ | ២១១ | ១៥០ | -២៨,៩% |
| ៣ | គោ-ក្របី | ២០ ៥៦១ | ១១ ៤៤៩ | ១០ ០៩៥ | ១៣ ៤២៧ | ១៤ ៧៩៧ | ១០,២% |
| ៤ | ជ្រូក | ៧៤២ ៧៧១ | ៨១២ ៩៣៨ | ១ ១៥៥ ៤៣១ | ១ ៣៧៩ ៦២៣ | ១ ៧៦៨ ៦៣០ | ២៨,២% |
| ៥ | បក្សី | ៧ ៩៩២ ៩៣០ | ៩ ២១០ ៤០៩ | ១២ ៦៣១ ៩៧៤ | ១៧ ៥០៨ ៩៣៦ | ២១ ៩៣០ ៧៥២ | ២៣,០% |
| ៦ | សេះ | ៨២ | ៨៩ | ៣០ | ០ | ០ | ០% |
| ៧ | ចៀម | ០ | ០ | ០ | ៧៨១ | ១ ៨០០ | ១៣០,៥% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | ពពែ | ៣៦៥ | ៧០០ | ០ | ៣០០ | ១ ០៥៥ | ២៥១,៧% |
| ៩ | ស្វា | - | - | ១៤ ០៧៩ | ១៧ ០១០ | ៦៨ ០០០ | ២៩៩,៨% |
| ១០ | ទន្សាយ | - | - | - | ០ | ០ | ០ |
| **សរុប** | | **៨ ៣៥៦ ៣០៩** | **១០ ០៣៥ ៥៨៥** | **១៣ ៨១១ ៦០៨** | **១៨ ៩២០ ០៧៧** | **២៣ ៣៨៥ ០៣៤** | **២៣,៦%** |

**ក្រាហ្វិកទី១៧៖ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មឆ្នាំ២០១៧ -២០២១**




## ២.១.៣ ស្ថិតិផលិតកម្មសត្វសរុបទូទាំងប្រទេស (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម)

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វគ្រប់ប្រភេទមានការកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន ៤២,៨៣លានក្បាល ក្នុងឆ្នាំ២០១៧ កើនដល់ចំនួន៥៩,៩៦លានក្បាល នៅឆ្នាំ២០២១។ ដោយឡែកក្នុងឆ្នាំ២០២១ នេះ ស្ថិតិសត្វគោមានចំនួន២,៩៦លានក្បាល ក្របីចំនួន៤៣២,៥៥ពាន់ក្បាល ជ្រូកចំនួន៣,០១លានក្បាល បក្សីចំនួន ៥៣,៤២លានក្បាល សេះចំនួន៣,៥៨ពាន់ក្បាល ចៀមចំនួន៤,២៩ពាន់ក្បាល ពពែចំនួន៤៣,៥៦ពាន់ក្បាល ដំរីចំនួន ៤៩ក្បាល ស្វាចំនួន៦៨,១៦ពាន់ក្បាល និងទន្សាយចំនួន៥៤៦ក្បាល។

បើប្រៀបធៀបទៅនឹងឆ្នាំ២០២០ ផលិតកម្មសត្វសរុបមានអត្រាកំណើនចំនួន១១,២% ក្នុងនោះគោកើនចំនួន ៤,២% ក្របីកើនចំនួន២,១% ជ្រូកកើនចំនួន២០,០% បក្សីកើនចំនួន១១,២% សេះកើនចំនួន២០,៦% ចៀមកើន ចំនួន១៤៨,៩% ពពែកើនចំនួន៤៣,៩% ស្វាកើនចំនួន២៩៥,៦% ទន្សាយកើនចំនួន៧៥,៦% ដោយឡែកដំរីថយចុះ ចំនួន៣,៩%។

**តារាងស្ថិតិផលិតកម្មសត្វសរុប ចិញ្ចឹមជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម ពីឆ្នាំ២០១៧-២០២១**

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀប ឆ្នាំ២០២១ &២០២០ | អត្រាកំណើន មធ្យម ៥ឆ្នាំ |
|---|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | | |
| ១ | គោ | ២ ៩៧១ ៧២២ | ២ ៩២៨ ៥៣៤ | ២ ៧៧៩ ៧៦២ | ២ ៨៤៨ ៥៧៦ | ២ ៩៦៧ ៣៩៨ | ៤,២% | ០,៤% |
| ២ | ក្របី | ៥០៨ ៦៥៦ | ៥០០ ៩៩៥ | ៤៤៧ ៣៨៥ | ៤២៣ ៨២៥ | ៤៣២ ៥៥៩ | ២,១% | -៣,៦% |
| ៣ | គោ ក្របី | ៣ ៤៨០ ៣៧៨ | ៣ ៤២៩ ៥២៩ | ៣ ២២៧ ១៤៧ | ៣ ២៧២ ៤០១ | ៣ ៣៩៩ ៩៥៧ | ៣,៩% | -០,២% |
| ៤ | កម្លាំងអូសទាញ | ៩៣៥ ២៣៩ | ៨៣៦ ៣០១ | ៧១៧ ៩០២ | ៦៤៨ ៧២៩ | ១៦១ ៥៥០ | -៧៥,១% | -២៤,១% |
| ៥ | ជ្រូក | ៣ ០៧៤ ២៨៣ | ២ ៧៤៧ ៨៥៥ | ២ ១៨៥ ៩២៤ | ២ ៥១៦ ៦៧៩ | ៣ ០១៨ ៧៩៧ | ២០,០% | ១,៥% |
| ៦ | បក្សី | ៣៦ ២៤៤ ៩៣៩ | ៣៨ ១៦៦ ៧៥១ | ៤០ ៣៩៥ ៤៥៣ | ៤៨ ០៦២ ១៦៩ | ៥៣ ៤២២ ៧០៤ | ១១,២% | ៨,៥% |
| ៧ | សេះ | ៥ ១៣៧ | ៤ ២៩៦ | ៣ ៨០១ | ២ ៩៧១ | ៣ ៥៨៣ | ២០,៦% | -៧,៧% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៨ | ចៀម | ៤៦១ | ៤៥៩ | ៦៤៨ | ១ ៧២៥ | ៤ ២៩៣ | ១៤៨,៩% | ៧០,៩% |
| ៩ | ពពែ | ២៨ ៩០៧ | ២៦ ៤៤៧ | ២៧ ៧៤០ | ៣០ ២៨១ | ៤៣ ៥៦១ | ៤៣,៩% | ៩,៨% |
| ១០ | ដំរី | ៦៣ | ៥៨ | ១៨ | ៥១ | ៤៩ | -៣,៩% | ២០,៥% |
| ១១ | ស្វា | - | - | ១៤ ២២៨ | ១៧ ២២៩ | ៦៨ ១៦៦ | ២៩៥,៦% | ៦៣,៣% |
| ១២ | ទន្សាយ | - | - | ១៨៥ | ៣១១ | ៥៤៦ | ៧៥,៦% | ២៨,៧% |
| សរុប | | ៤២ ៨៣៤ ១៦៨ | ៤៤ ៣៧៥ ៣៩៥ | ៤៥ ៨៥៥ ១៤៣ | ៥៣ ៩០៣ ៨១៧ | ៥៩ ៩៦១ ៦៥៦ | ១១,២% | ៧,៥% |

**ក្រាហ្វិកទី១៨៖ ផលិតកម្មសត្វសតុប (លក្ខណៈគ្រួសារ+ពាណិជ្ជកម្ម)ឆ្នាំ២០១៧ -២០២១**




### ២.១.៤ ការប្រៀបធៀបបែបផែនផលិតកម្មសត្វ

ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វ គឺជាគោលដៅអាទិភាពសម្រាប់ការធ្វើពាណិជ្ជកម្មសត្វ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានអត្រាកើនឡើងគួរឱ្យកត់សម្គាល់ គឺចាប់ពីចំនួន៨,៣៥លានក្បាល ក្នុងឆ្នាំ២០១៧ កើនដល់ចំនួន២៣,៣៨លានក្បាល នៅឆ្នាំ២០២១។ ដោយឡែកក្នុងឆ្នាំ២០២១នេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានអត្រាកំណើនចំនួន២៣,៦% ក្នុងនោះផលិតកម្មគោកើនចំនួន១០,៨% ផលិតកម្មជ្រូកកើនចំនួន២៨,២% និងផលិតកម្មបក្សីកើនចំនួន២៣,០%។ អត្រានៃកំណើននេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមានមួយ ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែល្អប្រសើរឡើង។

\+ **ការប្រៀបធៀបបែបផែនផលិតកម្មសត្វ៖** អត្រានៃការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន៣៥% ក្នុងឆ្នាំ២០២០ ដល់ចំនួន៣៩% នៅឆ្នាំ២០២១។ ដោយឡែកអត្រានៃការចិញ្ចឹមសត្វលក្ខណៈគ្រួសារបានថយចុះពីចំនួន៦៥% ក្នុងឆ្នាំ២០២០ មកត្រឹមចំនួន៦១% នៅឆ្នាំ២០២១។

**ស្ថិតិសត្វសរុប តាមបែបផែនផលិតកម្ម ពីឆ្នាំ២០១៧-២០២១**

| បែបផែន ផលិតកម្មសត្វ | ស្ថិតិសត្វសរុប ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ៣៤ ៤៧៧ ៨៥៩ | ៣៤ ៣៣៩ ៨១០ | ៣២ ០៤៣ ៥៣៥ | ៣៤ ៩៨៣ ៧៤០ | ៣៦ ៥៧៦ ៦២២ | ៤,៦% |
| លក្ខណៈពាណិជ្ជកម្ម | ៨ ៣៥៦ ៣០៩ | ១០ ០៣៥ ៥៨៥ | ១៣ ៨១១ ៦០៨ | ១៨ ៩២០ ០៧៧ | ២៣ ៣៨៥ ០៣៤ | ២៣,៦% |
| សរុប | ៤២ ៨៣៤ ១៦៨ | ៤៤ ៣៧៥ ៣៩៥ | ៤៥ ៨៥៥ ១៤៣ | ៥៣ ៩០៣ ៨១៧ | ៥៩ ៩៦១ ៦៥៦ | ១១,២% |

## ក្រាហ្វិកទី១៩៖ ប្រៀបធៀបបែបផែនផលិតកម្មសត្វសរុបឆ្នាំ២០១៧ -២០២១




### អត្រានៃបែបផែនផលិតកម្មសត្វសរុប ពីឆ្នាំ២០១៧-២០២១

| បែបផែន ផលិតកម្មសត្វ | អត្រានៃបែបផែនផលិតកម្មសត្វសរុប ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ៨០% | ៧៧% | ៧០% | ៦៥% | ៦១% | -៤% |
| លក្ខណៈពាណិជ្ជកម្ម | ២០% | ២៣% | ៣០% | ៣៥% | ៣៩% | ៤% |

## ក្រាហ្វិកទី២០៖ ប្រៀបធៀបអត្រាបែបផែនផលិតកម្មសត្វសរុបឆ្នាំ២០១៧ -២០២១




**ការប្រៀបធៀបបែបផែនផលិតកម្មជ្រូក៖** អត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៥៥% ក្នុងឆ្នាំ២០២០ ដល់ចំនួន៥៩% នៅក្នុងឆ្នាំ២០២១។ ដោយឡែកអត្រានៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ បានថយចុះពីចំនួន៤៥% ក្នុងឆ្នាំ២០២០ មកត្រឹមចំនួន៤១% នៅឆ្នាំ២០២១។

### ស្ថិតិជ្រូក តាមបែបផែនផលិតកម្ម ពីឆ្នាំ២០១៧-២០២១

| បែបផែន ផលិតកម្មជ្រូក | ស្ថិតិជ្រូក ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ២ ៣៣១ ៥១២ | ១ ៩៣៤ ៩១៧ | ១ ០៣០ ៤៩៤ | ១ ១៣៧ ០៥៦ | ១ ២៥០ ១៦៧ | ៩,៩% |
| លក្ខណៈពាណិជ្ជកម្ម | ៧៤២ ៧៧១ | ៨១២ ៩៣៨ | ១ ១៥៥ ៤៣១ | ១ ៣៧៩ ៦២៣ | ១ ៧៦៨ ៦៣០ | ២៨,២% |
| **សរុប** | **៣ ០៧៤ ២៨៣** | **២ ៧៤៧ ៨៥៥** | **២ ១៨៥ ៩២៤** | **២ ៥១៦ ៦៧៩** | **៣ ០១៨ ៧៨៧** | **២០,០%** |

## ក្រាហ្វិកទី២១៖ ប្រៀបធៀបបែបផែនផលិតកម្មជ្រូក ឆ្នាំ២០១៧ -២០២១




## អត្រានៃស្ថិតិជ្រូក តាមបែបផែនផលិតកម្ម ពីឆ្នាំ២០១៧-២០២១

| បែបផែន ផលិតកម្មជ្រូក | អត្រានៃបែបផែនផលិតកម្មជ្រូក ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ៧៦% | ៧០% | ៤៧% | ៤៥% | ៤១% | -៤% |
| លក្ខណៈពាណិជ្ជកម្ម | ២៤% | ៣០% | ៥៣% | ៥៥% | ៥៩% | ៤% |

## ក្រាហ្វិកទី២២៖ ប្រៀបធៀបអត្រានៃបែបផែនផលិតកម្មជ្រូក ឆ្នាំ២០១៧ -២០២១




**ការប្រៀបធៀបបែបផែនផលិតកម្មបក្សី៖** អត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈពាណិជ្ជកម្មបានកើនពីចំនួន ៣៦% ក្នុងឆ្នាំ២០២០ ដល់ចំនួន៤០% នៅឆ្នាំ២០២១។ ដោយឡែកអត្រានៃការចិញ្ចឹមបក្សីជាលក្ខណៈគ្រួសារបាន ថយចុះពីចំនួន៦៤% ក្នុងឆ្នាំ២០២០ មកត្រឹមចំនួន៦០% នៅឆ្នាំ២០២១។

## ស្ថិតិបក្សី តាមបែបផែនផលិតកម្ម ពីឆ្នាំ២០១៧-២០២១

| បែបផែន ផលិតកម្មបក្សី | ស្ថិតិបក្សី ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ២៨ ៦៥២ ៤០៩ | ២៨ ៩៥៦ ៣៤២ | ២៧ ៧៦៣ ៤៧៩ | ៣០ ៥៥៣ ២៣៣ | ៣១ ៨៩១ ៩៥២ | ៤,៤% |
| លក្ខណៈពាណិជ្ជកម្ម | ៧ ៥៩២ ៥៣០ | ៩ ២១០ ៤០៩ | ១២ ៦៣១ ៩៧៤ | ១៧ ៥០៨ ៩៣៦ | ២១ ៥៣០ ៧៥២ | ២៣,០% |
| សរុប | ៣៦ ២៤៤ ៩៣៩ | ៣៨ ១៦៦ ៧៥១ | ៤០ ៣៩៥ ៤៥៣ | ៤៨ ០៦២ ១៦៩ | ៥៣ ៤២២ ៧០៤ | ១១,២% |

### ក្រាហ្វិកទី២៣៖ ប្រៀបធៀបបែបផែនផលិតកម្មបក្សី ឆ្នាំ២០១៧ -២០២១




### អត្រានៃបែបផែនផលិតកម្មបក្សី ពីឆ្នាំ២០១៧-២០២១

| បែបផែន ផលិតកម្មបក្សី | អត្រានៃបែបផែនផលិតកម្មបក្សី ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២០១៧-២០២១) | | | | | ប្រៀបធៀបឆ្នាំ ២០២១ & ២០២០ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | |
| លក្ខណៈគ្រួសារ | ៧៩% | ៧៦% | ៦៩% | ៦៤% | ៦០% | -៤% |
| លក្ខណៈពាណិជ្ជកម្ម | ២១% | ២៤% | ៣១% | ៣៦% | ៤០% | ៤% |

### ក្រាហ្វិកទី២៤៖ ប្រៀបធៀបបែបនៃផែនផលិតកម្មបក្សី ឆ្នាំ២០១៧ -២០២១




## ២.១.៥.តម្រូវការសត្វ និងសាច់

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ តម្រូវការសាច់សត្វសម្រាប់ការបរិភោគ មានការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពីចំនួន២៨០ពាន់តោន ក្នុងឆ្នាំ២០១៧ ឡើងដល់ចំនួន៣១០ពាន់តោន នៅឆ្នាំ២០២១។ ដោយឡែកក្នុងឆ្នាំ ២០២១នេះ តម្រូវការសាច់មានចំនួនសរុប៣១០ពាន់តោន ក្នុងនោះ សាច់គោ-ក្របីចំនួន៨៦ពាន់តោន សាច់ជ្រូក ចំនួន១៦០ពាន់តោន សាច់បក្សីចំនួន៦៣ពាន់តោន សាច់ចៀម-ពពែ និងសាច់ផ្សេងទៀតចំនួន៣៤៥តោន។ ផលិតកម្មសត្វក្នុងស្រុក អាចផ្គត់ផ្គង់សាច់បានប្រមាណ២៦៨ពាន់តោន ស្មើនឹង៨៧% នៃតម្រូវការសរុប ក្នុងនោះ សាច់គោ-ក្របី ចំនួន៨៩ពាន់តោន (៨១៥ពាន់ក្បាល) សាច់ជ្រូកចំនួន១១៥ពាន់តោន (២ ៣១០ពាន់ក្បាល) សាច់បក្សីចំនួន៦៣ពាន់តោន (៥២ ៩៤១ពាន់ក្បាល)។ បរិមាណសាច់ដែលខ្វះខាតត្រូវបាននាំចូលដើម្បីបំពេញតម្រូវការបន្ថែម ជាក់ស្តែង

នៅក្នុងឆ្នាំ២០២១នេះ កម្ពុជាបាននាំចូលសាច់ និងផលិតសត្វមួយចំនួនរួមមាន ជ្រូកសាច់រស់ចំនួន៧០៩ពាន់ក្បាល។ មាន់សាច់រស់ចំនួន៣,៨៣លានក្បាល ទាសាច់រស់ចំនួន៧៣៤ពាន់ក្បាល ចៀម-ពពែរស់ចំនួន៦ពាន់ក្បាល និងសាច់ចម្រុះចំនួន៧,៤២ពាន់តោន (សាច់ជ្រូក ចៀម មាន់ ទា ក្ងាន ក្រួច ព្រាប គោ ក្របី ប្រហិត និងផលិតផលសាច់សត្វ)។

**តារាងតម្រូវការប្រើប្រាស់ ការផ្គត់ផ្គង់ និងការបំពេញបន្ថែម ឆ្នាំ២០២១**

| ប្រភេទសត្វ | តម្រូវការប្រើប្រាស់ | | លទ្ធភាពផ្គត់ផ្គង់ក្នុងស្រុក | | លើស/ខ្វះ(+/-) | |
|---|---|---|---|---|---|---|
| | សាច់ (តោន) | សត្វ (ពាន់ក្បាល) | សាច់ (តោន) | សត្វ (ពាន់ក្បាល) | សាច់ (តោន) | សត្វ (ពាន់ក្បាល) |
| គោ ក្របី | ៨៦ ១៣៣ | ៧៨៣ | ៨៩ ៦៨៨ | ៨១៥ | ៣ ៥៥៤ | ៣២ |
| ជ្រូក | ១៦០ ០៣៦ | ៣ ២០១ | ១១៥ ៤៩០ | ២ ៣១០ | -៤៤ ៥៤៦ | -៨៩១ |
| បក្សី | ៦៣ ៥៦៧ | ៥២ ៩៧២ | ៦៣ ៥២៩ | ៥២ ៩៤១ | -៣៨ | -៣១ |
| ចៀម ពពែ & ផ្សេងៗ | ៣៤៥ | ៣៤ | ១៨៣ | ១៨ | -១៦២ | -១៦ |
| សរុប | ៣១០ ០៨១ | | ២៦៨ ៨៩០ | ស្មើនឹង ៨៧% | -៤១ ១៩១ | ស្មើនឹង ១៣% |

**ក្រាហ្វិកទី២៥៖ តម្រូវការសាច់ ការផ្គត់ផ្គង់ និងកង្វះខាត**




**ក្រាហ្វិកទី២៦៖ អត្រានៃការផ្គត់ផ្គង់ និងកង្វះខាត**




### ២.១.៦.ការនាំចេញសត្វ និងផលិតផលសត្វ

កម្ពុជាមានលទ្ធភាពធ្វើការនាំចេញគោ ក្របី ជ្រូក មាន់ ស្វាក្ដាម សាច់ ផលិតផលសត្វ ចំណីសត្វ និងទឹកដោះគោមួយចំនួនទៅបរទេសផងដែរ។ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ កម្ពុជាបាននាំចេញគោ-ក្របីចំនួន៨៨,៦ពាន់ក្បាល ជ្រូកពូជ (មេ,បា,កូន) ចំនួន៧,៧ពាន់ក្បាល ស្វាក្ដាមចំនួន៨០,៦ពាន់ក្បាល សាច់គោចំនួន១៩តោន ទឹកដោះគោ

ចំនួន១២,៣ពាន់តោន ចំណីឆ្អែចំនួន១១ពាន់តោន រោមសត្វចំនួន៧៤,៨តោន និងស្បែកគោ ក្របី ជ្រូកចំនួន៧,៧ពាន់តោន។ ដោយឡែកនៅឆ្នាំ២០២១ បាននាំចេញគោ ក្របីចំនួន៤,៦ពាន់ក្បាល ជ្រូកពូជចំនួន៧១៧ក្បាល ស្វាក្តាម ចំនួន២៣,២ពាន់ក្បាល ទឹកដោះគោចំនួន៣៨១តោន ចំណីឆ្អែចំនួន៤,៨ពាន់តោន រោមសត្វចំនួន១២តោន និងស្បែកគោ-ក្របី ជ្រូកចំនួន១,០៥ពាន់តោន។

**តារាងស្ថិតិនាំចេញសត្វ សាច់ ផលិតផលសត្វ និងចំណីសត្វ ពីឆ្នាំ២០១៧-២០២១**

| បរិយាយ | ឯកតា | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | សរុប |
|---|---|---|---|---|---|---|---|
| គោ-ក្របី | ក្បាល | ១១ ២៤០ | ៦ ៧៨៦ | ៥៦ ២១៨ | ៩ ៧៤២ | ៤ ៦៩៨ | ៨៨ ៦៨៤ |
| ជ្រូកពូជ (មេ បា) | ក្បាល | ១ ១៤០ | ៥០៥ | ២០០ | ២០០ | ៧១៧ | ២ ៧៦២ |
| ជ្រូកពូជ (កូន) | ក្បាល | - | ៥ ០០០ | - | - | | ៥ ០០០ |
| ស្វាក្តាម | ក្បាល | ៦ ៩៣៤ | ១០ ៤៧២ | ១៦ ១៩៦ | ២៣ ៧៧០ | ២៣ ២៤៧ | ៨០ ៦១៩ |
| សាច់គោ | តោន | ៧ | ១២ | - | - | - | ១៩ |
| ទឹកដោះគោ | តោន | ៤៥១ | ៧ ៥៥៨ | ៣ ៩៨៤ | - | ៣៨១ | ១២ ៣៧៤ |
| ចំណីឆ្អែ | តោន | ១ ៣៦៥ | ១ ៤៩៤ | ១ ០១១ | ២ ២៧៦ | ៤ ៨៨១ | ១១ ០២៧ |
| រោមសត្វ | តោន | ២៨ | ២៤ | ៨ | ២,៨ | ១២ | ៧៤,៨ |
| ស្បែកគោ-ក្របីសើម | តោន | ១ ៩៧២ | ១ ២៧៥ | ១ ៤៤០ | ១ ៥៥៤ | ១០៤ | ៦ ៣៤៥ |
| ស្បែកគោ-ក្របីស្ងួត | តោន | - | - | - | - | ៩០០ | ៩០០ |
| ស្បែកជ្រូកស្ងួត | តោន | - | - | - | - | ៤៦ | ៤៦ |

### ២.១.៧ កម្មវិធីកែលម្អពូជ

នៅឆ្នាំ២០២១នេះ ការបង្កាត់គោដោយសិប្បនិម្មិតសម្រេចបានចំនួន២ ៦៣២ក្បាល និងមេកើតកូនបានចំនួន១ ១៤២ក្បាល (ញី៦១៩ក្បាល) ស្មើនឹង៤៣% នៃមេដែលបានបង្កាត់សិប្បនិម្មិត និងមេមិនទាន់កើតកូនមានចំនួន១ ៤៩០ក្បាល ស្មើនឹង៥៧%។ ការបង្កាត់គោដោយសិប្បនិម្មិតនេះបានចូលរួមចំណែកពីវិស័យឯកជនផងដែរ ប៉ុន្តែតួលេខនៃការកើតកូនគោមិនស្មើទៅនឹងតួលេខបង្កាត់ពីព្រោះគោផើមមានរយៈពេល០៩ខែ និង១០ថ្ងៃ ដូច្នេះមេគោមួយចំនួនត្រូវកើតកូននៅឆ្នាំបន្ទាប់។ ការបង្កាត់ជ្រូកសិប្បនិម្មិតសម្រេចបាន១៩ ៤៣៩ក្បាល និងបង្កើតកូនជ្រូកបានចំនួន ១៨១ ៤៦៣ក្បាល (ញី៨៤ ១២៥ក្បាល)។ ជាការកត់សម្គាល់ពិនិត្យឃើញថា ពូជជ្រូកត្រូវបានកែលម្អយ៉ាងឆាប់រហ័សនៅទូទាំងប្រទេស។

### ២.១.៨ ចំណីសត្វ

កម្មវិធីកែលម្អចំណីសត្វ និងផ្សព្វផ្សាយពូជស្មៅ ដែលសំបូរទៅដោយសារធាតុចិញ្ចឹម និងផ្តល់ទិន្នផលខ្ពស់គឺជាសកម្មភាពដ៏អាទិភាពមួយដើម្បីជំរុញផលិតកម្មសត្វ។ បច្ចុប្បន្នការដាំដុះដំណាំចំណីសត្វ បានរីកសាយភាយយ៉ាងទូលំទូលាយនៅទូទាំង២៥រាជធានី ខេត្ត ជាក់ស្តែងក្នុងឆ្នាំ២០២១នេះ កន្លែងដាំដុះ និងធ្វើបង្ហាញដំណាំចំណីសត្វមានចំនួនសរុប២ ៥៧៩កន្លែង លើផ្ទៃដីចំនួន១ ៨៧៤,៩៥ហិកតា។

ក្នុងឆ្នាំ២០២១នេះ ក្រុមហ៊ុនដែលបានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វ នៅក្នុងប្រទេសកម្ពុជាសរុបមានចំនួន២១ក្រុមហ៊ុន រួមមាន ក្រុមហ៊ុនស៊ីភី អេហ្វ្រីម៉ាស្ទ័រ ហ្វ្រីនហ្វីត បេតាហ្គ្រោ ញ៉ូវហូប អ៊ីស្តហូប ស៊ីជេសាណាហ្គ្រូ អិមភិក អេស៊ីអិមស៊ី ស៊ីខេវ៉ាយអ៊ី ប្រាយអេហ្វ្រីស្តារ វើលដ៍វេត រោងចក្រចំណីសត្វកណ្តោលជុំ អេអែនធីហ្វីដ ដេហ៊ីស ធីអិមអេច វឌ្ឍនៈអេនីម័លហ៊ែល ហ្វីដប្រូខេអេច ភីធិបបែលយូអ នូបលេថេស្តហ្វូដ អាយតាវេផត សិបផ្លាយ និងឡូឌី ផេត ប្រូដាក ដែលមានរោងចក្រផលិតចំណីសត្វសរុបចំនួន២៣រោងចក្រ និងរោងចក្រចំនួន២ទៀតកំពុងដំណើរការសាងសង់បន្ថែម។ ក្រុមហ៊ុនផលិតចំណីសត្វទាំងអស់ បាននិងកំពុងដំណើរការផលិតចំណីសត្វយ៉ាងសកម្ម

ដោយផលិតចំណីសត្វបានប្រមាណជាង១,២៤លានតោន ស្មើនឹងចំនួន៥៥% នៃសមត្ថភាពផលិតរបស់រោងចក្រ ជាង២,២៧លានតោន។

ម្យ៉ាងវិញទៀត ក្រៅពីចំណីសត្វដែលផលិតបាននៅក្នុងស្រុក ក៏មានក្រុមហ៊ុនមួយចំនួនទៀត បាននាំចូលបន្ថែម នូវចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម ដើម្បីបំពេញសេចក្ដីត្រូវការប្រើប្រាស់ និងផលិតចំណីសត្វក្នុងស្រុក។ ជាក់ស្ដែងក្នុងឆ្នាំ២០២១នេះ កម្ពុជាបាននាំចូលនូវចំណីសត្វចំនួន៣២២ពាន់តោន វត្ថុធាតុដើមចំនួន៦៧៩៣ពាន់តោន និងសារធាតុបន្ថែមចំនួន២៩,៨ពាន់តោន បសុឱសថចំនួន៦,៣ពាន់តោន វ៉ាក់សាំងចំនួន១ពាន់តោន សម្ភារបសុពេទ្យ និងឧបករណ៍ចិញ្ចឹមសត្វចំនួន៦៦តោន។

### ២.១.៩ ការគ្រប់គ្រងកាកសំណល់សត្វ

ការសាងសង់ឡជីវឧស្ម័ន ត្រូវបានជំរុញ និងលើកទឹកចិត្តឱ្យសាងសង់យ៉ាងទូលំទូលាយ ដើម្បីគ្រប់គ្រងកាកសំណល់សត្វ និងបានទាញយកនូវថាមពលកកើតឡើងវិញ និងផ្ដល់នូវជីធម្មជាតិ។

កម្មវិធីឡជីវឧស្ម័នជាតិបានអនុវត្តតាំងពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ននេះ ការសាងសង់ឡជីវឧស្ម័នគ្រួសារបានចំនួន២៩ ១៨៤ឡ ក្នុងខេត្តចំនួន១៤ គឺខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្ដាល ព្រៃវែង ពោធិ៍សាត់ សៀមរាប ស្វាយរៀង តាកែវ ត្បូងឃ្មុំ និងខេត្តបន្ទាយមានជ័យ។ ដោយឡែកក្នុងឆ្នាំ២០២១ កម្មវិធីឡជីវឧស្ម័នជាតិ សាងសង់ឡជីវឧស្ម័នគ្រួសារបានចំនួន៤៩៩ឡ។

គម្រោងសាងសង់ឡជីវឧស្ម័នកម្ពុជា-ចិនចំនួន១ ៥០០ឡ ក្រោមហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន បានអនុវត្តពីចុងឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្ននេះសាងសង់ឡជីវឧស្ម័នគ្រួសារបានតែចំនួន៥០ឡប៉ុណ្ណោះនៅក្នុងខេត្តចំនួន៧គឺ ខេត្តកំពង់ចាម កំពង់ឆ្នាំង ព្រៃវែង ពោធិ៍សាត់ ស្វាយរៀង ព្រះវិហារ និងខេត្តត្បូងឃ្មុំ។ ជាក់ស្ដែងនៅក្នុងឆ្នាំ២០២១ នេះ ការសាងសង់ឡជីវឧស្ម័នគ្រួសារសម្រេចបានតែចំនួន១០ឡទៀតប៉ុណ្ណោះ (ខេត្តព្រះវិហារ៦ឡ ឧត្តរមានជ័យ២ឡ និងខេត្តពោធិ៍សាត់២ឡ)។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងជំរុញ និងកំណត់អត្តសញ្ញាណកសិករដែលស្ម័គ្រចិត្តទទួលឡជីវឧស្ម័នឱ្យបានចំនួនជាក់លាក់ ដើម្បីលើកសំណើសុំថវិកាបដិភាគរបស់រាជរដ្ឋាភិបាលបន្ថែមសម្រាប់អនុវត្តគម្រោងឡជីវឧស្ម័នបន្តទៀត ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។

ម្យ៉ាងវិញទៀត គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាពធន់:បរិស្ថាន ក្រោមហិរញ្ញប្បទានសម្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានចាប់ផ្ដើមអនុវត្តក្នុងឆ្នាំ២០២០ ក្នុងផែនការសាងសង់ឡជីវឧស្ម័នគ្រួសារចំនួន១២ ០០០ឡ នៅខេត្តចំនួន០៤ គឺខេត្តកំពង់ចាម ត្បូងឃ្មុំ តាកែវ និងខេត្តកំពត ពុំទាន់ដំណើរការទេដោយសារបញ្ហាជំងឺកូវីដ-១៩ និងនីតិវិធីលទ្ធកម្ម។

**ក្រាហ្វិកទី២៧៖ ការសាងសង់ឡជីវឧស្ម័នគ្រួសារ ពីឆ្នាំ២០០៦-២០២១**



## ក្រាហ្វិកទី២៨៖ ការសាងសង់ឡជីវឧស្ម័នគ្រួសារ ពីឆ្នាំ២០០៦-២០២១




### ២.២.ការលើកកម្ពស់សុខនាពសត្វ និងសុខនាពសាធារណៈ

ការពង្រឹងសុខភាពសត្វ អនាម័យសត្វ សាច់ និងផលិតផលសត្វ បានផ្តោតជាសំខាន់លើការត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព ពង្រឹងការផ្តល់សេវាបសុព្យាបាល កាត់បន្ថយការឆ្លងរាលដាលជំងឺសត្វ និងការផ្គត់ផ្គង់សាច់ប្រកបដោយអនាម័យ គុណភាព និងសុវត្ថិភាពនៅលើទីផ្សារ ដើម្បីការពារសុខភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន។ ក្នុងឆ្នាំ២០២១នេះ ការលើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈ ទទួលបានលទ្ធផល ដូចខាងក្រោម៖

### ២.២.១ ការលើកកម្ពស់សុខភាពសត្វ

នៅឆ្នាំ២០២១នេះ ក្រសួងបានពង្រឹងសកម្មភាពត្រួតពិនិត្យ និងទប់ស្កាត់បទល្មើសចរាចរណ៍សត្វ និងការធ្វើអាជីវកម្មសត្វ ដោយបានសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធបន្តអនុវត្តសេចក្តីណែនាំអំពីលក្ខខណ្ឌតម្រូវសម្រាប់ការនាំចូល នាំចេញ និងនាំឆ្លងកាត់សត្វ និងផលិតផលសត្វ។ ជាលទ្ធផល បានធ្វើការត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វចំនួនសរុប២០២ករណី នៅទូទាំងប្រទេស ក្នុងនោះ ក្រសួងបានត្រួតពិនិត្យចរាចរណ៍សត្វ និងផលិតផលសត្វមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន១១៤ករណី និងបង្ក្រាបបទល្មើសបានចំនួន៥៦ករណី (ដឹកជញ្ជូនមាន់រស់ចំនួន១៨ករណី ជ្រូករស់ចំនួន២៤ករណី សាច់ជ្រូកបង្កកចំនួន០២ករណី សាច់ក្របីបង្កកចំនួន០២ករណី ប្រហិតចំនួន ០៤ករណី ស្លាបមាន់និងជើងមាន់ចំនួន០២ករណី សាច់គោ ក្របីចំនួន០២ករណី គ្រឿងក្នុងជ្រូកចំនួន០២ករណី) និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត បង្ក្រាបបទល្មើសបានចំនួន៣២ករណី (ដឹកជញ្ជូនមាន់រស់ចំនួន១២ករណី ជ្រូករស់ចំនួន០៧ករណី និងផលិតផលកែច្នៃពីសត្វចំនួន១៣ករណី)។ ជាមួយគ្នានេះដែរ បានធ្វើការអង្កេតតាមដាន បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺឆ្លងសត្វ ព្រមទាំងបានរៀបចំប្រព័ន្ធព័ត៌មាន និងរាយការណ៍ជំងឺឆ្លងសត្វទាំងថ្នាក់ជាតិ និងអន្តរជាតិ ចាត់វិធានការជីវសុវត្ថិភាព កម្មវិធីឆ្លើយតបបន្ទាន់ករណីផ្ទុះជំងឺឆ្លងសត្វ និងការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសម្រេចបាន ដូចខាងក្រោម៖

១. ចាក់វ៉ាក់សាំងការពារជំងឺឆ្លងសំខាន់ៗដែលកើតមានលើគោ ក្របី ពពែ ចៀម ដូចជាជំងឺអុតក្តាម បូសខ្យល់សារទឹក និងជំងឺដុំពកស្បែកគោ ក្របីចំនួនសរុប៩៥០ ៨៨៩ក្បាល ចាក់វ៉ាក់សាំងការពារជំងឺលើជ្រូកចំនួន ២ ២១០ ៦២២ ក្បាល ចាក់វ៉ាក់សាំងការពារជំងឺលើបក្សីបានចំនួន៣៨ ៧៧៤ ៤៧១ក្បាល និងចាក់វ៉ាក់សាំងការពារជំងឺលើឆ្កែ និងឆ្មាចំនួន១១ ៧១៣ក្បាល។

២. ចាត់វិធានការជីវសុវត្ថិភាព ផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅសត្តឃាតដ្ឋាន ទីផ្សារសត្វ កសិដ្ឋានចិញ្ចឹមសត្វ កន្លែងចិញ្ចឹមសត្វ មធ្យោបាយដឹកជញ្ជូនសត្វ និងផលិតផលសត្វ និងកន្លែងផ្ទុះជំងឺសត្វសរុបចំនួន ២០២ ០២៤លើក

៣. ភ្នាក់ងារសុខភាពសត្វភូមិទូទាំងប្រទេសមានចំនួន៩ ២៦២ នាក់ (ស្ត្រី៧២២នាក់)។

### ២.២.២ ការពង្រឹងសុខភាពសាធារណៈបសុព្យាបាល

សុខភាពសាធារណៈបសុព្យាបាលជាផ្នែកមួយដ៏សំខាន់ មានភារកិច្ចពង្រឹងការគ្រប់គ្រងបទដ្ឋានបច្ចេកទេសសត្តឃាតដ្ឋាន ស្ថិតិសត្វពិឃាត និងត្រួតពិនិត្យអនាម័យសាច់ សត្វ និងផលិតផលសត្វ នៅតាមសត្តឃាតដ្ឋាន និងកន្លែងកែច្នៃបឋមផលិតផលសត្វ ឱ្យមានលក្ខណៈល្អប្រសើរឡើង ព្រមទាំងធ្វើការវាយតម្លៃផ្តល់គោលការណ៍អនុញ្ញាតបង្កើតសត្តឃាតដ្ឋាន ដើម្បីធានាសុខភាពសាធារណៈតាមរយៈការបង្កើនសមត្ថភាពមន្ត្រីផលិតកម្ម និងបសុព្យាបាល អាជីវករពិឃាតសត្វ និងអ្នកពាក់ព័ន្ធលើការគ្រប់គ្រងសត្តឃាតដ្ឋាន បទដ្ឋានបច្ចេកទេសក្នុងការពិឃាតសត្វ និងសុខុមាលភាពសត្វ ព្រមទាំងអនុវត្តវិធានការបសុព្យាបាល អនាម័យសត្វ សាច់ និងផលិតផលសត្វ។ ក្នុងឆ្នាំ២០២១នេះ ក្រសួងបានចុះជំរុញការអនុវត្តល្អក្នុងសត្តឃាតដ្ឋានតាមលក្ខណៈបច្ចេកទេស ដោយអនុលោមតាមអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ក្រសួងបានយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំចងក្រងឯកសារបច្ចេកទេសនានា និងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសពាក់ព័ន្ធនឹងការធ្វើអាជីវកម្មសត្វ ការពិឃាតសត្វតាមបទដ្ឋានបច្ចេកទេសដល់អ្នកពាក់ព័ន្ធ ក្នុងនោះបានចុះណែនាំជំរុញការយល់ដឹងការអនុវត្តល្អក្នុងសត្តឃាតដ្ឋានតាមលក្ខណៈបច្ចេកទេសចំនួន២៥លើក បានបណ្តុះបណ្តាលមន្ត្រីជំនាញ និងអ្នកពាក់ព័ន្ធចំនួន០៣វគ្គ បានចំនួនសរុប៤៦នាក់ (ស្ត្រីចំនួន០៨នាក់) និងបានរៀបចំប្រជុំលើកកម្ពស់ការយល់ដឹងអំពីជីវសុវត្ថិភាព និងហេដ្ឋារចនាសម្ព័ន្ធក្នុងសត្តឃាតដ្ឋានចំនួន១០លើក ដែលមានអ្នកចូលរួមចំនួនសរុប១៥០នាក់ (ស្ត្រីចំនួន៤៤នាក់)។ លើសពីនេះទៅទៀត បានចុះត្រួតពិនិត្យបច្ចេកទេសការស្នើសុំបង្កើតសត្តឃាតដ្ឋានចំនួន១៣កន្លែង (អនុលោមតាមអនុក្រឹត្យលេខ១០៨) និងបន្តសុពលភាពសត្តឃាដ្ឋានចំនួន ១៣កន្លែង (អនុលោមតាមអនុក្រឹត្យលេខ១០៨ចំនួន០៦ និងអនុក្រឹត្យ១០៨និងវិនិយោគចំនួន០៧) ព្រមទាំងបានចុះជ្រើសរើសសត្តឃាតដ្ឋានគំរូដើម្បីបំពាក់ឧបករណ៍ពិឃាតសត្វតាមស្តង់ដារបច្ចេកទេស និងមានលក្ខខណ្ឌអនាម័យល្អចំនួន០៣កន្លែង រួមមានខេត្តសៀមរាបចំនួន០២កន្លែង និងខេត្តបន្ទាយមានជ័យចំនួន០១ កន្លែង។ ដោយឡែកសត្តឃាតដ្ឋានចំនួន១៦កន្លែង ត្រូវបានកែលម្អស្របតាមស្តង់ដារអនាម័យបច្ចេកទេស។

គិតមកដល់ដំណាច់ឆ្នាំ២០២១ នេះ សត្តឃាតដ្ឋាននៅទូទាំងប្រទេសមានចំនួន២៣៦កន្លែង ក្នុងនោះមានសត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យ១០៨ មានចំនួន១២៣កន្លែង សត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យ១០៨និងវិនិយោគចំនួន៦៣កន្លែង និងសត្តឃាតដ្ឋានវិនិយោគចំនួន៥០កន្លែង ក្នុងនោះមានសត្តឃាតដ្ឋានពិឃាតបក្សីទំនើបនៅខេត្តកណ្តាលចំនួន០១កន្លែង និងសត្តឃាតដ្ឋានពិឃាតគោទំនើបនៅខេត្តតាកែវចំនួន០១កន្លែង។ ទោះបីជាសត្តឃាតដ្ឋានកើនជាលំដាប់ ប៉ុន្តែសត្តឃាតដ្ឋានមួយចំនួននៅមិនទាន់មានអនាម័យល្អស្របតាមបទដ្ឋានបច្ចេកទេសនៅឡើយ។ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានខិតខំណែនាំពង្រឹងការគ្រប់គ្រងអនុវត្តនូវបទដ្ឋានបច្ចេកទេស អនាម័យសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និងផលិតផលសត្វ និងបង្កើនសមត្ថភាពមន្ត្រីជំនាញផលិតកម្ម និងបសុព្យាបាល ដែលប្រចាំការនៅតាមសត្តឃាតដ្ឋាន និងអ្នកពាក់ព័ន្ធលើការគ្រប់គ្រងសត្តឃាតដ្ឋាន បទដ្ឋានបច្ចេក-ទេសក្នុងការពិឃាតសត្វ និងសុខុមាលភាពសត្វបន្ថែមទៀត។

## ២.៣.ការផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម

### ២.៣.១.ការងារផ្សព្វផ្សាយបច្ចេកទេស

ក្រសួងបានរៀបចំកម្មវិធីផ្សព្វផ្សាយ សម្ភាសន៍ វេទិកាសាធារណៈ សម្រាប់អ្នកពាក់ព័ន្ធលើប្រធានបទសំខាន់ៗ និងបានផ្សព្វផ្សាយឯកសារបទសម្ភាសន៍ វីដេអូអប់រំបច្ចេកទេសផលិតកម្ម និងបសុព្យាបាល ច្បាប់ លិខិតបទដ្ឋានគតិ-យុត្ត ប្រកាស សារាចរ សេចក្តីណែនាំ ព័ត៌មាន និងឯកសារពាក់ព័ន្ធនានាតាមវិទ្យុ ទូរទស្សន៍ គេហទំព័រ ហ្វេសប៊ុក និង

ចែកជូនការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្តទាំង២៥ និងសាធារណៈជននូវឯកសារបង្ហាញពីការចិញ្ចឹមសត្វ និងការដាំដំណាំចំណីសត្វ និងជំងឺឆ្លងសត្វ។ លើសពីនេះទៀត មន្ត្រីជំនាញបានរៀបប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំចំណីសត្វ និងជំងឺឆ្លងសត្វ ជាពិសេសជំងឺប៉េស្តជ្រូកអាហ្វ្រិក ជំងឺផ្តាសាយបក្សី និងជំងឺដុំពកលើស្បែកគោ ក្របី ដល់កសិករចិញ្ចឹមសត្វ និងអ្នកពាក់ព័ន្ធចំនួនសរុប១ ៨០៩នាក់ (ស្ត្រី ៩០៣នាក់)។

មន្ត្រីជំនាញបានចុះប្រមូលទិន្នន័យពីក្រុមកសិករចិញ្ចឹមសត្វ សហគមន៍កសិកម្មដែលមានចិញ្ចឹមសត្វ និងសមាគមភ្នាក់ងារសុខភាពសត្វភូមិ រួមជាមួយការចុះវាយតម្លៃដោយផ្ទាល់ជាមួយកសិករសកម្មដែលចិញ្ចឹមសត្វ ក្នុងគោលបំណងដើម្បីរៀបចំសហគមន៍សុខភាពសត្វ និងផលិតកម្មសត្វ។ ឆ្នាំ២០២១ នេះ មន្ត្រីជំនាញបានបន្តរៀបចំប្រជុំជ្រើសរើសថ្នាក់ដឹកនាំ និងរៀបចំលក្ខន្តិកៈសម្រាប់សហគមន៍សុខភាពសត្វ និងផលិតកម្មសត្វ ព្រមទាំងបានចុះផ្សព្វផ្សាយស្តីពីបច្ចេកទេសចិញ្ចឹមសត្វ ដល់សមាជិកក្រុមកសិករចិញ្ចឹមសត្វ សហគមកសិកម្មដែលមានចិញ្ចឹមសត្វ និងសមាគមភ្នាក់ងារសុខភាពសត្វភូមិ រួមមានខេត្តចំនួន០៨ គឺខេត្តកំពង់ធំ សៀមរាប តាកែវ កំពង់ស្ពឺ កំពត កែប ព្រៃវែង និងខេត្តកំពង់ចាម ដោយមានអ្នកចូលរួមចំនួនសរុប៣១៥នាក់ ស្ត្រីចំនួន២០០នាក់។

### ២.៣.២ ការងារនីតិកម្ម

#### ក. លិខិតបទដ្ឋានគតិយុត្ត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ជាសេនាបាននឹងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់សំខាន់ៗចំនួន១៥ ដែលក្នុងនោះមានលិខិតបទដ្ឋានក្រោមច្បាប់មួយចំនួនត្រូវបានរៀបចំរួចរាល់ និងមួយចំនួនទៀតកំពុងស្ថិតក្នុងដំណើរការរៀបចំ កែសម្រួល និងបន្តពិភាក្សា រួមមាន៖

- ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈបសុពេទ្យ
- ធ្វើការកែសម្រួលអនុក្រឹត្យលេខ១០៨ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន និងការធ្វើអាជីវកម្មពិឃាតសត្វ អនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ។
- ធ្វើការកែសម្រួលប្រកាសអន្តរក្រសួងលេខ១០១៣ ស្តីពីសេវាសាធារណៈរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌
- ប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ
- ប្រកាសស្តីពីនីតិវិធីចុះបញ្ជី និងការគ្រប់គ្រងសហគមន៍សុខភាពសត្វ និងផលិតកម្មសត្វ
- ប្រកាសស្តីពីនីតិវិធីក្នុងការត្រួតពិនិត្យនូវបសុឱសថ ចំណីសត្វ និងវត្ថុធាតុដើម សារធាតុសកម្ម ឬសារធាតុបន្ថែមដែលនាំចេញ-នាំចូល ផលិតលាយផ្សំ និងវេចខ្ចប់ជាថ្មី
- កែសម្រួលប្រកាសស្តីពីនីតិវិធីនៃការជ្រើសរើសការបណ្តុះបណ្តាល ការគ្រប់គ្រងឱ្យមាននិរន្តរភាព និងភារកិច្ចភ្នាក់ងារសុខភាពសត្វភូមិ
- ប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត វិញ្ញាបនបត្របសុព្យាបាល និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ចរាចរណ៍សត្វ និងផលិតផលសត្វ

- ប្រកាសស្តីពីនីតិវិធី និងការតម្រូវសម្រាប់ការទទួលស្គាល់កិច្ចប្រតិបត្តិការរបស់មន្ទីរពិសោធន៍រដ្ឋ និងឯកជនសម្រាប់វិស័យសុខភាពសត្វ និងផលិតកម្មសត្វ
- ប្រកាសស្តីពីនីតិវិធី និងការតម្រូវបទដ្ឋានបច្ចេកទេសសម្រាប់ការបង្កើត ការគ្រប់គ្រង និងការអនុញ្ញាតបង្កើតស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ
- រៀបចំទម្រង់ពាក្យស្នើសុំ បែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់នានាសម្រាប់ការផ្តល់សេវារដ្ឋបាលការងារសុខភាពសត្វ និងផលិតកម្មសត្វ នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្តដែលនៅសេសសល់
- រៀបចំសេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពីគោលការណ៍ នីតិវិធី និងស្តង់ដារសេវាសម្រាប់គ្រប់គ្រងចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ខ. ការចេញលិខិតអនុញ្ញាត និងការចុះបញ្ជីកា**

គិតមក់ដល់ឆ្នាំ២០២១នេះ ក្រុមហ៊ុនចំណីសត្វចំនួន០៤ បានការអនុញ្ញាតឱ្យផលិត លាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវចំណីសត្វ ក្នុងនោះមានក្រុមហ៊ុន អេ អេន ធី ហ្វីដ ឯ.ក អាយ តាវ ផេត ស៊ីបផ្លាយ (ខេមបូឌា) ឯ.ក ភី.ដាប់បែលយូ.អ មេនូហ្វេកឈ័ររីង ខមភេនីនិងក្រុមហ៊ុនចំរើន ចិត្រា ឯ.ក។ រីឯក្រុមហ៊ុនចំនួន០២ បានការអនុញ្ញាតឱ្យផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មីនូវបសុឱសថ រួមមានក្រុមហ៊ុន អឺហ្វាក់ និងក្រុមហ៊ុន វីផាវ៉េត។ ក្រុមហ៊ុនចំណីសត្វចំនួន១៤ក្រុមហ៊ុន បានចុះបញ្ជិកាចំណីសត្វ សារធាតុបន្ថែម និងវត្ថុធាតុដើមចំនួនសរុប១៨៩មុខ ក្នុងនោះមានចំណីសត្វចំនួន១២០មុខ សារធាតុបន្ថែមចំនួន៦៩មុខ និងបានចុះបញ្ជិកាបសុឱសថ វត្ថុធាតុជីវ-បសុព្យាបាល សារធាតុសកម្ម និងសមាសធាតុចំនួន១៣ក្រុមហ៊ុនចំនួនសរុប៣០០មុខ ក្នុងនោះបសុឱសថចំនួន២៧៨មុខ និងវ៉ាក់សាំងចំនួន២២មុខ។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនចំណីសត្វ បានការអនុញ្ញាតចុះបញ្ជីឃ្លាំងសន្និធិចំនួន១៩ក្រុមហ៊ុន និងបានចុះបញ្ជីឃ្លាំងសន្និធិបសុឱសថចំនួន១១ក្រុមហ៊ុន ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយចំណីសត្វចំនួន២១ក្រុមហ៊ុន ដែលមានយថាប្រភេទចំនួន៧៦៤មុខ និងលិខិតអនុញ្ញាត ផ្គត់ផ្គង់ចែកចាយបសុឱសថចំនួន១១ក្រុមហ៊ុន ដែលមានយថាប្រភេទចំនួន១ ៣០០មុខ។

### ២.៣.៤.ការងារស្រាវជ្រាវ និងអធិការកិច្ច

ក្នុងឆ្នាំ២០២១ នេះ ក្រសួងបានរៀបចំប្រជុំផ្សព្វផ្សាយច្បាប់ និងកម្រងលិខិតបទដ្ឋានគតិយុត្តវិស័យសុខភាពសត្វ និងផលិតកម្មសត្វ និងបើកវគ្គបណ្តុះបណ្តាលស្តីពីការអប់រំសមត្ថភាពវិជ្ជាជីវៈអ្នកផ្គត់ផ្គង់ចែកចាយ និងលក់ដុំលក់រាយចំណីសត្វ និងបសុឱសថ ព្រមទាំងនីតិវិធីច្បាប់ និងបទដ្ឋានបច្ចេកទេសសម្រាប់អ្នកលក់ដុំលក់រាយចំណីសត្វ និងបសុឱសថ ដោយមានអ្នកចូលរួមចំនួនសរុប១៨០នាក់ ក្នុងនោះស្រីចំនួន៤៣នាក់។ ទន្ទឹមនឹងនេះ ក្រសួងក៏បានចាត់មន្ត្រីចុះធ្វើអធិការកិច្ចប្រកាសប្រតិវេទន៍ចំណីសត្វ និងបសុឱសថនៅតាមក្រុមហ៊ុនចំណីសត្វ និងបសុឱសថក្នុងបណ្តារាជធានី ខេត្តចំនួន៥២ក្រុមហ៊ុន និងធ្វើអធិការកិច្ច តាមដេប៉ូលក់ដុំ លក់រាយចំណីសត្វ និងបសុឱសថក្នុងបណ្តារាជធានី ខេត្ត បានចំនួន៣៣ដេប៉ូ ក្នុងចំណោមដេប៉ូសរុបចំនួន១ ០៦២ដេប៉ូនៅទូទាំង២៥រាជធានី ខេត្ត ដោយបានរកឃើញនូវចំណុចខ្វះខាតមួយចំនួនដែលមិនទាន់បានអនុវត្តតាមច្បាប់ និងបទដ្ឋានបច្ចេកទេសឱ្យបានត្រឹមត្រូវក្នុងនោះ ការចែកចាយ និងធ្វើចរាចរណ៍ចំណីសត្វ (ជាពិសេសចំណីឆ្កែ ឆ្មា) និងបសុឱសថដែលមិនទាន់បានចុះបញ្ជិកាត្រឹមត្រូវនៅតែបន្ត ការប្រើប្រាស់សំបកវេចខ្ចប់ពុំទាន់ត្រឹមត្រូវតាមការណែនាំ ឬតាមប្រភេទចំណីសត្វ (ខ្វែងបន្លំស្លាកសញ្ញាព័ត៌មាន) នៅតែមានការបន្តលក់ចំណីសត្វ និងបសុឱសថមិនបានបកប្រែជាភាសាខ្មែរនៅលើសំបកវេចខ្ចប់ចំណី និងបសុឱសថ និងភាពខ្វះចន្លោះក្នុងការអនុវត្តបមាណីយតាមណែនាំរបស់អង្គភាពជំនាញ ដូចមានកំណត់ក្នុងវិញ្ញាបនបត្រ។ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ បានណែនាំ និងធ្វើកិច្ចសន្យាជាមួយ

ក្រុមហ៊ុន និងម្ចាស់ដេប៉ូលក់ជុំ លក់រាយចំណីសត្វ និងបសុឱសថ ដែលនៅខ្វះចន្លោះខាងលើត្រូវអនុវត្តតាមបទដ្ឋានគតិយុត្តដែលបានចូលជាធរមាន។

### ២.៤.ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ

ក្នុងគោលដៅលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានពង្រឹងសមត្ថភាពការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ ឱ្យមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ធ្វើរោគវិនិច្ឆ័យរកមេរោគបង្កជំងឺឆ្លងសត្វសំខាន់ៗ ភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ ពិនិត្យឈាម សេរ៉ូម កោសិកា/ជាលិកា វះពិនិត្យសាកសពសត្វ វិភាគចំណីសត្វ កាកសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងសត្វ និងផលិតផលសត្វ ផលិតទឹកមេជីវិតគោបង្កក បង្កាត់សិប្បនិម្មិតគោពិសោធន៍ ផលិតថ្នាំសម្លាប់មេរោគ និងបណ្តុះបណ្តាលមន្ត្រីជំនាញលើការងារស្រាវជ្រាវ។

ជាក់ស្តែងក្នុងឆ្នាំ២០២១នេះ ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ សម្រេចបានលទ្ធផលដូចខាងក្រោម៖

#### ក. ការងារស្រាវជ្រាវសុខភាពសត្វ

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើរោគវិនិច្ឆ័យជំងឺសត្វ តាមដាន អង្កេតឃ្លាំមើល និងស្រាវជ្រាវជំងឺឆ្លងសត្វ និងភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគ វិភាគកាកសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងផលិតផលសត្វ
- បានយក និងទទួលវត្ថុវិភាគសរុបចំនួន ២២ ១៦៤ មកធ្វើរោគវិនិច្ឆ័យជំងឺ ក្នុងនោះបានរកឃើញវត្ថុមានមេរោគជំងឺឆ្លងសំខាន់ដូចជា ជំងឺបង្កឡើងដោយវីរុសមានផ្តាសាយបក្សី អុតក្តាម ដុំពកស្បែកគោ ក្របី ប៉េស្តជ្រូកអាហ្វ្រិក ប៉េស្តជ្រូក ជ្រូកត្រចៀកខៀវ និងញូវកាស ជំងឺបង្កឡើងដោយបាក់តេរីមានសារទឹកបូសខ្យល់គោ ក្របី សាល់ម៉ូណេឡូស៊ីស អឺកូលី ក្លឹបស៊ីយែលឡា និងស្តាហ្វីឡូកុកគុស អូរេអ៊ុស និងជំងឺបង្កឡើងដោយប៉ារ៉ាស៊ីតមានកុកស៊ីឌីយ៉ា អេម៉ុងយុស ប៊ុយណូស្តូមូម ស្រ្តុងហ្ស៊ីឡូអ៊ីដ កូពើរីយ៉ា តុកសូការ៉ា និងប៉ារ៉ាមហ្វីស្តូមូម
- បានអង្កេតឃ្លាំមើលវត្ថុមានជំងឺផ្តាសាយបក្សីនៅទីផ្សារបក្សីរស់ក្នុងរាជធានី ខេត្តចំនួន១២ (ខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ កំពត កណ្តាល ភ្នំពេញ មណ្ឌលគីរី ព្រៃវែង សៀមរាប ស្វាយរៀង និងខេត្តតាកែវ)។ ជំងឺផ្តាសាយជ្រូក ប៉េស្តជ្រូក ប៉េស្តជ្រូកអាហ្វ្រិក ជ្រូកត្រចៀកខៀវ រលូតកូនជ្រូក ជំងឺគ្រុន Q-Fever និងរលូតកូនគោ នៅតាមសត្តឃាតដ្ឋានក្នុងរាជធានី ខេត្តចំនួន៧ រួមមាន ខេត្តបាត់ដំបង កំពង់ស្ពឺ កណ្តាល ភ្នំពេញ ព្រៃវែង សៀមរាប និងខេត្តតាកែវ។
- បានរកឃើញជំងឺសំខាន់ៗ ដូចជា ជំងឺផ្តាសាយបក្សីផ្ទុះឡើងចំនួន២ករណីគឺ ១).ស្ថិតនៅភូមិព្រៃកតាច្រែង ឃុំព្រៃកនរិទ្ធ ស្រុកឯកភ្នំ ខេត្តបាត់ដំបង និង ២).ស្ថិតនៅភូមិទំពស្តេច ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង។ ជំងឺប៉េស្តជ្រូកអាហ្វ្រិកបានរកឃើញតាមរយៈការលួចនាំចូលជ្រូកពីប្រទេសថៃឡង់ដ៍ និងប្រទេសឡាវចំនួន៥ករណី ក្នុងនោះ៤ករណីនាំចូលពីប្រទេសថៃឡង់ដ៍គឺ ១).ឃាត់ចាប់បានក្នុងខេត្តបន្ទាយមានជ័យចំនួន២ករណី រាជធានីភ្នំពេញចំនួន២ករណី និង១ករណីនាំចូលពីប្រទេសឡាវតាមខេត្តស្ទឹងត្រែង
- បានរកឃើញជំងឺដុំពកស្បែកគោ ក្របី នៅរាយប៉ាយនៅទូទាំង២៥ រាជធានី ខេត្ត ចាប់ពីខែមិថុនា រហូតដល់ខែវិច្ឆិកា ឆ្នាំ២០២១ ប៉ុន្តែក្រោយពីមន្ត្រីជំនាញចុះអន្តរាគមន៍ពិនិត្យព្យាបាល ចាក់វ៉ាក់សាំង យក

វត្ថុវិភាគ អនុវត្តវិធានជីវសុវត្ថិភាព អប់រំណែនាំ និងផ្សព្វផ្សាយបច្ចេកទេសដល់កសិករចិញ្ចឹមសត្វបាន ធ្វើឱ្យជំងឺមានសភាពស្ងប់ស្ងាត់ទៅវិញ។

- បាននឹងកំពុងធ្វើការអង្កេតតាមដានអំពីស្ថានភាពនៃភាពស៊ាំទៅនឹងឱសថប្រឆាំងមេរោគនៅកម្ពុជាជាប្រចាំ។ ក្នុងឆ្នាំ២០២១ បានយកវត្ថុវិភាគតំបារចំនួន២២៤ ពីទីផ្សារលក់មាន់នៅខេត្តកំពង់ស្ពឺ តាកែវ និងរាជធានីភ្នំពេញ ដែលជាលទ្ធផលមានវត្តមានអ៊ីកូលី ៦៣ (២៨%) សាល់ម៉ូណែលឡា ២ (១%) និងក្លឹបស៊ីយែលឡា ១៣ (៦%)
- បានយក និងទទួលវត្ថុវិភាគចំនួន២៥៦វត្ថុវិភាគ ក្នុងនោះចំនួន២២០វត្ថុវិភាគ មានសាច់គោចំនួន៦០ សាច់ជ្រូកចំនួន៩០ និងសាច់មាន់ចំនួន៧០ ពីទីផ្សារនៅខេត្តកំពង់ចាម កំពង់ស្ពឺ ព្រះសីហនុ ព្រៃវែង ស្វាយរៀង តាកែវ និងខេត្តត្បូងឃ្មុំ និងទទួលវត្ថុវិភាគសាច់ និងផលិតផលសត្វចំនួន៣៦វត្ថុវិភាគ មានសាច់គោបង្កកចំនួន៧ ក្រួចបង្កកចំនួន១៤ សាច់ជ្រូកចំនួន៣ គ្រឿងក្នុងជ្រូកនិងមាន់ចំនួន១២ មកពីប្រទេសវៀតណាម ដើម្បីវិភាគរកកាកសំណល់អង់ទីប៊ីយ៉ូទិកក្នុងក្រុមតេត្រាស៊ីគ្លីន ស៊ុលហ្វា បេតាអាហ្គោនីស និងសារធាតុហ្វរម៉ុល។ លទ្ធផលនៃការវិភាគបង្ហាញថា មិនមានវត្តមានសំណល់អង់ទីប៊ីយ៉ូទិកក្នុងក្រុមតេត្រាស៊ីគ្លីន ស៊ុលហ្វាបេតាអាហ្គោនីស និងហ្វរម៉ុលនៅក្នុងផលិតផលទាំងនោះទេ
- បានសហការជាមួយអ្នកជំនាញជនជាតិរុស្សីធ្វើការពិសោធន៍ និងផលិតថ្នាំសម្លាប់មេរោគដោយប្រើបច្ចេកទេសអេឡិកត្រូលីត្រទឹក ដែលមានលទ្ធភាព និងប្រសិទ្ធភាពក្នុងការសម្លាប់មេរោគបានយ៉ាងល្អ។

**ខ. ការងារស្រាវជ្រាវផលិតកម្មសត្វ**

នៅឆ្នាំ២០២១នេះ ក្រសួងបានផលិត និងចែកចាយទឹកនីត្រូសែន ចំនួន ១ ៨០៥លីត្រ ទៅតាមបណ្តាខេត្តនានា និងទឹកមេជីវិតគោបង្កកចំនួន ១ ២១០ដើម ក្នុងនោះ ៨៧០ដើម បានបែងចែកជូនខេត្តកំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ពោធិ៍សាត់ ព្រៃវែង សៀមរាប ស្ទឹងត្រែង តាកែវ និងរាជបណ្ឌិតសភាកម្ពុជា។ ចំពោះការបង្កាត់សិប្បនិម្មិត ក្រសួងបានបង្កាត់សិប្បនិម្មិតគោពិសោធន៍បានចំនួន៦៤០ក្បាល និងកើតកូនបានចំនួន២១៨ក្បាល។ ក្រសួងបានដឹកនាំចុះបង្កាត់គោដោយសិប្បនិម្មិតនៅឃុំ កោះរកា កោះទន្ទឹម និងឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចំនួន ២១៤ក្បាល កើតកូនបានចំនួន ២១ក្បាល នៅសល់មេធើមមិនទាន់គ្រប់ខែកើតកូនចំនួន ៩៣ក្បាល។

**តារាងលទ្ធផលនៃការផលិត និងចែកទឹកមេជីវិតបង្កកគោ និងទឹកនីត្រូសែនពីឆ្នាំ២០១៨-២០២១**

| សកម្មភាព | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ |
|---|---|---|---|---|
| ផលិតទឹកមេជីវិតគោបង្កក (ដើម) | ១ ៥៥០ | ១ ៥១០ | ២ ៥០០ | ១ ២១០ |
| បែងចែកទឹកមេជីវិតគោបង្កក(ដើម) | ៣ ៤៨០ | ៦០០ | ៩៨០ | ៨៧០ |
| បង្កាត់គោដោយសិប្បនិម្មិត (ក្បាល) | ៨៣៨ | ៨៨០ | ២ ៣៥៧ | ៦៤០ |
| បែងចែកទឹកនីត្រូសែន (លីត្រ) | - | ៣៩០ | ១ ០២៥ | ១ ៨០៥ |

ចំពោះការងារវិភាគចំណីសត្វ ក្នុងឆ្នាំ២០២១នេះ ក្រសួងបានវិភាគគុណភាពចំណីសត្វដោយពិនិត្យទៅលើប៉ារ៉ាម៉ែតសំខាន់ៗមួយចំនួនដូចជា ប្រូតេអ៊ីន ខ្លាញ់ ផូស្វរ សារធាតុសរសៃ សំណើម ផេះ ជាតិម្សៅ និងវត្ថុធាតុដើមផ្សំចំណីសត្វក្នុងនោះចំណីមាន់ (សាច់ ពង និងកូន) ចំណីជ្រូក (សាច់ មេធើម មេបំបៅ បា និងកូន) ចំណីទា (ពង សាច់ និងកូន) មេចំណី ចំណីគោ ចំណីក្រួច ចំណីឆ្កែ ឆ្មា និងកាកស្វាយ ដើម្បីធានាថាចំណីសត្វដែលដាក់លក់នៅលើទីផ្សារពិតជាមានគុណភាពល្អ។

### ២.៥ ការពង្រឹងការផ្តល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ

#### ២.៥.១ ការពង្រឹងការគ្រប់គ្រងអង្គភាព

នៅក្នុងឆ្នាំ២០២១នេះ ក្រសួងបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងការតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចថ្នាក់ដឹកនាំជាមួយនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន វិទ្យាស្ថាន ការិយាល័យ មន្ទីរពិសោធន៍ និងស្ថានីយស្រាវជ្រាវផលិតកម្ម និងបសុព្យាបាល ស្របតាមតាមអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងប្រកាសលេខ៣៨១ ប្រក.កសក.ប ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វស្របតាមការតែងតាំងរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅទូទាំងប្រទេសមន្ត្រីបម្រើការងារសុខភាពសត្វ និងផលិតកម្មសត្វចំនួនសរុប៧៧០រូប ស្រីចំនួន១៧២រូប ក្នុងនោះមន្ត្រីបម្រើការងារនៅថ្នាក់កណ្តាលចំនួនសរុប២៩៤រូប ស្រីចំនួន ៨៨រូប និងមន្ត្រីបម្រើការងារនៅទូទាំង២៥រាជធានី ខេត្ត ចំនួនសរុប៤៧៦រូប ស្រីចំនួន៨៤រូប។

#### ២.៥.២ ការអភិវឌ្ឍធនធានមនុស្ស

ឆ្លើយតបទៅនឹងការកំណត់អាទិភាពនៃកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងបានយកចិត្តទុកដាក់លើការបង្កើនសមត្ថភាពមន្ត្រីជាបន្តបន្ទាប់ ទាំងសមត្ថភាពរៀបចំ និងអនុវត្តផែនការ ព្រមទាំងសមត្ថភាពបច្ចេកទេសសម្រាប់ផ្តល់សេវាសុខភាពសត្វ និងផលិតកម្មសត្វ ឱ្យកាន់តែប្រសើរថែមទៀតដោយបានគៀរគរជំនួយពីដៃគូអភិវឌ្ឍន៍ និងគាំទ្រនានាពីរាជរដ្ឋាភិបាលសម្រាប់បង្កើនសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធ ផ្តោតលើអាទិភាពនៃការសិក្សាពីតម្រូវការបណ្តុះបណ្តាលលើការងារគ្រប់គ្រង និងបច្ចេកទេសដោយសម្របសម្រួលចាត់មន្ត្រីបច្ចេក-ទេសចូលរួមប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា ដែលរៀបចំដោយរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍ដោយផ្ទាល់ និងតាមរយៈប្រព័ន្ធវីដេអូពីចម្ងាយចំនួន២៨លើក ក្នុងនោះអ្នកចូលរួមចំនួន៣០៥នាក់ (ស្ត្រី៦៣នាក់)។

#### ២.៥.៣ ការងាររៀបចំផែនការ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានចូលរួមរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រនានា ផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម កសាងផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ និងទិសដៅការងារសម្រាប់អនុវត្តបន្តដោយធ្វើបច្ចុប្បន្នភាពលើផែនការ និងកម្មវិធីសម្រាប់ទិសដៅសំខាន់ៗ រួមមាន (១) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ (២) ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ (៣) ផែនការសកម្មភាពឆ្នាំ២០២២ សម្រាប់ថវិកាកម្មវិធីរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និង (៤) កម្មវិធីវិនិយោគសាធារណៈ០៣ឆ្នាំរំកិល ២០២២-២០២៤។ លើសពីនេះទៀត ក្រសួងបានផ្តល់ធាតុចូលលើទស្សនទានសម្រាប់គម្រោងក្នុងការនាំចេញផលិតផលកសិកម្មហេដ្ឋារចនាសម្ព័ន្ធ និងការស្រាវជ្រាវទាក់ទងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ សេចក្តីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី២០២១-២០២៣ ឯកសារគោលដៅអភិវឌ្ឍន៍ដោយចិរភាពកម្ពុជា២០១៦-២០៣០ ក្របខ័ណ្ឌជំរុញវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មកម្ពុជា២០២១-២០២២ និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា២០១៩-២០២៣។

#### ២.៥.៤.ការពង្រឹងសេវាសុខភាពសត្វ និងផលិតកម្មសត្វ

សេវាសំខាន់ៗ ដែលអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បាននឹងកំពុងអនុវត្តរួមមានការត្រួតពិនិត្យចេញលិខិតអនុញ្ញាត និងចេញវិញ្ញាបនបត្រមានដូចជា នាំចូល នាំចេញ និងនាំឆ្លងកាត់សត្វនិងផលិតផលសត្វ បង្កើត

សត្តឃាតដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វនិងបង្កាត់ពូជសត្វ ផលិតលាយផ្សំ ឬវេចខ្ចប់ជាថ្មី ផ្គត់ផ្គង់ចែកចាយ ចុះបញ្ជី បញ្ជីឃ្លាំងសន្និធិនិងការវិភាគចំណីសត្វ វត្ថុធាតុដើម សារធាតុបន្ថែម បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល សារធាតុសកម្មសមាសធាតុគ្រប់ប្រភេទ និងការវិភាគគុណភាពសត្វ សាច់ និងផលិតផលសត្វ ព្រមទាំងបង្ក្រាបបទល្មើសចរាចរណ៍សត្វ និងផលិតផលសត្វ។

នៅក្នុងឆ្នាំ២០២១នេះ បានប្រមូលចំណូលចំនួនសរុប១២ ៧៨៩ ៣០៧ ៨២៥រៀល ក្នុងនោះចំណូលបានមកពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វមានចំនួន៨ ៧២៧ ០៩០ ៤៧៥រៀល និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី ខេត្ត ចំនួន៤ ០៦២ ២១៧ ៣៥០ រៀល។ បើប្រៀបធៀបនឹងឆ្នាំ២០១៧ មានកំណើនចំនួន៦៨,៤៥% និងធៀបនឹងឆ្នាំ២០២០ ថយចុះចំនួន(-២៨,៥៣%) ដែលក្នុងនោះថ្នាក់កណ្តាលថយចុះចំនួន (-៣៧%) និងរាជធានី ខេត្តកើនចំនួន០,៥១%។ ការថយចុះចំណូលបណ្តាល មកពីផលិតកម្មសត្វក្នុងស្រុកមានសន្ទុះកើនឡើងខ្ពស់ ជាពិសេសជាក់ស្តែងចាប់ខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២១ មិនមានករណីជ្រូកសាច់រស់ ជ្រូកមេ បាពូជ និងកូនជ្រូកពូជនាំចូលពីបរទេសឡើយ ប៉ុន្តែបើប្រៀបធៀបនឹងច្បាប់ថវិកាឆ្នាំ២០២១ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វរកចំណូលបានប្រមាណ១៧៩,៣ភាគរយ។ ម្យ៉ាងវិញទៀត ដោយកម្ពុជាទទួលរងនូវជំងឺផ្លូវដង្ហើមប្រភេទថ្មី (COVID-19) បានធ្វើឱ្យកម្មវិធីតាមបែបប្រពៃណីស្ទើរតែទាំងអស់ត្រូវបានផ្អាក (ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យ...) បណ្តាលឱ្យការបរិភោគសាច់សត្វថយចុះ។

**ក្រាហ្វិកទី២៩៖ ប្រៀបធៀបលទ្ធផលប្រមូលពីឆ្នាំ២០១៧-២០២១**




### ២.៥.៥.ការងារសហប្រតិបត្តិការ

ក្នុងការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ ក្រសួងបានសហការយ៉ាងជិតស្និទ្ធជាមួយដៃអភិវឌ្ឍន៍ អង្គការជាតិ និងអង្គការអន្តរជាតិ និងវិស័យឯកជន ដែលរួមមាន៖ OIE, FAO, ASEAN, CHINA, KOICA, ACIAR, IAEA, JICA, UNIDO, WB, ADB, DTRA, USAID សមាគមអ្នកចិញ្ចឹមសត្វកម្ពុជា និងក្រុមហ៊ុនដែលបាននិងកំពុងវិនិយោគក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។ ទន្ទឹមនឹងនេះ ក្រសួងក៏បាននិងកំពុងសហការជាមួយកម្មវិធី និងគម្រោងសំខាន់ៗមួយចំនួន រួមមាន៖ កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ (NBP) គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរបរិស្ថាន និងកម្មវិធីឡជីវឧស្ម័នពីរដ្ឋាភិបាលចិន គម្រោងពិពិធកម្មវិស័យកសិកម្មកម្ពុជា គម្រោងពង្រឹងសមត្ថភាពចំណីអាហារ និងចំណីសត្វថ្នាក់ជាតិ គម្រោងគាំទ្របច្ចេកទេសដើម្បីអភិវឌ្ឍនិងអនុវត្តប្រព័ន្ធអត្តសញ្ញាណកម្ម

និងចុះបញ្ជីសត្វ និងគម្រោង Understanding the Risk of Zoonotic Disease from Swine Production and Exchange Systems in Cambodia។

## ៣. លទ្ធផលនៃការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍវារីវប្បកម្ម

នៅក្នុងឆ្នាំ២០២១នេះ ទោះបីមានវិបត្តិកូវីដ-១៩ យ៉ាងណាក៏ដោយ ក៏រដ្ឋបាលជលផល បានបំពេញតួនាទីនិងភារកិច្ចយ៉ាងសកម្មក្នុងនាមជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសម្រេចបានលទ្ធផលគ្រប់ផ្នែកនៃវិស័យជលផល ក្នុងនោះមានការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ការអភិវឌ្ឍវារីវប្បកម្ម ការងារបច្ចេកវិទ្យាកែច្នៃនិងគុណភាព ការអភិរក្សជលផល ការពង្រឹងសហគមន៍នេសាទ ការងារកិច្ចការជលផល ការបង្ក្រាបបទល្មើសជលផល ការសិក្សាស្រាវជ្រាវ និងការផ្សព្វផ្សាយជាដើម។ល។ ជាមួយគ្នានេះ ក្រសួងបានបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីជលផលថ្មី និងបានបញ្ជូនទៅលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដើម្បីពិនិត្យ ពិភាក្សា និងកែសម្រួល។ ចំណែកលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ និងលិខិតបទដ្ឋានបច្ចេកទេសមួយចំនួនទៀត បានកំពុងពិនិត្យ និងរៀបចំធ្វើវិសោធនកម្មកែសម្រួល ដើម្បីធានាដល់ការគ្រប់គ្រងវិស័យជលផលប្រកបដោយប្រសិទ្ធភាព។ បច្ចុប្បន្ន ក្រសួងបាននិងកំពុងសហការជាមួយដៃគូអភិវឌ្ឍន៍នានាក្នុងការពង្រឹងសមត្ថភាពមន្ត្រី ក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍វិស័យជលផលប្រកបដោយនិរន្តរភាពដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

### ៣.១. ការអភិវឌ្ឍន៍វារីវប្បកម្ម

នៅឆ្នាំ២០២១ បានបញ្ចប់គោលនយោបាយ និងវិធានការផ្សេងៗទៀតក្នុងការជំរុញវារីវប្បកម្មកម្ពុជា។ សហការជាមួយសហភាពអឺរ៉ុប (EU) និងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) ក្នុងការអនុវត្តកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន (ផ្នែកវារីវប្បកម្ម) (CapFish-Aquaclture) ព្រមទាំងសហការជាមួយគម្រោងអភិវឌ្ឍន៍វារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្មប្រកបដោយនិរន្តរភាពនៅកម្ពុជា (CAST-USDA Support Project) គម្រោង GIZ មជ្ឈមណ្ឌលស្រាវជ្រាវជលផលទឹកសាប វិទ្យាស្ថានសាគរសាស្ត្រហ្វូជៀន សាកលវិទ្យាល័យ Shanghai Ocean University នៃសាធារណរដ្ឋប្រជាមានិត្យចិន និង JICA ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី វារីវប្បកម្មទឹកសាបសមុទ្រ និងដើម្បីជំរុញវារីវប្បកម្មកម្ពុជាឱ្យកាន់តែរីកចម្រើន និងខ្លាំងក្លា។ បានរៀបចំចងក្រង បោះពុម្ព និងផ្សព្វផ្សាយសៀវភៅស្តីពីគោលការណ៍ណែនាំសម្រាប់ស្រះជម្រកត្រី ការគ្រប់គ្រងប្រព័ន្ធជលផលតាមវាលស្រែ ការគ្រប់គ្រងជំងឺនិងសុខភាពត្រីទឹកសាប ការកែប្រែវារីវប្បកម្មកម្ពុជា តាមរយៈការនាំចូលពូជត្រីទីឡាព្យាដែលមានគុណភាព។ បានបោះពុម្ពផ្សាយអត្ថបទ ស្តីពីការចិញ្ចឹមត្រីឆ្តង់ក្នុងប្រទេសកម្ពុជា ចំនួន០១ច្បាប់ និងខ្សែច្រវាក់ផលិតកម្មចិញ្ចឹមត្រីឆ្តង់នៅកម្ពុជា ចំនួន០១ច្បាប់។

ក្នុងទស្សនាវដ្តី World Aquaculture និងបានបោះពុម្ពផ្សាយអត្ថបទ ស្តីពីការប្រើប្រាស់គ្រឿងផ្សំក្នុងស្រុកសម្រាប់ផលិតចំណីត្រីឆ្តង់ក្នុងទស្សនាវដ្តី Feed Technology - Asia Pacific Aquaculture ចំនួន០១ច្បាប់។ បានរៀបចំបណ្តុះបណ្តាល និងផ្សព្វផ្សាយវារីវប្បកម្ម ពីការចិញ្ចឹមត្រីក្នុងបែទឹកសាប ស្រះជម្រកត្រីសហគមន៍ ការអនុវត្ត វារីវប្បកម្មល្អ ពង្រឹងបណ្តាញផលិតកូនត្រីពូជ វារីវប្បកម្មសមុទ្រ និងការចិញ្ចឹមត្រីក្នុងស្រែ ព្រមទាំងបានចុះជ្រើសរើសកសិករផលិតពូជសម្រាប់គម្រោងវារីវប្បកម្មបន្ទាន់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាជំងឺ COVID-១៩ បានចំនួន១០វគ្គ។ បានរៀបចំបណ្តុះបណ្តាលអំពីការអនុវត្តវារីវប្បកម្មល្អដល់កសិដ្ឋាន និងបានចេញវិញ្ញាបនបត្របញ្ជាក់អំពីការអនុវត្តវារីវប្បកម្មល្អជូនដល់កសិករចំនួន០៤ច្បាប់។ ចំពោះទិន្នផលវារីវប្បកម្ម ការចិញ្ចឹមត្រី បង្គា អនុវត្តបានចំនួន៣៤៨. ៣៥០តោន ស្មើ៧២,៤២% នៃផែនការ៤៨១.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាថយចុះ៥២.០៥០តោន។ ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន៣២៤.១០៦.០០០ក្បាល ស្មើ១២០,០៤% នៃផែនការ២៧០.០០០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើង៨៩.១០៦.០០០ក្បាល។ ការចិញ្ចឹមក្រពើអនុវត្តបានចំនួន២៩២.១០០ក្បាល ស្មើ៨៨,៥២%

នៃផែនការ៣៣០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាថយចុះ២១.០០០ក្បាល។ បានបង្កើតបណ្តុំវារីវប្បករចំនួន៣២៦កន្លែង មានសមាជិកចំនួន១១ ០០០នាក់។ បានផ្តល់វិញ្ញាបនបត្របញ្ជាក់ការអនុវត្តវារីវប្បកម្មល្អដល់ម្ចាស់កសិដ្ឋានចំនួន៥កន្លែង។ បានបង្កើតស្រះជម្រកត្រីសហគមន៍ចំនួន៩១៥កន្លែង ក្នុងនោះខេត្តកំពង់ស្ពឺមានចំនួនច្រើនជាងគេរហូតដល់១៧៣កន្លែង។

### ៣.២. ការងារបច្ចេកវិទ្យាកែច្នៃ និងគុណភាព

ការងារបច្ចេកវិទ្យាកែច្នៃ និងគុណភាព ដើរតួយ៉ាងសំខាន់សម្រាប់អនុវិស័យជលផល ក្នុងការចូលរួមចំណែកផ្គត់ផ្គង់ សន្តិសុខស្បៀង អាហារូបត្ថម្ភ លើកកម្ពស់ជីវភាពរស់នៅប្រជាជន និងចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ ក្នុងឆ្នាំ២០២១ សម្រេចបានលទ្ធផលការងាររួមមាន៖ បានសហការជាមួយអង្គការ UNIDO រៀបចំនូវក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរវាងស្ថាប័នសិក្សាស្រាវជ្រាវ និងវិស័យឯកជនលើការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកែច្នៃដោយបង្កើតនូវវេទិកាបច្ចេកវិទ្យាអាហារ និងសិក្សាលើក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពអាហារសម្រាប់ផល ផលិតផលជលផល និងវាយតម្លៃនូវចំនុចចន្លោះប្រហោង។ បានសហការជាមួយអង្គការ INFOFISH សិក្សាស្រាវជ្រាវវាយតម្លៃបន្ទាន់លើផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើសកម្មភាពកែច្នៃ និងពាណិជ្ជ-កម្មសម្រាប់ផល ផលិតផលជលផល និងឱកាសនវានុវត្តន៍ឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។ បានចុះធ្វើអធិការកិច្ចលើទីតាំងខ្សែច្រវាក់តម្លៃជលផលចំនួន១៣៤កន្លែង នៅក្នុងខេត្តគោលដៅចំនួន១៧ ដោយបានប្រមូលសំណាកសរុបចំនួន៥២៦សំណាក។ បានអនុវត្តកម្មវិធីជាតិតាមដានសំណល់បសុឱសថ និងសារធាតុគីមីនៅក្នុងផលិតផលវារីវប្បកម្ម ដោយបានប្រមូលសំណាកចំនួន១៧៣សំណាកពីកសិដ្ឋានចិញ្ចឹមត្រីប្រា ត្រីពោ ត្រីឆ្ពោ ត្រីរ៉ស់ និងត្រីទីឡាព្យា នៅក្នុងខេត្តគោលដៅចំនួន១០ ដើម្បីធ្វើការវិភាគរកប៉ារ៉ាម៉ែត្រ A1, A3, A6, B1, B2a, B3a, B3c, B3d, B3e។ បានសហការជាមួយអង្គការ UNIDO រៀបចំបង្កើតក្របខ័ណ្ឌគោលនយោបាយ និងយន្តការគតិយុត្តនិងពិនិត្យមើលលើគ្រប់គ្រងបសុឱសថក្នុងផល ផលិតផលជលផល ដើម្បីធានាថា ផលវារីវប្បកម្មរបស់កម្ពុជាអនុលោមតាមស្តង់ដារនៃកាកសំណល់ MRLs។ បានចេញវិញ្ញាបនបត្រសុខភាពបានចំនួន៦៧វិញ្ញាបនបត្រដល់ក្រុមហ៊ុនចំនួន៥ ដើម្បីនាំចេញផល ផលិតផលជលផលសរុបចំនួន២ ៩៩៣តោន ទៅកាន់ទីផ្សារក្នុងប្រទេសកូរ៉េ ថៃ និងប្រទេសវៀតណាម។

### ៣.៣. ការអភិរក្សធនធានជលផល

មកដល់ឆ្នាំ២០២១នេះ កន្លែងអភិរក្សជលផលសរុបទាំងអស់មានចំនួន៦៨២កន្លែង (កន្លែងអភិរក្សជលផលក្នុងដែនសហគមន៍នេសាទចំនួន៥៥០កន្លែង និងកន្លែងអភិរក្សជលផលដែលបង្កើតដោយខណ្ឌរដ្ឋបាលជលផលចំនួន១៣២កន្លែង)។ បានបញ្ចប់ការរៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តកំពង់ធំ សៀមរាប និងខេត្តបាត់ដំបង និងបន្តរៀបចំផែនការសម្រាប់ខេត្តបន្ទាយមានជ័យ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។ បានបោះបង្គោលបេតុងព្រំប្រទល់កន្លែងអភិរក្សជលផលចំនួន១៨៥បង្គោល ក្នុងខេត្តកំពង់ធំ សៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តតាកែវ។ បានបោះបង្គោលឈើចំនួន២ ៧៥០បង្គោល ក្នុងខេត្តសៀមរាប និងខេត្តកំពង់ធំ។ បានសាងសង់ស្នាក់ការល្បាតចំនួន៤ខ្នង សម្រាប់ការពារកន្លែងអភិរក្សជលផលក្នុងខេត្តសៀមរាប និងខេត្តស្ទឹងត្រែង។ បានទម្លាក់ប្រអប់បេតុងចំនួន២៥០ប្រអប់នៅខេត្តតំបន់ឆ្នេរ។ បានដាំព្រៃលិចទឹកទំហំ១៥០ហិកតា ក្នុងខេត្តសៀមរាប បាត់ដំបង និងខេត្តកំពង់ឆ្នាំង។ បានការពារអភិរក្សផ្កាថ្មនិងស្មៅសមុទ្រចំនួន៧ ០០០ហិកតា នៅតាមតំបន់ឆ្នេរ និងកោះ។

### ៣.៤.ការអភិវឌ្ឍន៍សហគមន៍នេសាទ

សហគមន៍នេសាទនៅទូទាំងប្រទេសមានចំនួនសរុប៥១៦ ក្នុងនោះសហគមន៍នេសាទទឹកសាបចំនួន៤៧៥ និងសហគមន៍នេសាទសមុទ្រចំនួន៤១ ដែលមានសមាជិកសរុបចំនួន៣៣២ ១៦៨នាក់ (ស្ត្រីប្រមាណ៣៥%) ត្រូវជា ១៤៧ ៥១៨គ្រួសារ។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍នេសាទចំនួន៤៣៥ ត្រូវបានចុះបញ្ជីទទួល

ស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហគមន៍នេសាទចំនួន១២ បានរៀបចំឯកសាររួចរាល់សម្រាប់ការស្នើសុំចុះបញ្ជីបន្ថែម។

ចំពោះសហគមន៍នេសាទដែលផុតអាណត្តិចំនួន២៥ ត្រូវបានបោះឆ្នោតជ្រើសរើសគណៈកម្មការថ្មីឡើងវិញ។ ទន្ទឹមនេះ ក៏បានរៀបចំផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទថ្មីចំនួន៦សហគមន៍ និងធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងចំនួន៧០សហគមន៍នេសាទ។ បានដាក់ស្លាកសញ្ញាកន្លែងអភិរក្សសហគមន៍ចំនួន១១០ស្លាក ទម្លាក់ប្រអប់បេតុងចំនួន១៥០ប្រអប់ បោះបង្គោលការពារស្មៅសមុទ្រក្នុងកន្លែងសហគមន៍ចំនួន២០០ដើម បណ្តុះបណ្តាលសមត្ថភាពសហគមន៍នេសាទចំនួន៧៦វគ្គ មានអ្នកចូលរួមចំនួន១ ៥២២នាក់ និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសហគមន៍នេសាទចំនួន១០៩វគ្គ មានអ្នកចូលរួមចំនួន៥ ៦១៤នាក់។

បច្ចុប្បន្នសហគមន៍នេសាទ ទទួលបាននូវការគាំទ្រពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ជាច្រើន ក្នុងការផ្សព្វផ្សាយ កសាងសមត្ថភាពរៀបចំធ្វើផែនការការពារធនធានជលផលនៅក្នុងកន្លែងនេសាទសហគមន៍ និងការបង្កើននូវមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ។ នៅក្នុងឆ្នាំ២០២១នេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ថវិកាដល់សហគមន៍នេសាទចំនួន១៥០សហគមន៍ ក្នុងមួយសហគមន៍ទទួលបាន៤លានរៀល សម្រាប់អនុវត្តផែនការសកម្មភាពរបស់ខ្លួន។

### ៣.៥. ការងារកិច្ចការជលផល

បានប្រជុំពិភាក្សាលើការកំណត់ថ្លៃឰ្យរដាយត្រី ដាយត្រីលេញ និងដាយបង្កងចំនួន៥១ គន្លងដាយ សម្រាប់ដាក់ឱ្យដេញថ្លៃធ្វើអាជីវកម្មក្នុងរដូវនេសាទឆ្នាំ២០២១-២០២២ និងឆ្នាំ២០២២-២០២៣ ដែលក្នុងនេះមាននៅរាជធានីភ្នំពេញចំនួន១២ គន្លងដាយ ខេត្តកណ្តាលចំនួន២១ គន្លងដាយ និងខេត្តព្រៃវែងចំនួន១៨គន្លងដាយ និងរៀបចំសេចក្តីសម្រេចបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីការប្រគល់សិទ្ធិជូនអតិថិជនដែលដេញថ្លៃបាន និងបានជួលតាមការព្រមព្រៀង។ ជាមួយគ្នា បានរៀបចំសេចក្តីជូនដំណឹងដល់ប្រជាពលរដ្ឋឱ្យមកធ្វើប្រហុកផ្អកទុកសម្រាប់បរិភោគឆ្នាំ២០២១ និងជូនដំណឹងដល់អាជីវករនេសាទតាមតំបន់ឆ្នេរ ឱ្យមកបំពេញបែបបទស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មនេសាទ លិខិតអនុញ្ញាតឱ្យប្រើប្រាស់ទូក កាណូតនេសាទ និងបង់ថ្លៃឈ្នួលដែននេសាទ សម្រាប់ធ្វើអាជីវកម្មនេសាទឆ្នាំ២០២១។

បានបោះបង្គោលព្រំប្រទល់ការពារព្រៃលិចទឹកសរុបបានចំនួន១ ០២១ដើម ក្នុងនោះបង្គោលចំនួន១៣៦ដើមបានបោះនៅខេត្តជុំវិញបឹងទន្លេសាបក្នុងឆ្នាំ២០២១។ បានចុះផ្សព្វផ្សាយប្រកាស ស្តីពីប្រភេទឧបករណ៍នេសាទគ្រួសារ មានអ្នកចូលរួមចំនួន៥៤០នាក់ នៅខេត្តពោធិ៍សាត់ បាត់ដំបង និងខេត្តកំពង់ធំ។ បានប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធនឹងការនេសាទ ក្នុងដែននេសាទសមុទ្រ មានអ្នកចូលរួមចំនួន១៤០នាក់ នៅខេត្តកំពត កោះកុង និងខេត្តព្រះសីហនុ។ បានចុះផ្សាព្វផ្សាយពីសារៈសំខាន់ព្រៃលិចទឹក និងរៀបចំផែនទីព្រៃលិចទឹកដល់អាជ្ញាធរមូលដ្ឋាន មានអ្នកចូលរួមចំនួន៥១០នាក់ នៅខេត្តពោធិ៍សាត់ បាត់ដំបង និងខេត្តកំពង់ធំ។

### ៣.៦. ការងារបង្ក្រាបបទល្មើសជលផល

ក្នុងឆ្នាំ២០២១នេះ សំណុំរឿងនៃបទល្មើសជលផលសរុបចំនួន៣.២៣១ ករណី (សមុទ្រ២៨០ករណី) ប្រៀបធៀបឆ្នាំមុនកើនឡើងចំនួន៦៩ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន២.៩៦២ករណី ពិន័យអន្តរការណ៍ចំនួន៧៩ករណី បញ្ជូនទៅតុលាការចំនួន១៩០ករណី ប្រាក់ពិន័យនិងលក់វត្ថុតាងចំនួន២៣៣.៤៣២.៥០០រៀល។ ចំពោះវត្ថុតាងរឹបអូស និងបំផ្លាញចោលរួមមាន របាំងស្បៃមុង និងសាច់អួនប្រវែង១.៦៥១.៣០៨ម៉ែត្រ បង្គោល/ចម្រឹងចំនួន៦០៨.៥០២ដើម លូស្បៃមុងនិងសាច់អួនចំនួន៣០.៥៣៨មាត់ ឧបករណ៍ឆក់ត្រីចំនួន១៥២គ្រឿង សម្រាស់ទំហំ៣៧.៧០៨ម៉ែត្រក្រឡា មងបណ្តែតប្រវែង១២០.៩៩០ម៉ែត្រក្រឡា លបកែច្នៃ ឬលបកន្ទុយកណ្តុរចំនួន៥.៤៣៩គ្រឿង បានលែងត្រីចម្រុះចូលក្នុងធម្មជាតិចំនួន៣៣.៨៧៣គីឡូក្រាម និងបានផ្សព្វផ្សាយច្បាប់ស្តីពីជលផលនិងលិខិត

បទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន១៨០វគ្គ មានអ្នកចូលរួមចំនួន១.៨៥០រូប (ស្ត្រីចំនួន១២០រូប)។ ទន្ទឹមនឹងនេះ បន្ទាប់ពីទទួលបានបទបញ្ជាពី សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ឱ្យទប់ស្កាត់ បង្ក្រាបការទន្ទ្រានឈូសឆាយ និងដកហូតដីព្រៃលិចទឹកជុំវិញបឹងទន្លេសាប គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ ប្រជាពលរដ្ឋ១៤ ៦៥៦គ្រួសារ បានស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋទំហំ៦១ ១៦១.៧៦ហិកតា និងបានដាំកូនឈើព្រៃលិចទឹកចំនួន៤២ ២៣៥ដើម ឬស្សីចំនួន៨ ៤៤៩ដើម កូនត្នោតចំនួន៣៣៩ដើម និងគ្រាប់ត្នោតចំនួន២៤២ ២០៥គ្រាប់។

### ៣.៧. ការងារសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផល

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាប និងសមុទ្របានដំណើរការល្អ ដោយសហ-ប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានាដូចជា អង្គការ EU, UNIDO, FAO, WB, MRC, CI, WWF, IUCN World Fish Center ជាដើម។ល។ ដោយមានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប និងសមុទ្រជាអង្គភាពអនុវត្តផ្ទាល់។ ដោយអនុវត្តលើសកម្មភាពមួយចំនួនដូចជា៖ ការសិក្សាស្រាវជ្រាវជីវសាស្ត្រវារីសត្វ សិក្សាតាមដានផលនេសាទតាមដាយត្រី សិក្សាតាមដានប្រភេទកូនត្រី សិក្សា DNA ប្រភេទត្រីទឹកសាប សិក្សាស្រាវជ្រាវការធ្វើចរាចរណ៍និងការពងកូនរបស់ត្រីនៅតំបន់មេគង្គលើ សិក្សាតាមដានសុខភាពអេកូឡូស៊ីនៅកម្ពុជា និងបានបោះពុម្ពលទ្ធផលនៃការសិក្សាសស្រាវជ្រាវ។

### ៣.៨. ការងារសហប្រតិបត្តិការអន្តរជាតិ

ក្នុងឆ្នាំ២០២១ រដ្ឋបាលជលផលបានសហការជាមួយអង្គការ EU, FAO, UNIDO, MRC, NACA, SEAFDEC, INFOFISH, World Bank, IWC, CI និង WorldFish Centre។ល។ ដើម្បីជំរុញការអភិវឌ្ឍធនធានមនុស្ស ការងារអភិវឌ្ឍន៍វារីវប្បកម្ម ការអភិរក្សធនធានជលផល ការងារកិច្ចការជលផល ការគ្រប់គ្រងសហគមន៍នេសាទ ការបង្ក្រាបបទល្មើសជលផល និងការរៀបចំបង្កើតសហគមន៍ស្រះជម្រកត្រី ដែលបានអនុវត្តនៅគ្រប់ខណ្ឌរដ្ឋបាលជលផលទូទាំងប្រទេស។

### ៣.៩. ស្ថិតិកែច្នៃផលនេសាទ

ក្នុងឆ្នាំ២០២១នេះ៖ ការកែច្នៃផលនេសាទទឹកសាបអនុវត្តបានចំនួន៥១ ៦៥០តោន ស្មើ៦៤,៥៦%នៃផែនការ៨០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាថយចុះចំនួន១០ ៣៥០តោន។ ការកែច្នៃផលនេសាទសមុទ្រអនុវត្តបានចំនួន១១ ៦៦០តោន ស្មើ៩៧,១៧% នៃផែនការ១២ ០០០តោន ប្រៀបធៀបនឹងរយៈពេលដូចគ្នាកើនឡើងចំនួន២៦០តោន និងការផលិតទឹកត្រីអនុវត្តបានចំនួន៥១ ៣០០ ០០០លីត្រ ស្មើ៩៣.២៧%នៃផែនការ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាថយចុះចំនួន១ ៧០០ ០០០លីត្រ។

### ៣.១០. ស្ថិតិនាំចេញផល ផលិតផលជលផល

ក្នុងឆ្នាំ២០២១នេះ៖ ការនាំចេញផល ផលិតផលអនុវត្តបានចំនួន៣ ៤៦៩តោន ស្មើ៣៤.៦៩%នៃផែនការ១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាកើនឡើងចំនួន១ ២៩០តោន។

### ៣.១១. ការងារហិរញ្ញវត្ថុ

ប្រាក់ចំណូលពីអនុវិស័យជលផលមានចំនួន៦២១.៩១២.៩៧៦រៀល ក្នុងនោះមានប្រាក់ចំណូលពីការលក់ឯកសារដេញថ្លៃចំនួន៣.៩០៩.៣៤៨រៀល ចេញលិខិតអនុញ្ញាតចំនួន៨៦.២៨០.០០០រៀល ការជួលទ្រព្យសម្បត្តិរដ្ឋចំនួន១៥៧.២១៦.២៨៤រៀល វិញ្ញាបនបត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផលសម្រាប់នាំចេញចំនួន២៧.៦០០.០០០រៀល និងប្រាក់រង្វាន់បង្ក្រាបបទល្មើសនេសាទចំនួន២៣៣.៤៣២.៥០០រៀល ផលហិរញ្ញវត្ថុ

ផ្សេងៗទៀត (សំណែសចំណាយ) ចំនួន១៩.៧៥៣.៦២៥រៀល និងផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ (ដោះដូរ) ចំនួន៩៣.៧២១.២១៩រៀល។

### ៣.១២. ស្ថិតិផលនេសាទ និងវារីវប្បកម្ម

ស្ថិតិផលនេសាទ និងវារីវប្បកម្មអនុវត្តបានចំនួន៨៥៦.៤០០តោន ថយចុះជាងឆ្នាំមុនចំនួន៧៩.៩០០តោន (ស្មើនឹង៨,៥៣%) ក្នុងនោះមាន៖

- ផលនេសាទទឹកសាបចំនួន៣៨៣.០៥០តោន ថយចុះ៣០.១៥០តោន (ស្មើនឹង៧,៣០%)
- ផលនេសាទសមុទ្រចំនួន១២៥.០០០តោន កើនឡើង២.៣០០តោន (ស្មើនឹង១,៨៧%)
- ផលវារីវប្បកម្មចំនួន៣៤៨.៣៥០តោន ថយចុះ៥២.០៥០តោន (ស្មើនឹង១៣,០០%)

**ក្រាហ្វិកទី៣០៖ ផលនេសាទទឹកសាប ផលនេសាទសមុទ្រ និងវារីវប្បកម្មរយៈពេល៥ឆ្នាំ២០១៧-២០២១**




## ៤. លទ្ធផលនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ

### ៤.១ ការគ្រប់គ្រង និងអភិវឌ្ឍន៍ព្រៃឈើ

**ក- សហគមន៍ព្រៃឈើ**

គិតត្រឹមឆ្នាំ២០២១ សហគមន៍ព្រៃឈើបានបង្កើតសរុបចំនួន ៦៤៣សហគមន៍ គ្របដណ្តប់លើផ្ទៃដី ៥២២ ២៧៣ ហ.ត ក្នុងនោះ ក្រសួងបានចេញប្រកាសចំនួន ៥៣៦សហគមន៍ លើផ្ទៃដី ៤៤៩ ៤៧៥ហ.ត និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ៤៤៩សហគមន៍ លើផ្ទៃដី ៣៧២ ១៧៥ហ.ត និងបានអនុម័តផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន១០៦សហគមន៍ គ្របដណ្តប់លើផ្ទៃដីទំហំ ៧២ ៦២០ហ.ត។ ការបង្កើតសហគមន៍ព្រៃឈើមានសន្ទុះកើនឡើងគួរឲ្យកត់សម្គាល់។

## ក្រាហ្វិកទី៣១៖ ចំនួនសហគមន៍ព្រៃឈើពីឆ្នាំ២០១៧-២០២១




ជាមួយគ្នានេះ បានអនុវត្តប្រព័ន្ធកសិ-រុក្ខកម្មនៃគម្រោងលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋនៅសហគមន៍ព្រៃឈើចំនួន ៨ លើផ្ទៃដីសរុបទំហំ ១៦ហ.ត។

**ខ- គម្របព្រៃឈើ**

- ការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០១៨ មានផ្ទៃដីគម្របព្រៃឈើ ៨ ៥២៩ ៣៧២ហិកតា ស្មើនឹង ៤៦,៩៧%
- បានពង្រឹងសមត្ថភាពមន្ត្រីលើជំនាញបច្ចេកទេស Google earth engine , GPS, Avenza តាមបណ្តាផ្នែករដ្ឋបាលព្រៃឈើនីមួយៗ។

**គ- ការគ្រប់គ្រងផល អនុផលព្រៃឈើ**

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៩ ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ៨នាក់ ដែលមានឈើហ៊ុបមូលចំនួន ២១ ៦៥០ ម៉ែត្រត្រីគុណ ឈើអារចម្រុះខ្នាតចំនួន ១ ៥២៧ ម៉ែត្រត្រីគុណ កូនឈើ បង្គោលរបងនិងបង្គោលគ្រាក់ចំនួន ២៥២ ៣៧០ ដើម អុសចម្រុះចំនួន ១៩០ ៥៩៧ស្ទែរ ជ័រទឹកចំនួន ៦២៨ តោន ឬស្សីចំនួន ៩៦តោន ធ្យូងចំនួន ៣ ០០០ គីឡូក្រាម ព្រមទាំងគ្រឿងសង្ហារឹមនិងអនុផលផ្សេងៗមួយចំនួនទៀត។
- បានធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើចំនួន ០៥ក្រុមហ៊ុន ក្នុងខេត្តក្រចេះ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តព្រះវិហារ។

**ឃ- ការដាំឈើ**

- បានថែទាំចម្ការឈើចាស់ ចម្ការពូជឈើ និងឡូត៍បង្ហាញកសិ-រុក្ខកម្មចំនួន ៨២២ហិកតា និងដាំឈើជាចម្ការថ្មីលើផ្ទៃដីសរុបទំហំ ៧ ៥៩៩ហិកតា ក្នុងនោះដោយរដ្ឋលើផ្ទៃដីទំហំ ១៤០ហិកតា និងវិស័យឯកជន ក្រុមហ៊ុន ដៃគូសហការ និងលក្ខណៈគ្រួសារលើផ្ទៃដីទំហំ ៧ ៤៥៩ហិកតា និងបានបណ្តុះកូនឈើចំនួន ៥៧២ ៥២៩ដើម និងចែកចាយកូនឈើដល់ប្រជាពលរដ្ឋដាំអាស្រ័យផលចំនួន ៣៧៣ ៧៤៦ដើម។ ទន្ទឹមនឹងនេះបានអនុវត្តសកម្មភាពជីកប្រឡាយការពារចម្ការឈើគ្រញូងប្រវែង ៨ ០០០ម៉ែត្រ នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំ។
- បានបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសែនមនោរម្យ ខេត្តមណ្ឌលគិរី លើផ្ទៃដីទំហំ ១០០,២៦ហិកតា និងបានចុះពិនិត្យ និងចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីព្រៃឯកជនលើផ្ទៃដីទំហំ ៣៥៨,៩២ហិកតា នៅទីតាំងចំនួន០៤ កន្លែង ក្នុងខេត្តកោះកុង កំពង់ស្ពឺ និងខេត្តកំពតចំនួន ០២កន្លែង។
- បានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុលើផ្ទៃដីទំហំ ២៦៦ ០៤៣ម៉ែត្រការ៉េ នៃស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសំបួរមាស ខេត្តបាត់ដំបង។ ព្រមទាំងបានបញ្ចប់នីតិវិធី និងត្រៀមទទួលប័ណ្ណសម្គាល់កាន់

កាប់អចនវត្ថុលើផ្ទៃដីទំហំ ៤ ១៤២,៧៨ហិកតា នៃចម្ការឈើដាំស្ថិតនៅស្ថានីយដាំឈើម្សៅក្រដាសហ៊ុន សែន មានក ខេត្តកំពង់ឆ្នាំង

- ចុះសិក្សាទីតាំងបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើលើផ្ទៃដីសរុបទំហំ ២២ ៣០៨,០៦ហិកតា ស្ថិតនៅខេត្តប៉ៃលិន កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ និងបានចុះសិក្សាទីតាំងសម្រាប់បង្កើតសួនរុក្ខជាតិ ខេត្តកំពត លើផ្ទៃដីទំហំ៤៩,១៩ហិកតា
- ការងារពិសោធន៍តាមរយៈការកាត់ត្រួយពីដើមមេបណ្តុះនៅស្ថានីយដាំឈើម្សៅក្រដាស ហ៊ុន សែន មាន ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ដោយប្រើប្រាស់អ័រម៉ូនម្សៅ (Hormex: Rooting powder No.8) ជាលទ្ធផល អាកាស្យា (Acacia hybrid) អត្រារស់ ៩០% និងប្រេងខ្យល់ (ពូជ K7) អត្រារស់ ៨៤% និងអ័រម៉ូនទឹក (Vitamin B 1) មានអត្រារស់ប្រហាក់ប្រហែលគ្នា ដែលផលិតបានចំនួន ៦០ ០០០ដើម
- បានបោះពុម្ពផ្សព្វផ្សាយ "គោលការណ៍ណែនាំសម្រាប់បង្កើត និងចុះបញ្ជីព្រៃឯកជននៅកម្ពុជា" ដើម្បីផ្សព្វផ្សាយ និងប្រើប្រាស់ជាសាធារណៈនូវឯកសារគោលការណ៍ណែនាំនេះដល់មន្ត្រីរដ្ឋបាលព្រៃឈើប្រើប្រាស់ អនុវត្ត ការងារចុះបញ្ជីព្រៃឯកជន។

**ង- ការងារឧស្សាហកម្ម ពាណិជ្ជកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ**

- ឧស្សាហកម្មឈើមាន ១ ០៦៥កន្លែង ក្នុងនោះមានរោងចក្រ រោងម៉ាស៊ីនអារកែច្នៃឈើ និងរោងសន្និធិប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ៦២កន្លែង និងរោងសិប្បកម្មកែច្នៃ និងរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទតូច ចំនួន ១ ០០៣កន្លែង
- ផ្តល់ទិដ្ឋាការ អាជ្ញាប័ណ្ណនាំចេញ ជូនក្រុមហ៊ុនចំនួន១០ នូវឈើកែច្នៃសរុបចំនួន **១ ៥៦៩ម៣** (ឈើធម្មជាតិចំនួន ៤៤៨ម៣ ឈើដាំចំនួន ៥០០ម៣ និងពីឈើនាំចូល ៦២១ម៣) ចំណាំងកម្ទេចឈើប្រេងខ្យល់ ចំនួន ១១ ០០០តោន សង្ហារឹមឫស្សីកែច្នៃចំនួន ៧៩តោន និងជ័រទឹកចំនួន ៣៦៤តោន និងផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើកែច្នៃពីបរទេសជូនក្រុមហ៊ុនចំនួន០៤ មានបរិមាណសរុបចំនួន ៣ ២១៦ម៣
- គម្រោងកិច្ចសហប្រតិបត្តិការអន្តរជាតិចំនួន ០៧គម្រោង ក្រោមកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលព្រៃឈើជាមួយប្រទេសផ្តល់ជំនួយ និងដៃគូអភិវឌ្ឍន៍ ដូចជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋកូរ៉េ ជប៉ុន APFNet AFoCO និង Darwin Initiative ព្រមទាំងគម្រោងផ្សេងៗទៀត ក្រោមកិច្ចសហប្រតិបត្តិការអន្តរក្រសួង/ស្ថាប័នជាតិ ជាមួយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ដូចជា JICA FAO-EU RCOFTC Wildlife Alliance និងកិច្ចសហប្រតិបត្តិការអាស៊ាន។

## ៤.២ ពង្រឹងការគ្រប់គ្រងសិក្សា ស្រាវជ្រាវ និងអនិវឌ្ឍព្រៃឈើ និងសត្វព្រៃ

**ក-ការពង្រឹងការស្រាវជ្រាវ ថែរក្សា និងអភិវឌ្ឍសត្វព្រៃ និងជីវចម្រុះ**

- បានចុះដាក់ម៉ាស៊ីនថតស្វ័យប្រវត្តចំនួន ៤៦គ្រឿង ដើម្បីថតតាមដានវត្តមាននិងកត្តាគំរាមកំហែងសត្វព្រៃនៅតាមតំបន់ព្រៃឈើក្នុងខេត្តកំពង់ស្ពឺ កោះកុង ក្រចេះ និងខេត្តកំពង់ធំ ដោយថតបានប្រភេទសត្វព្រៃសំខាន់ៗ រួមមាន ដំរី ខ្លាឃ្មុំ ខ្ទីង ទន្សោង ប្រើស ស្វាត្រោស ជ្រូកពោន ឆ្កែចចក សំពោច ក្ងោក និងបានធ្វើការដោះអន្ទាក់សត្វព្រៃបានជាច្រើន។ បានសហការជាមួយភាគីពាក់ព័ន្ធចុះពិនិត្យតំបន់មានជម្លោះរវាងសត្វដំរីព្រៃ និងប្រជាពលរដ្ឋមូលដ្ឋាន និងបានចុះប្រមូលលាមកសត្វដំរីសរុបចំនួន ១៤៩សំណាក សម្រាប់វិភាគ DNA នៅក្នុងខេត្តស្ទឹងត្រែងនិងខេត្តព្រះវិហារ។
- បានចុះសិក្សាកំណត់តំបន់សក្តានុពលទេចរណ៍នៅតំបន់ភ្នំដំរីរមៀល ខេត្តតាកែវ និងចុះសិក្សាស្រាវជ្រាវ ប្រមូលសំណាកកេសរកូល (អ័រគីដេព្រៃ)បានចំនួន២៣៧សំណាក នៅខេត្តមណ្ឌលគីរី និងព្រះវិហា

- បានសហការជាមួយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងវិទ្យាស្ថានជាតិអាឡែកហ្ស៊ី និងជំងឺឆ្លងរបស់សហរដ្ឋអាមេរិក ដើម្បីចុះប្រមូលសំណាកសត្វជ្រើងនិងប្រចៀវ រកក្រុមប្រភេទមេរោគ Beta-Corona virus ដែលជាមេរោគអាចបង្កឱ្យមានជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ នៅខេត្តមណ្ឌលគិរី ស្ទឹងត្រែង និងកំពត ចំនួន២០៨៣សំណាក
- ក្រុមហ៊ុនចំនួន០៧ ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្ដាមយកកូននាំចេញចំនួន ០៨ទីតាំង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ធំ មានសត្វស្វាក្ដាមសរុបចំនួន១០៥ ៦៣៦ក្បាល ក្នុងនោះកូនកើតក្នុងខែរយៈពេល០១ឆ្នាំមានចំនួន ៦៩ ១៣៨ ក្បាល ដឹកជញ្ជូនក្នុងស្រុកចំនួន ៤ ៤២០ក្បាល និងដឹកជញ្ជូនឆ្លងទៅកាន់ មាត់ច្រកអន្តរជាតិសម្រាប់នាំចេញទៅក្រៅប្រទេសចំនួន ២៤ ២០៥ក្បាល
- ក្រុមហ៊ុន ស៊ី តែល និង ក្រុមហ៊ុន សាន់ ជយ ហ្វើ ប្រូសេស៊ីង នាំចូលស្បែកជាប់រោមសត្វ ១ ៧៥១ ៤០០ គីឡូក្រាម និង ៧ ៦២០ ០០០ PCS (បន្ទះ)។ ដោយឡែកក្រុមហ៊ុន ហ្វីស៊ីង ហ្វាយ បាននាំចេញស្បែកជាប់រោមសត្វចំនួន ១០១០,៣០គីឡូក្រោម
- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១២១ច្បាប់ ក្នុងនោះ ១០៨ច្បាប់សម្រាប់ការថែរក្សាសត្វត្រចៀកកាំ និង ១៣ច្បាប់ ទៀតសម្រាប់ការថែរក្សាសត្វព្រៃ ដែលមានទីតាំងស្ថិតនៅ រាជធានីភ្នំពេញ ខេត្តកោះកុង កែប ពោធិ៍សាត់ បាត់ដំបង កំពត តាកែវ កណ្ដាល សៀមរាប បន្ទាយមានជ័យ ក្រចេះ កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ និងខេត្តមណ្ឌលគិរី។

**ខ-ការសិក្សាស្រាវជ្រាវ និងស្ដារព្រៃឈើឡើងវិញ**

- បានបន្តសហការជាមួយដៃគូនានាសំដៅទទួលបានការគាំទ្រក្នុងការងារកសាងមូលដ្ឋានសិក្សាស្រាវជ្រាវរួមមានអគារបច្ចេកទេសជាលិកាវប្បកម្មរុក្ខជាតិ ចម្ការព្រៃឈើ Eco Forest Farm សួនអភិរក្សសេនេទិចពូជឈើសំខាន់ៗចំនួន ៥០ហិកតា និងស្ថានីយស្រាវជ្រាវព្រៃឈើ ១កន្លែង នៅខេត្តកោះកុង
- បានរៀបចំវគ្គបណ្ដុះបណ្ដាលចំនួន ៩វគ្គ លើប្រធានបទបច្ចេកទេសដាំស្ដារ និងគ្រប់គ្រងព្រៃសហគមន៍ ការប្រែប្រួលអាកាសធាតុក្នុងវិស័យព្រៃឈើ ការលើកកម្ពស់ជីវភាពសហគមន៍ដែលពឹងអាស្រ័យលើព្រៃឈើ ការវិភាគទិន្នន័យព្រៃឈើដោយប្រើកម្មវិធី R Program។ល។ សិក្ខាកាមរួមមានមន្ត្រីរដ្ឋបាលព្រៃឈើ សហគមន៍មូលដ្ឋាន និស្សិត និងអ្នកពាក់ព័ន្ធដទៃទៀតសរុបចំនួន ៤៩៥នាក់។
- បានបន្តថែរក្សា និងស្រង់ទិន្នន័យពីឡូត៍ស្រាវជ្រាវក្នុងចំការបង្កាត់ពូជឈើគ្រញូង ធ្នង់ និងត្រាចចំនួន ២៤ហិកតា នៅខេត្តសៀមរាប និងបានដាក់តាំងឡូត៍ស្រាវជ្រាវថ្មីចំនួន១៨ឡូត៍ពាក់ព័ន្ធ និងវិធីសាស្ត្រដាំស្ដារព្រៃឈើតាមបច្ចេកទេសថ្មីៗ
- បានបន្តការងារស្រាវជ្រាវពិសោធន៍ជាលិកាវប្បកម្មនៅក្នុងបន្ទប់ពិសោធន៍ ពិសេស ការងារស្រាវជ្រាវបណ្ដុះពូជផ្កាអរគីដេ និងពូជឈើសំខាន់ៗមួយចំនួនទៀត
- បានធ្វើការវិភាគទិន្នន័យដែលបានកត់ត្រាពីបណ្ដាឡូត៍ពិសោធន៍ស្រាវជ្រាវនានា ហើយលទ្ធផលទាំងនេះត្រូវបានចងក្រងជាឯកសារបទពិសោធន៍ និងបច្ចេកទេស និងបានបោះពុម្ពបានចំនួន ១៧០០ក្បាល។ បានរៀបចំបោះពុម្ពជាឯកសារផ្សព្វផ្សាយរួមមាន ខិត្តបណ្ណចំនួន ៣ ៦០០សន្លឹក ផ្ទាំងបង្ហាញចំនួន ៣ ២១៥សន្លឹក និងឈុតវីដេអូខ្លីៗចំនួន ៦ឈុត ដែលផ្ដោតជាសំខាន់លើបច្ចេកទេសដាំស្ដារនិងគ្រប់គ្រងព្រៃឈើ ការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានដែលរស់នៅក្នុងនិងក្បែរតំបន់ព្រៃឈើ សម្រាប់ពង្រីកចំណេះដឹងដល់សាធារណជន។

## ៨.៣ ការគ្រប់គ្រងខុទ្យានសួនសត្វ និងសង្គ្រោះថែរក្សាសត្វព្រៃ

- បាននិងកំពុងចិញ្ចឹមថែរក្សាសត្វព្រៃចំនួន១ ៦៧៥ ក្បាល (បក្សីចំនួន ៥៨ ប្រភេទ ថនិកសត្វចំនួន៤៤ ប្រភេទ និងល្មូនចំនួន ១៦ ប្រភេទ) និងបានសង្គ្រោះសត្វព្រៃថ្មីចំនួន ៩៤៤ក្បាល ព្យាបាលបានចំនួន ៣៩០ក្បាល និងលែងចូលព្រៃធម្មជាតិវិញបាន៧៥៥ក្បាល។
- គាំទ្រគម្រោងក្រុមល្បាតសហគមន៍ចំនួន២៦នាក់ ល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន០៥កន្លែង អារ៉ែងឆាយរាប តំបន់ស្ពារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)។
- បានជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង១៨គីឡូម៉ែត្រ សាងសង់ និងជួសជុលទ្រុងសត្វ អគារផ្សេងៗបាន ទំហំ៣ ៨៣៣ម៉ែត្រក្រឡា និងកាប់ឆ្ការអនាម័យព្រៃទំហំ៤៥ហិកតា នៅក្នុងតំបន់សួនសត្វ។

## ៨.៤ ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

បានចងក្រងសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃឈើចំនួន ៨១១ករណី ក្នុងនោះ សំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ៣២០ករណី និងសុំណុំរឿងបទល្មើសព្រៃឈើដែលត្រូវ បញ្ជូនទៅតុលាការចំនួន ៤៩១ករណី។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើ០១រូប ជាជនបង្គោលរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់សម្របសម្រួល និងសហការជាមួយអង្គភាពប្រឆាំងអំពើពុករលួយ (លិខិត លេខ៣៧៨ សសរ.កសក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨) និងថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើចំនួន០២រូបទៀត ជា សមាជិកក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្របសម្រួលការអនុវត្តច្បាប់សម្រាប់ស៊ើបអង្កេតបទល្មើសសម្អាត ប្រាក់(លិខិតលេខ០០៧/១៩ សរ.អបព ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៩)។

**ក្រាហ្វិកទី៣២៖ ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសព្រៃឈើពីឆ្នាំ២០១៧-២០២១**




**ក្រាហ្វិក៣៣៖ បទល្មើសព្រៃឈើពិន័យអន្តរការណ៍ និងទៅតុលាការពីឆ្នាំ២០១៧-២០២១**



## ៥. លទ្ធផលនៃការពង្រឹងសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

### ៥. ១. ការលើកកម្ពស់ការកសាង និងការអនុវត្តគោលនយោបាយ និងការវិនិយោគឯកជនកសិកម្ម

ក្នុងគោលដៅជំរុញការធ្វើទំនើបកម្មលើវិស័យកសិកម្ម ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍផ្នែកសេដ្ឋកិច្ចរបស់ប្រទេស ជាពិសេសការប្រែប្រួលពីប្រទេសដែលមានការអភិវឌ្ឍតិចតួច មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងឈានទៅរកប្រទេសដែលមានចំណូលកម្រិតខ្ពស់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននាយកដ្ឋានផែនការនិងស្ថិតិ ជាសេនាធិការ បានខិតខំសម្របសម្រួល និងរៀបចំកសាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព រៀបចំនិងការគ្រប់គ្រងប្រព័ន្ធទិន្នន័យស្ថិតិកសិកម្ម ប្រព័ន្ធព័ត៌មានទីផ្សារកសិកម្ម ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងការតាមដាននិងវាយតម្លៃលើរាល់សកម្មភាពគាំទ្រក្នុងវិស័យកសិកម្ម។

ដោយមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួង ក៏ដូចជាការចូលរួមសហការពីគ្រប់អង្គភាពជំនាញថ្នាក់កណ្ដាល និងរាជធានីខេត្ត ក្នុងឆ្នាំ២០២១នេះ នាយកដ្ឋានផែនការនិងស្ថិតិ សម្រេចបានលទ្ធផលការងារ ដូចខាងក្រោម៖

#### ក. លទ្ធផលនៃការរៀបចំផែនការ គោលនយោបាយ និងការគ្រប់គ្រងការងារវិនិយោគ

#### ក.១ លទ្ធផលនៃកាពង្រឹងការងារផែនការ និងការវិនិយោគឯកជន

ក្នុងឆ្នាំ២០២១នេះ បានបញ្ចប់នូវការរៀបចំឯកសារសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០ បន្ទាប់ពីបានពិគ្រោះយោបល់ តាមរយៈកិច្ចប្រជុំកម្រិតបច្ចេកទេសជាបន្តបន្ទាប់ជាមួយអង្គភាពជំនាញក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន និងបានបញ្ជូនឯកសារសេចក្តីព្រាងគោលនយោបាយនេះ ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ សម្រេចឱ្យបានទាន់ពេលវេលា។ បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤ ផែនការសកម្មភាពនៃថវិកាកម្មវិធីឆ្នាំ២០២២ និងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០២២-២០២៤។ បានចូលរួមប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល តាមរយៈប្រព័ន្ធបញ្ជូនសំលេងនិងរូបភាពពីចម្ងាយពាក់ព័ន្ធនឹងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការងារថវិកាកម្មវិធី ការងារគម្រោងអភិវឌ្ឍន៍លើវិស័យកសិកម្ម ក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ការងារវិនិយោគ។ បានរៀបចំធាតុចូលដែលជាសមិទ្ធផលការងារក្នុងវិស័យកសិកម្ម សម្រាប់បញ្ចូលទៅក្នុងគោលនយោបាយជាតិមួយចំនួន រួមមាន (១)គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ (២)គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥ -២០២៥ (៣) គោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ (៤)គោលដៅអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០១៦-២០៣០ និងការផ្តល់ទិន្នន័យក្នុងវិស័យកសិកម្មសម្រាប់ជាធាតុចូលក្នុងការរៀបចំផែនការមេអភិវឌ្ឍន៍ទេសចរណ៍របស់ខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តមណ្ឌលគិរី (៥)ផ្តល់ធាតុចូលរបាយការណ៍ពាក់កណ្តាលអណត្តិផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ (៦)គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ២០២២-២០៣៥។

#### ក.២. ការពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃ

ក្នុងការពង្រឹងប្រព័ន្ធតាមដាននិងវាយតម្លៃ ក្រសួងបានរៀបចំបូកសរុបរបាយការណ៍សមិទ្ធកម្មស្តីពីលទ្ធផលនៃការអនុវត្តថវិកាកម្មវិធីប្រចាំ២០២១ និងបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងបានបូកសរុបរបាយ-ការណ៍សមិទ្ធផលនៃការអនុវត្តគម្រោង និងកម្មវិធីប្រចាំឆ្នាំ ក្នុងនោះមានគ្រោងចំនួន៨ ដែលបាននិងកំពុងចូលរួមអភិវឌ្ឍវិស័យកសិកម្ម តាមរយៈការគាំទ្រសម្ភារៈ និងបច្ចេកទេសដល់អ្នកទទួលផលផ្ទាល់ចំនួន១ ២២២ ៧៤៥នាក់ អ្នកទទួលផលដោយប្រយោលប្រមាណ៣,៣៣លាននាក់ និងមានថវិកាគាំទ្រប្រមាណ ៣,៣៣លានដុល្លារអាមេរិក។ បានបើវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំពិភាក្សាលើប្រព័ន្ធផែនការ តាមដាន និងវាយតម្លៃប្រព័ន្ធកុំព្យូទ័រ (Online)។ បានសហការជាមួយអង្គភាពថវិកាថ្នាក់កណ្តាល និងរាជធានីខេត្ត ចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តថវិកា

ឆ្នាំ២០២១។ បានសម្របសម្រួល និងសហការបើកវគ្គបណ្តុះបណ្តាលស្តីពី ប្រព័ន្ធតាមដាន និង វាយតម្លៃគម្រោងនិងថវិកាកម្មវិធី ដល់អង្គភាពពាក់ព័ន្ធ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។ បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំពិគ្រោះយោបល់ពាក់ព័ន្ធនឹងផែនការអភិវឌ្ឍន៍តាមបណ្តាវិស័យ ប្រព័ន្ធតាមដាន និងវាយតម្លៃ ពង្រឹងសមត្ថភាពស្ថាប័ន សុវត្ថិភាពស្បៀង ពិពិធកម្មកសិកម្ម ការរៀបចំថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា កម្មវិធីវិនិយោគសាធារណៈ និងការងារសម្របសម្រួលនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ បានចូលរួមរៀបចំកិច្ចប្រជុំស្តីពី ការបន្សុីគ្នារវាងប្រព័ន្ធវាស់វែងលទ្ធផលក្នុងការអនុវត្តថវិកាកម្មវិធីនៃកម្មវិធី ASPIRE ជាមួយប្រព័ន្ធផែនការ តាមដាន និងវាយតម្លៃថវិកាកម្មវិធីរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ។

### ក.៣ ការពង្រឹងប្រព័ន្ធព័ត៌មានស្ថិតិកសិកម្ម

បានសហការជាមួយក្រសួងផែនការក្នុងការចុះធ្វើការអង្កេត ជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២១។ បានចុះពិនិត្យតាមដានសភាពការណ៍និងការងារបង្កបង្កើនផលស្រូវឆ្នាំ២០២១ និងចូលរួមចុះត្រួតពិនិត្យ គ្រោះធម្មជាតិ (ជំនន់ទឹកភ្លៀង) នៅតាមបណ្តាខេត្តដែលទទួលរងគ្រោះ។ បានរៀបចំរបាយការណ៍ការងារបង្កបង្កើនផលប្រចាំសប្តាហ៍ ជូនប្រមុខរាជរដ្ឋាភិបាល និងបានផ្សព្វផ្សាយដល់គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ថ្នាក់ដឹកនាំក្រសួង និងអង្គភាពជំនាញក្រោមឱវាទ។ បានរៀបចំរបាយការណ៍សមិទ្ធផលក្នុងវិស័យកសិកម្ម និងទិសដៅអនុវត្តបន្ត ព្រមទាំងបានផ្សព្វផ្សាយដល់គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ថ្នាក់ដឹកនាំក្រសួង និងអង្គភាពជំនាញក្រោមឱវាទ។

### ក.៤ ការពង្រឹងប្រព័ន្ធព័ត៌មានទីផ្សារកសិផល

បានចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិផលទូទាំង២៥ រាជធានី ខេត្ត ដើម្បីផលិតព្រឹត្តិប័ត្រព័ត៌មានទីផ្សារ ប្រចាំខែ ប្រចាំឆ្នាំ និងបានផ្សព្វផ្សាយ ជូនគ្រប់ថ្នាក់ដឹកនាំក្រសួង និងអង្គភាពជំនាញក្រោមឱវាទ។ បានចុះប្រមូលទិន្នន័យ និងវាយតម្លៃទៅលើស្ថានភាព មានសក្តានុពលនៃផលិតភាពកសិកម្ម ព្រមទាំងកំណត់សហគមន៍គោលដៅ ដើម្បីជំរុញការអនុវត្ត និងឆ្លើយតបជាបន្ទាន់ក្នុងដំណាក់កាលនៃជំងឺកូវីដ-១៩។ បានចុះពិនិត្យតាមដានការស្រង់ព័ត៌មានតម្លៃទីផ្សារកសិកម្មនៅតាមបណ្តាខេត្តគោលដៅ និងរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងវិធីសាស្ត្រប្រមូលព័ត៌មានថ្លៃកសិផល និងអង្កេតតម្លៃកសិផល ដែលមានសិក្ខាកាមសរុប៤៨នាក់ ស្ត្រី២០នាក់។ សិក្សាស្រាវជ្រាវព័ត៌មានតម្លៃអង្ករលើទីផ្សារអន្តរជាតិ តាមរយៈគេហទំព័រ www.haroonabdulsaltar.com; www.thairiceexporters.or.th/price.htm; www.vietnamrice. netfirms.com; www.oryza.com និងត្រួតពិនិត្យ តាមដានការប្រើប្រាស់សារជាអក្សរ និងបញ្ចូលតម្លៃជាប្រចាំក្នុងគេហទំព័រ www.amis.org.kh។

### ក.៥ ការជំរុញការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

បានរៀបចំវគ្គបណ្តុះបណ្តាលជាមួយកសិករស្តីពី ការផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់បរិស្ថានក្នុងផលិតកម្មកសិកម្ម ក្នុងខេត្តកែប។ បានចុះតាមដានការគ្រប់គ្រង និងត្រួតពិនិត្យបរិស្ថានក្នុងវិស័យកសិកម្មនៅតាមបណ្តាខេត្ត។ បានចូលរួមជាសមាជិកក្រុមការងារអនុវត្តគម្រោងបែងចែកដីសម្បទានសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី III (មន្ត្រីគាំពារបរិស្ថាន) ដោយបានចូលរួមសហការជាមួយផ្នែកពាក់ព័ន្ធក្នុងការតាមដាន ត្រួតពិនិត្យ និងផ្តល់អនុសាសន៍សម្រាប់ផ្នែកសុវត្ថិភាពបរិស្ថាននិងសង្គមក្នុងគម្រោងទាំងមូល។ បានចុះពិនិត្យផលប៉ះពាល់បរិស្ថាន និងសង្គម នៃសហគមន៍កសិកម្មនៅខេត្តស្ទឹងត្រែង និងក្រចេះ នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចូលរួមពិនិត្យ ការរៀបចំសេចក្តីព្រាងផែនទីយុទ្ធសាស្ត្របញ្ជ្រាបការប្រែប្រួលអាកាសធាតុ ក្នុងសកម្មភាពផ្សព្វផ្សាយកសិកម្មនៃកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)។ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី The

system of Environmental-Economic Accounting រៀបចំដោយកម្មវិធីអភិវឌ្ឍន៍នៃសហប្រជាជាតិ (UNDP) តាមរយៈប្រព័ន្ធអនឡាញ។

### ៥.២. ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបន្តរៀបចំផែនការថវិកា ដោយឈរលើគោលបំណងគោលនយោបាយរួមគឺ "ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានព្រៃឈើនិងជលផលប្រកបដោយចីរភាព"។ ក្នុងការឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្រ្តសម្រាប់អនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង ៤៦អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២១អង្គភាពថវិកានិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តចំនួន២៥ ។

ក្នុងឆ្នាំ២០២១ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលកញ្ចប់ថវិការបស់រាជរដ្ឋាភិបាលសម្រាប់ចំណាយក្នុងការអនុវត្តចង្កោមសកម្មភាពនៃអនុកម្មវិធី កម្មវិធីសរុបចំនួន២៧៧ ៥៥៣លានរៀល។ ថវិកានេះបានបែងចែកសម្រាប់រដ្ឋបាលកណ្តាលចំនួន១៨០ ២៧៧លានរៀល និងមន្ទីររាជធានី ខេត្តចំនួន៩៧ ២៧៦លានរៀល។ ទន្ទឹមនឹងនេះ ក្រសួងមានកាតព្វកិច្ចត្រូវប្រមូលចំណូលមិនមែនសារពើពន្ធសរុបទឹកប្រាក់ចំនួន៣៥ ៤២៥,៤លានរៀល។

ចំពោះលទ្ធផលនៃការអនុវត្តថវិកាក្នុងឆ្នាំ២០២១ សម្រេចបានដូចខាងក្រោម ៖

**១-ផ្នែកចំណូល**: ក្រសួងសម្រេចអនុវត្តប្រមូលចំណូលសរុបបានចំនួន៧៤ ៨៨៧,៦លានរៀល ស្មើនឹង២១១,៤%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ក្នុងនោះចំណូលពីផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២៥ ០៨១,៦លានរៀល ស្មើនឹង១១៩,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ចំណូលពីផលទុននៃការលក់ ជួលទ្រព្យសម្បត្តិ និងសេវាមានចំនួន១៩ ២១៥,៩លានរៀល ស្មើនឹង១៧២,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្មមានចំនួន២ ៧១១,១លានរៀល ស្មើនឹង៨២,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ផលហិរញ្ញវត្ថុមានចំនួន ២៥៣,១លានរៀល និងផលពិសេសផ្សេងៗ (ចំណូលពីការលក់ដីសម្បទានសេដ្ឋកិច្ចនិងការដោះដូរទីតាំង) មានចំនួន ២៧ ៦២៥,៩ លានរៀល។

**២-ផ្នែកចំណាយ**: ក្រសួងបានអនុវត្តចំណាយថវិកាសរុបចំនួន ២៣២ ៦៦២លានរៀល ស្មើនឹង៨៣,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឬស្មើនឹង៨៨,៦%ធៀបនឹងឥណទានកែតម្រូវ ក្នុងនោះ (១)ចំណាយលើការទិញមានចំនួន៣០ ០៤៥,៨លានរៀល ស្មើនឹង៨៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឬស្មើនឹង៩០,៩%ធៀបនឹងឥណទានកែតម្រូវ (២) ចំណាយលើសេវាកម្មមានចំនួន ៣៧ ៥៨០,៨លានរៀល ស្មើនឹង៥៥,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឬស្មើនឹង៦៨,៥% ធៀបនឹងឥណទានកែតម្រូវ (៣)ចំណាយលើអត្ថប្រយោជន៍សង្គមមានចំនួន ៧ ៣១០,២លានរៀល ស្មើនឹង៩៩,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ (៤)ចំណាយលើពន្ធអាករមានចំនួន ២០៩,៤លានរៀល ស្មើនឹង៥៦,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ (៥)ចំណាយលើបន្ទុកបុគ្គលិកមានចំនួន ១២៥ ៩០០,៤លានរៀល ស្មើនឹង៩៨,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឬស្មើនឹង៩៨%ធៀបនឹងឥណទានកែតម្រូវ (៦)ចំណាយលើការឧបត្ថម្ភធនមានចំនួន ២២ ៤៦៣,៩លានរៀល ស្មើនឹង ៩៩,៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ និងចំណាយមូលធនមានចំនួន ៩ ១៥១,៥លានរៀល ស្មើនឹង៥៧,២%ធៀបនឹងច្បាប់ហិរញ្ញវត្ថុ ។

**៣. គម្រោងថវិកាវិនិយោគរបស់រាជរដ្ឋាភិបាល**៖ ថវិកាវិនិយោគជំពូក២១ (**គម្រោងវិនិយោគផ្ទាល់**) មានចំនួនសរុប **១៦ ០០០ ០០០ ០០០**រៀល និងបានធ្វើការទូទាត់លើការចំណាយមានចំនួន **៦ ០១១ ៥០០ ០០០**រៀល។ ក្នុងនោះមាន (១)ថវិកាវិនិយោគជំពូក២១ ចំនួន **៤ ០១១ ៥០០ ០០០**រៀល សម្រាប់ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព សាងសង់ស្ថានីយបូមទឹកបណ្តែត អាងស្តុកទឹកបឋម និងភ្ជាប់បណ្តាញអគ្គិសនីនៅតាមបណ្តា

សហគមន៍កសិកម្មចំនួន០៦ នៅក្នុងខេត្តកំពង់ចាម ព្រៃវែង និងខេត្តកំពង់ឆ្នាំង (២)ថវិកាវិនិយោគជំពូក២១ ចំនួន **២ ០០០ ០០០ ០០០**រៀល សម្រាប់ទូទាត់ថវិកាបុរេប្រទានលើកញ្ចប់ថវិកាពិសេស ដែលបានចំណាយក្នុងការអនុវត្តផែនការសកម្មភាពវារីវប្បកម្មក្នុងការឆ្លើយតបនឹងបរិបទនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ជូនរដ្ឋបាលជលផល។

**៤. ប្រាក់កក់និងថ្លៃសម្បទានដីសេដ្ឋកិច្ច៖** បានទទួលបង្កាន់ដៃបង់ប្រាក់កក់ពីក្រុមហ៊ុនចំនួន០១ ( ឌីស្មីង ហាវេស (ខេមបូឌា) ខូអិលធីឌី)។ បានចុះបំពេញបេសកកម្មប្រមូលថ្លៃសម្បទានដីសេដ្ឋកិច្ចសរុបមានចំនួន ៥៩ ក្រុមហ៊ុនក្នុងខេត្តចំនួន១០។ បានទទួលចំណូលពីការបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន៣៩ ដែលមានទឹកប្រាក់សរុបចំនួន១ ៤៥៨ ៤៥៩,៤២ដុល្លារអាមេរិក ស្មើនឹង៥ ៩៣៨ ០៨១ ៧៨២រៀល និងបានធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងបញ្ជីតាមដានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។

**៥. ការងារបិទ និងបើកបញ្ជីប្រគល់ ទទួលទ្រព្យសម្បត្តិ៖** បានចុះបិទ និងបើកបញ្ជីប្រគល់ទទួលថវិកា និងទ្រព្យសម្បត្តិសម្រាប់ការផ្ទេរតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំដែលត្រូវផ្លាស់ប្តូរ និងចូលនិវត្តន៍នៅអង្គភាពចំនួន០៥អង្គភាព រួមមាន វិទ្យាស្ថានជាតិស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា រដ្ឋបាលជលផល វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា អគ្គនាយកដ្ឋានកៅស៊ូ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង។

**៦. ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- បានចូលរួមប្រជុំពិភាក្សាដើម្បីប្រមូលធាតុចូលលើការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌរួម ផែនទីបង្ហាញផ្លូវ និង ផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះតាមរយៈប្រព័ន្ធអនឡាញ
- បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសទី១ និងត្រីមាសទី២ ឆ្នាំ២០២១ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ + ២ របស់ក្រសួង-ស្ថាប័ន តាមប្រព័ន្ធអនឡាញ
- បានចូលរួមកិច្ចប្រជុំស្វែងយល់ពីការបំពេញកម្រងសំណួរអង្កេតស្តីពីការទំនាក់ទំនង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានរៀបចំរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ២០២០ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេស ដើម្បីពិភាក្សាអំពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធរបស់ក្រសួងតាមរយៈប្រព័ន្ធវីឌីអូអនឡាញ
- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើកចុងក្រោយលើរបាយការណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិឆ្នាំ២០២០ តាមរយៈប្រព័ន្ធវីឌីអូអនឡាញ
- បានរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ២០២១ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានចូលរួមកិច្ចប្រជុំជាមួយក្រុមបេសកកម្មរបស់ធនាគារអភិវឌ្ឍអាស៊ី(ADB) ដើម្បីរៀបចំស្នើសុំហិរញ្ញប្បទានកម្ចីឥណទានកម្មវិធី (Program Loan) សម្រាប់កម្មវិធីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអនុកម្មវិធីទី២ (SPFM.SP2) តាមរយៈប្រព័ន្ធវីឌីអូអនឡាញ
- បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេស ពិភាក្សាអំពីបញ្ហាប្រឈម និងដំណោះស្រាយពាក់ព័ន្ធនឹងការផ្ទេរចំណូលមិនមែនសារពើពន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈប្រព័ន្ធវីឌីអូអនឡាញ។

**៧ . ការងារផ្គត់ផ្គង់ និងគ្រប់គ្រងសន្និធិ៖** បានទទួលគ្រប់គ្រងសន្និធិឃ្លាំងដោយបានធ្វើការបញ្ចូលបញ្ចេញនិងបែងចែកបើកផ្តល់ជូនបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវប្រេងឥន្ធនៈ សម្ភារការិយាល័យ បោះពុម្ព សង្ហារិម និងសម្ភារបរិក្ខារសម្រាប់ការប្រើប្រាស់ប្រចាំឆ្នាំ២០២១ ដែលមានទឹកប្រាក់សរុប

ចំនួន២ ៩៣៧ ៤៨១ ០០០រៀល ក្នុងនោះ ប្រេងឥន្ធនៈមានទឹកប្រាក់ចំនួន១ ០៥៤ ៨០៣ ៧០០រៀល សម្ភារការិយាល័យមានទឹកប្រាក់ចំនួន៣៩៤ ៤៣៣ ៣០០រៀល សម្ភារបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យាមានទឹកប្រាក់ចំនួន ២២២ ៦៥០ ០០០រៀល សម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យាមានទឹកប្រាក់ចំនួន ១៩១ ៣៥០ ០០០រៀល សង្ហារិមមានទឹកប្រាក់ចំនួន ៩២ ០០០ ០០០រៀល និងបោះពុម្ពមានទឹកប្រាក់ចំនួន ៩៨២ ២៤៤ ០០០រៀល។

**៨. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុជាសេនាធិការ បានរៀបចំវគ្គបណ្តុះបណ្តាលលើការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធព័ត៌មានវិទ្យា SARMIS ហើយបច្ចុប្បន្ន អង្គភាពចំនួន៤៦ ទាំងថ្នាក់កណ្តាលនិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត បាន និងកំពុងបញ្ចូលទិន្នន័យ និងគ្រោងដាក់ឱ្យប្រើប្រាស់ពេញលេញនៅឆ្នាំ២០២២នេះ
- បានត្រួតពិនិត្យលើការងារផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិរដ្ឋកើនឡើង និងថយចុះក្នុងឆ្នាំ២០២០ ដែលមានអង្គភាពចំនួន២១ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ចំនួន១៧ បានរៀបចំរួចរាល់។ ដោយឡែកចំពោះអង្គភាពនិងមន្ទីរមួយចំនួនដែលនៅមានភាពយឺតយ៉ាវ ក្រសួងបាននិងកំពុងជំរុញបន្ថែម។
- ក្រសួងបានពិនិត្យនិងធ្វើការជម្រះចេញពីបញ្ជីសារពើភណ្ឌនូវទ្រព្យសម្បត្តិចាស់ ដោយក្នុងនោះអង្គភាពថ្នាក់កណ្តាលចំនួន០២ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន០៧ បានស្នើសុំជម្រះនិងបានអនុវត្តនីតិវិធីចប់សព្វគ្រប់រួចរាល់។

**៩. ការងារលទ្ធកម្មសាធារណៈ** : បានចូលរួមនិងជួយរៀបចំឯកសារអង្គភាពលទ្ធកម្មសម្រាប់ដំណើរការអនុវត្តកិច្ចលទ្ធកម្មសម្រាប់បម្រើឱ្យការផ្គត់ផ្គង់ទំនិញ ការសាងសង់ ជួសជុលសំណង់ សេវាកម្ម និងសេវាទីប្រឹក្សាជូនអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ២៦គម្រោង មានទឹកប្រាក់សរុបចំនួន ២៣ ៩១៥ ០០៦ ០០០រៀល ក្នុងនោះ កិច្ចលទ្ធកម្មទំនិញមានចំនួន ១៦គម្រោង មានទឹកប្រាក់សរុបចំនួន ១០ ៣៦៧ ៦៩៩ ៧០០ រៀល កិច្ចលទ្ធកម្មសំណង់មានចំនួន ០៦គម្រោង មានទឹកប្រាក់សរុបចំនួន ១០ ៦៣៧ ៥៥០ ០០០ រៀល កិច្ចលទ្ធកម្មសេវាកម្មមានចំនួន ០៤គម្រោង មានទឹកប្រាក់សរុបចំនួន ២ ៩០៩ ៧៥៦ ៣០០ រៀល។ បានចូលរួមចុះពិនិត្យនិងវាយតម្លៃបញ្ចប់សុពលភាពថែទាំគុណភាពសំណង់សម្រាប់ការអនុវត្តកិច្ចសន្យាលទ្ធកម្មសំណង់ចំនួន០៦គម្រោង ដូចខាងក្រោម ៖

- ហេដ្ឋារចនាសម្ព័ន្ធ (ផ្ទះសំណាញ់បំពាក់ស៊ីទែនទឹកចំណុះ១៥០០លីត្រ និងប្រព័ន្ធលាយជីស្វ័យប្រវត្តិ) សម្រាប់គាំទ្រគម្រោងកម្មវិធីជំរុញផលិតកម្មស្បៀងក្នុងឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកសិកម្មដែលសាងសង់ដោយក្រុមហ៊ុនសំណង់បុរីកម្មករ
- ការងារជីកប្រឡាយការពារតំបន់ចម្ការឈើដាំនៅខេត្តកំពង់ធំ ដែលអនុវត្តដោយរដ្ឋបាលព្រៃឈើក្នុងឆ្នាំ ២០២០
- ការងារជួសជុលកែលម្អអគារប្រចាំឆ្នាំ២០២០ របស់អង្គភាពក្រោមឱវាទក្រសួងដែលអនុវត្តដោយក្រុមហ៊ុន ណៃ ស្រេង អ៊ីមផត អិចផត
- ការងារជួសជុលទ្រុងសត្វ ទំនប់ស្ទាក់ទឹកអនាម័យជើងព្រៃនៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ សាងសង់ចំណតរថយន្តរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ និងជួសជុលអគាររដ្ឋបាលរបស់រដ្ឋបាលព្រៃឈើប្រចាំឆ្នាំ២០២០ ដែលអនុវត្តដោយក្រុមហ៊ុន ណៃ ស្រេង អ៊ីមផត អិចផត
- ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅតាមស្ថានីយពិសោធន៍កសិកម្មប្រចាំឆ្នាំ២០២០ ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ និងខេត្តកណ្តាល របស់អគ្គនាយកដ្ឋានកសិកម្ម ដែលអនុវត្តដោយក្រុមហ៊ុនសំណង់បុរីកម្មករ

- ការងារជួសជុលអគារមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលសមុទ្រ និងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបរបស់រដ្ឋបាលជលផល ដែលអនុវត្តដោយក្រុមហ៊ុន ណៃ ស្រេង អ៊ីមផត អិចផត។

## ៥.៣. ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យកសិកម្ម

### ៥.៣.១. ការគ្រប់គ្រងធនធានមនុស្ស

ក្នុងឆ្នាំ២០២១នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានមន្ត្រីរាជការសរុបចំនួន៥ ៩៤០នាក់ ស្ត្រី ១ ៤៦៩នាក់ ស្មើនឹង២៤,៧៣% ក្នុងនោះអង្គភាពថ្នាក់កណ្តាលមានចំនួន២ ៩៨៦នាក់ ស្ត្រី៨៥៩នាក់ ស្មើនឹង ២៨,៧៦% ថ្នាក់រាជធានី ខេត្តមានចំនួន២ ៩៥៤នាក់ ស្ត្រី៦១០នាក់ ស្មើនឹង២០,៦៤%។ ទន្ទឹមនឹងនេះ ក្រសួងបានដាក់មន្ត្រីឱ្យចូលនិវត្តន៍ ចំនួន៣៩នាក់ ស្ត្រី១៧នាក់ (ចូលនិវត្តន៍ ចំនួន២៤នាក់ ស្ត្រី១២នាក់ ចូលនិវត្តន៍មុនអាយុ ចំនួន១៤នាក់ ស្ត្រី០៥នាក់ និងចូលបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន០១នាក់) ដាក់មន្ត្រីស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន២៦នាក់ ស្ត្រី០៨នាក់ ដាក់មន្ត្រីឱ្យចូលបម្រើការងារនៅអង្គភាពដើមវិញ ចំនួន២១នាក់ ស្ត្រី០៧នាក់ និងបានលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន២១នាក់ ស្ត្រី០៣នាក់ (បោះបង់ការងារ ចំនួន០១នាក់ លាឈប់ពីការងារ ចំនួន០៦នាក់ ស្ត្រី០២នាក់ និងមរណភាព ចំនួន១៤នាក់ ស្ត្រី០១នាក់)។ ក្រសួងបានទទួលមន្ត្រីក្របខ័ណ្ឌថ្មីចំនួន១៣៣នាក់ (ក្របខ័ណ្ឌ "ក"ចំនួន១២១នាក់ និង"ខ"ចំនួន១២នាក់) តាមរយៈការប្រឡងប្រជែងក្របខ័ណ្ឌថ្មី ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២១ និងបានតែងតាំង និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការបានចំនួន១៣៣នាក់ ស្ត្រីចំនួន៤៧នាក់ ព្រមទាំងទទួលបានគ្រឿងឥស្សរិយយស និងមេដាយ ជូនថ្នាក់ដឹកនាំនិងមន្ត្រីរាជការ ចំនួន៧១៣នាក់ ស្ត្រីចំនួន១៧៣នាក់ ក្នុងនោះមាន៖ ជាតូបការ ចំនួន០៣នាក់ ព្រះរាជាណាចក្រកម្ពុជា ចំនួន២២នាក់ (រួមមាន៖ ថ្នាក់មហាសេរីវឌ្ឍន៍ ចំនួន០៥នាក់ ថ្នាក់មហាសេនា ចំនួន០២នាក់ និងថ្នាក់អស្សប្ញទ្ធិ ចំនួន១៥នាក់) សុវត្ថារា ចំនួន២៧៧នាក់ (រួមមាន៖ ថ្នាក់មហាសេរីវឌ្ឍន៍ ចំនួន២៤នាក់ ថ្នាក់មហាសេនា ចំនួន៤៣នាក់ ថ្នាក់ធិបឌិន្ទ ចំនួន៧១នាក់ ថ្នាក់សេនា ចំនួន៥៦នាក់ និងថ្នាក់អស្សប្ញទ្ធិ ចំនួន៨៣នាក់) មេដាយមាសការងារ ចំនួន៧៣នាក់ មេដាយប្រាក់ការងារ ចំនួន៧០នាក់ និងមេដាយសំរឹទ្ធិ ចំនួន២៦៨នាក់។

ផ្អែកតាមក្រាហ្វិកនៃស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការក្នុងរយៈពេល០៥ឆ្នាំ (២០១៧-២០២១) ឃើញថា ចំនួនក្របខ័ណ្ឌបានថយចុះជាបន្តបន្ទាប់ ទន្ទឹមនឹងក្របខ័ណ្ឌថ្មីទទួលបានមិនមានតុល្យភាពនឹងក្របខ័ណ្ឌដែលបានបាត់បង់។ ករណីនេះ ជាបញ្ហាប្រឈមសម្រាប់ការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសកម្មវិធីជាតិកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើឱ្យសម្រេចជោគជ័យនូវផែនការយុទ្ធសាស្ត្ររបស់ក្រសួង។

**ក្រាហ្វិកទី៣៤៖ ស្ថានភាពមន្ត្រីរាជការក្របខ័ណ្ឌ ឆ្នាំ២០១៧-២០២១**



ដើម្បីឆ្លើយទៅនឹងកំណែទម្រង់ស៊ីជម្រៅនិងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ដែលជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើផ្នែកគ្រប់គ្រងធនធានមនុស្ស បានកំពុងរៀបចំនិងធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមព័ត៌មានវិទ្យា (HRMIS) ដែលបានជួយសម្រួលច្រើនដល់ការគ្រប់គ្រងស្ថិតិមន្ត្រីរាជការ និងការបោះពុម្ពប័ណ្ណសម្គាល់ខ្លួនជូនដល់មន្ត្រីរាជការគ្រប់អង្គភាព ដោយសម្រេចបានជាង ៨០% និងបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយធនធានមនុស្សសម្រាប់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឆ្នាំ២០២១នេះផងដែរ។

### ៥.៣.២. ការអភិវឌ្ឍធនធានមនុស្ស

នៅក្នុងនីតិកាលកន្លងមក ក៏ដូចជានៅក្នុងដំណាក់កាលទី២ នៃយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល បានកំណត់អាទិភាពចម្បងចំនួន៤ គឺ៖ ផ្លូវ ទឹក ភ្លើង និងមនុស្ស ។ ប៉ុន្តែនៅក្នុងបរិបទសេដ្ឋកិច្ចពុទ្ធិ និងបច្ចេកវិទ្យាទំនើបប្រកបដោយឧត្តមភាព និងការប្រកួតប្រជែងដែលមានសន្ទុះយ៉ាងខ្លាំងក្លា រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភាបានផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើការអភិវឌ្ឍធនធានមនុស្ស មានន័យថា ប្រែក្លាយអាទិភាពចម្បងចំនួន៤ គឺ៖ មនុស្ស ផ្លូវ ភ្លើង និងទឹក នៅក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ ហើយបន្តទៅក្នុងដំណាក់កាលទី៤នេះ។

ដើម្បីឆ្លើយតបទៅនឹងការកំណត់អាទិភាព "មូលធនមនុស្ស" របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ បានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការប្រកបដោយគុណវុឌ្ឍិខ្ពស់តាមរយៈការបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងរយៈពេលវែងទាំងក្នុង និងក្រៅប្រទេស។

ជាក់ស្តែងក្នុងឆ្នាំ២០២១ ក្រសួងបានបណ្តុះបណ្តាលមន្ត្រីរាជការសរុបចំនួន១ ៥១៧នាក់ ស្ត្រី៤១៤នាក់។ វគ្គបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លីនិងមធ្យមសរុបមានចំនួន១ ៤៥៣នាក់ ស្ត្រី៣៩៨នាក់ និងវគ្គបណ្តុះបណ្តាលក្រៅប្រទេស សរុបមានចំនួន៦៤នាក់ ស្ត្រី១៦នាក់ ដែលក្នុងនោះ៖ វគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងមធ្យមមានចំនួន៥៦នាក់ ស្ត្រី១៣នាក់ និងវគ្គបណ្តុះបណ្តាលរយៈពេលវែងមានចំនួន០៨នាក់ ស្ត្រីចំនួន០៣នាក់ ( ថ្នាក់បណ្ឌិតចំនួន០២នាក់ និងបរិញ្ញាជាន់ខ្ពស់ ចំនួន០៦នាក់ ស្ត្រី០៣នាក់)។

នៅក្នុងបរិបទនៃវិបត្តិជំងឺឆ្លងកូវីដ-១៩ បានកំពុងរីករាលដាលជាសាកលនិងជះឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ចនិងសង្គមនៅតាមបណ្តាប្រទេសស្ទើតែទាំងអស់ពេញពិភពលោក រួមទាំងកម្ពុជាយើងយ៉ាងណាក្តី ក៏ក្រសួងនៅតែផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ដោយបានធ្វើការសម្របសម្រួលនិងសហប្រតិបត្តិការជាមួយអង្គភាព ក្រោមឱវាទនិងដៃគូអភិវឌ្ឍន៍នានាធ្វើការបណ្តុះបណ្តាលពាក់ព័ន្ធតាមរយៈប្រព័ន្ធអនឡាញ។

តារាងទី១៖ ស្ថិតិបណ្តុះបណ្តាលវគ្គខ្លី មធ្យម និងវែង របស់មន្ត្រីរាជការ និស្សិត នៅក្នុងប្រទេសនិងក្រៅប្រទេស របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២១ មានដូចខាងក្រោម៖

| ល.រ | ប្រទេស | បណ្តុះបណ្តាលវគ្គខ្លី(នាក់) | ថ្នាក់កម្រិតសញ្ញាបត្រ | | | សរុប | |
|---|---|---|---|---|---|---|---|
| | | | ថ្នាក់បរិ. | ថ្នាកបរិ.ជាន់ខ្ពស់ | ថ្នាក់បណ្ឌិត | ចំនួន (នាក់) | ស្ត្រី |
| I. វគ្គបណ្តុះបណ្តាលនៅក្នុងប្រទេស | | | | | | | |
| ១ | ក្នុងប្រទេស | ១ ៤៥៣ | | | | ១ ៤៥៣ | ៣៩៨ |
| **សរុប □** | | **១ ៤៥៣** | | | | **១ ៤៥៣** | **៣៩៨** |
| II. វគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស | | | | | | | |
| ១ | កូរ៉េ | ១៣ | | ៣ | | ១៦ | ១ |
| ២ | ជប៉ុន | ៣១ | | ១ | ១ | ៣៣ | ១២ |
| ៣ | ហ្វីលីពីន | | | ១ | | ១ | 0 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | ចិន | ៥ | | | | ៥ | ១ |
| ៥ | អូស្ត្រាលី | ១ | | | ១ | ២ | 0 |
| ៦ | នូវែលហ្សេឡង់ | ១ | | | | ១ | 0 |
| ៧ | សហរដ្ឋអាមេរិច | | | ១ | | ១ | ១ |
| ៨ | ថៃ | ៥ | | | | ៥ | ១ |
| **សរុប II** | | **៥៦** | **0** | **៦** | **២** | **៦៤** | **១៦** |
| **សរុប I + II** | | **១ ៥0៩** | **0** | **៦** | **២** | **១ ៥១៧** | **៤១៤** |

តារាងទី២៖ ស្ថិតិមន្ត្រីដែលបានបញ្ចប់ការសិក្សារយៈពេលវែង នៅក្រៅប្រទេស របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២១ មានដូចខាងក្រោម៖

| **ល.រ** | **ឈ្មោះប្រទេស** | **កម្រិតសញ្ញាបត្រ** | | **សរុប** | |
|---|---|---|---|---|---|
| | | **បរិញ្ញាជាន់ខ្ពស់** | **បណ្ឌិត** | **ចំនួន(នាក់)** | **ស្ត្រី** |
| ១ | ថៃ | ៤ | | ៤ | ១ |
| ២ | ជប៉ុន | ២ | ១ | ៣ | ៣ |
| ៣ | កូរ៉េ | ១ | | ១ | ១ |
| ៤ | ចិន | ៣ | | ៣ | ១ |
| ៥ | អូស្ត្រាលី | ១ | ១ | ២ | |
| ៦ | អូទ្រីស | | ១ | ១ | ១ |
| **សរុប** | | **១១** | **៣** | **១៤** | **៧** |

### ៥.៣.៣. ការងារបណ្តុះបណ្តាលនិស្សិត

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានគ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មចំនួនបីគឺ សាកលវិទ្យាល័យភូមិន្ទកសិកម្ម (ស.វ.ភ.ក) វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប (វ.ជ.ក.ព.ល) និងវិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម (វ.ជ.ក.ក.ច)។

តារាងទី៣៖ ស្ថិតិមន្ត្រី គ្រូបង្រៀន និស្សិត របស់គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី ឆ្នាំ២០២១ មានដូចខាងក្រោម៖

| ល.រ | គ្រឹះស្ថានសិក្សា | បណ្ឌិត | | អនុបណ្ឌិត | | បរិញ្ញាបត្រ | | បរិញ្ញាបត្ររង | | បឋម | | គ្មានជំនាញ | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ១ | **សាកវិទ្យាល័យភូមិន្ទកសិកម្ម** | | | | | | | | | | | | | | |
| ក | *ចំនួនមន្ត្រី (គ្របខ័ណ្ឌ កិច្ចសន្យា និងគ្រូក្រៅម៉ោង)* | ៤៣ | ៤ | ១៧៥ | ៣៤ | ៨៨ | ១០ | - | - | ៣៩ | ៥ | - | - | ៣៤៥ | ៥៣ |
| ខ | *ចំនួននិស្សិត* | ៣៣ | ៦ | ១៦៧ | ៥២ | ៣៣៨២ | ១៣៤៧ | ៧៤ | ២៧ | - | - | - | - | ៣៦៥៦ | ១៤៣៤ |
| | អាហារូបករណ៍ | - | - | - | - | ៦៦៨ | ៣៣៦ | - | - | - | - | - | - | ៦៦៨ | ៣៣៦ |
| | សិក្សាបង់ថ្លៃ | ៣៣ | ៦ | ១៦៧ | ៥២ | ២៧១៤ | ១០១៣ | ៧៤ | ២៧ | - | - | - | - | ២៩៨៨ | ១០៩៨ |
| ២ | **វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប** | | | | | | | | | | | | | | |
| ក | *ចំនួនមន្ត្រី* | ៩ | 0 | ៥៧ | ២០ | ៥២ | ១២ | ២ | 0 | - | - | ១ | ១ | ១២១ | ៣៥ |

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ខ | *ចំនួននិស្សិត* | - | - | - | - | ១០៧៥ | ៤៤៦ | ៤៥២ | ១៤៦ | - | - | - | - | ១៥២៧ | ៥៩២ |
| | អាហារូបករណ៍ | - | - | - | - | ៩៤០ | ៤០៤ | ៤៣១ | ១៤០ | - | - | - | - | ១៣៧១ | ៥៤៤ |
| | សិក្សាបង់ថ្លៃ | - | - | - | - | ១៣៥ | ៤២ | ២១ | ៦ | - | - | - | - | ១៥៦ | ៤៨ |
| ៣ | **វិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម** | | | | | | | | | | | | | | |
| ក | *ចំនួនមន្ត្រី* | - | - | ៣៣ | ៥ | ២៥ | ១១ | ១ | ០ | - | - | - | - | ៥៩ | ១៦ |
| ខ | *ចំនួននិស្សិត* | - | - | - | - | ៩៤១ | ៣៩៨ | ២០៦ | ៧៤ | - | - | - | - | ១១៤៧ | ៤៧២ |
| | អាហារូបករណ៍ | - | - | - | - | ៨៦១ | ៣៦៨ | ១៩៧ | ៧៤ | - | - | - | - | ១០៥៨ | ៤៤២ |
| | សិក្សាបង់ថ្លៃ | - | - | - | - | ៨០ | ៣០ | ៩ | ០ | - | - | - | - | ៨៩ | ៣០ |

ក្នុងរយៈពេល០៥ឆ្នាំនេះ គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី បានទទួលនិស្សិតឱ្យចូលរៀន និងបញ្ចប់ការសិក្សាដោយជោគជ័យ មានដូចខាងក្រោម៖

### តារាងទី៤៖ ស្ថិតិនិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម

| និស្សិត / ឆ្នាំសិក្សា | បរិញ្ញារង | | បរិញ្ញា | | បរិញ្ញាជាន់ខ្ពស់ | | បណ្ឌិត | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៦-២០១៧ | ៤៣ | ៩ | ៧៦៩ | ២៤៣ | ១៣ | ៣ | ០ | ០ | ៨២៥ | ២៥៥ |
| ២០១៧-២០១៨ | ៣៦ | ១២ | ៤៦០ | ១៣៤ | ២២ | ៤ | ០ | ០ | ៥១៨ | ១៥៩ |
| ២០១៨-២០១៩ | ២២ | ៦ | ៥៨៨ | ២២៨ | ១៧ | ៦ | ០ | ០ | ៦២៧ | ២៤០ |
| ២០១៩-២០២០ | ២៨ | ១០ | ៦០៧ | ២៣៧ | ៤៨ | ២០ | ២ | ០ | ៦៨៥ | ២៦៧ |
| ២០២០-២០២១ | ២០ | ៦ | ៦៧៣ | ២៦១ | ១៧ | ៨ | ៣ | ០ | ៧១៣ | ២៧៥ |
| **សរុប៥ឆ្នាំ** | ១៤៩ | ៤៣ | ៣០៩៧ | **១១១២** | ១១៧ | ៤១ | ៥ | ០ | ៣៣៦៨ | ១១៩៦ |

### តារាងទី៥៖ ស្ថិតិនិស្សិតសិក្សាក្នុងឆ្នាំនិមួយៗ របស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម

| និស្សិត / ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | អនុបណ្ឌិត | | បណ្ឌិត | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៦-២០១៧ | ១៥៣ | ៤២ | ៣៣៤៧ | ១១០២ | ១១១ | ៤០ | ២៧ | ៣ | ៣៦៣៨ | ១១៨៧ |
| ២០១៧-២០១៨ | ១៣៧ | ៣១ | ២៨០៦ | ១០០៦ | ៤៤ | ១៦ | ២៦ | ៣ | ៣០១៣ | ១០៥៦ |
| ២០១៨-២០១៩ | ១៣៥ | ៤២ | ២៩៤៩ | ១១៦៩ | ៤០ | ១៥ | ៣៣ | ៣ | ៣១៥៧ | ១២២៩ |
| ២០១៩-២០២០ | ១៣៥ | ៥៦ | ៣១១៥ | ១២៥៩ | ៩០ | ៣០ | ៣០ | ២ | ៣៣៧០ | ១៣៤៧ |
| ២០២០-២០២១ | ៧៤ | ២៧ | ៣៣៨២ | ១៣៤៧ | ១៦៧ | ៥២ | ៣៣ | ៦ | ៣៦៥៦ | ១៤៣៤ |
| **សរុប៥ឆ្នាំ** | **៦៣៤** | **១៩៨** | **១៥៥៩៩** | **៥៨៨៣** | **៤៥២** | **១៥៣** | **១៤៩** | **១៧** | **១៦៨៣៤** | **៦២៥៣** |

### តារាងទី៦៖ ស្ថិតិនិស្សិតចូលរៀនរបស់វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៦-២០១៧ | ១១៩ | ៤៩ | ១០៤ | ៤០ | ២២៣ | ៨៩ |
| ២០១៧-២០១៨ | ១១៩ | ៣៤ | ១៨០ | ៧៩ | ២៩៩ | ១១៣ |
| ២០១៨-២០១៩ | ៥៣ | ២៣ | ២៣៦ | ១១៦ | ២៨៩ | ១៣៩ |
| ២០១៩-២០២០ | ១៤៩ | ៤០ | ១៩៧ | ៧២ | ៣៤៦ | ១១២ |

| | | | | | | |
|---|---|---|---|---|---|---|
| ២០២០-២០២១ | ១២ | ០ | ៣៥៨ | ១៣៩ | ៣៧០ | ១៣៩ |
| **សរុប៥ឆ្នាំ** | **៤៥២** | **១៤៦** | **១០៧៥** | **៤៤៦** | **១៥២៧** | **៥៩២** |

## តារាងទី៧៖ ស្ថិតិនិស្សិតបញ្ចប់ការសិក្សារបស់វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៦-២០១៧ | ១០៤ | ២៤ | ២៨៨ | ១០៨ | ៣៩២ | ១៣២ |
| ២០១៧-២០១៨ | ១៣៧ | ៥២ | ២០៧ | ៧៣ | ៣៤៤ | ១២៥ |
| ២០១៨-២០១៩ | ១១០ | ៤៣ | ១៦៥ | ៤៧ | ២៧៥ | ៩០ |
| ២០១៩-២០២០ | ១៤៩ | ៤០ | ១៩៧ | ៧២ | ៣៤៦ | ១១២ |
| ២០២០-២០២១ | ៨៦ | ២៤ | ១២៦ | ៤៩ | ២១២ | ៧៣ |
| **សរុប៥ឆ្នាំ** | **៥៨៦** | **១៨៣** | **៩៨៣** | **៣៤៩** | **១៥៦៩** | **៥៣២** |

## តារាងទី៨៖ ស្ថិតិនិស្សិតចូលរៀនរបស់វិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៦-២០១៧ | ៦២ | ២៦ | ១៩៦ | ១១៥ | ២៥៨ | ១៤១ |
| ២០១៧-២០១៨ | ៥៨ | ១៨ | ១៩៣ | ១០៨ | ២៥១ | ១២៦ |
| ២០១៨-២០១៩ | ៧០ | ១៨ | ៣០៣ | ១៤៧ | ៣៧៣ | ១៦៥ |
| ២០១៩-២០២០ | ៩០ | ៣៤ | ៣៥៧ | ១៦៣ | ៤៤៧ | ១៩៧ |
| ២០២០-២០២១ | ៣ | ១ | ១៤៨ | ៦២ | ១៥១ | ៦៣ |
| **សរុប៥ឆ្នាំ** | **២៨៣** | **៩៧** | **១១៩៧** | **៥៩៥** | **១៤៨០** | **៦៩២** |

## តារាងទី៩៖ ស្ថិតិនិស្សិតបញ្ចប់ការសិក្សារបស់វិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម

| ឆ្នាំសិក្សា | បរិញ្ញាបត្ររង | | បរិញ្ញាបត្រ | | សរុបរួម | |
|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០១៦-២០១៧ | ៨២ | ៤៦ | ១៩៥ | ៩៩ | ២៧៧ | ១៤៥ |
| ២០១៧-២០១៨ | ១១៤ | ៤៨ | ១៨៩ | ៧៣ | ៣០៣ | ១២១ |
| ២០១៨-២០១៩ | ៥៣ | ១៥ | ១៤១ | ៥៤ | ១៩៤ | ៦៩ |
| ២០១៩-២០២០ | ៣៦ | ១៣ | ១២១ | ៤៩ | ១៥៧ | ៦២ |
| ២០២០-២០២១ | ១៨ | ៩ | ១៤៣ | ៤៧ | ១៦១ | ៥៧ |
| **សរុប៥ឆ្នាំ** | **៣០៣** | **១៣១** | **៧៨៩** | **៣២២** | **១០៩២** | **៤៥៣** |

គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី បានកំពុងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ តាមរយៈការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាល ស្រាវជ្រាវ និងសេវាកម្ម សម្រាប់សហគមន៍ ក្នុងបរិបទសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងសកលភាវូបនីយកម្ម។

នៅឆ្នាំ២០២១នេះ គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី បានធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងទ្វេភាគី និងពហុភាគី កាន់តែល្អប្រសើរ ជាមួយដៃគូអភិវឌ្ឍន៍នានា។

សាកលវិទ្យាល័យភូមិន្ទកសិកម្មបាននឹងកំពុងដំណើរការអនុវត្តន៍គម្រោងពិសោធន៍ស្រាវជ្រាវតូចៗ ចំនួន ៤១គម្រោង ក្នុងនោះរួមមាន៖ គម្រោងចំនួន២២គម្រោងទទួលបានថវិកាពីរាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ គម្រោងចំនួន០៧ ទទួលបានថវិកាពីគម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP) និងគម្រោងចំនួន១២ ជាកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិដូចជា៖ ជាមួយសហភាពអឺរ៉ុប (EU) អង្គការសុខភាពសត្វពិភពលោក (OIE) ជំនួយការរបស់ទីភ្នាក់ងារអាមេរិក (USAID) មជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មប្រកបដោយនិរន្តភាពនិងអាហារូបត្ថម្ភ (CESAIN) អង្គការ SIIL សម្រាប់កម្មវិធីមន្ទីរពិសោធន៍នវានុវត្តប្រកបដោយចីរភាព មជ្ឈមណ្ឌល អូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ក្រុមប្រឹក្សានៃប្រទេសស៊ុយអែត (Sweden Council) និងមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) និងសហការជាមួយក្រុមហ៊ុន Agro-Study អ៊ីស្រាអែល បញ្ជូននិស្សិតទៅចូលរួមកម្មសិក្សានិងហ្វឹកហាត់ការងារ ចំនួន២០០នាក់ ។

វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប មានកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យអន្តរជាតិ និងក្រុមហ៊ុន មានដូចជា៖ សាកលវិទ្យាល័យបច្ចេកវិទ្យា RAjamangala Isan ប្រទេសថៃ សាកលវិទ្យាល័យបច្ចេកវិទ្យា Bogor ប្រទេសឥណ្ឌូនេស៊ី សាកលវិទ្យាល័យមេគង្គ ប្រទេសវៀតណាម សាកលវិទ្យាល័យជាតិបច្ចេកវិទ្យា និងវិទ្យាសាស្ត្រតៃវ៉ាន់ Pintung សាកលវិទ្យាល័យ Hainan ប្រទេសចិន សាកលវិទ្យាល័យ Anguing Teachers Colleague ប្រទេសចិន Southeast Asia One Health University Network សាកលវិទ្យាល័យ Hiroshima ប្រទេសជប៉ុន ក្រុមហ៊ុន Cambojob ក្រុមហ៊ុន Mopo Energy (Cambodia) Co., Ltd ក្រុមហ៊ុន Axei Asia Human Resource (AAHR) ក្រុមហ៊ុន Cambodia First Unite Contraction Development Co., Ltd អង្គការមូលនិធិចក្ខុខ្មែរ និងក្រុមហ៊ុន Energy Cambodia Co., Ltd។ ជាងនេះទៅទៀត បានសហការជាមួយក្រុមហ៊ុនកូរ៉េ លើការស្រាវជ្រាវជាលិកាវប្បកម្ម និងសហការជាមួយ Cambodia-Japan Research Center for Agriculture ដើម្បីជំរុញការស្រាវជ្រាវដំណាំកសិកម្ម។ ជាពិសេសវិទ្យាស្ថានបាននឹងកំពុងបន្តអនុវត្តកម្មវិធីដែលបានចុះអនុស្សរណៈនិងកិច្ចព្រមព្រៀងជាមួយរាជបណ្ឌិត្យសភាកម្ពុជានិងសាកលវិទ្យាល័យជាតិគ្រប់គ្រង និងអន្តរជាតិ និងត្រៀមបន្តឆ្នាំ២០២២។

វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម នៅឆ្នាំ២០២១ បានធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការ KOICA និងសាកលវិទ្យាល័យជាតិ Kangwon របស់សាធារណរដ្ឋកូរ៉េ ដើម្បីបង្កើនគុណភាព និងនវានុវត្តន៍របស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម ដែលមានជំនាញការចូលរួមចំនួន១៥រូប និងបណ្តុះបណ្តាលដល់មន្ត្រីចំនួន២៥រូប ព្រមទាំងបន្តអនុវត្តកម្មវិធីកសាងធនធានមនុស្ស ផ្នែកមន្ទីរពិសោធន៍ របស់វិទ្យាស្ថានជាតិកសិកម្ម កំពង់ចាមបន្ថែមទៀត។ ជាមួយគ្នានេះដែរវិទ្យាស្ថានក៏បានចុះអនុស្សរណៈ និងកិច្ចព្រមព្រៀងជាមួយនឹង Hainan Institute of Vocational and Technique នៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីធ្វើការផ្លាស់ប្តូរនិស្សិតទៅសិក្សា ព្រមទាំងសហការជាមួយនឹងអង្គការ ERICON ចុះធ្វើការផ្សព្វផ្សាយណែនាំកសិករពីកសិកម្មសរីរាង្គនៅខេត្តកំពង់ចាម និងរួមសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រផ្សព្វផ្សាយកសិកម្មសម្រាប់ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម សហការជាមួយអង្គការ OISCA ដើម្បីបញ្ជូននិស្សិតបញ្ចប់ការសិក្សា ទៅបន្តការសិក្សាឯកទេសកសិកម្មសរីរាង្គនៅប្រទេសជប៉ុន ជាងនេះទៅទៀតវិទ្យាស្ថានបាននឹងកំពុងអនុវត្តន៍គម្រោងជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងក្រុមហ៊ុន Agro-Study អ៊ីស្រាអែល ដើម្បីបញ្ជូននិស្សិតទៅបន្តការសិក្សានិងហ្វឹកហាត់ការងារនៅប្រទេសអ៊ីស្រាអែល។

ក្រៅពីការងារសហប្រតិបត្តិការខាងលើ គ្រឹះស្ថានសិក្សាបច្ចេកទេសកសិកម្មទាំងបី បានទទួលនូវកម្មវិធីផ្លាស់ប្តូរនិស្សិត និងមន្ត្រីរាជការ ទៅប្រទេសអេស្ប៉ាញ ថៃឡង់ដ៍ ជប៉ុន ចិន និងប្រទេសអ៊ីស្រ្តាអែល សរុបចំនួន២២២នាក់ ដើម្បីស្វែងយល់ និងដកស្រង់បទពិសោធន៍លើវិស័យកសិកម្ម។

### ៥.៥. ការងារកិច្ចការរដ្ឋបាល

ផ្ដើមចេញពីការអនុវត្តនូវតួនាទី ភារកិច្ច និងផែនការសកម្មភាពរបស់ខ្លួន ក្នុងឆ្នាំ២០២១នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននាយកដ្ឋានកិច្ចការរដ្ឋបាល ជាសេនាធិការ សម្រេចបាននូវលទ្ធផល ដូចខាងក្រោម៖

- បានទទួលលិខិតសរុបចំនួន ៧ ៨១៨ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៣ ០៦៩ច្បាប់ ពីអង្គភាពក្រោមឱវាទចំនួន ៣ ៤៧៣ច្បាប់ និងពីរាជធានី-ខេត្តចំនួន ១ ២៧៦ច្បាប់ ព្រមទាំងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល
- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១២ ២៨៨ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៤៦២ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ២៦១ច្បាប់
- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស ខែវិច្ឆិកា និងប្រចាំឆ្នាំ
- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំ ដើម្បីក្តាប់ឱ្យបាននូវរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការរៀបចំកិច្ចប្រជុំ ការទទួលភ្ញៀវ ពិធីចុះហត្ថលេខា និងសិក្ខាសាលាមានចំនួន ១៤៣លើក មានសមាជិកចូលរួមចំនួន ៣ ៨៥៨នាក់។
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញ ផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

### ៥.៦. ការងារអធិការកិច្ច

នៅក្នុងឆ្នាំ២០២១នេះ ក្រសួងបានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងតាមបណ្តាអង្គភាពជំនាញថ្នាក់កណ្តាល និងថ្នាក់រាជធានីខេត្ត ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**ក.ការងារអធិការកិច្ច:**

បានចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងតាមបណ្តាអង្គភាពក្រោមឱវាទក្រសួងមានបេសកកម្មចំនួន ១៣លើក រួមមាន៖

- ចុះត្រួតពិនិត្យលើការងារអនុវត្តតួនាទីភារកិច្ចរបស់អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ និងមេគង្គ ចាប់ពីថ្ងៃទី០៨-១២ ខែមករា ឆ្នាំ២០២១ អនុវត្តតាមការចង្អុលបង្ហាញរបស់ឯកឧត្តមរដ្ឋមន្ត្រី
- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាត នៅខេត្តកណ្តាល និងខេត្តត្បូងឃ្មុំ ចាប់ពីថ្ងៃទី១៤-២៤ ខែមករា ឆ្នាំ២០២១ អនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។
- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាត នៅខេត្តតាកែវ កណ្តាល ព្រៃវែង និងខេត្តត្បូងឃ្មុំ ចាប់ពីថ្ងៃទី២៦ ខែមករា ដល់ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ អនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង

- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាត នៅខេត្តតាកែវ និងខេត្តកំពត ចាប់ពីថ្ងៃទី០៩-១៧ ខែកុម្ភៈ ឆ្នាំ២០២១ អនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង
- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបន្ទាយមានជ័យ និងពិនិត្យលើចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរដែលក្រសួងបានណែនាំឱ្យកែលម្អកន្លងមក ចាប់ពីថ្ងៃទី១៥-២៣ ខែកុម្ភៈ ឆ្នាំ២០២១ អនុវត្តតាមផែនការសកម្មភាពការងារប្រចាំឆ្នាំ
- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាត នៅខេត្តតាកែវ និងខេត្តកំពត ចាប់ពីថ្ងៃទី២៥-៣១ ខែឧសភា ឆ្នាំ២០២១ អនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង
- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាត នៅខេត្តកណ្តាល និងខេត្តព្រៃវែង ចាប់ពីថ្ងៃទី១៤-២៤ ខែមិថុនា ឆ្នាំ២០២១ អនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង
- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាត នៅខេត្តត្បូងឃ្មុំ ព្រៃវែង កណ្តាល តាកែវ កំពត ស្វាយរៀង និងរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២២-៣១ ខែកក្កដា ឆ្នាំ២០២១ អនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។
- ចុះត្រួតពិនិត្យការអនុវត្តលិខិតកែលម្អលេខ ១៥៣២កសក.អធ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ នៅខេត្តសៀមរាប ចាប់ពីថ្ងៃទី២៥-៣០ ខែកក្កដា ឆ្នាំ២០២១ អនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង ចុះពង្រឹងការត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាត ដល់ខណ្ឌរដ្ឋបាលជលផលត្បូងឃ្មុំ ព្រៃវែង កណ្តាល តាកែវ កំពត ស្វាយរៀង និងរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១១-២១ ខែសីហា ឆ្នាំ២០២១ ដោយអនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង
- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់ខណ្ឌរដ្ឋបាលជលផលស្វាយរៀង នៅខេត្តស្វាយរៀង ចាប់ពីថ្ងៃទី១០-១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយអនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង
- ចុះស្រាវជ្រាវលើការងារដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វនាំចូលពីបរទេស នៅខេត្តត្បូងឃ្មុំ ចាប់ពីថ្ងៃទី២២-២៧ ខែវិច្ឆិកា ឆ្នាំ២០២១ អនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង
- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាត នៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ចាប់ពីថ្ងៃទី២៨-៣០ ខែវិច្ឆិកា ឆ្នាំ២០២១ អនុវត្តតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

### ខ.ការងារទទួលពាក្យបណ្តឹង

ក្នុងឆ្នាំ២០២១ ក្រសួងបានទទួលពាក្យបណ្តឹងបានចំនួន០៥ករណី និងបានចុះធ្វើការស្រាវជ្រាវជាក់ស្តែងលើករណីទាំងនេះ រួមមាន (១) ពាក្យបណ្តឹងរបស់ អូម វ៉ាន់ ប្តឹងសុំអន្តរាគមន៍ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង ប្រគល់ដីស្រែភោគៈមិនទាន់ចុះបញ្ជីទំហំ ៤ហិកតា ស្ថិតនៅភូមិតាប៉ោញ ឃុំព្រៃតាអី ស្រុកស្វាយទាប ខេត្តស្វាយរៀង ធ្វើជាកម្មសិទ្ធិស្របច្បាប់ (២) ចុះស្រាវជ្រាវពាក្យបណ្តឹងពាក់ព័ន្ធនឹងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប លើការកាត់ប្រាក់បេសកកម្ម និងប្រាក់អនុវត្តសកម្មភាពរបស់គម្រោង Aspire ចំនួន ០២ករណី (៣) ចុះស្រាវជ្រាវពាក្យបណ្តឹងពាក់ព័ន្ធការអនុវត្តលិខិតកែលម្អដែលក្រសួងបានដាក់ចេញលិខិតលេខ

១៥៣២ កសក.អធ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប (៤) ចុះស្រាវជ្រាវពាក្យបណ្តឹងអនាមិកស្តីពី ភាពមិនប្រក្រតីក្នុងកិច្ចលទ្ធកម្មជ្រើសរើសទីប្រឹក្សាបច្ចេកទេសក្រោមកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ហិរញ្ញប្បទានដោយមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**គ.ការងារតាមដានការអនុវត្តៈ**

ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ១១២៨ករណី ក្នុងនោះ អនុវិស័យព្រៃឈើមានចំនួន ២៤១ ករណី អនុវិស័យជលផលមានចំនួន ២៦៤ ករណី អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វចំនួន ១៤៧ ករណី អនុវិស័យកៅស៊ូចំនួន ១២ ករណី ផ្នែកកសិ-ឧស្សាហកម្មចំនួន ០៥ ករណី អនុវិស័យដំណាំចំនួន ០៦ ករណី ផ្នែកនីតិកម្មកសិកម្មចំនួន ០៥ ករណី និងផ្នែកផ្សេងៗចំនួន ៤៤៨ ករណី។

**ឃ.ការងារចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គម**

ក្នុងឆ្នាំ២០២១នេះ បានចូលរួមប្រជុំ សិក្ខាសាលា និងកិច្ចការងារសង្គម បានចំនួន ៤៩លើក ក្នុងនោះ ការចូលរួមប្រជុំការងារទូទៅចំនួន ៣៧ លើក ចូលរួមសិក្ខាសាលាចំនួន ០៦ លើក ចូលរួមប្រកាសចូលកាន់តំណែងចំនួន ០១ លើក ចូលរួមការងារ សង្គមចំនួន ០២ លើក និងចូលរួមក្នុងពិធីផ្សេងៗចំនួន ០៣ លើក។

### ៥.៧. ការងារសហប្រតិបត្តិការអន្តរជាតិ

នៅក្នុងឆ្នាំ២០២១ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិបានសម្របសម្រួល និងរៀបចំលិខិតព្រមទាំងឯកសារជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីក្រោមឱវាទក្រសួង ដើម្បីចូលរួមសិក្ខាសាលា ទស្សនកិច្ច ទិវា កិច្ចប្រជុំនិងកិច្ចប្រជុំតាមប្រព័ន្ធវីដេអូពីចម្ងាយសិន្និសីទ វគ្គបណ្តុះបណ្តាលនៅបរទេស និងបានចរចារក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគីក៏ដូចជាដៃគូអភិវឌ្ឍន៍ដោយបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងដូចខាងក្រោម៖

ក. <u>កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី</u>

- សម្របសម្រួលជាមួយអង្គភាពជំនាញ និងគាំទ្រលើការស្នើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ក្នុងនោះ ហិរញ្ញប្បទានរដ្ឋាភិបាលជប៉ុនសម្រាប់ឆ្នាំសារពើពន្ធ២០២២ ចំនួន០៣គម្រោង និងគម្រោងបច្ចេកទេសចំនួន ០១គម្រោង ហិរញ្ញប្បទានរដ្ឋាភិបាលកូរ៉េ ក្រោមក្របខ័ណ្ឌ Korean Agricultural Policy Experiences for Food Security (KAPEX)សម្រាប់ឆ្នាំសារពើពន្ធ២០២៣ ចំនួន ០៦គម្រោង និងក្របខ័ណ្ឌ ODA កូរ៉េ ចំនួន ០៤គម្រោង ហិរញ្ញប្បទានរដ្ឋាភិបាលចិន ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ចំនួន ០៦គម្រោង និងគម្រោងកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានរដ្ឋាភិបាលឥណ្ឌា ចំនួន ៩គម្រោង
- ផ្តល់ការសម្របសម្រួល និងផ្តល់ធាតុចូល លើការរៀបចំ MOU ជាមួយដៃគូអភិវឌ្ឍន៍រួមមាន សហព័ន្ធសហករណ៍ រ៉ៃអិនសិន អាល្លឺម៉ង់ (DGRV) សាកលវិទ្យាល័យ Konkuk នៃសាធារណរដ្ឋកូរ៉េ ក្រុមហ៊ុន Geotwo Co.Ltd នៃសាធារណរដ្ឋកូរ៉េ ក្រុមហ៊ុន Cardno Emerging Markets (Australia)
- រៀបចំកិច្ចប្រជុំជម្រុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម កម្ពុជា-ហុងគ្រី។
- រៀបចំសំណើសុំផ្តល់ធាតុចូលលើរបាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌ CLV, CLMV, GMS និងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង

- ចូលរួម និងសម្របសម្រួលជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីក្រោមឱវាទក្រសួង ដើម្បីចូលរួមសិក្ខាសាលា ទស្សនកិច្ច ទិវា កិច្ចប្រជុំនិងកិច្ចប្រជុំតាមប្រព័ន្ធវីដេអូពីចម្ងាយ សិន្និសីទ និងវគ្គបណ្តុះបណ្តាលនៅបរទេស ក្រោមក្របខ័ណ្ឌ ទ្វេភាគី (កម្ពុជា-ឥណ្ឌាស្តីពីពាណិជ្ជកម្ម និងវិនិយោគ) CLV, CLMV, GMS និងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង
- កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម ជាមួយភាគីចិន រួមមាន៖
  + រៀបចំលិខិតការពន្លឿន នីតិវិធីចុះហត្ថលេខាលើពិធីសារអនាម័យ និងភូតគាមអនាម័យសម្រាប់នាំផ្លែមៀន ទៅកាន់ប្រទេសចិន
  + កំពុងរៀបចំផែនការការងារត្រួតពិនិត្យ និងវិភាគហានិភ័យលើផ្លែមៀន រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គរដ្ឋបាលគយនៃសាធារណប្រជាមានិតចិន
  + ចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការស្តីពី ការត្រួតពិនិត្យអនាម័យសត្វ និង ភូតគាមអនាម័យ និងសុវត្ថិភាពចំណីអាហារការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យ និងសុវត្ថភាពចំណី អាហាររវាងអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី០៨ ខែវិច្ឆិកា ២០២១។
  + កំពុងចរចាដើម្បីរៀបពិធីសារ ស្តីពីលក្ខខណ្ឌតម្រូវសម្រាប់នាំចេញផលវារីវប្បកម្មពីព្រះរាជាណាចក្រកម្ពុជា ទៅសាធារណៈរដ្ឋប្រជាមានិតចិនរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃព្រះរាជាណាចក្រកម្ពុជា និង អគ្គនាយកដ្ឋានរដ្ឋបាលគយនៃសាធារណៈរដ្ឋប្រជាមានិតចិន
  + បានទទួលជំនួយវ៉ាក់សាំងជំងឺសាទឹក និងអ៊ុតក្តាមចំនួន ២០០,០០០ (ពីរសែន) ដូស ពីក្រសួងកសិកម្ម និងកិច្ចការជនបទនៃសាធារណរដ្ឋប្រជាមានិតចិន លើកទី១ ថ្ងៃទី១២ ខែមករា ឆ្នាំ ២០២១ បានទទួលវ៉ាក់សាំងជម្ងឺសាទឹក ចំនួន ១០០ ០០០ (មួយសែន) ដូស និងលើកទី២ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ បានទទួលវ៉ាក់សាំងជំងឺអ៊ុតក្តាម(FMD) ចំនួន ១០០ ០០០ (មួយសែន) ដូស។

ខ. <u>**កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន**</u>

- បានសម្របសម្រួល និងរៀបចំកិច្ចប្រជុំតាមវិស័យ និងអនុវិស័យ ក្រោមក្រមខ័ណ្ឌកិច្ច សហប្រតិបត្តិការស្បៀង កសិកម្ម និងព្រៃឈើ ដោយកិច្ចប្រជុំទាំងនេះបានរៀបចំ និងចូលរួមដោយផ្ទាល់ និងប្រជុំតាមរយៈប្រព័ន្ធវីដេអូ។
- បានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំក្រុមការងារអាស៊ាន ក្រោមកិច្ចសហប្រតិបត្តិការស្បៀង កសិកម្ម និង ព្រៃឈើ ចំនួន ០៥ កិច្ចប្រជុំ (តាមប្រព័ន្ធវីដេអូ) ដូចខាងក្រោម៖

១. កិច្ចប្រជុំលើកទី១៩ របស់មន្ត្រីបង្គោលសម្រាប់ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងអាស៊ាន (The 19th AFSIS Focal Point Meeting)

២. កិច្ចប្រជុំលើកទី១១ របស់សម្ព័ន្ធបង្គាអាស៊ាន (The 11th Meeting of the ASEAN Shrimp Alliance) វេទិកាពិគ្រោះយោបល់ជលផលអាស៊ានលើកទី១៣ (The 13rd Meeting of the ASEAN Fisheries Consultative Forum) និងកិច្ចប្រជុំលើកទី២៩ របស់ក្រុមការងារជលផលអាស៊ាន (The 29th Meeting of the ASEAN Sectoral Working Group on Fisheries)។

៣. កិច្ចប្រជុំលើកទី៩ របស់មន្ត្រីបង្គោលសម្រាប់អនាម័យ និងភូតគាមអនាម័យអាស៊ាន (The 9th Meeting of the ASEAN Sanitary and Phytosanitary Contact Point) និងកិច្ចប្រជុំលើកទី១១ របស់គណៈកម្មការអនាម័យ និងភូតគាមអនាម័យអាស៊ាន (The 11st Meeting of the ASEAN

Committee on Sanitary and Phytosanitary Measures)

៤. កិច្ចប្រជុំលើកទី១៧ របស់ក្រុមការងារសម្រាប់អាហារហាឡាល់អាស៊ាន (The 17th Meeting of the ASEAN Working Group on Halal Food)

៥. កិច្ចប្រជុំពិសេសឧត្តមមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ានលើកទី៤២ និងកិច្ចប្រជុំអមជាមួយផ្សេងទៀត (Special Senior Officials Meeting of the 42nd Meeting of the ASEAN Ministers on Agriculture and Forestry and Related Meetings)

- សហការជាមួយអគ្គនាយកដ្ឋានកសិកម្ម ចុះពិភាក្សា និងពិនិត្យទីតាំងសម្រាប់រៀបចំពិធីចែកអង្ករជំនួយសង្គ្រោះ បន្ទាន់របស់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េជូនប្រជាជន ដែលរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩
- ឯកសារដែលបានអនុម័តក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ាន៖ (1) ASEAN Guidelines on Traceability for Food and Feed; (2) Revised MIG for e-Phyto Certificate (ver4.4) & Report on the Revision of ASEAN′s e-Phyto Certificate to align with IPPC′s e-Phyto guidelines (ver1.1); (3) ASEAN Guidelines on Genetically Modified Organism Analysis; (4) TOR&ROP of Regional Reference Center (RRC) for Bioinformatics; TOR&ROP of RRC for –Biorisk Management & Quality Assurance; (5) ASEAN Strategy for Exotic, Emerging, Re-emerging Diseases and Animal Health Emergencies; (6) South-East Asia and China Foot and Mouth Disease (SEACFMD) Roadmap 2021- 2025; (7) Recommend ASEAN Harmonised MRLs: i) Amitraz in longan at 2 mg/kg; ii) prochloraz in chili at 3 mg/kg, iii) azoxystrobin in pepper (black & white) at 0.5 mg/kg, iv) difenoconazole in pepper (black & white) at 0.3 mg/kg, v) Cyfluthrin/beta-cyfluthrin in eggplant at 0.2 mg/kg (adopted Codex MRL); (8) ASEAN Standards for Loose lettuce (Romaine lettuce); (9) Intra-ASEAN Phytosanitary Guidelines for Importation of Fresh Rambutan Fruit (*Nephelium lappaceum L.*) (for Consumption); (10) Regional Guideline on Performing Risk Analysis for Antimicrobial Resistance Arising from the Use of Antimicrobial Agents in Aquaculture; (11) ASEAN Guidelines for the Prudent Use of Antimicrobials in Aquaculture; (12) Plan of Action (POA) for the ASEAN Cooperation in Combatting AMR in Aquaculture Sector (2021–2025); (13) Guideline on Techniques for Veterinary Drug Residue Detection in Aquaculture Products; (14) Plan of Action for the ASEAN Cooperation on Good Aquaculture Practices (2021-2025); (15) Recommendations on the ASEAN General Fisheries Policy Feasibility Study; (16) Stock and Risk Assessments of Kawakawa (*Euthynnus affinis*) and Longtail Tuna (*Thunnus tonggol*) Resources in the Southeast Asian Waters using ASPIC; (17) Regional Action Plan for Management of Transboundary Species: Indo-Pacific Mackerel in the Gulf of Thailand Sub-region; (18) Assessment on the Implementation of Standard Operating Procedure

(SOP) for Responsible Movement of Live Aquatic Animals for ASEAN; (19) State and Outlook of Agroforestry in ASEAN; (20) ASEAN Handbook on Legal Cooperation to Combat Illegal Wildlife Trade; (21) ASEAN Framework Support Food, Agriculture and Forestry Small Producers, Cooperatives and Micro, Small, and Medium-Sized Enterprises (MSMEs) to Improve Product Quality to Meet Regional/International Standards and Ensure Competitiveness (22) ASEAN Guidelines on Promoting the Utilization of Digital Technologies for ASEAN Food and Agricultural Sector; (23) ASEAN Good Manufacturing Practices for Slaughterhouses and Meat Cutting Plants; (24) ASEAN Strategy on Sustainable Biomass Energy for Agriculture Communities and Rural Development in 2020-2030 (adopted by ATWGARD by ad referendum on 25th September 2020)។ **For Notation:** Revised Mechanism for the ASEAN registration of Animal Vaccine; Revised Protocol for ASEAN Recognition of Reference Animal Testing Laboratories; Revised Manual of Recognition of ASEAN Reference Laboratories Criteria for Animal Vaccine Testing; Concept Note Development of ASEAN Guidelines on Inspection and Quarantine for Imported Aquaculture Fish and Fisheries Products។

**គ. <u>កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអង្គការអន្តរជាតិ</u>**

- ផ្តល់កិច្ចសហការណ៍ និងគាំទ្រដល់អង្គការជាដៃគូរ រួមមាន Free The Bear Fund Inc, School Aid Japan, RECOFTC, FAO, Wildlife Alliance, WFP, AVSF, Brookly Bridge to Cambodia, អង្គការហេហ្វឺ អន្តរជាតិ អង្គការ ADRA អង្គការ Gret និងអង្គការគោរសប្បុរស
- បានសម្របសម្រួលធ្វើលិខិតមតិយោបល់បន្តអនុស្សរណៈនៃការយោគយល់គ្នា រវាង អង្គការហេហ្វឺអន្តរជាតិ ជាមួយនឹងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានសម្របសម្រួលធ្វើលិខិតមតិយោបល់ករណីសំណើសុំអនុញ្ញាតផ្តល់ការឯកភាពពន្យាការអនុវត្តគម្រោង ACIAR លេខ SMCN/2021/075 រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ របស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
- បានសម្របសម្រួលនិងផ្តល់យោបល់លើគោលការណ៍អនុញ្ញាតចុះហត្ថលេខាលើកិច្ចព្រមព្រៀង (PA) រវាង រដ្ឋបាលព្រៃឈើនិងអង្គការ ITTO, កិច្ចព្រមព្រៀងស្តីពីការអនុវត្តគម្រោងកសិកម្មជីវចំរុះ និងប្រព័ន្ធសុវត្ថិភាព ស្បៀងអាហារនៅកម្ពុជា រវាងអង្គការហ្វ្រេត, អនុស្សរណៈនៃការយោគយល់គ្នា រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយអង្គការ Cirad, កិច្ចព្រមព្រៀង Project Agreement “GCP/CMB /045/CDF-Promoting Climate-resilient Livelihoods in rice-base Communities in Tonle Sap Region” ជាមួយអង្គការFAO។
- បានសម្របសម្រួលធ្វើលិខិតស្តីពីករណីសំណើសុំកម្ពុជាគាំទ្រសន្និបាតវិសាមញ្ញលើកទី២ នៃ The Conference of Parties (COP ES-2) របស់លេខាធិការដ្ឋាន UNCCD
- បានសម្របសម្រួលធ្វើលិខិតមតិយោបល់ស្តីពីករណីសំណើអញ្ជើញមន្ត្រី ០៥រូប ចូលរួមក្នុង “វេទិកានៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មកម្ពុជា-ចិន” តាមរយៈប្រព័ន្ធវីឌីអូ Zoom

- បានសម្របសម្រួលធ្វើលិខិតករណីសំណើអញ្ជើញរដ្ឋសមាជិកចូលរួម UN Food Systems Pre-Summit នៅទីក្រុងរ៉ូម ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានសម្របសម្រួលធ្វើលិខិតសំណើសូមជួយអន្តរាគមន៍ទៅស្ថានទូតសហភាពអឺរ៉ុប ប្រចាំព្រះរាជាណាចក្រកម្ពុជា សុំបន្ថែមថវិកាចំនួន ២៥០,០០០អឺរ៉ូ ក្នុងការអនុវត្តកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកនេសាទ(CAPFISH-Capture)

ឃ. **<u>កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌកសិ-ពាណិជ្ជកម្មពិភពលោក</u>** <u>(WTO)</u>

- បានសម្របសម្រួលជាមួយអង្គភាពជំនាញក្រោមឱវាទ ផ្តល់ធាតុចូលលើឯកសារពាក់ព័ន្ធក្រោមក្រខ័ណ្ឌកសិ-ពាណិជ្ជកម្មពិភពលោក (WTO) ដែលរួមមាន៖ ការរៀបចំស្នើសេចក្តីផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការរឹតត្បិតបរិមាណទំនិញនាំចេញនាំចូល, ឯកសារសេចក្តីប្រកាសពាក់ព័ន្ធនឹងបញ្ហាអានាម័យ និងភូតគាមអនាម័យសម្រាប់កិច្ចប្រជុំសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១២ (MC12), ធ្វើសេចក្តីព្រាងនៃការរៀបចំផ្ទេរកម្មវិធីកាត់បន្ថយ និង/ឬលុបបំបាត់ពន្ធនាំចូលរបស់កម្ពុជាក្រៅប្រព័ន្ធសុខដុមនីយកម្ម AHTN 2017 ក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ជប៉ុន (AJCEP), ផ្តល់របាយការណ៍វឌ្ឍនភាពលើសេចក្តីថ្លែងការរួមកិច្ចប្រជុំលើកទី៣ នៃក្រុមការងាររួមកិច្ចសហប្រតិបត្តិការ កម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី, រៀបចំសេចក្តីព្រាងច្បាប់ ឯកសារ Non-paper ស្តីពីកសិកម្ម-សន្តិសុខស្បៀងសម្រាប់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី លើកទី១២, ផ្តល់ធាតុចូលលើការអនុវត្តម៉ាទ្រីសសកម្មភាពរបស់យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (Cambodia Trade Integration Strategy) ២០១៩-២០២៣, បច្ចុប្បន្នភាពនៃការអនុវត្តសកម្មភាព លើតារាងកម្មវិធីការងាររបស់រាជរដ្ឋាភិបាល (WTO Work Program) សម្របសម្រួលរៀបចំលិខិតអញ្ជើញដើម្បីចូលរួមប្រជុំពិភាក្សាលើករណីលេខាធិការដ្ឋានអង្គការ WTO ស្នើសុំ ឲ្យផ្ទៀងផ្ទាត់ព័ត៌មានបន្ថែមក្នុងទម្រង់ថ្មី និងផ្តល់តំណ ភ្ជាប់ទៅកាន់ច្បាប់ដើមនៃលិខិតបទដ្ឋាន-គតិយុត្ត ដែលបានផ្តល់ព័ត៌មានក្រោមកិច្ចព្រមព្រៀងស្តីពី នីតិវិធីអាជ្ញា ប័ណ្ណនាំចូលទំនិញ (Agreement on Import Licensing Procedure, សម្របសម្រួលលើស្តីពីសំណើសុំពិនិត្យ និងផ្តល់យោបល់លើសំណើរបស់សហភាពអឺរ៉ុប (EU) សុំឱ្យកម្ពុជាពិនិត្យលទ្ធភាពចូលរួមគាំទ្រ (Co-Sponsor) លើកំណត់ទំនាក់ទំនងស្តីពីពាណិជ្ជកម្ម និងចិរភាពបរិស្ថាន (Conservation on Trade and Environment Sustainability), រៀបចំរបាយការណ៍លទ្ធផលកិច្ចប្រជុំស្តីពី រៀបចំនីតិវិធីឯការអនុវត្តខ្លឹមសារអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីបញ្ជីទំនិញ ហាមឃាត់ និងទំនិញជាប់កម្រិត ជាប់កម្រិតកំណត់របស់រាជរដ្ឋាភិបាល, សម្របសម្រួលជាមួយអង្គភាពជំនាញ ស្តីពីករណីសុំចាត់ប្រធានអនុក្រុមការងារវិធានអនាម័យ និងភូត-គាមអនាម័យ ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងអាសិប ចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យការបកប្រែអត្ថបទនៃកិច្ចព្រមព្រៀង និងបន្តនីតិវិធីសម្រាប់ស្នើ សុំការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង RCEP, សម្របសម្រួលរៀបចំលិខិតឆ្លើយតបស្តីពី ករណីសំណើរសុំបំពេញ UN Global Survey on Digital and Sustainable Trade Facilitation 2021, សម្របសម្រួលរៀបចំក្រុមការងារបច្ចេកទេសសម្រាប់កិច្ចសម្រួលពាណិជ្ជកម្មវិស័យកសិកម្ម និងរៀបចំផែនការសកម្មភាព, សម្របសម្រួលផ្តល់ធាតុចូល លើការរៀបចំផែនទីចង្អុលផ្លូវ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម សម្រាប់ឆ្នាំ២០២២-២០២៤ និងផែនការសកម្មភាពឆ្នាំ២០២២-២០២៣, សម្របសម្រួលរៀបចំក្រុមការងារចូលរួមជាសមាជិកក្រុមការងារអន្តរក្រសួង ដើម្បីកែសម្រួលឯកសារយុទ្ធសាស្ត្រទាញយកអត្ថប្រយោជន៍ជាអតិបរិមា ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ចូលរួម និងសម្របសម្រួលជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីក្រោមឱវាទ

ក្រសួង ដើម្បីចូលរួម កិច្ចប្រជុំនិងកិច្ចប្រជុំតាមប្រព័ន្ធវីដេអូពីចម្ងាយក្រោមក្របខ័ណ្ឌ WTO និងកិច្ចសម្រួលពាណិជ្ជកម្ម។

- **ក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី**

កន្លងមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលរួមកិច្ចចរចារ និងជាប្រធានផ្នែក SPS នៅក្នុងដំណើរការនៃការរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលក្នុងនោះកិច្ចព្រមព្រៀងបានចុះហត្ថលេខារួច រួមមាន៖ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ RCEP, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី កម្ពុជា-ចិន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី កម្ពុជា-កូរ៉េ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលកំពុងស្ថិតក្នុងដំណើរការរៀបចំ និងសិក្សា រួមមាន៖ កិច្ចព្រមព្រៀងសេរីទ្វេភាគីកម្ពុជា-សហភាពសេដ្ឋកិច្ចអឺរ៉ាស៊ា (EAEU), កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្រ្តាលី-នូវែលហ្សេឡង់ (AANZFTA), បានចូលរួមផ្តល់ (input) លើការសិក្សារៀបចំ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អង់គ្លេស អាមេរិក ជប៉ុន ម៉ុងហ្គោលី និងឥណ្ឌា។

**តារាងគម្រោងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍**

| ល.រ | អនុស្សារៈនៃការយោគយល់គ្នា/កិច្ចព្រមព្រៀង | ជាមួយប្រទេស | កាលបរិច្ឆេទចុះហត្ថលេខា | សុពលភាព | ថវិកាគម្រោង |
|---|---|---|---|---|---|
| I | **គម្រោងក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី** | | | | |
| | **១. អនុស្សារៈនៃការយោគយល់គ្នា/កិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា** | | | | |
| ១ | Project Agreement Between Geotwo Co.,LTD. of the Republic of Korea and The Ministry of Agriculture, Forestry and Fisheries of the Kingdom of Cambodiaon the Project Pilot Project For Establishing Basic data for National Spatial information infrastructure in Cambodia: Establishment of Smart Agricultural Land Management System | Korea | ២៦-០៣-២០២១ | ៣ ឆ្នាំ | |
| ២ | អនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពី Maricul True Industrial Cooperation and Technical Exchanges រវាងរដ្ឋបាលជលផល និងវិទ្យាស្ថាបសាគរសាស្រ្តខេត្តហ្វូចៀន ក្រុមហ៊ុនជលិតកូន ពូជស៊ីរ៉ុងតេងខូអិលធីឌី នៃសាធារណរដ្ឋប្រជាមានិតចិន | ចិន | ១៨-១១-២០២១ | | |
| ៣ | អនុស្សរណៈនៃការយោគយល់គ្នារវាង អគ្គនាយកដ្ឋានកសិកម្មជាមួយសហព័ន្ធសហករណ៍រ៉ៃអែសិនអាល្លឺម៉ង់ (DGRV) ស្តីពីការអភិវឌ្ឍសហគមន៍កសិកម្មដោយអនុលោមតាមច្បាប់ស្តីពីសហគមន៍កសិកម្ម | អាល្លឺម៉ង់ | | ៣ ឆ្នាំ | |
| ៤ | អនុស្សរណៈនៃកិច្ចព្រមព្រៀងបន្តកិច្ចសហប្រតិបត្តិការលើការសិក្សាស្រាវជ្រាវ និង ប្រើប្រាស់ធនធានជីវចម្រុះ | កូរ៉េ និងព្រៃឈើ | | ២០២១-២០២៤ | |
| ៥ | កិច្ចព្រមព្រៀងសហប្រតិបត្តិការស្តីពី ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យ និងសុវត្ថិភាពចំណីអាហារ | ចិន | | ២០២១-២០២២ | |

| | | | | | |
|---|---|---|---|---|---|
| ៦ | អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការវារីវប្បកម្ម និងការផ្លាស់ប្តូរបច្ចេកទេស | វិទ្យាស្ថានស្រាវជ្រាវសាគរសាស្រ្ត ខេត្តហ្វូចៀន ក្រុមហ៊ុនស៊ិនរ៉ុងតេង | ២៤-១១-២០២១ | | |
| ៧ | កិច្ចព្រមព្រៀងគម្រោងស្តីពី "Post Management Project for Forest Restoration and Establishment of Forest Research Facilities in Cambodia" with Korea Ruraln Community Cooperation (KRCC) | Korea | | | |
| ៨ | អនុស្សរណៈនៃការយោគយល់គ្នា ដើម្បីអនុវត្តគម្រោងព្រៃឈើលំហែកម្សាន្តធម្មជាតិ កម្ពុជា-កូរ៉េ ជំហ៊ានទី២ | Korea | | ២០២១-២០២៤ | |
| | **២. អនុស្សរណៈនៃការយោគយល់គ្នា/កិច្ចព្រមព្រៀងដែលស្ថិតក្នុងដំណាក់កាលស្នើសុំ** | | | | |
| ១ | អនុសារអនុស្សរណៈ នៃការយោគយល់គ្នា (MoU) សម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យព្រៃឈើ និង The National Forestry and Grassland Administration (NFGA) | ចិន | កំពុងស្នើ | | |
| ២ | កិច្ចព្រមព្រៀងសហប្រតិបត្តិការស្តីពី Animal and Plant Inspection and Food Safety រវាងកម្ពុជា-ចិន | ចិន | កំពុងស្នើ (៣១-១២-២២) | | |
| II | **គម្រោងក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអាស៊ាន** | | | | |
| ១ | ការអនុម័តយល់ព្រមលើពិធីសារស្តីពីការកែសម្រួលឧបសម្ព័ន្ធទី២ នៃកិច្ចព្រមព្រៀងអាស៊ានបូកបីស្តីពីការត្រៀមបម្រុងអង្ករសង្គ្រោះបន្ទាន់ | សភា | ០៥.១០.២០២១ | | |
| III | **គម្រោងកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌអង្គការអន្តរជាតិ** | | | | |
| | **១. ការចុះកិច្ចព្រមព្រៀងអនុវត្តគម្រោង** | | | | |
| ១ | កម្មវិធីសង្គ្រោះ និងថែរក្សាសត្វព្រៃ | សម្ព័ន្ធនិមិត្តសត្វព្រៃ | ១៥.១១.២០២១ | ២០២២-២០២៤ | ២.៨២៣.៤០០ ដុល្លារអាមេរិក |
| ២ | GCP/CMB/037/LDF-Climate Adaptation and Resilience in Cambodia's Coastal Fishery Dependent Communities | FAO | | ២០២១-២០២៥ | ៤.៣៥០.០០០ ដុល្លារអាមេរិក |
| ៣ | ការពង្រឹងការអភិរក្ស និងគាំពារសុខភាពសត្វព្រៃនៃព្រះរាជាណាចក្រកម្ពុជា | WCPO | ០១.០៣.២០២១ | ២០២១-២០២៣ | ១៣៣.១០៤ ដុល្លារអាមេរិក |
| ៤ | កម្មវិធីនវានុវត្តន៍កសិកម្មប្រកបដោយនិរន្តរភាព | Swiss contact | ០២.០៦.២០២១ | ២០២១-២០២៤ | ១.៤៤៩.០០០ ដុល្លារអាមេរិក |
| ៥ | ពន្យាការអនុវត្តគម្រោង ACIARលេខ SMCN/2016/237 ស្តីពី"Land Suitability Assessment and Site Specific Soil Management for Cambodia Upland" | ACIAR | ១១.០៦.២០២១ | ២០២១-២០២២ (៦ខែ) | ២២.៨៣៨ ដុល្លារអាមេរិក |

| | | | | | |
|---|---|---|---|---|---|
| ៦ | ពន្យាការអនុវត្តគម្រោង ACIARលេខ SMCN/2012/075 ស្តីពី "Management Practices for profitable crop livestock systems for Cambodia and Lao PDR" | ACIAR | ១១.០៦.២០២១ | ២០២១-២០២៤ | None |
| ៧ | លើកកម្ពស់ផលិតផលមាន់ស្រែខ្មែរសម្រាប់មោទណភាពជាតិខ្មែរ | Heifer | ០៧.០៩.២០២១ | ២០២១-២០២៦ | ៣.៧៩២.៤០៩ ដុល្លារអាមេរិក |
| ៨ | សត្វគោដើម្បីកម្ពុជា | គោសប្បុរសដើម្បីកម្ពុជា | ១៦.០៧.២០២១ | ២០២១-២០២៦ | ៧៨៥.០០០ ដុល្លារអាមេរិក |
| ៩ | វិវឌ្ឍនាការនៃប្រព័ន្ធកសិអេកូឡូស៊ី និងស្បៀងអាហារប្រកបដោយសុវត្ថិភាព(ASSET) នៅក្នុងប្រទេសកម្ពុជា | Gret | ១៧.០៩.២០២១ | ២០២១-២០២៥ | ២.៣៨៤.២៩០ EU |
| ១០ | Strengthen Capacity to Control African Swine Fever and other high impact TADs in Asia | FAO | ១២.០៨.២០២១ | ២០២០-២០២៣ | ៣.៧៦៣,១៤៧ ដុល្លារអាមេរិក |
| ១១ | កម្មវិធីអភិបាលកិច្ចធនធានធម្មជាតិ និងកម្មវិធីសេដ្ឋកិច្ចប្រកបដោយ បរិយាប័ន្ន | Oxfam | ១៥.១១.២០២១ | ២០២១-២០២៤ | ៩.៣៨៦.២១៦ ដុល្លារអាមេរិក |
| ១២ | Implementation of Codex standards of support containment and reduction of foodborne antimicrobial resistance (AMR) | FAO | ២៦.១០.២០២១ | ២០២១-២០២៦ | ១០.០០០.០០០ ដុល្លារអាមេរិក |
| ១៣ | Technical assistance to producers and suppliers on enhancing production capacity to engage with HGSF | FAO | ២៥.០៦.២០២១ | ២០២១-២០២៣ | ៤៤៤.៨៩០ ដុល្លារអាមេរិក |
| | **សរុប៖ ១៣** | | | | **៣៥.៥០១.០០៤ ដុល្លារអាមេរិក**<br>**២.៣៨៤.២៩០EU** |
| IV | **២. ការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU)** | | | | |
| ១ | គម្រោង ACIAR-CROP/2019/145 ស្តីពី "បច្ចេកទេសគ្រប់គ្រងស្មៅ សម្រាប់ ប្រព័ន្ធដាំដុះដំណាំនៅវាលទំនាបដោយម៉ាស៊ីន និងព្រោះនៅ ប្រទេសកម្ពុជា និងប្រទេសឡាវ"។ | CARDI | ២២.០១.២០២១ | ២០២១-២០២៥ | ២.០៣៩.៩៩៧ ដុល្លារអាមេរិក |
| ២ | គម្រោងស្តីពី "ការពង្រឹងកិច្ចសហប្រតិបត្តិការសម្រាប់ការស្រាវជ្រាវ កសិកម្ម នវានុវត្តន៍ និងការអប់រំកសិកម្ម ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក" | APAARI | | ២០២០-២០២៣ | ២០.០០០ ដុល្លារអាមេរិក |
| ៣ | ការពង្រឹងការអភិរក្ស និងគាំពារសុខភាពសត្វព្រៃនៃព្រះរាជាណាចក្រកម្ពុជា | WCPO | ០១.០៣.២០២១ | ២០២១-២០២៣ | |

| | | | | | |
|---|---|---|---|---|---|
| ៤ | កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍មនុស្សធម៌ និង សុខុមាលភាពសង្គម ក្នុងបណ្តា ខេត្តនានានៃព្រះរាជាណាចក្រកម្ពុជា | SNV | ០៥.០៨.២០២១ | ២០២១-២០២៣ | |
| | **សរុប៖ I+II+III+IV** | | | | **២.០៥៩.៩៩៧ ដុល្លារអាមេរិក** |

## I. កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា

### ក. កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) គឺជាកម្មវិធីរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ដែលមានរយៈពេល៧ឆ្នាំ ដោយទទួលបានការគាំទ្រហិរញ្ញប្បទានពី មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD)។ គោលដៅអភិវឌ្ឍន៍រួមនៃកម្មវិធី ASPIRE គឺដើម្បីកាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុដល់គ្រួសារកសិករក្រីក្រ និងជនងាយរងគ្រោះចំនួន ១៤៤ ០០០គ្រួសារ ដោយបង្កើនតម្លៃផលិតកម្មកសិកម្មជាមធ្យម ២០% និងតម្លៃទ្រព្យសម្បត្តិគ្រួសារ ២៥%។

ការអនុវត្តកម្មវិធីរយៈពេលជាង ៦ឆ្នាំកន្លងមកនេះ សម្រេចបានលទ្ធផលជារួម (១).គាំទ្រគ្រួសារកសិករបានចំនួន១៤៨ ២៣០គ្រួសារ ឬស្មើនឹង ១០៣%នៃគ្រួសារគោលដៅ (២).បង្កើនតម្លៃទ្រព្យសម្បត្តិគ្រួសារកសិករគោលដៅពី ១ ៤៥៣ដុល្លារ នៅឆ្នាំ២០១៨ ដល់ ២ ០៥៥ដុល្លារ នៅឆ្នាំ២០២១ ពោលគឺកើនបានចំនួន ៤១% និងបង្កើនតម្លៃផលិតកម្មកសិកម្មរបស់គ្រួសារកសិករគោលដៅពី ១ ២០៦ដុល្លារ នៅឆ្នាំ២០១៨ ដល់ ១ ៤៤៨ដុល្លារ នៅឆ្នាំ២០២១ ពោលគឺកើនឡើងបានចំនួន ១៨%។ ដោយឡែក លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២១ រួមមាន៖

<u>សមាសភាគទី១៖ ការអភិវឌ្ឍនិងអនុវត្តគោលនយោបាយ</u>

- បញ្ចប់ការសិក្សាស្តីពីផលិតភាពកសិកម្មកម្ពុជា ផ្តោតលើបញ្ហាប្រឈម និងទិសដៅគោលនយោបាយ (Cambodia Agriculture Productivity: Challenges and Policy Directions)
- បាននិងកំពុងធ្វើបច្ចុប្បន្នភាពស្តីពីគោលនយោបាយផ្សព្វផ្សាយកសិកម្ម
- បាននិងកំពុងសិក្សាស្តីពីកាផ្តល់ថវិកាសម្រាប់សេវាកម្មផ្សព្វផ្សាយកសិកម្មនាពេលអនាគត
- បង្កើតកម្មវិធី App ស្តីពីការបញ្ចូលវិធីសាស្ត្រវាស់វែងការអនុវត្តថវិកាកម្មវិធី ក្នុងការធ្វើឱ្យប្រសើរឡើងនៃប្រព័ន្ធតាមដាន (ASPIRE MIS) និងវាយតម្លៃថវិកាកម្មវិធី (MAFF PME Online)។

<u>សមាសភាគទី២៖ ការអភិវឌ្ឍសមត្ថភាពសម្រាប់ផ្នែកសេវាផ្សព្វផ្សាយ</u>

- បង្កើតកសិដ្ឋានបង្ហាញនិងផ្តល់វិញ្ញាបនបត្រ CamGAP លើកសិដ្ឋានបន្លែនិងផ្លែឈើ ព្រមទាំង បង្ហាញអំពីប្រព័ន្ធធានាដែលមានការចូលរួម Participatory Guarantee System (PGS)
- ដាំពង្រីកពូជដំឡូងមី KU-៥០ លើផ្ទៃដី ១៥ហិកតា នៅកសិដ្ឋានផលិតគ្រាប់ពូជដំណាំចំការលើ
- គាំទ្រសហគមន៍កសិកម្ម តាមរយៈការផ្តល់ពូជ គាំទ្របច្ចេកទេស និងការគ្រប់គ្រងដំឡូងមី ដែលមិនមានជំងឺម៉ូសាអ៊ិច
- អភិវឌ្ឍន៍មូលដ្ឋានគេហទំព័រសម្រាប់កម្មវិធី e-Learning ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដល់ភ្នាក់ងារផ្សព្វផ្សាយឃុំ
- បាននិងកំពុងសិក្សាអំពីតំបន់សក្តានុពលសម្រាប់ការជំរុញផលិតកម្មដំណាំអាទិភាព
- បាននិងកំពុងអភិវឌ្ឍប្រព័ន្ធឌីជីថលគ្រប់គ្រងទិន្នន័យផលិតកម្មដំណាំ។

សមាសភាគទី ៣: ជំរុញសេវាកម្មផ្សព្វផ្សាយ

- បង្កើតបណ្តុំអាជីវកម្មបានចំនួន ៥៨៧បណ្តុំ មានសមាជិកសរុបចំនួន ២៣ ២៩២នាក់ ក្នុងនោះ ស្ត្រីមានចំនួន ៨ ៤៦៣នាក់ ដែលបណ្តុំអាជីវកម្មទាំងនោះផ្តោតលើផលិតកម្មកសិកម្មចំនួន ៣៣មុខ រួមមាន៖ ស្រូវ ស្រូវពូជ បន្លែ ឪឡឹក ស្លឹកគ្រៃ ផ្សិត ម្ទេស ផ្លែប៉ិរ ទុរេន មៀន ត្រសក់ផ្អែម ក្រូចថ្លុង សារម៉ាវ ពោត ស្វាយចន្ទី ស្វាយ ដំឡូងមី ដំឡូងជ្វា អំពៅ កូនឈើ កាហ្វេ ឬស្សីផ្អែម ទឹកឃ្មុំ ជ្រូក គោ ពពែ មាន់ ទា ក្តាម បង្គា ត្រី កង្កែប និងចង្រិត
- សម្របសម្រួលរៀបចំកិច្ចព្រមព្រៀងស្តីពីផលិតកម្មតាមកិច្ចសន្យាបានជាង២០កិច្ចសន្យា ដែលមានតម្លៃសរុបជាង ១៥លានដុល្លារអាមេរិច
- ផ្តល់អគារប្រមូលផលផ្តុំផលិតផលកសិកម្ម បានចំនួន ១៦៦កន្លែង និងផ្ទះសំណាញ់បានចំនួន ៩៣
- បង្កើតប្រព័ន្ធតាមដាននិងវាយតម្លៃនិងព័ត៌មានសម្រាប់គ្រប់គ្រង ដើម្បីប្រមូលទិន្នន័យស្តីពីការអនុវត្តសេដ្ឋកិច្ច ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការចុះបញ្ជីកសិករ អ្នកទទួលផល បណ្តុំអាជីវកម្ម និងការវាយតម្លៃបណ្តុំអាជីវកម្ម។

សមាសភាគ ៤ - ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្នែកកសិកម្មដែលមានភាពធន់ទ្រាំនឹងអាកាសធាតុ

- គាំទ្រគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុដល់កសិករ ចំនួន ២០ ៣៩៣គ្រួសារ ដែលមានលទ្ធភាពទទួលបានទឹកស្រោចស្រពលើផ្ទៃដីសរុប ២០ ៣៩៣ហិកតា
- វាយតំលៃផែនការអភិវឌ្ឍន៍យុំរយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគឃុំរយៈពេល ៣ឆ្នាំ ស្តីពីការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងបញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ចំពោះការអនុវត្តកម្មវិធីចំការ App តាមរយៈគម្រោងការបង្កើនយ៉ាងរហ័សនូវកម្រិតជីវភាពគ្រួសារកសិករដែលមានទំហំផលិតកម្មតូច ដោយប្រើប្រាស់ព័ត៌មានវិទ្យា សំដៅឆ្លើយតបនឹងបញ្ហា COVID-19 នៅកម្ពុជា (RUSH-IT Rapid Upscaling for Smallholder Households through Information Technology)

- កសិករចំនួន ៤៤ ០០០នាក់ (ស្ត្រីមានចំនួន ២៩% និងអាយុពី ១៧-២៩ឆ្នាំ ចំនួន ៣៩%) បានចុះឈ្មោះក្នុងកម្មវិធី Chamk App
- កសិករចំនួន ៤ ៤៣០នាក់ (ស្ត្រី ៣១%) បានប្រើការហៅទូរស័ព្ទ និងប្រើបណ្តាញពិភាក្សាព័ត៌មានបច្ចេកទេសកសិកម្ម ដើម្បីទទួលបានព័ត៌មានផ្នែកផ្សព្វផ្សាយបច្ចេកទេសលើដំណាំ និងបសុសត្វ
- កសិករចំនួន ២ ៨១៣នាក់ (ស្ត្រី ២១%) បានប្រើប្រាស់បណ្តាញទីផ្សារ ដើម្បីទិញធាតុចូលកសិកម្ម និងបង្កើតទំនាក់ទំនងអាជីវកម្មជាមួយក្រុមហ៊ុនឯកជន
- ចុះឈ្មោះអ្នកផ្គត់ផ្គង់ធាតុចូលចំនួន ៤០នាក់ ក្នុងកម្មវិធី Chamka App ដើម្បីលក់ធាតុចូលកសិកម្មរបស់ពួកគាត់
- គាំទ្រជាធាតុចូលកសិកម្មដល់គ្រួសារកសិករខ្នាតតូចក្រីក្រដែលមាន និងគ្មានប័ណ្ណក្រីក្របានចំនួន ១ ៩០០គ្រួសារ
- កសិករច្រើនជាង ៤ ០០០នាក់ បានទទួលការគាំទ្របច្ចេកទេសលើផលិតកម្មបន្លែ និងមាន់ស្រែ។

## ខ. កសាងសមត្ថភាពបន្សាំតាមរយៈការពង្រីកបច្ចេកវិទ្យាថាមពលកកើតឡើងវិញក្នុងវិស័យកសិកម្ម (S-RET)

S-RET (Renewable Energy Technologies) គឺជាគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងរបស់មូលនិធិអន្តរជាតិសម្រាប់

អភិវឌ្ឍន៍កសិកម្ម (IFAD) ដែលទទួលបាន ការគាំទ្រថវិកាពីមូលនិធិបរិស្ថានពិភពលោក (GEF)។ គោលដៅរបស់គម្រោង គឺធ្វើឱ្យកាន់តែប្រសើរជីវភាពរស់នៅរបស់កសិករក្រីក្រតាមជនបទនៃខេត្តគោលដៅចំនួន៥ គឺខេត្តកំពតកណ្ដាល ព្រៃវែង ស្វាយរៀង និងខេត្តតាកែវ តាមរយៈការពង្រីកឱ្យកាន់តែទូលាយនូវការទទួលយក និងប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ ( RETs) ដើម្បីគាំទ្រការផលិត ការកែច្នៃ និងការធ្វើអាជីវកម្មកសិកម្មរបស់កសិករ។

ទន្ទឹមនឹងនេះ គម្រោងក៏បានពង្រីកទៅខេត្តទាំងអស់ដែលគាំទ្រដោយកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ដែលកម្មវិធីនេះ បាននិងកំពុងអនុវត្តសកម្មភាពនៅខេត្តគោលដៅ ចំនួន ២៥ រាជធានី ខេត្តក្នុងប្រទេសកម្ពុជា។ គម្រោង S-RET មានរយៈពេល ៥ ឆ្នាំ ចាប់ផ្ដើមពីខែតុលា ឆ្នាំ២០១៦ ដល់ ខែធ្នូ ឆ្នាំ២០២១ (រួមទាំងការពន្យាពេល១ ឆ្នាំ) ដោយមានថវិកាសរុបចំនួន ៤,៦ លានដុល្លារអាមេរិក។

ក្នុងឆ្នាំ២០២១នេះ ការអនុវត្តគម្រោង ទទួលបានលទ្ធផល ដូចខាងក្រោម៖

- គម្រោងបានជ្រើសរើសក្រុមហ៊ុនចំនួន ៩ សម្រាប់ធ្វើការសាកល្បង RETs និងក្រុមហ៊ុនចំនួន ៧ សម្រាប់ពង្រីកបច្ចេកវិទ្យាឲ្យសាយភាយតាមរយៈការបង្កើតបណ្ដាញចែកចាយ ការលក់ និងសេវាជួសជុសក្រោយពេលលក់។ ជាលទ្ធផលគម្រោងតម្លើងបាន RETs ចំនួន ៤,២២៨ គ្រឿង ក្នុងនោះរួមមាន (១) ម៉ូទ័របូមទឹកប្រើថាមពលព្រះអាទិត្យចំនួន ១,២៧៨ គ្រឿង ក្នុងខេត្តចំនួន ២៥ (២) ទូភ្ញាស់ស៊ុតមាន់ ប្រើថាមពលព្រះអាទិត្យចំនួន ៣៤២ គ្រឿង ក្នុងខេត្តចំនួន ៧ (៣) ធ្យូងអនាម័យ សម្រាប់ដុតកម្ដៅកូនមាន់ចំនួន ២,២៨៩ កញ្ចប់ ក្នុងខេត្តចំនួន ១៥ (៤) ឧបករណ៍ហាលសម្ងួត ប្រើថាមពលព្រះអាទិត្យចំនួន ១១៧ គ្រឿង ក្នុងខេត្តចំនួន ៦ (៥) ប្រព័ន្ធកម្ដៅទឹកសម្រាប់ត្រាំ និងលាងសម្អាតបន្លែនិងផ្លែឈើ ប្រើថាមពលព្រះអាទិត្យ ចំនួន ១៥ គ្រឿង ក្នុងខេត្តក្រុងចំនួន ៤ (៦) ប្រព័ន្ធដាំបន្លែលើទឹក ប្រើថាមពលព្រះអាទិត្យចំនួន ៧ បណ្ដុំបន្លែ ដែលមានចំនួន ២១ ថ្នាល សម្រាប់សហគមន៍ ក្នុងខេត្តចំនួន ២ (៧) ទូភ្ញាស់ និងចិញ្ចឹមចង្រឹត ប្រើថាមពលព្រះអាទិត្យចំនួន ១៥ គ្រឿង ក្នុងខេត្តស្វាយរៀង (៨) ប្រព័ន្ធសូឡាផ្គួបជាមួយជីវឧស្ម័នសម្រាប់ដំណើរការសត្តឃាតដ្ឋានចំនួន ១០ ទីតាំង ក្នុងខេត្តចំនួន ៧ (៩) ម៉ាស៊ីនកែច្នៃចំណីសត្វ ប្រើថាមពលព្រះអាទិត្យចំនួន ៥៤ គ្រឿង និងប្រអប់ត្រជាក់ ប្រើថាមពលព្រះអាទិត្យ សម្រាប់រក្សាទុកវ៉ាក់សាំងចំនួន ១០១ គ្រឿង ក្នុងខេត្តចំនួន ៦ ។
- គម្រោងក៏បានជ្រើសរើសយកកម្មវិធីឡជីវឧស្ម័នជាតិ ដើម្បីតម្លើងឡជីវឧស្ម័ន ប្រភេទនវានុវត្តន៍ចំនួន ២,៨៦២ កន្លែង និងសាងសង់រោងជីកំប៉ុស្ត ចំនួន ៤៥០ កន្លែង សម្រាប់កសិករខ្នាតតូចដើម្បីប្រើប្រាស់ក្នុងការងារកសិកម្ម។
- គម្រោងបានរៀបចំសិក្ខាសាលាបូកសរុបលទ្ធផល និងបិទបញ្ចប់គម្រោងដោយជោគជ័យ កាលពីថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០២១ គម្រោងបានតម្លើង RETs ចំនួន ៧ ០៩០ គ្រឿង សម្រាប់គ្រួសារកសិករខ្នាតតូច ដែលបានការចាប់អារម្មណ៍ខ្ពស់ និងពេញចិត្តវិនិយោគលើការប្រើប្រាស់បច្ចេកវិទ្យាទាំងនេះ ហើយកសិករចំនួន ១៧ ៨១១ (៨ ៦៥២ ជាស្ត្រី) បានទទួលផលពីការទទួលប្រើប្រាស់បច្ចេកវិទ្យាប្រើថាមពលកកើតឡើងវិញ។ ជាមួយគ្នានេះ គម្រោងបានរៀបចំគោលនយោបាយស្ដីពី " ការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញក្នុងវិស័យកសិកម្ម ឆ្នាំ២០២១-២០៣០ " ។

### គ. គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ដំណាក់២

គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាបដំណាក់ទី២ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្ដល់ហិរញ្ញប្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី(ADB) នាថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ មានថវិកាសរុប ៦៦លានដុល្លារអាមេរិក ដែលក្នុងនោះធនាគារអភិវឌ្ឍន៍អាស៊ីបានផ្ដល់ហិរញ្ញប្បទាន ៥០

លានដុល្លារអាមេរិក មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្មបានផ្តល់ហិរញ្ញប្បទាន១០លាន ដុល្លារអាមេរិក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា មានចំនួន ០៦លានដុល្លារអាមេរិក ។

គម្រោងមានរយៈពេលអនុវត្ត០៥ឆ្នាំ ចាប់ផ្តើមអនុវត្តពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ហើយនឹងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។ គម្រោងបានអនុវត្តក្នុងខេត្តគោលដៅចំនួន០៧ រួមមាន ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ និងខេត្តព្រៃវែង ស្រុកគោលដៅមានចំនួន ៣៧ស្រុក ឃុំគោលដៅមានចំនួនសរុប២៧០ឃុំសង្កាត់។ រចនាសម្ព័ន្ធរបស់គម្រោងមានពីរផ្នែកៈ(១)ភ្នាក់ងារប្រតិបត្តិគម្រោង ដែលមានអង្គភាពសម្របសម្រួលការអភិវឌ្ឍ (DCU) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង(២)លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់ក្រសួងមហាផ្ទៃ។

លទ្ធផលរំពឹងទុកនៃគម្រោង រួមមាន (១)ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទគាំទ្រផលិតភាពកសិកម្ម និងកែលម្អជីវភាពដោយបង្កើន សមត្ថភាពគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ (២)កែលម្អបរិយាកាសសម្រាប់ការបង្កើនផលិតភាពកសិកម្ម ពិពិធកម្មកសិកម្ម និងភាពធន់នឹងអាកាសធាតុសម្របសម្រួលអនុវត្តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដែលមានសកម្មភាពគាំទ្រខ្សែច្រវ៉ាក់ផលិតកម្មតម្លៃ និងទំនាក់ទំនងទីផ្សារ ការបង្កើនលទ្ធភាពទទួលបានព័ត៌មានកសិកម្ម និងទិន្នន័យទីផ្សារ(ព័ត៌មានទីផ្សារជនបទ និងខ្សែសង្វាក់ផលិតកម្ម ដំណាំបន្លែ ស្រូវ ចិញ្ចឹមមាន់ និងការចិញ្ចឹមត្រី និង(៣)ការពង្រឹងការគ្រប់គ្រងគម្រោងអនុវត្តរួមគ្នាដោយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការចំណាយថវិកាឆ្នាំ២០២១នេះ អង្គភាពសម្របសម្រួលការអភិវឌ្ឍ(DCU) បានអនុវត្តនូវសកម្មភាព និងចំណាយថវិកាចំនួន២ ៦៤៥ ០៨៧ ដុល្លារអាមេរិក (៣៥%) ជាថវិកាកម្ចីហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងការចំណាយថវិកាបដិភាគរបស់រាជរដ្ឋាភិបាលមានចំនួន៦៩ ៥៥៥(១៧%)។ សម្រាប់លេខាធិការដ្ឋានគណៈ-កម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានចំណាយថវិកាចំនួន ៥ ៩១៦ ៣៤៥ ដុល្លារអាមេរិក(១០,៥៧%) ជាកម្ចីហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងថវិកាបដិភាគរបស់រាជរដ្ឋា-ភិបាលកម្ពុជាមានចំនួន ១៤៣ ៧៦០ ដុល្លារអាមេរិក(១៣,១៣%)។ ជារួម ថវិកាចំណាយសរុបរបស់គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប ដំណាក់កាលទី២ ក្នុងឆ្នាំ២០២១ មានចំនួន៨ ៧៧៤ ៧៤៦ ដុល្លារអាមេរិក ស្មើ១៣,២៩% និងការចំណាយគិតចាប់ពីគម្រោងចាប់ផ្តើមអនុវត្ត មកដល់ពេលបច្ចុប្បន្ន បានចំណាយថវិកាចំនួន២៥ ៤៨០ ៣១០ ដុល្លារអាមេរិក ៣៨,៦០%។

ចំពោះផ្នែកកសិកម្ម ការអនុវត្តគម្រោងជាលក្ខណៈរូបវន្តក្នុងឆ្នាំ២០២១ សម្រេចបាន ៧២% ដោយប្រើប្រាស់ពេលវេលាអស់៧៦% និងការអនុវត្តគម្រោងជាលក្ខណៈរូបវន្តរបស់គម្រោងជារួម មកដល់ពេលបច្ចុប្បន្នសម្រេចបាន៦៦% (សមាសភាគ១ស្មើនឹង៦៣% សមាសភាគ២ស្មើនឹង ៧២% និងសមាសភាគ៣ស្មើនឹង៦៥%)។ ផ្នែកកសិកម្ម កសិករដែលទទួលផលប្រយោជន៍ដោយផ្ទាល់ពីគម្រោងមានចំនួន២៩ ៨៥៣គ្រួសារ សរុបសមាជិកគ្រួសារមានចំនួន១២៥ ៣៨២នាក់។ គណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កសិករដែលទទួលផលប្រយោជន៍ដោយផ្ទាល់ពីគម្រោងមាន១៧ ៥៤៣គ្រួសារ ជាក្រុមកែលម្អជីវភាព និង២៨ ៧១៥ គ្រួសារ ពីគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងស្រោចស្រព (តាំងពីចាប់ផ្តើមគម្រោងមកដល់បច្ចុប្បន្ន) សរុបសមាជិកគ្រួសារទាំងអស់មានចំនួន១៩៤ ៣៧២នាក់។

### ឃ. គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយនាគរៈបរិស្ថាន

(Climate-Friendly Agribusiness Value Chains Sector Project-CFACV)

គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន(CFAVC) បានជួយគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ការប្រកួតប្រជែងនៃខ្សែច្រវាក់តម្លៃកសិពាណិជ្ជកម្មនៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ តាមដងទន្លេមេគង្គនៃច្រករបៀងសេដ្ឋកិច្ច ភាគខាងត្បូងរបស់អនុតំបន់ទន្លេមេគង្គ (GMS) និងនៅខេត្តកំពត និងតាកែវ តាមបណ្តោយច្រករបៀងសេដ្ឋកិច្ច ឆ្នេរប៉ែកខាងត្បូង។ គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន(CFAVC) ដែលមានក្រសួងចំនួន៣ ជាភ្នាក់ងារប្រតិបត្តិគម្រោង (១)ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២) ក្រសួងធនធានទឹក និងឧតុនិយម និង(៣)ក្រសួងអភិវឌ្ឍន៍ជនបទ ព្រមទាំងមានភ្នាក់ងារអនុវត្តគម្រោងថ្នាក់ខេត្តចំនួន៤ខាងលើ។

គម្រោងនេះជួយលើកកម្ពស់ភាពធន់ទ្រាំនឹងអាកាសធាតុ ដោយគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្មសំខាន់ៗ និងខ្សែច្រវាក់ផលិតកម្មដំណាំស្រូវ ពោត ដំឡូងមី និងស្វាយ ដោយជួយបង្កើនផលិតភាព និងពិពិធកម្មដំណាំ ការកែលម្អសមត្ថភាពឃ្លាំងស្តុកទុកដាក់ ការកែច្នៃ និងការធ្វើតេស្តគុណភាព និងសុវត្ថិភាពផលិតផល ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ថាមពលព្រះអាទិត្យ និងជីវថាមពល។ គម្រោងនឹងជួយពង្រឹងសមត្ថភាពបច្ចេកទេសកសិកម្មវៃឆ្លាត(CSA) និងបង្កើតបរិយាកាសនៃគោលនយោបាយសម្រាប់ផលិតកម្មកសិកម្មប្រកបដោយភាតរៈបរិស្ថាន និងបង្កើនប្រាក់ចំណូលដល់កសិករ។

គម្រោងនេះ មានរយៈពេល៦ឆ្នាំ (ខែតុលា ២០១៨ - ខែកញ្ញា២០២៤) ដោយមានថវិកាគាំទ្រសរុបចំនួនប្រមាណ១៤១,០៤ លានដុល្លារអាមេរិក ក្នុងនោះឥណទានសម្បទានរបស់ADB ចំនួន៩០លានដុល្លារអាមេរិក ឥណទាន សម្បទានរបស់មូលនិធិអាកាសធាតុបៃតង Green Climate Fund (GCF) ១០លានដុល្លារអាមេរិក ហិរញ្ញប្បទានឥត សំណងរបស់(GCF) ៣០លានដុល្លារអាមេរិក ការចូលរួមពីអ្នកទទួលផល (Beneficiaries) ៣,៦៦លានដុល្លារអាមេរិក និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួន៧,៣៨លានដុល្លារអាមេរិក។ ផ្អែកតាម Project Administrative Manual (PAM) ថវិកាទាំង១៤១,០៤លានដុល្លារអាមេរិកនេះ ត្រូវបានបែងចែកឱ្យអនុវត្តតាមវិស័យ នៃក្រសួងទាំង៣គឺក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានថវិកាចំនួន៥៦ ៣៤៣ ៨៤០ដុល្លាអាមេរិក ក្រសួងធនធានទឹក និងឧតុនិយម ៤៤ ១៨១ ១៣០ដុល្លាអាមេរិក ក្រសួងអភិវឌ្ឍន៍ជនបទមានចំនួន ៣៦,៣៤៩ ៦០៧ដុល្លាអាមេរិក និងថវិកាបម្រុងចំនួន ៣ ១៦៥ ៤២៣ដុល្លារអាមេរិក។

គម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថានអនុវត្តសម្រេចបានប្រមាណ៤៣% ដោយគិតពីចាប់ផ្តើមអនុវត្តគម្រោងមកដល់ឆ្នាំ២០២១។ សម្រាប់ឆ្នាំ២០២១នេះ គម្រោងអនុវត្តសម្រេចបានប្រមាណ ៣០% ធៀបនឹងផែនការសកម្មភាព និងថវិកាឆ្នាំ២០២១។

ក្នុងឆ្នាំ២០២១នេះ គម្រោងសម្រេចលទ្ធផលសំខាន់ៗរួមមាន៖

- គម្រោងនេះបានគ្រោងគាំទ្រសាងសង់ឃ្លាំងដាក់កសិផលដល់សហគមន៍កសិកម្ម សរុបចំនួន៨០ឃ្លាំង ក្នុងកំឡុងពេលអនុវត្តគម្រោង និងត្រូវបំពាក់ដោយម៉ាស៊ីនសម្ងួតប្រភេទ Flatbed Dryers មួយឃ្លាំងស្តុកទំហំ ១០០តោន ដែលមានចំនួនសរុប៤៤។
- កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងឃ្លាំងសម្រាប់សហគមន៍កសិកម្មចំនួន ៥៥ ត្រូវបានរៀបចំ និងចុះហត្ថលេខា រវាងគណៈកម្មាធិការគ្រប់គ្រងរបស់សហគមន៍កសិកម្ម និងប្រធានគ្រប់គ្រងគម្រោងថ្នាក់ខេត្ត នៅក្នុងខេត្តគោលដៅនៃគម្រោង
- ក្នុងឆ្នាំ២០២១នេះ ជាលទ្ធផលទាក់ទងនឹងការសាងសង់ឡជីវឧស្ម័ន និងរោងជីកំប៉ុស បានស្វែងរកអ្នកជាវឡជីវឧស្ម័ន និងរោងជីកំប៉ុស្ត បានចំនួន២៨៤នាក់ ដែលក្នុងនោះកសិករជាវឡជីវឧស្ម័ន មានចំនួន ១៦០នាក់ និងរោងជីកំប៉ុស្តមានចំនួន១២៤នាក់ នៅទូទាំងខេត្តគោលដៅរបស់គម្រោង។

- បានរៀបចំសិក្ខាសាលាថ្នាក់ឃុំ និងខេត្តបានធ្វើឡើងនៅក្នុងខេត្តគោលដៅ ដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីការអនុវត្តការផ្សព្វផ្សាយ និងទីផ្សារសម្រាប់អតិថិជនសក្តានុពលលើឡជីវឧស្ម័ន និងរោងជីកំប៉ុស និងចែករំលែកមេរៀនស្តីពីជីកាកសំណល់ពីឡជីវឧស្ម័ន។ សិក្ខាកាមចំនួន៥៧នាក់/១៥នាក់ជាស្ត្រី បានចូលរួមក្នុងសិក្ខាសាលានេះ។

## ង. កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

(Climate-Resilient Rice Commercialization Sector Development- Rice-SDP)

កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice-SDP) ត្រូវបានអនុម័តដោយធនាគារអភិវឌ្ឍន៍អាស៊ី នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ និងដាក់ឱ្យដំណើរការនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលមានថវិកាសរុបចំនួន ៨៧,៨៤ លានដុល្លារអាមេរិក។ កម្មវិធីទទួលបានកម្ចី២ប្រភព [កម្ចីពីមូលនិធិអភិវឌ្ឍន៍អាស៊ី (ADF) ចំនួន ៥៥ លាន ដុល្លារអាមេរិក និងកម្ចីពីមូលនិធិសម្រាប់យុទ្ធសាស្ត្រអាកាសធាតុ (SCF) ចំនួន ៥លានដុល្លារអាមេរិក ជំនួយឥតសំណង២ប្រភព [ជំនួយពីកម្មវិធីសន្តិសុខស្បៀងនិងកសិកម្មសកល (GAFSP) ចំនួន១៤,៦លានដុល្លារអាមេរិក និងជំនួយពី SCF ចំនួន៤,៥ លានដុល្លារអាមេរិក] និងបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជាចំនួន ៨,៣៣លានដុល្លារ អាមេរិក។ កម្មវិធីនេះបានដំណើរការអនុវត្តសកម្មភាពនៅខេត្តគោលដៅ ចំនួន០៣ គឺ ខេត្តបាត់ដំបង ព្រៃវែង និងខេត្តកំពង់ធំ។ ចំពោះថវិកាដែលគាំទ្រដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តកម្មវិធីនេះ មានចំនួនសរុប ១២,៦៧៥ លានដុល្លារអាមេរិក។

ក្នុងឆ្នាំ២០២១នេះ កម្មវិធីសម្រេចបានលទ្ធផល ដូចខាងក្រោម៖

- បានបញ្ចប់ការងារវិភាគប្រព័ន្ធ-កេ្សត្របរិស្ថានឃុំ )CAEA) និងបានបញ្ជូនទិន្នន័យទាំងនោះទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីរៀបចំផែនការប្រើប្រាស់ដីថ្នាក់ឃុំ។
- បានបញ្ចប់ការផលិត និងបោះពុម្ពផែនទីប្រព័ន្ធកេ្សត្រ-បរិស្ថានដំណាំស្រូវ ចំណាត់ថ្នាក់ដី និងប្រើប្រាស់ដីសម្រាប់ខេត្តគោលដៅទាំង០៣។
- បានបញ្ចប់ការអភិវឌ្ឍ និងដំឡើងប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានកសិកម្ម (FSMIS) ហើយបានបញ្ចូលទិន្នន័យ CAEA ទាំង៩០ឃុំ និងឯកសារផ្សព្វផ្សាយកសិកម្ម ទៅក្នុងប្រព័ន្ធនោះផងដែរ។ ក្នុងនោះគម្រោងក៏បានបញ្ចូលទិន្ន័យ CAEA ដែលបានសិក្សាពីមុនចំនួនជាង ៤០០ ឃុំ ទៅក្នុងប្រព័ន្ធនេះ ផងដែរ។
- ចុះកិច្ចសន្យាសាងសង់ឡសម្ងួត និងឃ្លាំងស្តុកគ្រាប់ពូជស្រូវនៅថ្ងៃ២៩ ខែកញ្ញា ឆ្នាំ២០២០ សម្រាប់ស្ថានីយកសិកម្មចំនួន ២ នៅខេត្តបាត់ដំបង និងព្រៃវែង។ ត្រឹមថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២១ ការងារសាងសង់ឡសម្ងួត និងឃ្លាំងស្តុកគ្រាប់ពូជស្រូវសម្រេចបាន៨៧% នៅខេត្តព្រៃវែង និង៧៦% នៅខេត្តបាត់ដំបង។
- ត្រឹមបំណាច់ ឆ្នាំ២០២០ អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះកិច្ចសន្យាសរុបចំនួន១៥ ជាមួយស្ថានីយកសិកម្មដើម្បីផលិតគ្រាប់ពូជស្រូវចុះបញ្ជី និងបានចុះកិច្ចសន្យាសរុបចំនួន៤៤ ជាមួយសហគមន៍កសិកម្មដើម្បីផលិតគ្រាប់ពូជស្រូវវិញ្ញាបនប័ត្រក្នុងខេត្តគោលដៅទាំង៣។ ជាលទ្ធផល អង្គភាពបានចុះកិច្ចសន្យាជាមួយបណ្តាស្ថានីយកសិកម្មផលិតគ្រាប់ពូជស្រូវចុះបញ្ជីសរុបចំនួន ២៣០ តោនលើផ្ទៃដីដាំដុះសរុបចំនួន៩៨ ហិកតា និងជាមួយបណ្តាសហគមន៍កសិកម្មផលិតគ្រាប់ពូជស្រូវវិញ្ញាបនប័ត្រសរុបចំនួន៦០០ តោន លើផ្ទៃដីដាំដុះសរុបចំនួន២៤៦ ហិកតា។
- បានរៀបចំចុះអង្កេតអំពី ការប្រើប្រាស់ពូជស្រូវរបស់កសិករ ការបាត់បង់ក្រោយពេលប្រមូលផលស្រូវ និងការទទួលបានការប្រឹក្សាផ្នែកបច្ចេកទេសពីអ្នកផ្គត់ផ្គង់សម្ភារៈកសិកម្ម។

- បានបញ្ចប់ការផលិត និងបោះពុម្ពសៀវភៅ TIPs មានចំនួន៨ប្រធានបទបច្ចេកទេស សរុបបានចំនួន ៨០០០ក្បាល។
- បានអនុវត្តសកម្មភាពកសាងសមត្ថភាពបានចំនួន៣១៦ដែលមានអ្នកចូលរួមសរុបចំនួន១៧ ៩៩៨នាក់ក្នុងនោះមានស្ត្រីចំនួន៨ ២១៣នាក់ស្មើ៤៦%។

**ច.គម្រោងពិពិធកម្មកសិកម្មកម្ពុជា** ( WB )

គម្រោងពិពិធកម្មកសិកម្មកម្ពុជាត្រូវបានរៀបចំនិងអនុវត្ត ដោយមានការគាំទ្រហិរញ្ញប្បទានឥណទានចំនួន ១០១,៦៧ លានដុល្លារអាមេរិក ក្នុងនេះ ពីធនាគារពិភពលោកចំនួន ៩១,៦៧លានដុល្លារអាមេរិក និងថវិកាបដិភាគពីរាជរដ្ឋាភិបាលកម្ពុជាចំនួន ១០លានដុល្លារអាមេរិក ដែលកិច្ចព្រមព្រៀងហិរញ្ញប្បទានឥណទានត្រូវបានចុះហត្ថលេខានៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩។ គម្រោងនេះមានគោលបំណងជួយសម្របសម្រួលដល់ការធ្វើពិពិធកម្មខ្សែច្រវាក់តម្លៃកសិកម្មនៅក្នុងតំបន់គោលដៅគម្រោង ព្រមទាំងឆ្លើយតបភ្លាមៗ និងប្រកបដោយប្រសិទ្ធភាពចំពោះការសង្គ្រោះបន្ទាន់ក្នុងករណីមានវិបត្តិ និងមានសមាសភាគសំខាន់ៗចំនួន៥ ដែលត្រូវបាននិងកំពុងចូលរួមអនុវត្តដោយក្រសួងពាក់ព័ន្ធចំនួន៤ គឺ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹកនិងឧតុនិយម។

ចំពោះលទ្ធផលនៃការអនុវត្តគម្រោង ក្នុងឆ្នាំ២០២១នេះ មានដូចខាងក្រោម៖

**សមាសភាគទី១** ៖ ការជំរុញពិពិធកម្មកសិកម្មនិងការផ្តល់ហិរញ្ញប្បទានតាមរយៈកញ្ចប់ជំនួយនិងកម្ចី ត្រូវបានអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសកម្មភាពចម្បង គឺ ការគាំទ្រដល់សហគមន៍កសិកម្ម និងក្រុមផលិត នូវទុនវិនិយោគបំពេញបន្ថែម (Matching Grant) និងឱកាសទទួលបានឥណទាន (Credit Line) ពីគ្រឹះស្ថានហិរញ្ញវត្ថុ ចូលរួមអនុវត្តគម្រោង (PFI) តាមរយៈសំណើពិពិធកម្មកសិកម្ម/សំណើធុរកិច្ច (DPr/BPr) និងផែនការពិពិធកម្មកសិកម្ម/ ផែនការធុរកិច្ច (DPl/BPl) ដែលបានរៀបចំឡើងដោយសហគមន៍កសិកម្ម ឬក្រុមផលិត។ គិតត្រឹមខែធ្នូ ឆ្នាំ២០២១នេះ ក្រុមអ្នកផ្តល់សេវាបច្ចេកទេស (TSP) បានជួយគាំទ្រដល់សហគមន៍កសិកម្មចំនួន៥៩ ក្នុងការរៀបចំសំណើពិពិធកម្ម កសិកម្មចំនួន៥៩ រួមជាមួយសំណើកសិធុរកិច្ចចំនួន៦៨ ដែលក្នុងនោះ សំណើពិពិធកម្មចំនួន៣៥ ត្រូវបានគណកម្មការ អនុម័តឱ្យបន្តរៀបចំផែនការពិពិធកម្មនិងផែនការកសិធុរកិច្ច។ ជាមួយនេះដែរ ផែនការពិពិធកម្មចំនួន៧ ត្រូវបាន គណកម្មការប្រឹក្សាយោបល់និងអនុម័តអនុញ្ញាតឱ្យទទួលបានហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ។

**សមាសភាគទី២** ៖ ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវបានអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹកនិងឧតុនិយម ក្នុងនោះ សកម្មភាពសំខាន់ គឺការជួយធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈជនបទដូចជា ១).ការស្តារប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ និង ២).ការកែលម្អផ្លូវជនបទដោយក្រាលកៅស៊ូប្រភេទ DBST។ ផ្លូវជនបទ និងប្រព័ន្ធធារាសាស្ត្រដែលបានលើកឡើងនៅក្នុងផែនការពិពិធកម្មចំនួន ៧ ដែលត្រូវបានអនុម័តដោយជោគជ័យពីគណកម្មការប្រឹក្សាយោបល់និងអនុម័ត (AEC) នឹងត្រូវបានសិក្សាលម្អិតសម្រាប់កែលម្អ និងស្តារនៅក្នុងឆ្នាំ២០២២នេះ។

**សមាសភាគទី៣** ៖ ការកែលម្អប្រព័ន្ធព័ត៌មានកសិកម្មនិងការគ្រប់គ្រង និងត្រួតពិនិត្យគុណភាព ដែលត្រូវបានអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងនោះ សកម្មភាពសំខាន់ គឺ ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានកសិកម្ម ទីផ្សារកសិកម្ម ការអនុវត្តប្រព័ន្ធអនាម័យនិងភូតគាមអនាម័យ ការគ្រប់គ្រងការកែច្នៃនិងសុវត្ថិភាពចំណីអាហារ។ នៅក្នុងឆ្នាំ២០២១នេះ ក្រុមការងារគម្រោងបានបញ្ចប់សេចក្តីព្រាងកម្រងព័ត៌មានទីប្រឹក្សាជាតិ និងអន្តរជាតិ (Consultancy Profile for ITA and NTA) សម្រាប់ជួយលើការអនុវត្តការងារពាក់ព័ន្ធនឹងព័ត៌មានកសិកម្ម

អនាម័យនិងភូតគាមអនាម័យ ការកែច្នៃនិងសុវត្ថិភាពចំណីអាហារ និងបានផ្សព្វផ្សាយការយល់ដឹងការងារអនាម័យនិងភូតគាមអនាម័យនិងសារៈសំខាន់នៃការងារត្រួតពិនិត្យភូតគាម អនាម័យ និងស្តង់ដារអន្តរជាតិស្តីពីវិធានភូតគាមអនាម័យ រួមទាំងលក្ខខណ្ឌតម្រូវក្នុងការនាំចេញផលិតផលកសិកម្ម ដល់មន្ត្រីជំនាញនៃមន្ទីរកសិកម្មក្នុងខេត្តគោលដៅចំនួនប្រាំមួយជាជំហានដំបូង។ បន្ថែមលើនេះ ក្រុមការងារគម្រោងបានពិភាក្សាស៊ីជម្រៅជាមួយអង្គការ UNIDO ក្នុងការពិនិត្យលទ្ធភាពពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដើម្បីប្រឹក្សាយោបល់អំពី ការរៀបចំរួមគ្នានូវគោលនយោបាយសុវត្ថិភាពចំណីអាហារនេះ។

**សមាសភាគទី៤** ៖ ការគ្រប់គ្រង ការសម្របសម្រួល និងការត្រួតពិនិត្យនិងវាយតម្លៃគម្រោង ដែលនៅក្នុងឆ្នាំ ២០២១ ក្រុមការងារគម្រោងបានចុះពិនិត្យតាមដានការរៀបចំសំណើពិពិធកម្មកសិកម្មនៅតាមសហគមន៍កសិកម្ម ការផ្តល់ធាតុចូលកសិកម្មសម្រាប់ដំណាំបន្លែ ការចិញ្ចឹមមាន់ និងវារីវប្បកម្មដល់គ្រួសារទទួលផលរបស់គម្រោងឆ្លើយតបបន្ទាន់ទៅនឹងជំងឺកូវីដ ១៩ ក្នុងក្របខ័ណ្ឌគ្រោងពិពិធកម្មកសិកម្មកម្ពុជា។ លើសពីនេះ អង្គភាពសម្របសម្រួលគម្រោងបានរៀបចំផែនការសកម្មភាពនិងថវិកាសម្រាប់ឆ្នាំ២០២២ ដោយបានដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីស្នើសុំការអនុម័ត និងបានរៀបចំវគ្គបណ្តុះបណ្តាលផ្សេងៗពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ ការទូទាត់ថវិកាចំណាយ និងការគាំពារបរិស្ថាននិងសង្គម។

**សមាសភាគទី៥** ៖ ការឆ្លើយតបនឹងការសង្គ្រោះបន្ទាន់ពេលមានអាសន្ន ដែលនៅក្រោមក្របខ័ណ្ឌសមាសភាគនេះ ក្រុមការងារគម្រោងបានរៀបចំគម្រោងឆ្លើយតបបន្ទាន់ទៅនឹងជំងឺកូវីដ១៩ ក្នុងគោលបំណងគាំទ្រដល់ជីវភាពគ្រួសារកសិករដែលរងផលប៉ះពាល់ចំនួន១៥ ៣៩៥គ្រួសារ ។ ដើម្បីអនុវត្តសកម្មភាពនេះ គម្រោងបានចុះ កិច្ចសន្យាជាមួយក្រុមហ៊ុនផ្គត់ផ្គង់ធាតុចូលកសិកម្ម និងផ្តល់សេវាបច្ចេកទេសចំនួន៣ កាលពីខែកញ្ញា មកដល់ចុងឆ្នាំ ២០២១ ក្រុមហ៊ុនទាំង៣ បាន សង់ផ្ទះសំណាញ់ចំនួន ១៣៥កន្លែង ស្រះប្លាស្ទិកចំនួ ន៩៤៥កន្លែងរួមទាំងកូនត្រីនិងកូនកង្កែប និងទ្រុងមាន់និងកូនមាន់ចំនួន ៣៤កន្លែង ក្នុងខេត្តគោលដៅគម្រោងបានចំនួន៩ រួមមានខេត្តត្បូងឃ្មុំ កំពង់ចាម កំពង់ស្ពឺ កំពង់ឆ្នាំង កណ្តាល ព្រះវិហារ ស្ទឹងត្រែង រតនគិរី និងរាជធានីភ្នំពេញ។

### ឆ. គម្រោងបែងចែកដីសង្គមកិច្ច ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច )LASED III)

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី៣ (LASED III) គឺជាគម្រោងដែលមានសកម្មភាពដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីចែកដីដល់ប្រជាពលរដ្ឋក្រីក្រដែលគ្មានដី និងមានដីតាមរយៈសម្បទានដីសង្គមកិច្ចដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់គ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះ។ គម្រោងនេះអនុវត្តការធ្វើដើម្បីដីសង្គមកិច្ចតាមមូលដ្ឋានឃុំដែលជាការផ្ទេរដីឯកជនរបស់រដ្ឋទៅដល់ប្រជាពលរដ្ឋក្រីក្រសម្រាប់ក្នុងគោលបំណងប្រើប្រាស់ជាលំនៅដ្ឋាន និងការដាំដុះដំណាំ ការចិញ្ចឹមត្រី-សត្វតាមគ្រួសារដែលផ្តួចផ្តើមដោយឃុំនិងសមាជិករបស់ខ្លួនរួមមាន៖ )i) ចែកដីរបស់រដ្ឋដែលសមស្របសម្រាប់ផ្នែកកសិកម្មរួមជាមួយនឹងសេវាកម្មគាំទ្រសមស្របទៅដល់គ្រួសារក្រីក្រគ្មានដីធ្លី និងមានដីធ្លីតិចតួចដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និង (ii) ណែនាំនិងអនុវត្តដំណើរការដោយតម្លាភាពនិងស្តង់ដារដើម្បីពង្រីក ការអនុវត្តសម្បទានដីសង្គមកិច្ចដែលផ្តួចផ្តើមឡើងនៅមូលដ្ឋាន។ គម្រោងនេះចាប់អនុវត្តជា៣ដំណាក់កាល ដែលដំណាក់កាលទី១ (LASED I ) បានចាប់ផ្តើមពីឆ្នាំ២០១២-២០១៦ ដំណាក់កាលទី២ (LASED II) បានចាប់ផ្តើមពីឆ្នាំ២០១៦-២០២១ និងដំណាក់កាលទី៣ (LASED III) ពីឆ្នាំ២០២០-២០២៦។

គម្រោង (LASED III) នេះ មានថវិកាសរុប១០៧លានដុល្លារអាមេរិក ក្នុងនោះ (៩៣លានដុល្លារអាមេរិកថវិកាកម្ចីពីធនាគារពិភពលោក និងថវិកាចំនួន១៤ លានដុល្លារអាមេរិក បដិភាគពីរាជរដ្ឋាភិបាលកម្ពុជា) ដែលអនុវត្តផ្ទាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គម្រោង

គ្រប ដណ្ដប់ លើខេត្តគោលដៅចំនួន៩ គឺខេត្តក្រចេះ ត្បូងឃ្មុំ កំពង់ធំ កំពង់ឆ្នាំង កំពង់ស្ពឺ មណ្ឌលគិរី រតនគិរី ព្រះវិហារ និង ខេត្តស្ទឹងត្រែង ដែលផ្តោតការវិនិយោគលើប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងផ្តល់សេវាគាំទ្របច្ចេកទេស សម្រាប់ការ ប្រកបរបរចិញ្ចឹមជីវិតផ្អែកលើកសិកម្មជាមូលដ្ឋាន ដែលមានប្រជាកសិករអ្នកទទួលសរុប១៥ ០០០គ្រួសារ។

ក្នុងឆ្នាំ២០២១នេះ ការអនុវត្តគម្រោងក្នុងបរិបទជំងឺកូវីដ-១៩ សម្រេចបានលទ្ធផលដូចខាងក្រោម៖

**ក.សមាសភាគទី១៖ ការជ្រើសរើស និងការរៀបចំផែនការសម្រាប់អភិវឌ្ឍន៍ទីតាំងសម្បទានដីសង្គមកិច្ច )SLC) និង សហគមន៍ជនជាតិដើមភាគតិច** (ICLT)

១.ការងារស្វែងរកសម្បទានដីសង្គមកិច្ច (SLC)៖ ក្នុងឆ្នាំ២០២១នេះ មានទីតាំងចំនួន១៩ ដែលខេត្តស្នើ ឡើង ស្ថិតក្នុងខេត្តចំនួន១២ ក្នុងស្រុកចំនួន១៤ ក្នុងឃុំចំនួន១៨ មានផ្ទៃដីដែលបានឯកភាពចំនួន១១,១៨៩ ហិកតា ស្មើនឹង៥៩%នៃផ្ទៃដី គ្រោងស្នើឡើង២៦,៨១៤ហិកតា។ តាមលទ្ធផលនៃជំហ៊ានទី១ ក្រុមការងារបានធ្វើការ សន្និដ្ឋានទាញយកទីតាំងចំនួន១២ សម្រាប់បន្តនីតិវិធីទី២ បន្តទៀត រហូតដល់និតីវិធីទី៦ ក្នុងឆ្នាំ២០២២។

២.ការងារស្រង់ទិន្នន័យព័ត៌មានសហគមន៍ជនជាតិដើមភាគតិច (ICLT Profile)៖ យោងតាមផែនការ ក្នុង ឆ្នាំ២០២១ ក្រុមការងារគ្រោងចុះចំនួន ១៥ទីតាំង គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២១ អនុវត្តបាន ២ទីតាំង គឺ៖

-ទីតាំងទី១ ស្ថិតនៅភូមិតាង៉ាច ឃុំប៉ូយ ស្រុកអូរជុំ ខេត្តរតនគិរី

-ទីតាំងទី២ ស្ថិតនៅភូមិក្រេះ ឃុំប៉ូយ ស្រុកអូរជុំ ខេត្តរតនគិរី

នៅសល់ ១៣ទីតាំងទៀត នឹងត្រៀមចុះអនុវត្តបន្ត។ ដោយឡែក ក្នុងឆ្នាំ២០២២ គ្រោងចុះចំនួន១០ទីតាំង នៅក្នុងខេត្តក្រចេះ រតនគីរី និងខេត្តមណ្ឌលគីរី។ ជាមួយគ្នានោះបានចូលរួមប្រជុំជាមួយក្រុមការងារក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ ចំនួន៥លើក។

៣.ការងារផ្សព្វផ្សាយសកម្មភាពរបស់គម្រោងដល់សហគមន៍ជនជាតិដើមភាគតិច (ICLT Outreach)

ក្រុមការងារបានចុះផ្សព្វផ្សាយអំពីគោលបំណង និងសកម្មភាពរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និង ការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ ចំនួន៣លើកនៅក្នុងខេត្តរតនគិរី ស្មើនឹង១៦ទីតាំង នៃផែនការ៣៣ទីតាំង ដូច មានជូនភ្ជាប់ក្នុងឧបសម្ព័ន្ធទី២។

បន្ថែមលើនេះដើម្បីពង្រីកការផ្សព្វផ្សាយ គម្រោងបានបង្កើត Facebook Page ផងដែរ ដែលមកដល់ពេល នេះមាន Total Likes 306 និង Total Follows 320។

**ខ.សមាសភាគទី២៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសហគមន៍** (Community Infrastructure Development)

ក្រុមការងារបាននឹងកំពុងរៀបចំ ToR សម្រាប់ទីប្រឹក្សាជាតិផ្នែកប្រព័ន្ធស្រោចស្រព និងផ្គត់ផ្គង់ទឹក ដើម្បីចុះ ពិនិត្យទីតាំងលើដីសម្បទានសង្គមកិច្ចដែលបានអនុវត្តរួចនៅជំហានទី២ និងដើម្បីពិនិត្យលទ្ធភាពក្នុងការសាងសង់ បន្ថែមនូវប្រព័ន្ធផ្គត់ផ្គង់ទឹកនិងប្រព័ន្ធស្រោចស្រពនៅលើទីតាំងចំនួន ៧កន្លែង ដែលមានស្រាប់។ ម្យ៉ាងទៀត ក្រុម ការងារបានពិនិត្យ និងវាយតម្លៃលើការសិក្សាបឋមនៃទីតាំងទាំង៧កន្លែង ដែលនឹងត្រូវបន្ថែមប្រព័ន្ធស្រោចស្រព និង ផ្គត់ផ្គង់ទឹក នៅក្នុងទីតាំងនៃគម្រោង LASED II។

**គ.សមាសភាគទី៣៖ ការអភិវឌ្ឍកសិកម្ម និងកែលម្អជីវភាពរស់នៅរបស់ប្រជាជន**

)Agriculture and Livelihood Development)

១.ការងារផលិតកម្មកសិកម្មតាមកិច្ចសន្យា (Contract Framing)

ក្រុមការងារបានចុះអនុវត្តសកម្មភាពការងារ ដោយបានចុះស្រង់ទិន្នន័យព័ត៌មានអំពីការយល់ដឹងរបស់ ប្រជាជនអំពីការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ព្រមទាំងជួបជាមួយវិស័យឯកជនសិក្សាអំពីតម្រូវការ និង ការផ្គត់ផ្គង់ទីផ្សារនៅក្នុងខេត្តគោលដៅចំនួន៤ គឺខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី។

២.អាហារូបត្ថម្ភ (Nutrition Sensitive(

ក្រុមការងារបានចុះអនុវត្តសកម្មភាពការងារ ដោយបានចុះស្រង់ទិន្នន័យព័ត៌មានអំពីការយល់ដឹងរបស់ប្រជាជនអំពីអាហារូបត្ថម្ភចំនួន១លើក នៅក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។

**ឃ.សមាសភាគទី៣៖ ការងារគ្រប់គ្រង** (Management)

គម្រោងបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ដែលមាន នាយកគ្រប់គ្រង ១រូប ប្រធានទទួលបន្ទុកការងារសម្របសម្រួល ១រូប និងប្រធានទទួលបន្ទុកការងារបច្ចេកទេស ១រូប និងផ្នែកបច្ចេកទេសចំនួន៧ រួមមានផ្នែកកសិកម្ម សុខភាពសត្វនិងផលិតកម្មសត្វ ព្រៃឈើ ប្រព័ន្ធព័ត៌មាននិងផ្សព្វផ្សាយកសិកម្ម សវនកម្ម និងផ្នែកកសិ-ឧស្សាហកម្ម។ បន្ថែមពីនេះ បាននឹងកំពុងរៀបចំបង្កើតក្រុមការងារបច្ចេកទេសចំពោះមុខចំនួន៣ក្រុម គឺក្រុមការងារទទួលបន្ទុកផ្នែកសម្បទានដីសង្គមកិច្ច (SLC) ក្រុមការងារទទួលបន្ទុកផ្នែកទិន្នន័យសហគមន៍ជនជាតិដើមភាគតិច (ICLT Profile) និងក្រុមការងារទទួលបន្ទុកផ្សព្វផ្សាយសកម្មភាពគម្រោងដល់សហគមន៍ជនជាតិដើមភាគតិច (ICLT Outreach) ដើម្បីសហការណ៍អនុវត្តសកម្មភាពជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការគ្រប់គ្រងការងាររដ្ឋបាលគម្រោង តាមដាននិងវាយតម្លៃគម្រោង ការគាំទ្រដល់បុគ្គលិកគម្រោងចុះអនុវត្តសកម្មភាព និងការគ្រប់គ្រងហិរញ្ញវត្ថុ ដោយធានាបាននូវលំហូរចំណូល-ចំណាយ តុល្យការហិរញ្ញវត្ថុ និងដំណើរការហិរញ្ញវត្ថុបានទាន់ពេលវេលា។ ចំពោះការចំណាយថវិកា ទទួលបានលទ្ធផល ដូចខាងក្រោម៖

- បានរៀបចំ AWPB ២០២២ ដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យ និងបញ្ចូលគ្នា
- បានស្នើសូមបំពេញបន្ថែមឡើងវិញរបស់គណនី IDA លើកទី១ នូវថវិកាចំនួន ២៣២,៣៦១ ដុល្លាអាមេរិក
- បានទទួលថវិកាបុរេប្រទានលើកទី២ ចំនួន២៣២,៣៦១ ដុល្លាអាមេរិកពីធនាគារពិភពលោក
- ផែនការថវិកាឆ្នាំ២០២១ មានចំនួន ១,០៦៧,៤៨០ ដុល្លារអាមេរិក ចំណាយរយៈពេល១២ខែ សរុបចំនួន២៦០,៦០៧,០០ដុល្លារអាមេរិក ស្មើនឹង២៤.៤១% ធៀបទៅនឹងផែនការថវិកាឆ្នាំ ២០២១។

**ជ. កម្មវិធីខ្សែច្រវាក់តម្លៃកសិកម្មកម្ពុជា** (CAVAC II)

កម្មវិធីខ្សែច្រវាក់តម្លៃសិកម្មកម្ពុជាជំហ៊ានជំហ៊ានទី២ គាំទ្រថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី ដោយបានជួយជំរុញឱ្យសម្រេចបាន នូវការធ្វើពាណិជ្ជកម្មវិស័យកសិកម្ម និងពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។ កម្មវិធី CAVAC មានគោលបំណងពីរគឺ៖១). ជំរុញការលើកកម្ពស់ប្រាក់ចំណេញពីការស្រោចស្រពកសិកម្ម តាមរយៈនិរន្តរភាពការផ្តល់សេវាស្រោចស្រព និងជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែលម្អគុណភាព និរន្តរភាពនិងប្រសិទ្ធភាពប្រតិបត្តិនិងការវិនិយោគប្រព័ន្ធស្រោចស្រព។ ២).ជំរុញការបង្កើនភាពប្រកួតប្រជែងវិស័យកសិកម្ម និងការធ្វើពិពិធកម្មឧស្សាហកម្មកសិកម្ម តាមរយៈការជំរុញផលិតកម្មដំណាំកសិ-ស្បៀងអាហារ ឱ្យស្របតាមឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជា ការបង្កើនសមត្ថភាពចូលទៅកាន់ទីផ្សារសម្រាប់ផលិតផលកសិកម្ម និងការគាំទ្រការទទួលយកនូវការអនុវត្តកសិកម្មទំនើបនិងមានផលិតភាពខ្ពស់។

ក្នុងឆ្នាំ២០២១ នេះ កម្មវិធី CAVAC ទទួលបានលទ្ធផលជា ដូចខាងក្រោះ

**១.ការកែលម្អប្រព័ន្ធស្រោចស្រពកសិកម្ម:**

- បានបញ្ចប់ទាំងស្រុងនូវការសាងសង់និងស្តារប្រព័ន្ធស្រោចស្រពចំនួន១០ ហើយបានគ្រប់គ្រងដំណើរការប្រតិបត្តិ និងថែទាំដោយសហគមន៍កសិករប្រើប្រាស់ទឹកដែលទទួលបានការបណ្តុះបណ្តាលពីកម្មវិធី។ ប្រព័ន្ធស្រោចស្រពកម្មវិធីកាវ៉ាក់ បានស្រោចស្រពលើផ្ទៃដី ១២ ៨៧៦ ហិកតា គឺមានកើនឡើង

បើប្រៀបធៀបទៅនឹងទិន្នន័យដើមគ្រាក្នុងឆ្នាំ២០១៦ មាន ១០ ៨៨០ហិកតា។ ផ្ទៃដីស្រោចស្រពបានលើស្រូវដើមរដូវបានចំនួន ១២ ៦៦៣ហិកតា និងលើស្រូវប្រដេញទឹកបាន ៩ ២១៣ហិកតា គឺកើនឡើង ១៧% បើប្រៀបធៀបពីឆ្នាំ២០២០។ គ្រួសារកសិករដែលបានទទួលផលប្រយោជន៍ពីប្រព័ន្ធស្រោចស្រពបានកើនឡើងពី ៥ ៨៩៨ គ្រួសារនៅក្នុងឆ្នាំ ២០១៦ កើនដល់ ១២ ៩៩៨ នៅក្នុងឆ្នាំ ២០២១។ ចំពោះផលិតផលស្រូវបានកើនឡើងពីទិន្នន័យដើមគ្រា ពី ៥៣ ៥៤៦ តោន នៅក្នុងឆ្នាំ ២០១៦ កើនដល់ ១១២ ២៣៤ តោន គឺបានកើនឡើង ១១១% (គិតជាតម្លៃមានទំហំ ២៤ ៦៩១ ៤៨០ ដុល្លារអាមេរិក)

- បានបង្កើតសេវាស្រោចស្រពក្នុង១០ ប្រព័ន្ធស្រោចស្រព ដោយបន្ត និងគាំទ្រដល់ការកសាងសមត្ថភាពសហគមន៍កសិករប្រើប្រាស់ទឹក ក្នុងការប្រតិបត្តិ និងថែទាំប្រព័ន្ធស្រោចស្រព ការគ្រប់គ្រងទ្រព្យសម្បត្តិសហគមន៍ (មានស្ថានីយបូមទឹកនិងប្រព័ន្ធស្រោចស្រព) ការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវាផ្គត់ផ្គង់ទឹក។
- បានធ្វើការជាមួយដៃគូនានា ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ADB នៅក្នុងប្រព័ន្ធស្រោចស្រពព្រែកពោធិ៍ គាំទ្រដល់ការង្កើតសហគមន៍ប្រើប្រាស់ទឹកនិងការប្រតិបត្តិដំណើរការនិងការគ្រប់គ្រងប្រព័ន្ធស្រោចស្រពតាមរយៈអភិក្រមភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន (PPP) ។
- បានជួយគាំទ្រដល់ World Bank និង DFAT ក្នុងការបង្កើតក្រុមការងារអភិវឌ្ឍភាពជាដៃគូធនធានទឹក និងគាំទ្រលេខាធិការដ្ឋាន ក្រុមការងារអភិវឌ្ឍភាពជាដៃគូធនធានទឹកនេះ។
- កម្មវិធី CAVAC ក្នុងភាពជាដៃគូជាមួយ ក្រុមអេឡិចត្រនិកធនធានទឹក eWater បានរៀបចំផ្នែកស្រោចស្រពកសិកម្មរបស់កម្មវិធី CAVAC ឱ្យក្លាយទៅជាមជ្ឈមណ្ឌលធនធានទឹកនិងស្រោចស្រពមេគង្គ-អូស្ត្រាលី។

**២. ការលើកកម្ពស់ការប្រកួតប្រជែង និងពិពិធកម្មក្នុងខ្សែច្រវាក់តម្លៃកសិកម្ម:**

**<u>ការកែលម្អគុណភាពពូជនិងការប្រើប្រាស់ពូជស្រូវថ្មីៗ៖</u>**

- បានធ្វើការជាមួយអគ្គនាយកដ្ឋានកសិកម្ម វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា និងសហព័ន្ធស្រូវអង្ករកម្ពុជា បានដាក់បញ្ចូលពូជថ្មីៗចំនួនបួន មានពូជស្រូវសែនក្រអូប០១ ពូជផ្កាមាលតី ពូជស្រូវក្រអូបមិនប្រកាន់រដូវ និងពូជខា១៥ ព្រមទាំងបានកំណត់មួយពូជទៀតគឺ ពូជស្រូវដំណើបស្បែមង្គល សម្រាប់តម្រូវការអង្ករនៅលើទីផ្សារអន្តរជាតិ និងសក្តានុពលនាំចេញអង្ករកម្ពុជា
- បានជំរុញការប្រើប្រាស់ពូជស្រូវមានគុណភាពល្អ តាមរយៈការអនុវត្តសាកល្បងប្រព័ន្ធបញ្ជាក់គុណភាពពូជ QDS ដោយបានផ្តល់សុទ្ធគ្រឹះ ១,៧៦តោន និងពូជស្រូវវិញ្ញាបនបត្រនៃពូជស្រូវដំណើបស្បៃមង្គលចមនួន២៤០ គីឡូក្រាម ដល់អ្នកផលិតពូជស្ម័គ្រចិត្តចំនួន ៣១ នាក់ (មានស្ត្រី ៧នាក់)នៅក្នុងខេត្តចំនួនប្រាំ។ បានផលិត និងលក់ចែកចាយពូជស្រូវគុណភាពល្អចំនួន ១៨៦ តោន (ហើយសរុបពីដើមគ្រាមកដល់ឆ្នាំ២០២១ បាន ៦៩៣តោន)
- បានដល់បញ្ចូលបច្ចេកវិទ្យាប្រព័ន្ធដាំគ្រាប់ស្រូវ (Direct Seeded Rice Technology) ដោយបានធ្វើបង្ហាញប្រព័ន្ធដាំគ្រាប់ស្រូវលើផ្ទៃដីសរុប ៣៧៨.៥០ ហិកតានៅខេត្តតាកែវ និងខេត្តកំពង់ធំ ក្នុងនោះប្រើប្រាស់ម៉ាស៊ីនដាំគ្រាប់ស្រូវ Eli Seeders បានចំនួន៨៩,៨ ហិកតា ThaiKID Seed Planter ចំនួន ២១៧ ហិកតា និង Lungheng Seed Planters ចំនួន ៦៨,៥ ហិកតា។ កម្មវិធីការវ៉ាក់ក៏បានធ្វើការជាមួយក្រុមហ៊ុន ឈិន លី ហេង និងក្រុមហ៊ុនគង់ នួន បានបន្តគាំទ្រអនុវត្តការពង្រោបដីដោយប្រើប្រាស់ប្រព័ន្ធឡាស៊ែ និងសេវាពង្រាបដីស្រែបាន ៤ ១០០ ហិកតា នៅក្នុងឆ្នាំ២០២១ និងក្រុមហ៊ុនជាដៃគូកម្ម

វិធីការ៉ាក់ បានលក់ឧបករណ៍ពង្រាបដីដោយប្រព័ន្ធឡាស៊ែចំនួន ២៤ គ្រឿង នេះ ហើយមកដល់បច្ចុប្បន្ន មានឧបករណ៍ពង្រាបដីប្រើប្រាស់ប្រព័ន្ធឡាស៊ែ ចំនួន ៨២ កំពុងធ្វើប្រតិបត្តិការពង្រាបដី។

- បានសម្របសម្រួលការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ដោយជំរុញផលិតកម្មស្រូវពូជផ្ការំដួល និងពូជសែនក្រអូប០១ ដោយមានកសិករចូលរួមចំនួន ៧៧០ នាក់ (ស្ត្រី ៣៥០ នាក់) បានផលិតស្រូវលើផ្ទៃដីចំនួន ២ ៧១៣ ហិកតា (ស្រូវសែនក្រអូប០១មាន ២១១ ហិកតា) និងទទួលមានផលិតផលស្រូវសរុប ៦ ៨៩៧ តោន (ស្រូវសែនក្រអូប០១ មាន ៥៩០ តោន)។ កម្មវិធីការ៉ាក់បានសហការជាមួយក្រុមហ៊ុន Signature Asia (SoA) បានផ្តល់ការសមត្ថភាពដល់អ្នកផលិតពូជស្រូវចំនួន១០នាក់ (ស្ត្រី៦នាក់)ក្នុងការផលិតកម្មពូជស្រូវនៅក្នុងខេត្តព្រះវិហារ ចំនួន ១៣,៨ ហិកតា និងបានផលិតពូជស្រូវចំនួន ២៧,៦តោន។

<u>**ការជំរុញពូជដំណាំមានតម្លៃបន្ថែមខ្ពស់:**</u>

- កម្មវិធីការ៉ាក់ បានជំរុញការអនុវត្តបច្ចេកវិទ្យាមានផលិតភាពខ្ពស់ លើដំណាំស្រូវ និងដំណាំដំឡូងមី ក្នុងការពិសោធន៍ស្រាវជ្រាវ ជ្រើសរើសពូជស្រូវ និងពូជដំឡូងមី។ ដំណាំដំឡូងមីបានធ្វើការជាមួយនាយកដ្ឋានដំណាំឧស្សាហកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ដើម្បីកំណត់ជ្រើសរើសពូជដំឡូងមីធន់នឹងជំងឺម៉ូសាអ៊ិច តាមរយៈបង្កើនគុណភាពដើមពូជស្អាត សម្រាប់ដាំដុះ។ កម្មវិធីការ៉ាក់ក៏បានសហការជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានសាងសង់ផ្ទះសំណាញ់ចំនួនពីរ សម្រាប់ប្រើប្រាស់ជាថ្នាលបណ្តុះកូន និងស្តុកដើមពូជស្អាតសុខភាពល្អ និងគាំទ្រមន្ទីរពិសោធន៍ក្នុងការពង្រីកដើមពូជរហ័ស ក្នុងនោះមាន In-Vitro Clean KU50 variety (500 In-Vitro Plants) និងពូជដំឡូងចំនួន៥ ពូជទៀត ជា មាន In-Vitro Clean Materials ។
- បានគាំទ្រនាយកដ្ឋាននីតិកម្មកសិកម្មបានបង្កើនប្រព័ន្ធ QR Code សម្រាប់ត្រួតពិនិត្យលើលើស្លាកសញ្ញាផលិតផលសម្ភារកសិកម្មនានា មានថ្នាំកសិកម្មនិងជី ដោយបានត្រួតពិនិត្យផលិតផលចំនួន៩៧៩មុខ។ កម្មវិធីការ៉ាក់បានសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម បានបង្កើត និងបានដាក់ឱ្យប្រើប្រាស់ឧបករណ៍ Scanning App Mode of Action (MoA) សម្រាប់ប្រើប្រាស់ក្នុងបព័ន្ធ iOS និង Android សម្រាប់ត្រួតពិនិត្យគុណភាពថ្នាំកសិកម្ម ព្រមទាំងបានបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ឧបករណ៍ Scanning App នេះដល់បុគ្គលិកក្រុមហ៊ុន ន៩និងមន្ត្រីមន្ទីរកសិកម្មខេត្តសរុបចំនួន៥០នាក់។ កម្មវិធីការ៉ាក់បានសហការជាមួយ ក្រុមហ៊ុន KPP Global បានដាក់ឱ្យប្រើប្រាស់ឧបករណ៍ដ្រូន សម្រាប់ការប្រើប្រាស់ថ្នាំកសិកម្ម និងក្រុមបានលក់ឧបករណ៍ដ្រូនចំនួន១៦ គ្រឿង ហើយមកដល់ត្រឹមឆ្នាំ២០២១ នេះ បានដាក់ឱ្យប្រើប្រាស់ ឧបករណ៍ដ្រូន ២៦គ្រឿង លើផ្ទៃដីសរុបចំនួន ១៩ ៦០០ ហិកតា។

<u>**បរិយាកាសជំរុញសម្រាប់គុណភាពផលិតកម្មនិងការនាំចេញ:**</u>

- បានធ្វើជាមួយអគ្គនាយកដ្ឋាន បានជួយគាំទ្រនាយកដ្ឋានពូជដំណាំ បានបង្កើតប្រព័ន្ធទទួលស្គាល់គុណភាពពូជដំណាំ សម្រាប់ចេញវិញ្ញាបនបត្របញ្ជាក់គុណភាពនិងការគ្រប់គ្រងគុណភាពពូជដំណាំ ដែលរួមមាននីតិវិធីបញ្ជាក់គុណភាព និងគោលការណ៍ណែនាំបច្ចេកទេស(រួមមានឡូហ្គោ និងស្លាកសញ្ញា)
- កម្មវិធីការ៉ាក់បានធ្វើការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) និងអង្គការ UNIDO បានបញ្ចប់ការសិក្សាស្តីពីគុណភាពហេដ្ឋារចនាសម្ព័ន្ធ(ប្រព័ន្ធ នីតិវិធី និងគោលនយោបាយ) និងបានរៀបចំសិក្ខាសាលា ពិគ្រោះយោបល់ស្តីការសារសំខាន់ និងការអភិវឌ្ឍគោលនយោបាយគុណភាពជាតិនៅកម្ពុជា។ កម្មវិធីការ៉ាក់បាន ចាប់ផ្តើមធ្វើការលើកិច្ចអន្តរាគមន៍ពីរ ដោយផ្តោតលើការបង្កើតវេទិកាព័ត៌មានពាណិជ្ជកម្ម និងការិយាល័យវិនិយោគ កសិ-ស្បៀងអាហារ។

***ភាពជាដៃគូរបស់រដ្ឋនិងវិស័យឯកជនៈ***

- បានចុះហត្ថលេខាអនុសាសនៈយោគយល់ ជាមួយសហគ្រាសខ្មែរ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា វេទិកាបណ្ឌិតវិទ្យាសាស្ត្រសាធារណៈ-ឧស្សាហកម្មមួយ ដើម្បីគាំទ្រសហគ្រាសខ្នាតតូចនិងមធ្យម លើផ្នែកកសិ-ស្បៀងអាហារ និងអភិវឌ្ឍផលិតផល។ កម្មវិធីការ៉ាក់ក៏បានចុះកិច្ចសន្យាជាមួយសហគ្រាសខ្មែរ ដើម្បីគាំទ្រដល់ការកែច្នៃកសិផល សហគ្រាសខ្នាតតូចនិងមធ្យម ហើយបានកំណត់ជ្រើសរើសក្រុមហ៊ុនពីរគឺក្រុមហ៊ុន Khmer Necta Honey Kamya និង Agri-Trade ដែលទាក់ទងនឹងសេវាឃ្មុំ នាំលម្អងផ្កាសម្រាប់ដំណាំដែលមានតម្លៃបន្ថែមខ្ពស់។

**ឈ. "កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកនេសាទ"** (CAPFISH-Capture)

"កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកនេសាទ" (CAPFISH-Capture) ជាជំនួយឥតសំណងរបស់សហភាពអឺរ៉ុប មានទឹកប្រាក់សរុបចំនួន៣៥លានអឺរ៉ូ សម្រាប់អនុវត្តរយៈពេល៥ឆ្នាំ (២០១៩-២០២៤) ដែលមានសូចនាករសំខាន់ៗចំនួន៨ ក្នុងគោលបំណងដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព ភាពធន់ទៅនឹងអាកាសធាតុ និងបរិយាប័ន្ននៃធនធានជលផលទឹកសាប និងសមុទ្រនៅក្នុងប្រទេសកម្ពុជា។

ក្នុងឆ្នាំ២០២១នេះ កម្មវិធីបានអនុវត្តសកម្មភាពទៅតាមផែនការដែលបានកំណត់ និងទទួលបានលទ្ធផលដូចខាងក្រោមៈ

**ក. ការពង្រឹងការអនុវត្តច្បាប់ជលផល និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ**

កម្មវិធីបានជួយរដ្ឋបាលជលផលក្នុងការបណ្តុះបណ្តាល កម្មវិធីស្មាត ដើម្បីប្រមូលទិន្នន័យល្បាត និងបានផ្តល់ឧបករណ៍ Blackview បន្ថែមចំនួន៥០គ្រឿងដល់អធិការដ្ឋានទាំង៥ និងខណ្ឌរដ្ឋបាលជលផលទាំង២៥ សម្រាប់ប្រើប្រាស់។ បានត្រួតពិនិត្យ និងកត់ត្រាទូកនេសាទសមុទ្រចំនួន១១៨៦គ្រឿង និងកន្លែងឡើងត្រីបានចំនួន ១៨៣កន្លែង ព្រមទាំងបានចុះត្រួតពិនិត្យនិងអធិការកិច្ចឧបករណ៍នេសាទនិងសកម្មភាពនេសាទទឹកសាបសរុបចំនួន៤៥.៣២២ករណី នៅខេត្តគោលដៅចំនួន២០ ក្នុងនោះខេត្តតំបន់ឆ្នេរចំនួន៤។

**ខ. ការការពារទីជម្រកមច្ឆជាតិនៅដែននេសាទទឹកសាប**

កម្មវិធីបានជួយរដ្ឋបាលជលផលក្នុងការបញ្ចប់ការរៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹករយៈពេល៥ឆ្នាំ នៅខេត្តចំនួន៣ គឺខេត្តសៀមរាប បាត់ដំបង និងខេត្តកំពង់ធំ និងបានការអនុម័តដាក់ឱ្យអនុវត្តជាផ្លូវការ។ បាននិងកំពុងបន្តរៀបចំផែនការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកនៅខេត្តចំនួន៣ផ្សេងទៀត គឺខេត្តកំពង់ឆ្នាំង ពោធិសាត់ និងខេត្តបន្ទាយមានជ័យ ដោយរំពឹងថានឹងបញ្ចប់នៅត្រីមាសទី១ ឆ្នាំ២០២២ខាងមុខនេះ។ បានបោះបង្គោលចំនួន១៣០បង្គោល នៅតាមព្រំប្រទល់ព្រៃលិចទឹកក្នុងតំបន់៣ រីឯនាយកដ្ឋានអភិរក្សជលផលបាន១៦០បង្គោល ដែលសរុបមានចំនួន២៩០បង្គោលតាមផែនការកំណត់។ បានទម្លាក់ប្រអប់បេតុងចំនួន២០០ប្រអប់ ដើម្បីទប់ស្កាត់បទល្មើសនេសាទនិងបង្កើតជម្រកសិប្បនិមិត្តបន្ថែមដល់ធនធានជលផលសមុទ្រ។ បានបើកវគ្គបណ្តុះបណ្តាលនិងអនុវត្តជំនាញមុជទឹកបាតសមុទ្រ និងតាមដានវាយតម្លៃជម្រកផ្កាថ្មនិងស្មៅសមុទ្រ ដោយមានសិក្ខាកាមចំនួន១៩នាក់ និងបានចុះវាយតម្លៃពីស្ថានភាពធនធានផ្កាថ្មនិងស្មៅសមុទ្រ។

**គ. ការអភិវឌ្ឍន៍គោលនយោបាយស្តីពីជលផលនិងពង្រឹងការអនុវត្តច្បាប់**

កម្មវិធីបានជួយរដ្ឋបាលជលផលក្នុងការបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីជលផលថ្មី និងបានបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងមហាផ្ទៃ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានអនុម័តលើផែនការសកម្មភាពត្រួតពិនិត្យ និងអធិការកិច្ចជលផលសមុទ្រ (NPCI-MF) និងបានកំពុងអនុវត្តសកម្មភាពដើម្បី

ប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ (IUU) ដោយបានវាយការណ៍ពីភាពរីកចម្រើនចំនួន១១ចំនុច ទៅអគ្គនាយកដ្ឋានជលផលនិងសមុទ្រ (DG MARE) របស់សហភាពអឺរ៉ុប ដើម្បីដោះកាតក្រហមដែលបានពិន័យ។ បានបញ្ជាទិញនាវាល្បាតធុនតូចចំនួន៥គ្រឿង ទិញរថយន្តល្បាតចំនួន៦គ្រឿង។ បានផ្តល់លិខិតអនុញ្ញាតឱ្យធ្វើនេសាទចំនួន៧៥ដល់នាវានេសាទនៅខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តកែប និងកំពុងរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការឃ្លាំមើលសកម្មភាពនេសាទពីលើអាកាស។

**ឃ. ការរៀបចំនិងគ្រប់គ្រងទិន្នន័យផលចាប់ជលផល**

កម្មវិធីបានជួយរដ្ឋបាលជលផលក្នុងការរៀបចំ និងអនុម័តលើសៀវភៅណែនាំស្តីពីការតាមដានវាយតម្លៃផលនេសាទទឹកសាបនិងសមុទ្រ។ ទន្ទឹមនេះ កម្មវិធីបានជួយដល់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប និងសមុទ្រ (IFReDI) និង (MAFReDI) ក្នុងការបណ្តុះបណ្តាលពីការប្រមូលទិន្នន័យវិភាគនិងធ្វើរបាយការណ៍ស្ថិតិផលនេសាទនីមួយៗ ដើម្បីចងក្រងនិងផ្សព្វផ្សាយក្នុងគេហទំព័ររបស់ IFReDI និង MAFReDI នៃរដ្ឋបាលជលផល និងតាមអ៊ីនធើណេត។ បានរៀបចំចងក្រងទុកនូវឯកសារស្រាវជ្រាវ និងព័ត៌មានដែលបានចងក្រងកន្លងមកក្នុងវិស័យជលផលកម្ពុជា (ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០២០) និងបានរៀបចំផែនការយុទ្ធសាស្ត្រ និងផែនទីបង្ហាញផ្លូវក្នុងការសម្របសម្រួលការស្រាវជ្រាវស្តីពីវិស័យជលផលកម្ពុជាឱ្យប្រសើរឡើងតាមរយៈការផ្តល់កញ្ចប់ថវិកាជំនួយខ្នាតតូច។

**ង. ការបង្កើនសមត្ថភាពសហគមន៍ ដើម្បីចូលរួមក្នុងសហគ្រប់គ្រងធនធានជលផល**

កម្មវិធីបានជួយរដ្ឋបាលជលផលបានរៀបចំគោលការណ៍ណែនាំស្តីពីការគាំទ្រថវិកាដល់សហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រីនៅកម្ពុជា និងបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគាំទ្រថវិកាដល់សហគមន៍នេសាទនិងសហគមន៍ស្រះជម្រកត្រីនៅកម្ពុជាក្នុងឆ្នាំ២០២១ ចំនួន២៥០សហគមន៍ ក្នុងនោះសហគមន៍នេសាទចំនួន១៥០ និងសហគមន៍ស្រះជម្រកត្រីចំនួន១០០ (ចំនួន៤លានរៀល ក្នុងមួយសហគមន៍) និងកំពុងរៀបចំផែនការចុះសិក្សាវាយតម្លៃពីប្រសិទ្ធភាព និងសមិទ្ធិផលនៃការអនុវត្តគម្រោងរបស់សហគមន៍ដែលបានគាំទ្រថវិកា។ បានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យសហគមន៍នេសាទ និងសហគមន៍ស្រះជម្រកត្រីនៅកម្ពុជា ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង។

**ច. ការកែលម្អការគ្រប់គ្រងឋបនីយជីវមណ្ឌលបឹងទន្លេសាបក្រោមការគាំទ្របច្ចេកទេសពីអង្គការយូណេស្កូ**

បាននិងកំពុងរៀបចំពិគ្រោះយោបល់ជាមួយជំនាញការនិងភាគីពាក់ព័ន្ធ ក្នុងការរៀបចំរចនាសម្ព័ន្ធនិងតាក់តែងក្របខ័ណ្ឌការងារនិងតួនាទី ដើម្បីកំណត់អំពីយន្តការបែងចែកតំបន់គ្រប់គ្រងផ្សេងៗ នៃឋបនីយជីវមណ្ឌលបឹងទន្លេសាប និងបានសិក្សាវាយតម្លៃនៅតំបន់ស្នូល គោលដៅបឹងទន្លេឆ្មានិងស្ទឹងសែន ដើម្បីសិក្សាកំណត់អំពីយន្តការបែងចែកតំបន់គ្រប់គ្រងផ្សេងៗ ដោយបង្កើតជាផែនការយុទ្ធសាស្ត្រនិងចងក្រងជាឯកសារផ្សព្វផ្សាយអំពីគុណតម្លៃនៃឋបនីយជីវមណ្ឌលបឹងទន្លេសាបទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងវេទិកាអនឡាញ ដោយមានការចូលរួមពីអ្នកសិក្សាស្រាវជ្រាវ និស្សិត និងជំនាញការបច្ចេកទេសសរុបចំនួន២៧៥នាក់។

**ឆ. ការពង្រឹងលើការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផល ផលិតផលជលផល**

កម្មវិធីបានជួយរដ្ឋបាលជលផល ដែលបាននិងកំពុងអនុវត្តផែនការសកម្មភាពជាតិសម្រាប់អធិការកិច្ច និងត្រួតពិនិត្យគុណភាព សុវត្ថិភាពលើផលិតផលជលផលតាមរយៈការបណ្តុះបណ្តាលធនធានមនុស្សនិងបានចុះប្រមូលសំណាកចំនួន៥២៦ សម្រាប់ឆ្នាំ២០២១។ រដ្ឋបាលជលផលបានចុះអនុស្សារណៈនៃការយោគយល់គ្នា (MoU) ជាមួយមន្ទីរពិសោធន៍មួយចំនួននិងបានបណ្តុះបណ្តាលបច្ចេកទេស សម្រាប់ការធ្វើតេស្តគំរូ CQS និង NRMP ដល់អ្នកចូលរួមចំនួន៥៦នាក់ មកពីមន្ទីរពិសោធន៍ចំនួន១១ ស្តីពីការទទួលស្គាល់ ISO 17025 និងកំពុងរៀបចំបង្កើតគោលនយោបាយនិងយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍន៍មន្ទីរពិសោធន៍។ គម្រោងក៏បានពង្រឹងសមត្ថភាពវិស័យឯកជនចំនួន១៤ ដើម្បីឱ្យអនុលោមតាមស្តង់ដារសុវត្ថិភាពម្ហូបអាហារ និងតម្រូវការទីផ្សារលើសេវាធុរកិច្ច

លើផលិតផលកែច្នៃជលផលក្នុងសហគ្រាសខ្នាតតូច មធ្យម និងខ្នាតធំ។ គម្រោងកំពុងកំណត់ភាគីនៅក្នុងខ្សែច្រវាក់តម្លៃជលផលក្រោយប្រមូលផលនៅបណ្តាខេត្តជុំវិញបឹងទន្លេសាប និងតំបន់ឆ្នេរប្រមាណជា២,០០០នាក់ ដើម្បីដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់រដ្ឋបាលជលផលនាពេលអនាគត។

**ជ. ការបង្កើននិងគ្រប់គ្រងថវិការាជរដ្ឋាភិបាលសម្រាប់វិស័យជលផល**

កម្មវិធីបានជួយរដ្ឋបាលជលផលក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០២២ ដល់ខណ្ឌរដ្ឋបាលជលផលរាជធានី ខេត្តទាំង២៥ មានអ្នកចូលរួមសរុបចំនួន៧១នាក់ (ស្ត្រី១៩នាក់) បានរៀបចំផែនការសកម្មភាពនិងថវិកាឆ្នាំ២០២២ ទាំង២៥ រាជធានី ដោយផ្អែកលើគោលនយោបាយអនុវិស័យជលផលជាអាទិភាព ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (ASDP) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរាជធានី ខេត្ត (PASDP) និងគម្រោងថវិកា CAPFISH-Capture ឆ្នាំ២០២១។

**ញ. គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃនិងលើកកម្ពស់សុវត្ថិភាពកសិកម្ម** (ACSEP)

គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃនិងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ត្រូវបានរៀបចំបង្កើតឡើងដើម្បី គាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ កសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងចូលរួមដោះស្រាយនូវបញ្ហាប្រឈមដែលជួបប្រទះនៅក្នុងខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម ជាពិសេសផលិតផលតំឡូងមី ស្វាយ ចន្ទី បន្លែ និងមាន់ស្រុក នៅក្នុងខេត្តគោលដៅគម្រោង សំដៅពង្រឹងខ្សែច្រវាក់តម្លៃផលិតផលកសិកម្មទាំងនេះប្រកបដោយភាពប្រកួតប្រជែង។

គម្រោងត្រូវបានអនុម័តនៅក្នុងខែតុលា ឆ្នាំ២០២០ ហើយដែលកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការរវាង រាជរដ្ឋាភិបាលជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ត្រូវបានចុះហត្ថលេខានៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ និងមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១។ គម្រោងនឹងត្រូវអនុវត្តសម្រាប់រយៈពេល ០៧ឆ្នាំ (២០២១-២០២៧) នៅក្នុងខេត្តគោលដៅចំនួន ០៦ រួមមាន៖ ខេត្តកំពង់ចាម កំពង់ធំ សៀមរាប ឧត្តរមានជ័យ ព្រះវិហារ និងខេត្តត្បូងឃ្មុំ ហើយមានថវិកាសរុប៖ ១០០,០៦ លានដុល្លារអាមេរិក សម្រាប់ចំណាយលើការអនុវត្តសកម្មភាពគម្រោង ៖ (១). ការសម្របសម្រួល ឱ្យទទួលបានឥណទានសម្រាប់សហគ្រាសកសិកម្ម និងសហគមន៍កសិកម្ម (២). ការលើកកម្ពស់ការភ្ជាប់ទៅនឹងទីផ្សារប្រកប ដោយស្ថេរភាពក្នុងចំណោមសហគ្រាសកសិកម្ម និងសហគមន៍កសិកម្ម និងធ្វើឱ្យប្រសើរឡើងនូវគុណភាព និងសុវត្ថិភាព ចំណីអាហារ និង (៣) ធ្វើឱ្យប្រសើរឡើងនូវការភ្ជាប់ទំនាក់ទំនង (ផ្លូវជនបទ) ពីកសិដ្ឋានផលិតទៅកាន់ទីផ្សារ។

នៅក្នុងឆ្នាំ២០២១ នេះ ថវិកាដំបូងរបស់គម្រោងដែលទទួលបានមានចំនួន ៤៣០,០០០ដុល្លារអាមេរិក និងត្រូវបាន ចំណាយសម្រាប់អនុវត្តសកម្មភាពគម្រោងអស់ចំនួន ១២៣,២៨៤.៩៧ ដុល្លារអាមេរិក។ ដោយសារមានការរីករាលដាលនៃ ជំងឺកូវីឌ ១៩ នៅក្នុងសហគមន៍ នៅកំឡុងឆ្នាំ២០២១ ការអនុវត្តសកម្មភាពគម្រោងត្រូវបានរាំងស្ទះ និងពន្យាពេល ដែលទន្ទឹមនឹងបានរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០២២ និងរៀបចំកិច្ចប្រជុំលើកទី១ របស់គណៈកម្មការដឹកនាំគម្រោង ក្រុមការងារគម្រោងនៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអភិវឌ្ឍន៍ជនបទ បានខិតខំប្រឹងប្រែងអនុវត្ត សកម្មភាពគម្រោង និងទទួលបានលទ្ធផលដូចខាងក្រោម ÷

- **លទ្ធផលរពឹងទុកទី១៖** សកម្មភាពសម្រាប់អនុវត្តសំដៅសម្រេចលទ្ធផលរំពឹងទុកទី១នេះ ត្រូវអនុវត្តដោយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៖ ១). បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចីហិរញ្ញប្បទាន ២). បានធ្វើវិសោធនកម្មលើការរៀបចំលំហូរមូលនិធិ ៣. បានបញ្ចប់ការរៀបចំផែនការសកម្មភាពគ្រប់គ្រងហិរញ្ញវត្ថុ

៤. បញ្ចប់របាយការណ៍វាយតម្លៃ PRC និង CECs ៥. បានចុះហត្ថលេខា លើកិច្ចព្រមព្រៀងកម្ចីរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ និង ៦. បានចុះហត្ថលេខាលើ Credit Guarantee Fund រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ។

- **លទ្ធផលរំពឹងទុកទី២៖** សកម្មភាពសម្រាប់អនុវត្តសំដៅសម្រេចលទ្ធផលរំពឹងទុកទី២នេះ ត្រូវអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៖ ១. បានរៀបចំផែនការសកម្មភាព និងនីតិវិធីក្នុងការជ្រើសរើសសហគមន៍កសិកម្មចំនួន ២៣០ និងសហគ្រាសកសិកម្មចំនួន ៥០ នៅក្នុងខេត្តគោលដៅរបស់គម្រោងទាំង ៦ ២. បានសម្របសម្រួលជាមួយអ្នកជំនាញការផ្នែកព័តមានវិទ្យារបស់ ADB ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រឌីជីថល សម្រាប់វិស័យកសិកម្ម និង ៣. បានបំពេញនីតិវិធីលទ្ធកម្មសម្ភារប្រើប្រាស់សម្រាប់អនុវត្តគម្រោង។
- លទ្ធផលរំពឹងទុកទី៣៖ សកម្មភាពសម្រាប់អនុវត្តសំដៅសម្រេចលទ្ធផលរំពឹងទុកទី៣នេះ ត្រូវអនុវត្តដោយក្រសួង អភិវឌ្ឍន៍ជនបទ៖ ១. បាននិងកំពុងរៀបចំនីតិវិធីក្នុងការកែលម្អផ្លូវនៅខេត្តកំពង់ធំ និងខេត្តព្រះវិហារ ដែលមាន ប្រវែង ៣៦.៦០ គីឡូម៉ែត, ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប ដែលមានប្រវែង ៤៣,៩០ គីឡូម៉ែត និងខេត្ត កំពង់ចាម និងខេត្តត្បូងឃ្មុំ ដែលមានប្រវែង ៣០,០៥ គីឡូម៉ែត ២. បាននិងកំពុងរៀបចំនីតិវិធីលទ្ធកម្មសម្ភារប្រើប្រាស់ សម្រាប់អនុវត្តគម្រោង និង ៣. បាននិងកំពុងរៀបចំនីតិវិធីក្នុងការជ្រើសរើសទីប្រឹក្សាបច្ចេកទេសក្នុងការសាងសង់ផ្លូវ (Construction Supervision Consult)

### ដ. កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី (NAP)

ក្នុងឆ្នាំ២០២១នេះ កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី (NAP) បានអនុវត្តសកម្មភាពក្នុងគោលដៅដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

- បានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយអង្គការ Swisscontact និង CIRAD អំពីកិច្ចសហប្រតិបត្តិការរវាងក្រុមការងារ NAP និងក្រុមការងារ CASIC និងយុទ្ធសាស្ត្រសម្រាប់ពេលអនាគត។
- បានជួបពិភាក្សាជាមួយគណៈកម្មការតម្រង់ទិសសម្ព័ន្ធកសិកម្មអភិរក្ស (CASIC) ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការរវាងក្រុមការងារ NAP និងក្រុមការងារសម្ព័ន្ធកសិកម្មអភិរក្ស តាមរយៈប្រព័ន្ធអនឡាញ។
- បានចូលរួមជាមួយគណៈកម្មការតម្រង់ទិសសម្ព័ន្ធកសិកម្មអភិរក្ស ចុះទស្សនកិច្ចសិក្សាការនៅមជ្ឈមណ្ឌលអនុវត្តកសិកម្មអភិរក្សក្នុងខេត្តកំពង់ចាម។
- បានចូលរួមកិច្ចប្រជុំលើកទី១៩ នៃគណៈកម្មាធិការត្រួតពិនិត្យការអនុវត្តអនុសញ្ញាសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម (19th Session of the Committee for the Review of the Implementation of the UNCCD Convention) តាមប្រព័ន្ធអនឡាញ។
- បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្ត NAP និងកិច្ចការត្រូវអនុវត្តបន្តតាមប្រព័ន្ធអនឡាញ។
- បានរៀបចំកិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញ ដើម្បីកំណត់តម្រូវការ តួនាទី និងភារកិច្ចរបស់ទីប្រឹក្សាបច្ចេកទេសសម្រាប់កសាងសមត្ថភាពក្រុមការងារសកម្មភាពជាតិ និងគណៈកម្មាធិការគ្រប់គ្រងទីជម្រាលថ្នាក់ក្រោមជាតិ។
- បានសម្របសម្រួល និងរៀបចំឯកសារពាក់ព័ន្ធនឹងកិច្ចសន្យាជួលទីប្រឹក្សាបច្ចេកទេសសម្រាប់កសាងសមត្ថភាពក្រុមការងារសកម្មភាពជាតិ និងគណៈកម្មាធិការគ្រប់គ្រងទីជម្រាលថ្នាក់ក្រោមជាតិ។

- បានសម្របសម្រួល និងរៀបចំឯកសារទស្សនទាន លិខិតអញ្ជើញ និងបទបង្ហាញសំខាន់ៗ សម្រាប់កិច្ចប្រជុំគណៈកម្មាធិការថ្នាក់ក្រោមជាតិគ្រប់គ្រងទីជម្រាលតាមប្រព័ន្ធអនឡាញ។
- បានដំណើរការកិច្ចប្រជុំគណៈកម្មាធិការថ្នាក់ក្រោមជាតិគ្រប់គ្រងទីជម្រាលតាមប្រព័ន្ធអនឡាញ កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ ក្រោមអធិបតីភាព ឯកឧត្តម ចាន់ សុវុឌ្ឍ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាសហប្រធានគណៈកម្មាធិការថ្នាក់ក្រោមជាតិគ្រប់គ្រងទីជម្រាល។ កិច្ចប្រជុំនេះមានអ្នកចូលរួមចំនួន ៤៤នាក់ មកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត និងលេខាធិការដ្ឋានអចិន្ត្រៃយ៍ NAP។ កិច្ចប្រជុំរៀបចំឡើងក្នុងគោលបំណង៖ ១. ណែនាំអំពីតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការថ្នាក់ក្រោមជាតិគ្រប់គ្រងទីជម្រាល និងពិភាក្សាអំពីកិច្ចការរដ្ឋបាល និងយន្តការសម្របសម្រួល។
- បានសម្របសម្រួល និងរៀបចំឯកសារទស្សនទាន លិខិតអញ្ជើញ លិខិតបេសកម្ម គម្រោងចំណាយ និងទីតាំងសម្រាប់ទស្សនកិច្ចសិក្សាអំពីបទពិសោធន៍ក្នុងការគ្រប់គ្រងដីកសិកម្មក្នុងស្រុករតនមណ្ឌល ខេត្តបាត់ដំបង របស់ក្រុមការងារកម្មវិធីសកម្មភាពជាតិ លេខាធិការដ្ឋានអចិន្ត្រៃយ៍ NAP និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត ដែលជាសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការថ្នាក់ក្រោមជាតិគ្រប់គ្រងទីជម្រាល។
- បានដំណើរការទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍ក្នុងការគ្រប់គ្រងដីកសិកម្ម ក្នុងស្រុករតនមណ្ឌល ខេត្តបាត់ដំបង ចាប់ពីថ្ងៃទី២៩ ខែកញ្ញា ដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២១។ ទស្សនកិច្ចសិក្សានេះមានអ្នកចូលរួមសរុបចំនួន ៨០នាក់ ដែលជាសមាជិក សមាជិកា ក្រុមការងារ NAP លេខាធិការដ្ឋានអចិន្ត្រៃយ៍ NAP និងគណៈកម្មាធិការថ្នាក់ក្រោមជាតិគ្រប់គ្រងទីជម្រាល រៀបចំឡើងក្នុងគោលបំណង៖ ១). បង្កើនចំណេះដឹងរបស់សមាជិក សមាជិកា ក្រុមការងារទាំងអស់ដែលស្ថិតក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់កម្មវិធីសកម្មភាពជាតិ ពាក់ព័ន្ធនឹងបច្ចេកទេស និងបទពិសោធន៍ក្នុងការអនុវត្តកសិកម្មអភិរក្ស និង ២). ពិភាក្សាអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការរៀបចំរបាយការណ៍ស្តីពីសកម្មភាពប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដីនៅថ្នាក់ក្រោមជាតិ។
- បានចូលរួមសិក្ខាសាលាស្តីពីកសិកម្មអភិរក្ស រៀបចំដោយសម្ព័ន្ធកសិកម្មអភិរក្ស តាមប្រព័ន្ធអនឡាញ
- បានរៀបចំទម្រង់បញ្ជីស្រង់ទិន្នន័យសម្រាប់ការអនុវត្តកម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រចាំនឹងការធ្លាក់ចុះគុណភាពដីឆ្នាំ ២០១៨-២០២០។
- បានចូលរួមកិច្ចប្រជុំផ្តល់យោបល់លើលទ្ធផលនៃការសិក្សាជំហានដំបូងរបស់គម្រោង Climate-sensitive agroecology: transitioning Battambang to an agroecological landscape របស់កម្ម-វិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)
- បានរៀបចំឯកសារត្រៀមសម្រាប់ការកសាងសមត្ថភាពគណៈកម្មាធិការគ្រប់គ្រងទីជម្រាល ថ្នាក់ក្រោមជាតិ ស្តីពីការរៀបចំផែនការគ្រប់គ្រងទីជម្រាល គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងដីកសិកម្មក្នុងតំបន់ទីជម្រាលស្ទឹងព្រែកត្នោត តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការថ្នាក់ក្រោមជាតិគ្រប់គ្រងទីជម្រាល និងទម្រង់ប្រមូលព័ត៌មានស្តីពីស្ថានភាព និងការវិវឌ្ឍន៍របស់ទីជម្រាល ជាដើម។
- បានផ្ញើជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត ដែលជាសមាជិកគណៈកម្មាធិការថ្នាក់ក្រោមជាតិគ្រប់គ្រងទីជម្រាល នូវឯកសារពាក់ព័ន្ធ រួមមាន (១) បញ្ជីទីជម្រាល និងផែនទីជម្រាលទាំង ៣៩ (២) សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការថ្នាក់ក្រោមជាតិគ្រប់គ្រងទីជម្រាលទាំង៣៩ (៣)បញ្ជីស្រង់ទិន្នន័យស្តីពីការអនុវត្តកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណ

ភាពដីឆ្នាំ២០១៨-២០២០ និង (៤) បានបោះពុម្ពសៀវភៅឯកសារមួយចំនួន ដូចជា កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដីឆ្នាំ២០១៨-២០២០ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងទីជម្រាលស្ទឹងព្រែកត្នោត ទស្សនទាន និងពាក្យគន្លឹះសំខាន់ៗស្តីពីអនុសញ្ញា UNCCD ការធ្លាក់ចុះគុណភាពដី ការប្រែប្រួលអាកាសធាតុ ជាដើម។

## ៥.៨. ការងារគ្រប់គ្រងឯកសារ និងប្រព័ន្ធព័ត៌មានកសិកម្ម

### ក. ការគ្រប់គ្រងឯកសារ

នៅក្នុងឆ្នាំ២០២១នេះ បណ្ណាល័យកសិកម្មមានសកម្មភាពការងារដូចខាងក្រោម៖

- បានទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តី ពីនាយកដ្ឋានកិច្ចការរដ្ឋបាល និងផ្នែកផ្សេងៗសរុបចំនួន២៤៩ ក្បាល/ច្បាប់
- បានចែករំលែកតាមការស្នើសុំរបស់ក្រសួង ស្ថាប័ន ជាទម្រង់សៀវភៅចំនួន១១៤ក្បាល ទម្រង់ភីឌីអេសចំនួន៦២១ក្បាល/ច្បាប់ និងចំនួន៧០វីដេអូ
- ការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិកដែលមានអ្នកចូលទស្សនាចំនួន១៣៥ ៦៥៩ដង/ នាក់ អ្នកបានបង្កើតគណនីប្រើប្រាស់សរុបចំនួន៨ ០៤៧នាក់
- ការស្កេនឯកសារ ដើម្បីបញ្ចូលក្នុងប្រព័ន្ធបណ្ណាល័យអេឡិចត្រូនិកបានចំនួន១២ក្បាល
- បញ្ចូលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម និងអត្ថបទផ្សេងៗសរុបចំនួន១៤៨ក្បាល/ច្បាប់ និងព្រឹត្តបត្រព័ត៌មានចំនួន៦៩ច្បាប់ និងឯកសារវីដេអូសរុបចំនួន៥១វីដេអូ លើគេហទំព័រE-Library និងបានផ្សព្វផ្សាយលើទំព័រហ្វេសប៊ុកផេករបស់មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម និងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន១៨៤ក្បាល/ច្បាប់ និងចំនួន៥២វីដេអូ
- ជំរុញការផ្សព្វផ្សាយឯកសារបច្ចេកទេសកសិកម្ម សេចក្តីជូនដំណឹង សារាចរណែនាំ សេចក្តីសម្រេចប្រកាស និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីជំរុញឲ្យបានទូលំទូលាយលើបណ្តាញផ្សព្វផ្សាយសង្គម (ហ្វេសប៊ុក) និងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ខ. ការគ្រប់គ្រងប្រព័ន្ធព័ត៌មានកសិកម្ម

- បានចូលរួមជួយសម្របសម្រួលរៀបចំរាល់ការប្រជុំជូនឯកឧត្តមរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំផ្សេងៗ តាមប្រព័ន្ធវីដេអូ (Zoom Meeting) ចំនួន៩៥លើក។
- ដកស្រង់ព័ត៌មានប្រចាំថ្ងៃសកម្មភាពរបស់ថ្នាក់ដឹកនាំក្រសួង និងតាមបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីផុសក្នុងហ្វេសប៊ុកផេកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួនផុស ១,៨១៨ព័ត៌មាន
- ដកស្រង់ព័ត៌មានកសិកម្មប្រចាំថ្ងៃចេញពីបណ្តាញផ្សព្វផ្សាយសារព័ត៌មានសរុបចំនួន២,៦៣៤ព័ត៌មាន
- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់អង្គភាពថ្នាក់កណ្តាល លើគេហទំព័រសរុបចំនួនផុស ៧៩ព័ត៌មាន
- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត លើគេហទំព័រសរុបចំនួនផុស ៤ ១៦១ព័ត៌មាន
- បញ្ចូលសកម្មភាពរបស់ឯកឧត្តមរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួង ចូលរួមជួបភៀវ ប្រជុំ និងចូលរួមកម្មវិធីផ្សេងៗ លើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន១២០ព័ត៌មាន

- តំហែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន១៧ (១៦ គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- បានដាក់ឲ្យដំណើរការប្រើប្រាស់អ៊ីម៉ែល (@maff.gov.kh) ផ្លូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ថ្នាក់ដឹកនាំប្រើប្រាស់ក្នុងការទំនាក់ទំនងផ្លូវការ
- បានបង្កើត Sub Domain (dal.maff.gov.kh) របស់នាយកដ្ឋាននីតិកម្មកសិកម្ម សម្រាប់ភ្ជាប់ទៅកាន់ប្រព័ន្ធ QR Code នៃព័ត៌មានផលិតផលថ្នាំកសិកម្មដែលបានចុះបញ្ជី
- បានកែសម្រួលគេហទំព័ររបស់ក្រសួង ដោយបន្ថែម Menu ជាភាសាអង់គ្លេសលើគេហទំព័ររបស់ក្រសួង ប្តូរចំណងជើង "អង្គភាពអមទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" ទៅជា "គេហទំព័រនាយកដ្ឋានអង្គភាពអមទីស្ដីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" ប្តូរចំណងជើង "អង្គភាពក្រោឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" ទៅជា "គេហទំព័រអនុវិស័យនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" និងបន្ថែម Mouse Over លើផែនទី នៃគេហទំព័របេស់ក្រសួង ឲ្យចេញឈ្មោះមន្ទីរ។
- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ (ក្រសួង អគ្គនាយកដ្ឋាន នាយកដ្ឋាន និងមន្ទីរ)
- តាមដានទិន្នន័យដែល ផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១ (ក្រសួង អគ្គនាយកដ្ឋាន នាយកដ្ឋាន និងមន្ទីរ)
- បានរៀបចំទិន្នន័យផ្ទៃដីប្រមូលផល និងបរិមាណផលដំណាំសាកវប្បកម្មរយៈពេលខ្លីប្រចាំឆ្នាំ២០២០ សម្រាប់ទិន្នន័យដំណាំកសិកម្ម រាជធានី ខេត្ត ដែលរួមមាន៖ ដំណាំពោតស ដំណាំដំឡូងជ្វា ដំណាំដំឡូងមី ដំណាំបន្លែគ្រប់មុខ ដំណាំម្ទេស និងដំណាំឪឡឹក និងប្រភេទដំណាំឧស្សាហកម្មរយៈពេលខ្លីប្រចាំឆ្នាំ២០២០ សម្រាប់ទិន្នន័យដំណាំកសិកម្ម រាជធានី-ខេត្ត ដែលរួមមាន៖ ដំណាំពោតក្រហម ដំណាំដំឡូងមី ដំណាំសណ្តែកដី ដំណាំសណ្តែកបាយ ដំណាំសណ្តែកសៀង ដំណាំក្រចៅ ដំណាំថ្នាំជក់ ដំណាំល្ង ដំណាំអំពៅ និងដំណាំឈូក
- បានរៀបចំទិន្នន័យផ្ទៃដីប្រមូលផល និងបរិមាណផលដំណាំសាកវប្បកម្មរយៈពេលវែងប្រចាំឆ្នាំ ២០២០ សម្រាប់ទិន្នន័យដំណាំកសិកម្ម រាជធានី-ខេត្ត ដែលរួមមាន៖ ដំណាំចេកធម្មតា ចេកអំបូងលឿង ដំណាំស្វាយ ដំណាំល្មុត ដំណាំពុទ្រា ដំណាំល្ហុង ដំណាំម្នាស់ ដំណាំមៀនរួមនឹងតាងែន ដំណាំក្រូចពោធិ៍សាត់ ដំណាំក្រូចថ្លុង ដំណាំខ្នុរ ដំណាំទុរេន ដំណាំស្រកានាគ ដំណាំត្របែក ដំណាំទៀប ដំណាំក្រូចឆ្មារ ដំណាំប៉័រ ដំណាំសាម៉ាវ ដំណាំផាសិន និងបរិមាណផលដំណាំឧស្សាហកម្មរយៈពេលវែង សម្រាប់ទិន្នន័យដំណាំកសិកម្ម រាជធានី-ខេត្ត ដែលរួមមាន៖ ដំណាំម្រេច ដំណាំដូង ដំណាំដូងប្រេង ដំណាំកាហ្វេ ដំណាំស្វាយចន្ទី
- បានចុះប្រមូលទិន្នន័យដំណាំសក្តានុពលក្នុងស្រុកសន្ទុក នៃខេត្តកំពង់ធំ ដើម្បីរៀបចំជាផែនទីដំណាំកសិកម្ម
- ប្រមូលបាននូវទិន្នន័យដំណាំសក្តានុពលដែលស្ថិតនៅក្នុងស្រុកសន្ទុក មានដំណាំសំខាន់ៗ ដូចជា ដំណាំស្រូវ ដំណាំស្វាយចន្ទីរ ដំណាំស្វាយ ដំណាំដំឡូងមី ដំណាំល្មើរ និងដំណាំកៅស៊ូ ដែលស្ថិតនៅក្នុងភូមិសាស្ត្រឃុំចំនួន៤ គឺឃុំកកោះ ឃុំជ្រប់ ឃុំទីពោ និងឃុំបឹងល្វា
- ប្រមូលបាននូវទិន្នន័យដំណាំសក្តានុពលនៅស្រុកកំពង់ស្វាយ ដែលស្ថិតនៅក្នុងភូមិសាស្ត្រឃុំត្បែង ដែលបានដាំដំណាំមានដូចជា ដំណាំស្វាយចន្ទីរ ដំណាំដំឡូងមី ដំណាំល្មើរ ដំណាំកៅស៊ូ និងដំណាំស្រូវ

- បានចុះបណ្តុះបណ្តាលការប្រើប្រាស់ និងផ្សព្វផ្សាយកម្មវិធីស្មាតហ្វូន (Mobile App) និងគេហទំព័រ (Website) របស់បណ្ណាល័យកសិកម្ម និងពិនិត្យអំពីការរៀបចំបណ្ណាល័យកសិកម្ម សម្រាប់តម្កល់ឯកសាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តចំនួន២ ដូចជាៈ ខេត្តកំពង់ចាម និងខេត្តព្រៃវែង។

**គ. ការចុះថតផ្តិតយករូបភាព និងការផលិតវីដេអូ**

- ថតយកសកម្មភាពឯកឧត្តមរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួងចូលរួមប្រជុំ និងសកម្មភាពការងារផ្សេងៗ មានចំនួន១២០ដង និងវីដេអូបច្ចេកទេសកសិកម្មសរុបចំនួន១៥០វីដេអូ ដែលមាននៅក្នុងយូធូប (YouTub) របស់ក្រសួង ដោយបានបញ្ចូលបានចំនួន០៣វីដេអូបន្ថែមទៀត ដើម្បីជំរុញការផ្សព្វផ្សាយតាមរយៈគេហទំព័រក្រសួង និងបណ្តាញផ្សព្វផ្សាយសង្គម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម បានផលិតវីដេអូបានចំនួន០១វីដេអូ ស្តីពីបទពិសោធន៍របស់កសិករដាំធុរេនក្នុងខេត្តមណ្ឌលគិរី។

## ៥.៩. ការលើកកម្ពស់ការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នៅក្នុងឆ្នាំ២០២១នេះ ការលើកម្ពស់ការងារផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានលទ្ធផលដូចខាងក្រោមៈ

**១. ការកសាងសមត្ថភាព**

- បានរៀបចំសិក្ខាសាលា ស្តីពីការរៀបចំគោលការណ៍ណែនាំសម្រាប់ភ្នាក់ងារផ្សព្វផ្សាយភូមិ ដើម្បីប្រមូលរាល់មតិយោបល់ពីសិក្ខាកាមសម្រាប់ជាធាតុចូលក្នុងការរៀបចំគោលការណ៍ណែនាំ ដែលមានអ្នកចូលរួមសរុប ១១០នាក់ ក្នុងនោះស្ត្រី ៤៦នាក់
- បើកវគ្គបណ្តុះបណ្តាលស្តីពី "វិធីសាស្ត្រផ្សព្វផ្សាយដោយប្រើប្រព័ន្ធសេវាព័ត៌មានវិទ្យា" នៅខេត្តព្រះសីហនុ ព្រះវិហារ និងខេត្តត្បូងឃ្មុំ ដោយបានចែករំលែកពីប្រភពចាំបាច់នានាដើម្បីស្វែងរកឯកសារទាញយកឯកសារប្រើប្រាស់ និងចែករំលែកឯកសារ ព្រមទាំងបានយល់ដឹងពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាពាក់ព័ន្ធនានាលើការងារផ្សព្វផ្សាយកសិកម្ម ដែលមានអ្នកចូលរួមសរុបចំនួន ៥៥នាក់ ក្នុងនោះស្ត្រី ០៩នាក់
- បើកវគ្គបណ្តុះបណ្តាលមន្ត្រីឱ្យក្លាយជាទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម នៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម សិក្ខាកាមទាំងអស់បានទទួលនូវចំណេះដឹង និងបទពិសោធន៍ថ្មីៗ ដែលគ្រូឧទ្ទេសបានបង្ហាញ ដែលមានអ្នកចូលរួមសរុបចំនួន ២៧នាក់ ក្នុងនោះស្ត្រី ០៦នាក់។

**២. ការកែលម្អ និងសេវាផ្សព្វផ្សាយ**

- បានសិក្សាពីតម្រូវការកសិករលើការផ្សព្វផ្សាយកសិកម្ម តាមរយៈប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្មនៅខេត្តព្រះសីហនុ កំពង់ឆ្នាំង និងខេត្តព្រះវិហារ ក្រុមការងារបានដឹងពីតម្រូវចាំបាច់លើការប្រើប្រាស់ និងប្រភពដែលកសិករងាយទទួលបានព័ត៌មាន និងបច្ចេកទេសកសិកម្ម ពីបណ្តាញផ្សព្វផ្សាយនានាលើសរសេររបាយការណ៍ស្រាវជ្រាវនេះ ដែលមានអ្នកចូលរួមសរុបចំនួន ៦៨០នាក់ ក្នុងនោះស្ត្រី ២០៥នាក់
- បានរៀបចំចងក្រងក្រុមអភិវឌ្ឍន៍កសិករផ្សព្វផ្សាយកសិកម្ម បានចំនួន០២ក្រុម នៅខេត្តក្រចេះ និងខេត្តកែប ដើម្បីបង្កភាពងាយស្រួលក្នុងការទំនាក់ទំនងការផ្សព្វផ្សាយបច្ចេកទេសថ្មីៗការផ្លាស់ប្តូរបទពិសោធន៍ បង្កើនផលិតភាពកសិកម្ម និងបង្កើនប្រាក់ចំណូលគ្រួសារ ដែលមានអ្នកចូលរួមសរុប ៨០នាក់ ក្នុងនោះស្ត្រី ៣៥នាក់
- សិក្សាការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំ បានចំនួន០២ឃុំ គឺខេត្តកំពត និងខេត្តកំពង់ឆ្នាំង ដែលអ្នកចូលរួមមាន ចំនួន៥០ក្នុងនោះស្ត្រី ១៥នាក់

- សិក្សាវិភាគសេដ្ឋកិច្ចគ្រួសារកសិករបានចំនួន០២ គឺនៅខេត្តកំពត និងខេត្តព្រះវិហារ ដែលមានអ្នកចូលក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងកសិករចំនួន ៤៥០នាក់ស្ត្រី១៧០នាក់

**៣ .ការងារផលិត និងផ្សព្វផ្សាយតាមប្រព័ន្ធសាធារណៈ**

- បានថត និងផលិតវីដេអូក្នុងទម្រង់ជាបទយកការណ៍ វេទិកាស្វែងយល់ពីកសិកម្ម នាទីចុះស្រែជាមួយកសិករ និងនាទីកសិករជួបជាមួយកសិករបានចំនួន៣៥ប្រធានបទ រួមមាន អនុវិស័យដំណាំចំនួន១៣ អនុវិស័យជលផលចំនួន១១ អនុវស័យសត្វចំនួន១០ និងអនុវិស័យព្រៃឈើចំនួន០១ រាល់ឯកសារដែលផលិតបានខាងលើ ត្រូវបានធ្វើការផ្សព្វផ្សាយតាមរយៈស្ថានីយទូរទស្សន៍ជាតិកម្ពុជារៀងរាល់សប្តាហ៍។
- បានផ្សព្វផ្សាយអត្ថបទបច្ចេកទេសកសិកម្ម ជាសំឡេង នៅស្ថានីយ៍វិទ្យុជាតិ FM105.70.75MHZ ចំនួន ៥៧ ប្រធានបទ ក្នុងនោះរួមមាន អនុវិស័យដំណាំចំនួន៣៨ អនុវិស័យសត្វចំនួន១៥ អនុវិស័យជលផលចំនួន០៣ និងអនុវិស័យព្រៃឈើចំនួន០១។
- បានចងក្រង និងបោះពុម្ពផ្សាយទស្សនាវដ្តីកសិកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំចំនួន៤លេខ ស្មើនឹង ៥២០០ច្បាប់ កូនសៀវភៅបច្ចេកទេសកសិកម្មបានចំនួន៤លេខស្មើនឹង១៦០០០ច្បាប់ ព្រឹត្តិបត្រព័ត៌មានកសិកម្មចំនួន០២លេខស្មើនឹង ២០០០ច្បាប់
- បានរៀបចំពិធីតាំងពិព័រណ៍ផលិតផលកសិកម្ម និងសម្ភារផ្សព្វផ្សាយកសិកម្មចំនួន០២លើក នៅខេត្តតាកែវ និងខេត្តកំពង់ស្ពឺ។

**៤. ការងារផ្សព្វផ្សាយកសិកម្មតាមប្រព័ន្ធសេវាព័ត៌មានវិទ្យា (ប្រព័ន្ធសាធារណៈ និងគេហទំព័រ)**

- ក្រសួងបានផ្សព្វផ្សាយតាមរយៈទំព័រ ហ្វេកប៊ុក វីដេអូបច្ចេកទេសកសិកម្មចំនួន ១៣៦វីដេអូ ឯកសារជាអត្ថបទបច្ចេកទេសកសិកម្មចំនួន១៦៥ ឯកសារសកម្មភាពការអនុវត្តការងារនិងព័ត៌មានផ្សេងៗបានចំនួន ២១៣សកម្មភាព និងលិខិតប្រកាសនានារបស់ក្រសួង និងរបស់រាជរដ្ឋាភិបាល ចំនួន ៤៩០លិខិត។
- ក្រសួងទទួលបានចំនួនអ្នកទាញយកឯកសារផ្សេងៗ សរុបមានចំនួន ១៨៤ ៤០២នាក់ និងអ្នកចូលទស្សនាសរុបចំនួន ១៣៤ ៧៩៩នាក់ ពីគេហទំព័រ (www.khmeragri.info , www.deaff.maff.gov.kh)
- ផ្នែកសេវាផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជន (Call Center) បានជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មនានាដល់កសិករ និងអតិថិជនបានចំនួន ១៤៦ សំណួរចម្លើយ មកពី២៥ រាជធានី-ខេត្ត ទូទាំងប្រទេស។

## ៥.១០. ការងារយេនឌ័រ និងកុមារ

ដោយអនុវត្តនូវគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ការការពារ និងអភិវឌ្ឍន៍កុមារក្នុងវិស័យកសិកម្ម ក្រុមការងារយេនឌ័រនិងកុមារប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចនូវលទ្ធផលសំខាន់ៗ ក្នុងឆ្នាំ២០២១ នេះ ដូចខាងក្រោមៈ

- បានបើកវគ្គបណ្តុះបណ្តាល ស្តីពីចំណេះដឹងយេនឌ័រ និងអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ហៅកាត់ថា(ស៊ី.ដ) សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសរុបចំនួន១២វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន៤៤៦នាក់ ក្នុងនោះ ស្ត្រីចំនួន២៤០នាក់
- បានសហការជាមួយអង្គការ FAO លើការអនុវត្តសាកល្បងនូវ វិធានពង្រឹងភាពអង់អាចដល់ស្ត្រីក្នុងសាលាគំរូ ផលិតកម្មសម្រាប់អាជីវកម្ម (WE-FBS) តាមរយៈសកម្មភាពធ្វើការជ្រើសរើសគ្រូបង្គោល

ថ្នាក់ជាតិ ផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ស្តីពីវិធានពង្រឹងភាពអង់អាចដល់ស្ត្រី តាមរយៈសាលាគំរូផលិតកម្មសម្រាប់អាជីវកម្ម ផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្គោលថ្នាក់ខេត្ត ស្តីពីវិធានពង្រឹងភាពអង់អាចដល់ស្ត្រី តាមរយៈសាលាគំរូផលិតកម្មសម្រាប់អាជីវកម្មកសិកម្ម ខេត្តបន្ទាយមានជ័យ និងសៀមរាប ដែលមានសិក្ខាកាមចូលរួម សរុប ចំនួន៨០ នាក់ ស្រីសរុប ៣៧នាក់ និងបានផ្តល់ការគាំទ្រ និងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងការបង្កើតអាជីវកម្មដូចជា ការចិញ្ចឹមមាន់ ការដាំបន្លែ ការចិញ្ចឹមសត្វ និងកែច្នៃផលិតកម្មកសិកម្ម សម្រាប់លក់ និងផ្គត់ផ្គង់គ្រួសារចំនួន ៥៥០នាក់ ស្ត្រីចំនួន ២៨៥នាក់

- រៀបចំសិក្ខាសាលាពិគ្រោះយោបល់អំពីសេចក្តីព្រាងគោលនយោបាយបញ្ជ្រាបយេនឌ័រ ក្នុងវិស័យព្រៃឈើដែលមានសិក្ខាកាមចូលរួម សរុប ចំនួន៤០នាក់ ស្រីសរុប ២១នាក់ នៅខេត្តកំពង់ចាម
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយការបញ្ជ្រាបយេនឌ័រ ក្នុងអនុវិស័យកសិកម្មដល់មន្ត្រីរាជការអគ្គនាយកដ្ឋានកសិកម្មដែលមានអ្នកចូលរួម ២៥នាក់ (ស្ត្រី១៣នាក់) នៅខេត្តកែប
- បើកវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយគោលនយោបាយ និងក្របខណ្ឌបញ្ជ្រាបយេនឌ័រនិងអភិវឌ្ឍន៍កុមារក្នុងវិស័យកសិកម្ម ចំនួន០២វគ្គ ដែលមានសិក្ខាកាមចូលរួម ចំនួនសរុប ៨៦នាក់ ក្នុងនោះស្ត្រីមានចំនួន ៤២នាក់ នៅខេត្តកណ្តាល
- បានសម្របសម្រួលកិច្ចពិភាក្សាស្តីពីការអភិវឌ្ឍន៍ និងការពារកុមារក្នុងវិស័យកសិកម្ម និងបញ្ជ្រាបយេនឌ័រ បានចំនួន២វគ្គ មានអ្នកចូលរួមសរុប ចំនួន៣២០នាក់ ស្ត្រីចំនួន ៩៧នាក់
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងខ្សែច្រវាក់ផលិតកម្មស្វាយចន្ទី អ្នកចូលរួមសរុប ចំនួន ៣០នាក់ ស្ត្រីចំនួន ១៨នាក់
- បានកំពុងរៀបចំផែនការសកម្មភាពការការពារ និងអភិវឌ្ឍន៍កុមាក្នុងវិស័យកសិកម្ម ឆ្នាំ២០២០-២០២៥
- បានកំពុងរៀបចំធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្ម។

### ៥.១១. ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្នុងឆ្នាំ២០២១នេះ ក្រសួងបានពង្រឹងកិច្ចដំណើរការកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយបានទទួលលទ្ធផលដូចខាងក្រោម៖

- បានចុះតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគាំទ្របច្ចេកទេសលើមុខងារដែលបានផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ សរុបចំនួន០៧ខេត្ត
- បានប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពីបែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់នៃការផ្តល់សេវារដ្ឋបាលក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរដ្ឋបាលរាជធានី ខេត្ត ចំនួន១០ លើក (អន្តរក្រសួងចំនួន០៤លើក)
- បានប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងសេចក្តីណែនាំអន្តរក្រសួងស្តីពីគោលការណ៍ នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទក្រសួង ចំនួន០៥ លើក

- បានរៀបចំសេចក្តីណែនាំអន្តរក្រសួងស្តីពីបែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់នៃការផ្តល់សេវារដ្ឋបាលក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរដ្ឋបាលរាជធានី ខេត្ត រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងមហាផ្ទៃ
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំអន្តរក្រសួងស្តីពីបែបបទ នីតិវិធី និងលក្ខខណ្ឌភ្ជាប់នៃការផ្តល់សេវារដ្ឋបាលក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរដ្ឋបាលរាជធានី ខេត្ត ក្រោមអធិបតីភាព **ឯកឧត្តម វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មាធិការពង្រឹងយន្តការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព និងដោះស្រាយបញ្ហាប្រឈមនានានៃការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន០៣លើក
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០) ដែលរៀបចំឡើងដោយលេខាធិការដ្ឋានគ.ជ.អ.ប។
- បានចូលរួមកិច្ចប្រជុំលើកទី១៩ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប។

## VI- បញ្ហាប្រឈម

បញ្ហាជាសាកលដែលបានកើតមានឡើងនាដើមឆ្នាំ២០២១នេះ គឺការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលជាប្រភេទដែលតា និងអូមីក្រុង បានក្លាយជាបញ្ហាប្រឈមដ៏ធំ និងបានប៉ះពាល់ធ្ងន់ធ្ងរដល់សេដ្ឋកិច្ច សង្គមនៅក្នុងតំបន់ និងពិភពលោក រួមទាំងកម្ពុជាផងដែរ។ កត្តាប្រែប្រួលអាកាសធាតុ ជាពិសេសគ្រោះរាំងស្ងួត និងគ្រោះជំនន់ទឹកភ្លៀង បានវាយលុកមកលើផលិតកម្មដំណាំកសិកម្ម សត្វ និងជលផល។ ផលិតភាពកសិកម្មនៅមានកម្រិតទាប ការប្រកួតប្រជែងទីផ្សារនៃផលិតផលកសិកម្មនៅពុំទាន់ដោះស្រាយបានឱ្យប្រសើរនៅឡើយ ការផ្ទេរបច្ចេកទេសកសិកម្មទំនើប និងសមស្របដល់កសិករនៅពុំទាន់បានគ្រប់គ្រាន់ស្របតាមសេចក្តីត្រូវការជាក់ស្តែង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រផលិតកម្មកសិកម្ម រួមមាន ប្រព័ន្ធស្រោចស្រពក្នុងកសិដ្ឋានដោយសន្សំសំចៃទឹក ផ្ទះសំណាញ់ ផ្លូវចូលកសិដ្ឋាន ដើម្បីសម្រួលការដឹកជញ្ជូនផលិតផលរបស់កសិករ ប្រព័ន្ធស្តុកទុក ឃ្លាំងសម្ងួត ឃ្លាំងត្រជាក់ នៅមិនទាន់បង្កើតបានគ្រប់គ្រាន់សម្រាប់ការធ្វើកសិកម្ម និងកសិ-ពាណិជ្ជកម្ម កង្វះការវិនិយោគលើការកែច្នៃផលិតផលកសិកម្ម និងកង្វះលទ្ធភាពទទួលបានហិរញ្ញប្បទានក្នុងអត្រាការប្រាក់ទាប។ ម្យ៉ាងវិញទៀតកៅស៊ូនិងឈើកៅស៊ូមិនទាន់កែច្នៃជាច្រើន ត្រូវបាននាំចេញក្រៅផ្លូវការ ដែលបណ្តាឱ្យបាត់ចំណូលជាតិ បាត់បង់ការងារ បាត់អត្តសញ្ញាណកៅស៊ូកម្ពុជា និងខ្វះវត្ថុធាតុដើម ធ្វើឱ្យរោងចក្រ សិប្បកម្មមួយចំនួនត្រូវបានបិទ ថ្លៃកៅស៊ូនៅទាបបើធៀបនឹងបណ្តាប្រទេសដ៏ទៃទៀត។

ផលិតកម្មសត្វមានកំណើនប្រែប្រួលយឺត ដោយការប្តូរវិយាបទពីផលិតកម្មសត្វតាមបែបប្រពៃណីទៅជាផលិតកម្មសត្វតាមបែបពាណិជ្ជកម្ម ការរីកលូតលាស់នៃពាណិជ្ជកម្មសត្វនៅមានកម្រិត ជាពិសេសពាក់ព័ន្ធនឹងធាតុចូលសំខាន់ៗ រួមមាន តម្លៃអគ្គិសនីខ្ពស់ វត្ថុធាតុសម្រាប់កែច្នៃចំណីសត្វ និងថ្នាំការពារព្យាបាលសត្វដែលមិនអាចផលិតក្នុងស្រុកបានហើយតម្រូវឱ្យមានការនាំចូល ឡូជីស្ទិក កង្វះខាតកម្លាំងពលកម្ម សត្វនិងផលិតផលសត្វ មិនទាន់ស្របតាមស្តង់ដារទីផ្សារតម្រូវ លទ្ធភាពទទួលបានព័ត៌មានទីផ្សារនៅមានកម្រិត បទដ្ឋានគតិយុត្តមិនទាន់គ្រប់ជ្រុងជ្រោយដើម្បីសម្រួល ពាណិជ្ជកម្មសត្វ ដោយមានការលំបាកកន្លងមក និងការប្រឈមដូចជាជំងឺឆ្លងរាតត្បាត។ ការ

ប្រកួតប្រជែងនៃទីផ្សារសាច់សត្វក៏ជាបញ្ហាប្រឈមខ្លាំង ដោយសារថ្លៃដើមផលិតកម្មខ្ពស់ ពិសេសថ្លៃចំណីសត្វ និងថ្នាំព្យាបាលសត្វជាដើម។

ផលនេសាទចាប់ពីធម្មជាតិមាននិន្នាការប្រែប្រួលជារៀងរាល់ឆ្នាំ ពិសេសការបម្រែបម្រួលអាកាសធាតុ និងការធ្វើទំនប់វារីអគ្គិសនីជាបន្តបន្ទាប់នៅផ្នែកខាងលើនៃទន្លេមេគង្គ នាំឱ្យទឹកឡើងយឺត និងមានកម្ពស់ទាបខុសប្រក្រតី។ ការរំលោភទន្ទ្រានកាន់កាប់ដីព្រៃលិចទឹក និងព្រៃកោងកាងខុសច្បាប់។ ម្យ៉ាងទៀត ថ្លៃដើមនៃការធ្វើវារីវប្បកម្មមានតម្លៃខ្ពស់ ជាហេតុនាំឱ្យពិបាកក្នុងការប្រកួតប្រជែងទីផ្សារ។ កង្វះហេដ្ឋារចនាសម្ព័ន្ធខ្សែច្រវាក់ផ្គត់ផ្គង់ត្រជាក់សម្រាប់គាំទ្រដល់ការអនុវត្តអនាម័យល្អ ដែលជាផ្នែកមួយជួយបង្កើនតម្លៃបន្ថែម។ សមត្ថភាពមន្ទីរពិសោធន៍ សម្រាប់វិភាគគុណភាព សុវត្ថិភាពផល ផលិតផលជលផលនៅមានកម្រិត។

នៅក្នុងផ្នែកព្រៃឈើ ការធ្វើឱ្យសម្រេចបាននូវការពង្រីកគម្របព្រៃឈើ គឺជាភារកិច្ចមួយដ៏ធំធេង និងត្រូវមានការយកចិត្តទុកដាក់ខ្ពស់។ ការធ្លាក់ចុះនូវផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើក្នុងដំណាក់កាលចុងក្រោយនេះគឺបណ្តាលមកពីកំណើននៃការប្រើប្រាស់ដីកសិកម្ម ស្របទៅនឹងកំណើនប្រជាពលរដ្ឋ និងការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចកសិកម្ម។ ការទប់ស្កាត់ការកាប់រានទន្ទ្រានយកដីព្រៃឈើតែងជួបប្រទះការលំបាក។ ប្រជាពលរដ្ឋនៅមូលដ្ឋានដែលរស់នៅក្នុង និងក្បែរតំបន់ព្រៃឈើនៅតែពឹងអាស្រ័យខ្លាំងលើព្រៃឈើ ហើយការគ្រប់គ្រងជនចំណាកស្រុកនៅមានភាពធូររលុងដែលជាសម្ពាធធ្ងន់ធ្ងរចំពោះធនធានព្រៃឈើ។

## VII- ទិសដៅអនុវត្ត

ក្នុងទិសដៅចូលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ច សម្រាប់ឆ្នាំ២០២២នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំរិះរកចំណុចគន្លឹះ និងវិធានការជាមូលដ្ឋាន ដើម្បីដាក់ចេញនូវទិសដៅ និងផែនការ សកម្មភាពសម្រាប់អនុវត្តបន្តដូចខាងក្រោម៖

### ១. ផែនការជំរុញផលិតកម្មដំណាំស្រូវ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម

- បង្កើនផលិតកម្មដំណាំស្រូវឱ្យបានក្នុងរង្វង់ ២,៥% ដោយកើនបរិមាណផលពី ១២,២១លានតោន នៅឆ្នាំ២០២១ ដល់ ១២,៥២លានតោន នៅឆ្នាំ២០២២ តាមរយៈការសិក្សាស្រាវជ្រាវនិងបន្សុទ្ធពូជស្រូវ ការពង្រឹងការត្រួតពិនិត្យនិងបញ្ជាក់គុណភាពគ្រាប់ពូជស្រូវ ការចុះបញ្ជីគ្រាប់ពូជស្រូវ ការផលិតនិងចែកចាយគ្រាប់ពូជស្រូវមានគុណភាពល្អ ការធ្វើពិពិធកម្មស្រូវក្រអូប និងស្រូវដែលមានអាយុកាលខ្លីធន់នឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងលើកកម្ពស់ការអនុវត្តផលិតកម្មដំណាំស្រូវតាមស្តង់ដារ ផលិតកម្មស្រូវនិរន្តរភាពនិងស្រូវសរីរាង្គ និងការអនុវត្តបង្គុំបច្ចេកទេសទំនើបក្នុងនិងក្រោយពេលប្រមូលផល
- បង្កើនផលិតកម្មដំណាំសាកវប្បកម្មឱ្យបានក្នុងរង្វង់ ៥% ដោយកើនបរិមាណផលពី ៤,៣៧លានតោន នៅឆ្នាំ២០២១ ដល់ ៤,៥៨លានតោន នៅឆ្នាំ២០២២ តាមរយៈការលើកកម្ពស់ផលិតដំណាំសាកវប្បកម្ម និងពិពិធកម្មប្រភេទដំណាំដែលមានតម្លៃបន្ថែមខ្ពស់ ការអនុវត្តបង្គុំបច្ចេកទេសទំនើប (ប្រព័ន្ធផ្ទះសំណាញ់ និងស្រោចស្រពទំនើប) ការប្រមូល បន្សុទ្ធនិងពង្រីកពូជដំណាំដែលមានសក្តានុពលទីផ្សារ ការចុះបញ្ជីប្រភេទពូជដំណាំសាកវប្បកម្ម ជាពិសេសពង្រីកពូជរុក្ខជាតិលម្អ និងគ្រឿងទេសសំខាន់ៗ ការលើកកម្ពស់ការអនុវត្តកសិកម្មល្អ និងស្តង់ដារកសិកម្មសរីរាង្គលើដំណាំបន្លែ និងដំណាំហូបផ្លែ។ ម្យ៉ាងទៀត ត្រូវជំរុញការរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យសាកវប្បកម្ម និងរៀបចំយុទ្ធសាស្ត្រតាមដំណាំសំខាន់ៗដូចជាស្វាយចេក និងដំណាំបន្លែ និងបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំស្តីពីស្តង់ដារកសិកម្មសរីរាង្គ និងស្តង់ដារដំណាំសំខាន់ៗ

- បង្កើនផលិតកម្មដំណាំឧស្សាហកម្មឱ្យបានក្នុងរង្វង់ ៥% ដោយកើនបរិមាណផលពី ១៩,១៦លានតោន នៅឆ្នាំ២០២១ ដល់ ២០,១២ លានតោននៅឆ្នាំ២០២២ តាមរយៈ ការជ្រើសរើសនិងការប្រើប្រាស់ពូជធន់និងមានគុណភាពល្អ ពិពិធកម្មប្រភេទដំណាំដែលមានតម្លៃបន្ថែមខ្ពស់ ការបន្សុទ្ធនិងពង្រីកពូជដំណាំដែលមានសក្តានុពលទីផ្សារ ការចុះបញ្ជីប្រភេទពូជដំណាំសក្កានុពល ការអនុវត្តបង្គុំបច្ចេកទេសទំនើបក្នុងពេលនិងក្រោយពេលការប្រមូល ការពង្រឹងការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពផលិតផលដំណាំឧស្សាហកម្ម ព្រមទាំងការជំរុញរៀបចំយុទ្ធសាស្ត្រតាមមុខដំណាំសំខាន់ៗ ដូចជា ដំណាំដំឡូងមី ស្វាយចន្ទី ពោត ជាដើម
- ជំរុញការនាំចេញផលិតផលកសិកម្មឱ្យបានក្នុងរង្វង់ ៧% ដោយកើនពី ៧,៩៨លានតោន នៅឆ្នាំ២០២១ ដល់ ៨,៥៤លានតោន នៅឆ្នាំ២០២២ តាមរយៈ ការពង្រឹងវិធានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ការជំរុញការអនុវត្តវិធានការពារដំណាំ ពង្រឹងនិងពង្រីកសមត្ថកិច្ចភូតគាមអនាម័យក្នុងការត្រួតពិនិត្យផលិតផលកសិកម្មនាំចេញ-នាំចូល ដើម្បីចូលរួមសម្រួលពាណិជ្ជកម្ម និងកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការរាតត្បាតសមាសភាពចង្រៃភូតគាមអនាម័យហាមឃាត់ ទប់ស្កាត់ការធ្លាក់ចុះគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម ដែលនាំឱ្យប៉ះពាល់ដល់សុខភាពប្រជាជននិងខូចទីផ្សារក្នុងស្រុកនិងទីផ្សារសម្រាប់នាំចេញរបស់កម្ពុជា
- ជំរុញសេវាវិភាគ (សំណាក) ឱ្យបានក្នុងរង្វង់ ១៥% ដោយកើនពី ៣ ៤៧២សំណាក នៅឆ្នាំ២០២១ ដល់ ៤ ០០០សំណាក នៅឆ្នាំ២០២២ តាមរយៈការពង្រឹងនិងពង្រីកសមត្ថភាពមន្ទីរពិសោធន៍ជាតិក្នុងការពិនិត្យវិភាគ និងវាយតម្លៃគុណភាពធាតុចូលកសិកម្ម (ពូជ ជី ថ្នាំកសិកម្ម) គុណភាពដី និងកម្រិតសំណល់ធាតុពុលក្នុងផលិតផលកសិកម្ម ដី និងទឹក ការធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈដល់អតិថិជន និងការកែលម្អសមត្ថភាពមន្ទីរពិសោធន៍ដើម្បីទទួលបានការទទួលជាស្តង់ដារអន្តរជាតិ ISO
- ពង្រឹងរចនាសម្ព័ន្ធនិងធុរកិច្ចរបស់សហគមន៍កសិកម្ម ឱ្យក្លាយជាសហគ្រាសកសិកម្មទំនើបតាមរយៈការបង្កើតយន្តការគ្រប់គ្រងសហគមន៍កសិកម្ម ដែលរួមមានសម្ព័ន្ធសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសហគមន៍កសិកម្ម និងការបន្តធ្វើទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍ជនបទ និងគ្រឹះស្ថានហិរញ្ញវត្ថុនានាក្នុងការផ្តល់ឥណទានដល់សហគមន៍កសិកម្ម និងសហគ្រាសកសិកម្មធុនតូចនិងមធ្យម ដើម្បីប្រមូលទិញកសិផល ការកែច្នៃ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តចាំបាច់ ដូចជា ឃ្លាំងស្តុកកសិផល ឡសម្ងួត ឃ្លាំងត្រជាក់ជាដើម ដើម្បីផ្សារភ្ជាប់កសិករខ្នាតតូចទៅនឹងទីផ្សារ។
- លើកកម្ពស់ផលិតភាពនិងប្រសិទ្ធភាពនៃប្រើប្រាស់គ្រឿងយន្តកសិកម្ម ព្រមទាំងផលិតភាពនិងប្រសិទ្ធភាពការប្រើប្រាស់ទឹកកសិកម្មអនុវត្តបច្ចេកវិទ្យាទំនើប (ស្រោចស្រពដោយបង្ហៀរបញ្ចូលស្រែ ទុយយោបំពង់បង្កប់ដី ឧបករណ៍ស្រោចស្រពដំណក់ទឹក សាចទឹក ជាដើម)
- បន្តស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាគ្រប់គ្រងនិងប្រើប្រាស់ធនធានដីកសិកម្មប្រកបដោយនិរន្តរភាពផ្នែកសេដ្ឋកិច្ចសង្គម និងបរិស្ថាន ដោយផ្តោតអាទិភាពលើបច្ចេកវិទ្យាកែលម្អជីជាតិដីនិងទឹក កសិកម្មវៃឆ្លាតនឹងអាកាសធាតុ យុទ្ធសាស្ត្រគ្រប់គ្រងធនធានដីកសិកម្មដែលមានភាពទន់ភ្លន់ជាមួយការជ្រើសរើសមុខដំណាំដែលមានសក្តានុពលសមស្របនឹងដី ការអភិវឌ្ឍបច្ចេកវិទ្យាកសិកម្មអភិរក្ស និងការពង្រឹងសមត្ថភាពប្រើប្រាស់ព័ត៌មានប្រព័ន្ធផ្កាយរណបនិងបច្ចេកវិទ្យាឌីជីថល

- ពង្រឹងសមត្ថភាពអង្គភាព និងការអនុក្របខ័ណ្ឌគតិយុត្ត ដើម្បីលើកកម្ពស់ផលិតភាព ប្រសិទ្ធភាពការងារ និងសេវាគាំទ្រ តាមរយៈការបន្តការរៀបចំក្របខ័ណ្ឌគោលនយោបាយ បទដ្ឋានគតិយុត្ត ការកសាងសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងធនធានមនុស្សក្នុងអនុវិស័យដំណាំ។

## ២. ផែនការបង្កើនផលិតកម្មដំណាំកៅស៊ូ

### ក. សូចនាករគោលដៅ

ក្នុងឆ្នាំ២០២២ ទិសដៅសំខាន់ៗ ដែលត្រូវឱ្យសម្រេច រួមមាន៖

- ជំរុញបង្កើនផ្ទៃដីចៀរឱ្យបាន ៣៣១ពាន់ហិកតា
- ជំរុញបង្កើនផលិតកម្មកៅស៊ូឱ្យដល់ ៤០១ពាន់តោន
- បង្កើនការនាំចេញកៅស៊ូឱ្យបានប្រមាណ ៣៨៩ពាន់តោន
- ប្រមូលចំណូលឱ្យសម្រេចតាមចំណុចដៅចំនួន១ ៥១០,៧លានរៀល
- អនុវត្តអនុកម្មវិធីនៃថវិកាកម្មវិធីឆ្នាំ២០២២ ឱ្យសម្រេចបាននូវចំណុចដៅដែលបានកំណត់
- រៀបចំគម្រោងថវិកាកម្មវិធីឆ្នាំ២០២៣។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បន្តយកចិត្តទុកដាក់លើការសិក្សា ស្រាវជ្រាវ និងកសាងលិខិតគតិយុត្តពាក់ព័ន្ធនានា
- បន្តខំជំរុញការប្រមូលចំណូល ឲ្យសម្រេចតាមគោលដៅ
- ជំរុញការពង្រីកផ្ទៃដីកៅស៊ូយកផល របស់ក្រុមហ៊ុនកសិឧស្សាហកម្មនិងកៅស៊ូគ្រួសារ
- បន្តពិនិត្យតាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- ពិនិត្យតាមដានការអនុវត្តចង្កោមសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២២ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី
- ជំរុញការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងផែនការសកម្មភាពនៃថវិកាកម្មវិធីឆ្នាំ២០២៣ តាមការពិនិត្យឡើងវិញនូវអនុកម្មវិធី ចង្កោមសកម្មភាព សូចនាករ ចំណុចដៅសូចនាករ និងថវិកាចំណាយដើម្បីឱ្យត្រូវនឹងស្ថានភាពនិងលទ្ធភាពជាក់ស្តែង
- អនុវត្តនិងតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិឆ្ពោះទៅឆ្នាំ២០៣០
- បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពីការដាំដុះ ថែទាំកូនកៅស៊ូ ការគ្រប់គ្រងសមាសភាពចង្រៃ ការយកផល និងការកែច្នៃ
- បន្តចុះផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកវិទ្យាដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ
- ជំរុញក្រុមហ៊ុនវិនិយោគដំណាំកៅស៊ូ ឱ្យសហការផ្តល់របាយការណ៍វឌ្ឍនភាពប្រចាំខែ មកអគ្គនាយកដ្ឋានកៅស៊ូ ដើម្បីបូកសរុបរាយការណ៍ជូនក្រសួង ក៏ដូចរាជរដ្ឋាភិបាល បានទាន់ពេលវេលា
- អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ (CSR) សម្រាប់ការនាំចេញកៅស៊ូ អនុវត្តបែបបទវិញ្ញាបនបត្របញ្ជាក់គុណភាពច្បារពូជ ជំរុញការអនុវត្តកម្មវិធីផ្លាស់ប្តូរក្លូនពហុភាគីក្នុងរង្វង់ប្រទេសជាសមាជិកនៃ IRRDB
- បង្កើនកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន (ខេត្ត ស្រុក និងសមត្ថកិច្ចនៅតាមច្រកព្រំដែន) ដើម្បីជួយទប់ស្កាត់សកម្មភាពការបើកស្នាក់ការប្រមូលទិញកៅស៊ូគ្រួសារដែលគ្មានលិខិតអនុញ្ញាត និងការនាំចេញកៅស៊ូនិងឈើកៅស៊ូមិនទាន់កែច្នៃទៅប្រទេសជិតខាងដោយខុសច្បាប់

- បន្តចូលរួមសន្និសីទ កិច្ចប្រជុំ និង សន្និបាតប្រចាំឆ្នាំរបស់សមាគមបណ្ដាប្រទេសផលិតកៅស៊ូធម្មជាតិ ក្រុមប្រឹក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍កៅស៊ូអន្តរជាតិ និងអង្គការកៅស៊ូអន្តរជាតិនានា
- បន្តពង្រឹងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារ និងអង្គការកៅស៊ូអន្តរជាតិនានា លើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិជ្ជាវិទ្យាសាស្ត្រ ព័ត៌មានអំពីការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់កៅស៊ូ និងអំពីនិន្នាការនៃតម្លៃកៅស៊ូលើទីផ្សារក្នុងនិងក្រៅប្រទេស
- ពង្រីកដៃគូសហប្រតិបត្តិការក្នុងការស្វែងរកថវិកានិងបច្ចេកទេស ដើម្បីគាំទ្រអភិវឌ្ឍន៍កៅស៊ូគ្រួសារ និងបន្តចូលរួមសហការជាមួយគ្រឹះស្ថានសិក្សានានាលើការបណ្តុះបណ្តាលធនធានមនុស្សក្នុងអនុវិស័យកៅស៊ូ

## ៣. ផែនការកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ

### ក. សូចនាករគោលដៅ

- ផលិតផលសាច់សរុបកើនពី២៤០ពាន់តោននៅឆ្នាំ២០១៩ ដល់២៧០ពាន់តោននៅឆ្នាំ២០២៣ (កំណើន ៣%ក្នុងមួយឆ្នាំ)
- អត្រានៃការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មឱ្យកើនគឺ ពី២៣% នៅឆ្នាំ២០១៩ ដល់៣០% នៅឆ្នាំ២០២៣
- កាត់បន្ថយអត្រាជំងឺឆ្លងសត្វឱ្យនៅក្រោម៥%។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បន្តផ្តល់សេវាបសុព្យាបាល និងបង្កើនសមត្ថភាព បច្ចេកទេសដល់កសិករចិញ្ចឹមសត្វ តាមរយៈកម្មវិធីចាក់វ៉ាក់សាំងការពារ ពិនិត្យព្យាបាលជំងឺសត្វ អនុវត្តវិធានជីវសុវត្ថិភាព បណ្តុះបណ្តាលបច្ចេកទេស និងអនុវត្តការចិញ្ចឹមសត្វល្អ ជាពិសេសជំរុញផ្លាស់ប្តូរឥរិយាបថពីការចិញ្ចឹមតាមបែបប្រពៃណីទៅជាការចិញ្ចឹមបែបទំនើបសម្រាប់ធ្វើពាណិជ្ជកម្ម ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារនាពេលបច្ចុប្បន្ន តាមរយៈការកែលម្អពូជ ចំណីមានគុណភាពល្អ និងកាត់បន្ថយជំងឺឆ្លងរាលដាលសត្វ។
- បន្តផ្តល់ការគាំទ្រធ្វើឱ្យប្រសើរនូវបរិយាកាសវិនិយោគលើការចិញ្ចឹមសត្វ និងផលិតចំណីសត្វ ដើម្បីធ្វើឱ្យថ្លៃដើម ផលិតកម្មសត្វទាបដោយការកែច្នៃវត្ថុធាតុដើមក្នុងស្រុកដែលមានស្រាប់ឱ្យអស់លទ្ធភាព
- បន្តពង្រឹងការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ ពង្រឹងការអនុវត្តច្បាប់ សមត្ថភាពមន្ត្រី និងបណ្តុះបណ្តាលពីបច្ចេកទេសពិឃាតសត្វ ប្រកបដោយមនុស្សធម៌ដល់ម្ចាស់សត្តឃាតដ្ឋាន និងអាជីវករពិឃាតសត្វ
- បន្តជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំនានា ពង្រឹងសមត្ថភាពមន្ត្រី និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ បង្កើនការត្រួតពិនិត្យនិងធ្វើអធិការកិច្ចអនាម័យសត្តឃាតដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វ រោងចក្រ/កន្លែងផលិតចំណី បសុឱសថ សន្និធិ កែច្នៃចំណីសត្វ ផលិតផលសត្វ សត្វ សាច់ និងចរាចរណ៍នាំចេញ នាំចូល នាំឆ្លងកាត់សត្វនិងផលិតផលសត្វ ដើម្បីបង្ការ ទប់ស្កាត់ការឆ្លងរាលដាលជំងឺសត្វ ការពារសុខភាពសត្វ សុខភាពសាធារណៈ សុខុមាលភាពសត្វ និងបរិស្ថាន
- ការបង្កើនសមត្ថភាពមន្ត្រីគ្រប់កម្រិត ដើម្បីផ្ទេរចំណេះដឹងលើជំនាញសុខភាពសត្វ និងផលិតកម្មសត្វ ដូចជាការចិញ្ចឹម ការបង្កាត់ពូជសត្វ សុវត្ថិភាពចំណីអាហារ បសុឱសថ ជីវៈសុវត្ថិភាព ការបង្ការជំងឺ ខ្សែច្រវ៉ាក់ផលិតកម្មសត្វ ការធ្វើពាណិជ្ជកម្មសត្វដល់វិស័យឯកជន អង្គការដៃគូអភិវឌ្ឍន៍ សហគមន៍ សមាគមកសិករចិញ្ចឹមសត្វ ដើម្បីបង្កើនផលិតភាពសត្វ។ លើសពីនេះទៀត ភ្នាក់ងារសុខភាពសត្វត្រូវបានបណ្តុះបណ្តាលពីជំនាញបច្ចេកទេសសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីសម្របសម្រួល ពិនិត្យ ព្យាបាលសត្វ និងផ្តល់ព័ត៌មានពីស្ថានភាពជំងឺសត្វដល់មន្ត្រីជំនាញបានទាន់ពេល

- ជំរុញលើកទឹកចិត្តសហគមន៍ចិញ្ចឹមសត្វ កសិករចិញ្ចឹមសត្វតាមកិច្ចសន្យា ដើម្បីលើកកម្ពស់ផលិតកម្មសត្វ ធានាបាននូវបរិមាណផ្គត់ផ្គង់ ការពារផលប្រយោជន៍នូវផលិតផលដែលផលិតបាន ក្នុងការកាត់បន្ថយការនាំចូលសត្វពីបរទេស និងឈានទៅរកការនាំចេញ
- បន្តពង្រឹងការសិក្សាស្រាវជ្រាវ ការអង្កេតតាមដានជំងឺឆ្លងសត្វ សំដៅរកឱ្យឃើញប្រភពជំងឺ និងឆ្លើយតបទាន់ពេលវេលា ព្រមទាំងពង្រឹងការស្រាវជ្រាវចំណីសត្វ បសុឱសថ ពូជសត្វដែលមានលក្ខណៈបន្សាំនឹងការប្រែប្រួលអាកាសធាតុ ធន់នឹងជំងឺ លូតលាស់លឿនស្របនឹងតម្រូវការទីផ្សារ និងការបង្កាត់ពូជសិប្បនិម្មិត រួមជាមួយនឹងការបង្កើនសមត្ថភាពមន្ទីរពិសោធន៍ សមត្ថភាពស្រាវជ្រាវ និងបង្កើនធនធាន (មនុស្ស សម្ភារ និងថវិកា) សម្រាប់ការស្រាវជ្រាវ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ
- បន្តកិច្ចពិភាក្សាពិគ្រោះយោបល់ ចែករំលែកព័ត៌មាន ជាមួយវិស័យឯកជន អង្គការសង្គមស៊ីវិល សហគមន៍ សមាគម និងកសិករចិញ្ចឹមសត្វពាក់ព័ន្ធនឹងការងារសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីដោះស្រាយបញ្ហាប្រឈមកើតមានឡើងលើការចិញ្ចឹមសត្វ តម្លៃទីផ្សារ ស្ថានភាពជំងឺឆ្លងសត្វ ការចរាចរណ៍សត្វ និងផលិតផលសត្វ
- លើកទឹកចិត្ត គាំទ្រ និងជួយសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ប្រទេសបញ្ជាទិញ ដើម្បីអន្តរាគមន៍បានចូលទីផ្សារក្នុងការប្រកួតប្រជែងផលិតផលរបស់ខ្លួន។ ជាពិសេសរៀបចំកែសម្រួលលិខិតបទដ្ឋានគតិយុត្ត នីតិវិធីក្នុងការផ្តល់សេវា និងបច្ចេកទេសបានឆាប់ រហ័សដល់អ្នកវិនិយោគ
- បន្តកិច្ចពិភាក្សាពិគ្រោះយោបល់ ចែករំលែកព័ត៌មាន ក្នុងគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការទាំងកម្រិតថ្នាក់ជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិនានាពាក់ព័ន្ធអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

## ៤. ផែនការជំរុញការគ្រប់គ្រងធនធានជលផល និងការអភិវឌ្ឍន៍វារីវប្បកម្ម

### ក. សូចនាករគោលដៅ

- នេសាទទឹកសាបៈ
  - នេសាទដាយត្រី ដាយបង្កង និងសិប្បកម្ម ១០ ០០០តោន
  - នេសាទគ្រួសារក្នុងដែននេសាទ ៣០០ ០០០តោន
  - នេសាទគ្រួសារក្នុងវាលស្រែ ១៤០ ០០០តោន
- អាជីវកម្មនេសាទសមុទ្រៈ ១៣០ ០០០តោន
- វារីវប្បកម្មៈ
  - ការចិញ្ចឹមត្រី-បង្គា ៣៦០ ០០០តោន
  - ការចិញ្ចឹមក្រពើ ៣០០ ០០០ក្បាល
  - ការផលិតកូនត្រីពូជ ៣០០ ០០០ ០០០កូន
- ការកែច្នៃផលនេសាទៈ
  - ការកែច្នៃផលនេសាទទឹកសាប ៨០ ០០០តោន
  - ការកែច្នៃផលនេសាទសមុទ្រ ១២ ០០០តោន
  - ការផលិតទឹកត្រី ៥០ ០០០ ០០០លីត្រ
- ការនាំចេញផលនេសាទៈ ១០ ០០០តោន
- ចំណូលថវិកាៈ ៣ ៥៩ ២០០ ០០០ រៀល។

## ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- ជំរុញការអភិវឌ្ឍវារីវប្បកម្មតាមគ្រប់រូបភាព ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារ កាត់បន្ថយការនាំចូល
- ជំរុញការបង្កើតបណ្តាញវារីវប្បករតាមតំបន់ដែលមានសក្តានុពល និងជំរុញការចិញ្ចឹមវារីសត្វដែលជាតម្រូវការទីផ្សារ
- ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ បង្កើនការត្រួតពិនិត្យ និងវិភាគគុណភាព សុវត្ថិភាពផល ផលិតផលជលផល
- ជំរុញលើកទឹកចិត្ត ផ្តល់បច្ចេកទេស និងផ្តល់វិញ្ញាបនបត្របញ្ជាក់ការអនុវត្តវារីវប្បកម្មល្អ និងវិញ្ញាបនបត្របញ្ជាក់ការអនុវត្តអនាម័យល្អ ដល់វារីវប្បករ និងអាជីវករកែច្នៃផលជលផល
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សហគមន៍នេសាទ ដើម្បីពង្រឹងការគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព
- សហការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទ ពិសេសអនុវត្តបទបញ្ជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការទប់ស្កាត់ បង្ក្រាប និងដកហូតដីព្រៃលិចទឹកដែលបានកាប់ទន្ទ្រានឈូសឆាយនៅជុំវិញបឹងទន្លេសាប
- ផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ និងអនុសាសន៍៧ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បន្តលែងកូនត្រីពូជក្នុងតំបន់ទឹកធម្មជាតិ ដើម្បីបង្កើនផលស្តុកក្នុងធម្មជាតិ សម្រាប់បម្រើសេចក្តីត្រូវការរបស់ប្រជាកសិករ
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ ជាពិសេសសហភាពអឺរ៉ុប ដើម្បីជំរុញការងារអភិវឌ្ឍន៍វារីវប្បកម្ម ការគ្រប់គ្រងធនធានជលផល ការប្រយុទ្ធប្រឆាំង និងការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត
- ពង្រឹងការងារសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផលទឹកសាប និងសមុទ្រ
- បង្កើនសមត្ថភាពផ្តល់សេវាសាធារណៈឱ្យកាន់តែល្អប្រសើរឡើង ដើម្បីជួយសម្រួលដល់ការនាំចេញផល ផលិតផលជលផល។

# ៥ ផែនការជំរុញការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើ និងសត្វព្រៃ

## ក. សូចនាករគោលដៅ

- បរិមាណផលឈើដាំកើនដល់២៧៥៣ាន់ម៉ែត្រគូប
- អត្រាចំណូលសហគមន៍ព្រៃឈើត្រូវបានកើនឡើង១៦%
- អត្រាបទល្មើសព្រៃឈើត្រូវបានកាត់បន្ថយ១០%
- ទំហំផ្ទៃដីដាំឈើ រដ្ឋ និងឯកជន កើនដល់១០៣ាន់ហ.ត
- សហគមន៍ព្រៃឈើចំនួន ១៦ ត្រូវបានបង្កើនប្រាក់ចំណូល។

## ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

- បន្តបង្ក្រាបបទល្មើសព្រៃឈើទាំងការកាប់ឈើខុសច្បាប់ និងការធ្វើពាណិជ្ជកម្មឈើខុសច្បាប់ ទប់ស្កាត់ការជួញដូរសត្វព្រៃ ដោយប្រើកម្លាំងសរុប បង្ក្រាបបទល្មើសនៃការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធយកដីព្រៃឈើ វាតយកដីព្រៃឈើធ្វើជាកម្មសិទ្ធិតាមគ្រប់រូបភាព ដោយចុះស្រាវជ្រាវ រុករកទីតាំងប្រព្រឹត្តបទល្មើស រកអ្នកសមគំនិត ដកហូតវត្ថុតាង ឃាត់ខ្លួនជនប្រព្រឹត្តបទល្មើស និងបំពេញនីតិវិធីបញ្ជូនទៅតុលាការ។ មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានមានសមត្ថកិច្ច និងនិរាករណ៍ ឬបញ្ឈប់ជាបន្ទាន់រាល់ការបញ្ជាក់លើលិខិតទិញ-លក់ ឬធ្វើបណ្ណកម្មសិទ្ធិ ពាក់ព័ន្ធនឹងដីគម្របព្រៃឈើឆ្នាំ២០០២

- បន្តជំរុញការស្តារ ដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរិល ដីព្រៃរងការធ្វើអាជីវកម្ម ដីទំនេររបស់រដ្ឋ និង ដីព្រៃដែលបានដកហូតពីសម្បទានដីសេដ្ឋកិច្ច ដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំង បង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ
- បន្តជំរុញការទប់ស្កាត់ និងមានវិធានការការពារភ្លើងឆេះព្រៃ តាមរយៈយន្តការគណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានី-ខេត្ត ដឹកនាំបញ្ជាផ្ទាល់ដោយប្រើប្រាស់កម្លាំងសរុប ប្រជាពលរដ្ឋ សហគមន៍ សិស្សានុសិស្ស ព្រះសង្ឃ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ព្រមទាំងចាត់វិធានការផ្លូវច្បាប់ចំពោះជន ណាដែលបានកាប់រុករាន ដុតព្រៃ និងកាន់កាប់ដីព្រៃឈើដែលឆេះដោយអនាធិបតេយ្យផ្ទុយនឹងច្បាប់ និង បទបញ្ជានានារបស់រាជរដ្ឋាភិបាល
- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើ ដោយជួយប្រជាសហគមន៍ជនបទឱ្យបង្កើនចំណូល លើក កម្ពស់ជីវភាពរស់នៅតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ហើយអង្គភាពជំនាញត្រូវជួយណែនាំដល់ប្រជាសហ-គមន៍អំពីបច្ចេក-ទេសនៃការធ្វើកសិកម្មចម្រុះប្រកបដោយភាពវៃឆ្លាត ដោយមិនពឹងផ្អែកខ្លាំងលើការ យកផលពីព្រៃឈើ និងសត្វព្រៃនោះឡើយ
- បន្តកិច្ចសហការ ជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ បណ្តា ប្រទេសផ្តល់ជំនួយ សហគមន៍មូលដ្ឋាន តាមរយៈអភិក្រមអភិក្រម "រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហ-គមន៍" ដើម្បីជួយពង្រឹងដល់ការអនុវត្តច្បាប់ និងការគ្រប់គ្រងព្រៃឈើ សត្វព្រៃ ការអនុវត្តគម្រោងការ បណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីរដ្ឋបាលព្រៃឈើ ការបង្កើនការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃ ឈើ-សត្វព្រៃ រួមទាំងការអនុវត្តកិច្ចព្រមព្រៀងអន្តរ-ជាតិផ្សេងៗទៀតក្នុងវិស័យព្រៃឈើផងដែរ ក្នុង គោលដៅប្រែក្លាយតំបន់សហគមន៍ព្រៃឈើឱ្យទៅជាតំបន់អេកូទេសចរណ៍ ប្រកបដោយភាពទាក់ទាញ និងការអភិវឌ្ឍបៃតងប្រកបដោយភាតរៈបរិស្ថាន
- បន្តអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដោយត្រូវជំរុញការ អភិវឌ្ឍបៃតង ដែលជាមូលដ្ឋានគ្រឹះនៃការទ្រទ្រង់កិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច សម្រាប់រយៈពេលវែង ដែលនឹងជួយលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងពង្រឹងភាពធន់ទៅនឹងអាកាសធាតុ
- បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌតំបន់ និងសាកល ដើម្បីជំរុញការអភិវឌ្ឍ បៃតងនេះ ជាពិសេស ការជំរុញវិស័យឯកជនឱ្យបង្កើនការវិនិយោគបៃតង ពង្រឹងប្រសិទ្ធភាពនៃការ វិនិយោគ ក្នុងគ្រប់វិស័យពាក់ព័ន្ធ និងលើកទឹកចិត្តក្នុងការអភិវឌ្ឍឧស្សាហកម្មបៃតង និងការប្រើប្រាស់ បច្ចេកវិទ្យាបៃតង
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើ ការផ្សព្វផ្សាយបទបញ្ជា សេចក្តីជូន ដំណឹង និងលិខិតបទដ្ឋានគតិយុត្តនានាដូចបានរៀបរាប់ខាងលើឱ្យបានគ្រប់ជ្រុងជ្រោយ
- បន្តជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋាន ឱ្យយល់ដឹងជា សាធារណៈអំពីផលប្រយោជន៍ដ៏ធំធេងនៃព្រៃឈើ ដើម្បីធានាការចូលរួមក្នុងកិច្ចការពារ អភិរក្ស និង អភិវឌ្ឍន៍ធនធានព្រៃឈើប្រកបដោយនិរន្តភាព។

## VIII- សេចក្តីសន្និដ្ឋាន

ផ្អែកលើសមិទ្ធផលដែលទទួលបានក្នុងរយៈពេលមួយឆ្នាំ នៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ រាជរដ្ឋាភិបាល ក្រសួងអាចវាយតម្លៃជារួមថា បើទោះបីជាប្រទេសជាតិយើងកំពុងទទួលរងនូវហានិភ័យបណ្តាលមក ពីវិបត្តិនៃជំងឺឆ្លងកូវីដ-១៩ ក៏ដូចជាបានជួបប្រទះនូវគ្រោះធម្មជាតិខ្លះៗក៏ដោយ ក្រោមការខិតខំប្រឹងប្រែងរបស់ក្រសួង

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិសេសតាមការណែនាំនិងតម្រង់ទិស ក៏ដូចជាការអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវវិធានការឆ្លើយតបនានា និងដោយមានការចូលរួមដ៏សកម្មពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ ព្រមទាំងការរួមចំណែកពីដៃគូអភិវឌ្ឍន៍គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយបាននូវការលំបាកផ្សេងៗដូចបានរៀបរាប់ខាងលើ និងបានធ្វើឱ្យផលិតកម្មកសិកម្មមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលកន្លងមកនេះ។ ជារួមផលិតផលកសិកម្ម ធានាបានការផ្គត់ផ្គង់ស្បៀងអាហារក្នុងស្រុក និងសល់សម្រាប់នាំចេញ។ ផលិតផលដំណាំកសិកម្ម ក្នុងនោះមាន ស្រូវ អង្ករ ដំណាំរួមផ្សំ ដំណាំឧស្សាហកម្ម និងដំណាំហូបផ្លែសំខាន់ៗមួយចំនួនដូចជា ស្វាយ ចេក មៀន ស្វាយចន្ទី។ល។ បានផលិតលើសពីការហូបចុកក្នុងស្រុក និងមានការនាំចេញច្រើន។ តែផលិតផល បន្លែ និងផ្លែឈើមួយចំនួន ផ្គត់ផ្គង់បានប្រមាណ ៧៦% ដែលនៅមានតម្រូវការនាំចូលប្រមាណជាង ២៤០ ពាន់តោនក្នុង១ឆ្នាំសម្រាប់បំពេញតម្រូវការហូបចុកក្នុងស្រុក។ ចំពោះផលិតកម្មសត្វវិញ ផលិតផ្គត់ផ្គង់ក្នុងស្រុកបានប្រមាណ ៨៧% ។

ពិតណាស់ថា ការជំរុញកំណើនវិស័យកសិកម្មនៅតែជាគោលដៅចម្បង ដើម្បីធានាសន្តិសុខស្បៀងអាហារូបត្ថម្ភ និងការនាំចេញ ពិសេសក្នុងពេលដែលកម្ពុជាកំពុងប្រឈមនឹងវិបត្តិការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩នេះ។ គោលដៅនេះអាចសម្រេចបានដោយសារគោលនយោបាយវិត្តារកម្មរបស់រាជរដ្ឋាភិបាល ក្នុងការវិនិយោគបន្ថែមលើការកសាងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យកសិកម្ម ការស្រាវជ្រាវ ការប្រើប្រាស់ពូជថ្មីៗ ការផ្សព្វផ្សាយបច្ចេកទេស ដើម្បីដើរតាមឱ្យទាន់ក្នុងបរិបទនៃសាកលភាវូបនីយកម្ម។ ម្យ៉ាងវិញទៀត ផលិតកម្មដំណាំកសិ-ឧស្សាហកម្មត្រូវបានវាយតម្លៃថានឹងបន្តកំណើនខ្ពស់ ដោយផ្អែកលើការកើនឡើងនៃតម្រូវការទីផ្សារអន្តរជាតិ ព្រមទាំងការកើនឡើងនៃការវិនិយោគលើផ្នែកកសិ-ឧស្សាហកម្មនេះជាបណ្តើរៗជាដើម។ ជាមួយគ្នានេះ អនុវិស័យកសិកម្មផ្សេងទៀត ពិសេសវារីវប្បកម្ម និងការចិញ្ចឹមសត្វត្រូវបានវាយតម្លៃថាបានបន្តកំណើនល្អប្រសើរគួរជាទីពេញចិត្ត។ ក្នុងបរិការណ៍នេះ ក្រសួងនឹងបន្តផ្តោតការផ្តល់អាទិភាពខ្ពស់ចំពោះការរៀបចំកសាងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម និងការអនុវត្តផែនការរយៈពេលមធ្យមនិងវែង ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីអភិវឌ្ឍន៍វិស័យកសិកម្ម ដែលទាមទារឲ្យមានការចូលរួមយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់តាមអភិក្រម "រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្ម" ដោយត្រូវធ្វើសមាហរណកម្មឲ្យកៀកទៅនឹងផលិតករ សហគមន៍កសិកម្មនៅមូលដ្ឋាន ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយដែលបាននិងកំពុងជួបប្រទះ ដោយមិនមើលរំលងអំពីការចុះធ្វើវេទិកាសាធារណៈក្នុងនាមក្រុមការងាររាជរដ្ឋាភិបាលចុះតាមមូលដ្ឋាននានានោះឡើយ។ ដោយឡែក ប្រជាកសិករទទួលបាននូវការយកចិត្តទុកដាក់ខ្ពស់ប្រកបដោយភាពកក់ក្តៅពីសំណាក់រាជរដ្ឋាភិបាល តាមរយៈការវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជនបទ និងការលើកកម្ពស់ផលិតភាពកសិកម្ម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងជំរុញការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលដោយបានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងជលផលឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសក្រសួងបានពង្រឹងកិច្ចសហការជាមួយគណៈបញ្ជាការឯកភាពរាជធានី ខេត្តយ៉ាងល្អប្រសើរ។ ចំពោះការងារកែទម្រង់ផ្នែកគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការណែនាំអនុវត្តនូវចំណុចគន្លឹះមួយចំនួន ដើម្បីបន្តនិរន្តរភាពលើការគ្រប់គ្រង និងអភិវឌ្ឍដីសម្បទានសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព។

ដោយឡែក កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំងវិស័យឯកជនផងដែរ កំពុងត្រូវបានពង្រឹងនិងយកចិត្តទុកដាក់ខ្ពស់ រួមទាំងការអភិវឌ្ឍធនធានមនុស្ស ការស្តារហេដ្ឋារចនាសម្ពន្ធ័គាំទ្រចាំបាច់នានា ដែលជាកត្តាគន្លឹះសំខាន់មិនអាចមើលរំលងបានឡើយ។ រីឯដំណើរការប្រព្រឹត្តទៅនៃការកែទម្រង់រដ្ឋបាលសាធារណៈ

ហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ ព្រមទាំងការបញ្រ្ជាបយេនឌ័រនិងកុមារ ក៏ដូចជាការលើកកម្ពស់ការពង្រឹងរចនាសម្ព័ន្ធចាត់តាំងក្បាលម៉ាស៊ីនដឹកនាំរបស់ក្រសួងទាំងថ្នាក់កណ្តាល រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំងអស់ ក៏ត្រូវបានពង្រឹងក្នុងស្មារតីយកចិត្តទុកដាក់ខ្ពស់ និងប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ លើសពីនេះទៀត សេវាគាំទ្រផ្សេងៗក៏បានសម្រេចលទ្ធផលការងារតាមផ្នែកនីមួយៗល្អប្រសើរ ស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល ពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ ទន្ទឹមនឹងនេះ អង្គភាពជំនាញនីមួយៗដែលជាសេនាធិការរបស់ក្រសួងនឹងបន្តអនុវត្តតាមទិសដៅគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដែលបានដាក់ចុះសម្រាប់ឆ្នាំ២០២២ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

សរុបសេចក្តីមក ដើម្បីរួមចំណែកក្នុងការសម្រេចបានគោលដៅយុទ្ធសាស្ត្រក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា លើការលើកស្ទួយវិស័យកសិកម្ម ក្នុងការបង្កើតការងារ ការធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជនបទ ពិសេសក្នុងកាលៈទេសៈដែលប្រទេសជាតិយើងកំពុងទទួលរងនូវហានិភ័យពីវិបត្តិនៃជំងឺឆ្លងកូវីដ-១៩នោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងខិតខំបន្តជំរុញការធ្វើទំនើបកម្មកសិកម្មឱ្យអស់លទ្ធភាព ដើម្បីឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ចជាតិ តាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្រោមការដឹកនាំតម្រង់ទិសប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

ថ្ងៃ................................ខែ.............ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី......................ខែ.......................ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# ឧបសម្ព័ន្ធ

# ស្ថិតិផ្ទៃដីភ្ជួររាស់ និងផ្ទៃដីដាំដុះដំណាំស្រូវរដូវវស្សាឆ្នាំ ២០២១

ឧបសម្ព័ន្ធទី ១

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហត) | ផ្ទៃដីភ្ជួររាស់ (ហ.ត) | | | | | ផ្ទៃដីសាប (ហត) | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហត) | | | | | | | | សរុបស្ទូងនិងព្រោះបុកដាំ (ហត) | ភាគរយ (%) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | គោ-ក្របី | | គ្រឿងយន្ត | | | ស្រូវស្រាល | | កណ្តាល | | ធ្ងន់ | ចំការ | ឡើងទឹក | | | |
| | | | | ហ.ត | % | ហ.ត | % | | សរុប | បង្កើនរដូវ | សរុប | បង្កើនរដូវ | | | | | | |
| 01 | បន្ទាយមានជយ័ | 252,320 | 264,905 | | - | 264,905 | 100.00 | | 105,500 | 97,259 | 117,889 | - | 31,803 | - | 9,713 | | 264,905 | 104.99 |
| 02 | បាត់ដំបង | 330,000 | 397,628 | | - | 397,628 | 100.00 | | 224,393 | 68,657 | 116,483 | - | 52,722 | 177 | 3,853 | | 397,628 | 120.49 |
| 03 | កំពង់ចាម | 86,500 | 102,239 | 672 | 0.66 | 101,567 | 99.34 | 117 | 55,617 | 13,977 | 25,868 | - | 19,644 | - | 1,050 | | 102,179 | 118.13 |
| 04 | កំពង់ឆ្នាំង | 122,000 | 138,425 | | - | 138,425 | 100.00 | 322 | 25,501 | 5,985 | 64,292 | - | 48,632 | - | - | | 138,425 | 113.46 |
| 05 | កំពង់ស្ពឺ | 113,600 | 122,661 | 13,330 | 10.87 | 109,331 | 89.13 | 4,724 | 18,791 | 1,284 | 61,708 | - | 41,948 | 214 | - | | 122,661 | 107.98 |
| 06 | កំពង់ធំ | 213,300 | 233,941 | | - | 233,941 | 100.00 | 707 | 78,275 | 36,713 | 99,584 | - | 47,938 | 339 | 3,633 | | 229,769 | 107.72 |
| 07 | កំពត | 133,000 | 152,468 | 80 | 0.05 | 152,388 | 99.95 | 1,028 | 20,597 | - | 91,339 | 20,597 | 40,532 | - | - | | 152,468 | 114.64 |
| 08 | កណ្តាល | 30,600 | 42,015 | | - | 42,015 | 100.00 | 38 | 24,691 | - | 10,556 | - | 4,643 | - | - | | 39,890 | 130.36 |
| 09 | កោះកុង | 10,250 | 9,168 | 507 | 5.53 | 8,661 | 94.47 | 230 | 2,936 | - | 5,605 | - | 627 | 659 | - | | 9,827 | 95.87 |
| 10 | ក្រចេះ | 40,000 | 40,450 | 1,211 | 2.99 | 39,239 | 97.01 | | 22,900 | 1,395 | 15,230 | - | 2,159 | 154 | - | | 40,443 | 101.11 |
| 11 | មណ្ឌលគិរី | 23,000 | 29,119 | | - | 29,119 | 100.00 | 1,628 | 10,968 | - | 14,741 | - | 1,090 | 1,177 | - | | 27,976 | 121.63 |
| 12 | ភ្នំពេញ | 7,070 | 6,348 | 10 | 0.16 | 6,338 | 99.84 | 16 | 3,451 | - | 2,054 | - | 839 | - | - | | 6,344 | 89.73 |
| 13 | ព្រះវិហារ | 92,605 | 95,462 | 1 | 0.00 | 95,461 | 100.00 | 1,169 | 7,038 | - | 68,743 | - | 18,784 | 3,481 | - | | 98,046 | 105.88 |
| 14 | ព្រៃវែង | 250,000 | 297,177 | | - | 297,177 | 100.00 | | 150,863 | 40,988 | 114,449 | - | 31,865 | - | - | | 297,177 | 118.87 |
| 15 | ពោធិសាត់ | 115,000 | 146,902 | | - | 146,902 | 100.00 | | 97,385 | 17,331 | 33,147 | - | 12,888 | 363 | 1,392 | | 145,175 | 126.24 |
| 16 | រតនគិរី | 30,000 | 20,802 | | - | 20,802 | 100.00 | 923 | 2,782 | - | 13,113 | - | 4,907 | 10,042 | - | | 30,844 | 102.81 |
| 17 | សៀមរាប | 189,730 | 197,210 | 810 | 0.41 | 196,400 | 99.59 | 35 | 39,220 | 355 | 111,050 | - | 35,330 | 1,590 | 2,865 | | 190,055 | 100.17 |
| 18 | ព្រះសីហនុ | 13,000 | 11,174 | | - | 11,174 | 100.00 | | - | - | 11,174 | - | - | - | - | | 11,174 | 85.95 |
| 19 | ស្ទឹងត្រែង | 27,500 | 27,462 | | - | 27,462 | 100.00 | 1,371 | 8,564 | - | 15,098 | - | 2,304 | 1,370 | - | | 27,336 | 99.40 |
| 20 | ស្វាយរៀង | 167,500 | 172,390 | | - | 172,390 | 100.00 | | 54,684 | 12,121 | 110,230 | - | 7,476 | - | - | | 172,390 | 102.92 |
| 21 | តាកែវ | 180,000 | 213,576 | | - | 213,576 | 100.00 | | 81,513 | 67,941 | 128,724 | - | 3,339 | - | - | | 213,576 | 118.65 |
| 22 | ឧត្តរមានជ័យ | 95,800 | 118,100 | | - | 118,100 | 100.00 | 4 | 2,755 | - | 88,695 | - | 5,570 | 200 | - | | 97,220 | 101.48 |
| 23 | កែប | 3,520 | 3,568 | | - | 3,568 | 100.00 | | 1,157 | 498 | 1,295 | - | 1,116 | - | - | | 3,568 | 101.36 |
| 24 | ប៉ៃលិន | 6,500 | 6,990 | | - | 6,990 | 100.00 | | 140 | - | 6,730 | - | 120 | - | - | | 6,990 | 107.54 |
| 25 | ត្បូងឃ្មុំ | 76,270 | 77,120 | | - | 77,120 | 100.00 | 80 | 15,395 | 4,360 | 28,460 | - | 33,265 | - | - | | 77,120 | 101.11 |
| សរុប | | **2,609,065** | **2,927,300** | **16,621** | **0.57** | **2,910,679** | **99.43** | **12,392** | **1,055,116** | **368,864** | **1,356,257** | **20,597** | **449,541** | **19,766** | **22,506** | | **2,903,186** | **111.27** |
| គួលេខឆ្នាំមុន | | **2,588,130** | **3,176,028** | **27,405** | **0.86** | **3,148,623** | **99.14** | **15,793** | **905,252** | **300,371** | **1,398,970** | **18,041** | **448,270** | **20,683** | **33,448** | | **2,806,623** | **108.44** |
| ប្រៀបធៀប | | **20,935** | **-248,728** | **-10,784** | **-0.30** | **-237,944** | **0.30** | **-3,401** | **149,864** | **68,493** | **-42,713** | **2,556** | **1,271** | **-917** | **-10,942** | | **96,563** | **3.44** |

# ផ្ទៃដីប៉ះពាល់ និងខូចខាតលើដំណាំស្រូវរដូវវស្សាឆ្នាំ ២០២១

ឧបសម្ព័ន្ធទី ២

| ល.រ | រាជធានី-ខេត្ត | បញ្ចប់ផ្ទៃដី អនុវត្តបាន | ប៉ះពាល់និងខូចខាតដោយប្រការផ្សេងៗ | | | | | | | | ផ្ទៃដីស្តារឡើងវិញ (ហ.ត) | ខូចខាតទាំងស្រុង (ហ.ត) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ប៉ះពាល់ (ហ.ត) | | | | ខូចខាត (ហ.ត) | | | | | |
| | | | រាំងស្ងួត | សត្វបំផ្លាញ | ទឹកជំនន់ | សរុប | រាំងស្ងួត | សត្វល្អិត | ទឹកជំនន់ | សរុប | | |
| 01 | បន្ទាយមានជយ័ | 264,905 | 32,704 | - | 37,223 | **69,927** | 4,689 | - | 24,684 | **29,373** | 120 | 29,253 |
| 02 | បាត់ដំបង | 397,628 | 135,759 | - | 28,857 | **164,616** | 26,903 | - | 14,704 | **41,607** | 25,249 | 16,358 |
| 03 | កំពង់ចាម | 102,179 | 2,597 | | | **2,597** | | | | - | | - |
| 04 | កំពង់ឆ្នាំង | 138,425 | | | 227 | **227** | | | 7 | **7** | | 7 |
| 05 | កំពង់ស្ពឺ | 122,661 | 3,558 | - | 638 | **4,196** | | | 41 | **41** | | 41 |
| 06 | កំពង់ធំ | 229,769 | 18,867 | - | 587 | **19,454** | 876 | - | 233 | **1,109** | 233 | 876 |
| 07 | កំពត | 152,468 | | | | - | | | | - | | - |
| 08 | កណ្តាល | 39,890 | 1,169 | - | 565 | **1,734** | 177 | - | 279 | **456** | | 456 |
| 09 | កោះកុង | 9,827 | | 10 | | **10** | | | | - | | - |
| 10 | ក្រចេះ | 40,443 | | | 187 | **187** | | | 70 | **70** | | 70 |
| 11 | មណ្ឌលគិរី | 27,976 | | | 2,456 | **2,456** | | | 799 | **799** | | 799 |
| 12 | ភ្នំពេញ | 6,344 | 840 | - | 269 | **1,109** | 330 | - | 14 | **344** | | 344 |
| 13 | ព្រះវិហារ | 98,046 | 1,233 | | | **1,233** | 372 | | | **372** | 372 | - |
| 14 | ព្រៃវែង | 297,177 | 18,325 | - | - | **18,325** | 221 | | | **221** | 221 | - |
| 15 | ពោធិសាត់ | 145,175 | 30,633 | | | **30,633** | 2,807 | | | **2,807** | 2,807 | - |
| 16 | រតនគិរី | 30,844 | | | 3,971 | **3,971** | | | 511 | **511** | | 511 |
| 17 | សៀមរាប | 190,055 | 2,880 | | | **2,880** | 2,580 | | | **2,580** | | 2,580 |
| 18 | ព្រះសីហនុ | 11,174 | | | | - | | | | - | | - |
| 19 | ស្ទឹងត្រែង | 27,336 | | | 354 | **354** | | | 164 | **164** | | 164 |
| 20 | ស្វាយរៀង | 172,390 | | | | - | | | | - | | - |
| 21 | តាកែវ | 213,576 | 3,182 | - | 439 | **3,621** | 118 | | | **118** | 118 | - |
| 22 | ឧត្តរមានជ័យ | 97,220 | 1,500 | | | **1,500** | 30 | | | **30** | | 30 |
| 23 | កែប | 3,568 | 75 | | | **75** | | | | - | | - |
| 24 | ប៉ៃលិន | 6,990 | 550 | | | **550** | | | | - | | - |
| 25 | ត្បូងឃ្មុំ | 77,120 | 99 | | | **99** | | | | - | | - |
| សរុប | | **2,903,186** | **253,971** | **10** | **75,773** | **329,754** | **39,103** | **-** | **41,506** | **80,609** | **29,120** | **51,489** |
| តួលេខឆ្នាំមុន | | **2,806,623** | **149,284** | **2,498** | **316,734** | **468,516** | **20,877** | **815** | **128,179** | **149,871** | **20,088** | **129,783** |
| ប្រៀបធៀប | | **96,563** | **104,687** | **-2,488** | **-240,961** | **-138,762** | **18,226** | **-815** | **-86,673** | **-69,262** | **9,032** | **-78,294** |

# បរិមាណផល និងទិន្នផលដំណាំស្រូវរដូវវស្សាតាមប្រភេទឆ្នាំ ២០២១

ឧបសម្ព័ន្ធទី ៣ក

| ល.រ | រាជធានី-ខេត្ត | ស្រូវស្រាល | | | | ស្រូវកណ្តាល | | | | ស្រូវធ្ងន់ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) | ផ្ទៃ.ដាំដុះ (ហត) | ផ្ទៃ.ប្រ.ផល (ហត) | ទិន្នផល (ត/ហត) | បរិ.ផល (តោន) |
| 01 | បន្ទាយមានជ័យ | 105,500 | 94,519 | 4.089 | 386,484 | 117,889 | 106,192 | 2.975 | 315,889 | 31,803 | 29,068 | 2.715 | 78,929 |
| 02 | បាត់ដំបង | 224,393 | 208,514 | 3.923 | 818,053 | 116,483 | 116,004 | 2.887 | 334,929 | 52,722 | 52,722 | 3.260 | 171,886 |
| 03 | កំពង់ចាម | 55,617 | 55,617 | 3.595 | 199,970 | 25,868 | 25,868 | 3.370 | 87,167 | 19,644 | 19,644 | 3.515 | 69,052 |
| 04 | កំពង់ឆ្នាំង | 25,501 | 25,494 | 4.290 | 109,368 | 64,292 | 64,292 | 3.391 | 217,995 | 48,632 | 48,632 | 3.426 | 166,636 |
| 05 | កំពង់ស្ពឺ | 18,791 | 18,781 | 3.201 | 60,118 | 61,708 | 61,677 | 3.165 | 195,211 | 41,948 | 41,948 | 3.512 | 147,336 |
| 06 | កំពង់ធំ | 78,275 | 78,035 | 3.189 | 248,836 | 99,584 | 98,973 | 2.495 | 246,894 | 47,938 | 47,929 | 2.748 | 131,717 |
| 07 | កំពត | 20,597 | 20,597 | 3.214 | 66,196 | 91,339 | 91,339 | 3.242 | 296,132 | 40,532 | 40,532 | 3.169 | 128,431 |
| 08 | កណ្តាល | 24,691 | 24,691 | 4.065 | 100,365 | 10,556 | 10,257 | 2.765 | 28,358 | 4,643 | 4,486 | 2.902 | 13,019 |
| 09 | កោះកុង | 2,936 | 2,936 | 2.793 | 8,199 | 5,605 | 5,605 | 2.783 | 15,600 | 627 | 627 | 2.734 | 1,714 |
| 10 | ក្រចេះ | 22,900 | 22,830 | 2.955 | 67,472 | 15,230 | 15,230 | 2.742 | 41,754 | 2,159 | 2,159 | 2.350 | 5,074 |
| 11 | មណ្ឌលគិរី | 10,968 | 10,819 | 3.353 | 36,279 | 14,741 | 14,091 | 3.243 | 45,691 | 1,090 | 1,090 | 2.854 | 3,111 |
| 12 | ភ្នំពេញ | 3,451 | 3,239 | 2.552 | 8,265 | 2,054 | 2,026 | 2.733 | 5,538 | 839 | 735 | 3.448 | 2,534 |
| 13 | ព្រះវិហារ | 7,038 | 7,038 | 2.879 | 20,259 | 68,743 | 68,743 | 2.995 | 205,875 | 18,784 | 18,784 | 2.998 | 56,314 |
| 14 | ព្រៃវែង | 150,863 | 150,863 | 4.234 | 638,688 | 114,449 | 114,449 | 2.842 | 325,289 | 31,865 | 31,865 | 2.911 | 92,771 |
| 15 | ពោធិសាត់ | 97,385 | 97,385 | 4.012 | 390,729 | 33,147 | 33,147 | 3.373 | 111,813 | 12,888 | 12,888 | 3.492 | 45,002 |
| 16 | រតនគិរី | 2,782 | 2,782 | 2.781 | 7,737 | 13,113 | 12,704 | 2.799 | 35,565 | 4,907 | 4,805 | 2.718 | 13,058 |
| 17 | សៀមរាប | 39,220 | 36,640 | 2.580 | 94,532 | 111,050 | 111,050 | 2.597 | 288,385 | 35,330 | 35,330 | 2.671 | 94,371 |
| 18 | ព្រះសីហនុ | - | | - | | 11,174 | 11,174 | 3.302 | 36,896 | - | | | |
| 19 | ស្ទឹងត្រែង | 8,564 | 8,564 | 2.644 | 22,641 | 15,098 | 14,934 | 2.859 | 42,693 | 2,304 | 2,304 | 2.556 | 5,888 |
| 20 | ស្វាយរៀង | 54,684 | 54,684 | 3.631 | 198,538 | 110,230 | 110,230 | 2.593 | 285,873 | 7,476 | 7,476 | 2.745 | 20,519 |
| 21 | តាកែវ | 81,513 | 81,513 | 3.599 | 293,352 | 128,724 | 128,724 | 3.323 | 427,757 | 3,339 | 3,339 | 3.462 | 11,558 |
| 22 | ឧត្តរមានជ័យ | 2,755 | 2,755 | 2.502 | 6,892 | 88,695 | 88,665 | 2.754 | 244,144 | 5,570 | 5,570 | 3.472 | 19,337 |
| 23 | កែប | 1,157 | 1,157 | 3.320 | 3,841 | 1,295 | 1,295 | 3.039 | 3,936 | 1,116 | 1,116 | 3.219 | 3,592 |
| 24 | ប៉ៃលិន | 140 | 140 | 2.971 | 416 | 6,730 | 6,730 | 3.202 | 21,552 | 120 | 120 | 3.333 | 400 |
| 25 | ត្បូងឃ្មុំ | 15,395 | 15,395 | 3.610 | 55,579 | 28,460 | 28,460 | 3.309 | 94,183 | 33,265 | 33,265 | 3.428 | 114,021 |
| សរុប | | **1,055,116** | **1,024,988** | **3.749** | **3,842,809** | **1,356,257** | **1,341,859** | **2.947** | **3,955,119** | **449,541** | **446,434** | **3.128** | **1,396,270** |
| តួលេខឆ្នាំមុន | | **905,252** | **838,111** | **3.515** | **2,946,283** | **1,398,970** | **1,346,202** | **2.898** | **3,901,378** | **448,270** | **438,396** | **3.095** | **1,356,814** |
| ប្រៀបធៀប | | **149,864** | **186,877** | **0.234** | **896,526** | **-42,713** | **(4,343)** | **0.049** | **53,741** | **1,271** | **8,038** | **0.033** | **39,456** |

# បរិមាណផល និងទិន្នផលដំណាំស្រូវរដូវវស្សាតាមប្រភេទឆ្នាំ ២០២១

ឧបសម្ព័ន្ធទី ៣៦

| ល.រ | រាជធានី-ខេត្ត | ស្រូវចំការ | | | | ស្រូវឡើងទឹក | | | | សរុប | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល | ផ្ទៃ.ដាំដុះ | ផ្ទៃ.ប្រ.ផល | ទិន្នផល | បរិ.ផល |
| | | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) | (ហត) | (ហត) | (ត/ហត) | (តោន) |
| 01 | បន្ទាយមានជ័យ | - | | - | | 9,713 | 5,873 | 2.546 | 14,955 | 264,905 | 235,652 | 3.379 | 796,257 |
| 02 | បាត់ដំបង | 177 | 177 | 1.960 | 347 | 3,853 | 3,853 | 2.722 | 10,488 | 397,628 | 381,270 | 3.503 | 1,335,703 |
| 03 | កំពង់ចាម | - | | - | | 1,050 | 1,050 | 2.827 | 2,968 | 102,179 | 102,179 | 3.515 | 359,157 |
| 04 | កំពង់ឆ្នាំង | - | | - | | - | | - | | 138,425 | 138,418 | 3.569 | 493,999 |
| 05 | កំពង់ស្ពឺ | 214 | 214 | 2.346 | 502 | - | | - | | 122,661 | 122,620 | 3.288 | 403,167 |
| 06 | កំពង់ធំ | 339 | 339 | 1.602 | 543 | 3,633 | 3,617 | 1.651 | 5,971 | 229,769 | 228,893 | 2.770 | 633,961 |
| 07 | កំពត | - | | - | | - | | - | | 152,468 | 152,468 | 3.219 | 490,759 |
| 08 | កណ្ដាល | - | | - | | - | | - | | 39,890 | 39,434 | 3.594 | 141,742 |
| 09 | កោះកុង | 659 | 659 | 2.701 | 1,780 | - | | - | | 9,827 | 9,827 | 2.777 | 27,293 |
| 10 | ក្រចេះ | 154 | 154 | 2.136 | 329 | - | | - | | 40,443 | 40,373 | 2.839 | 114,629 |
| 11 | មណ្ឌលគិរី | 1,177 | 1,177 | 1.059 | 1,246 | - | | - | | 27,976 | 27,177 | 3.176 | 86,327 |
| 12 | ភ្នំពេញ | - | | - | | - | | - | | 6,344 | 6,000 | 2.723 | 16,337 |
| 13 | ព្រះវិហារ | 3,481 | 3,481 | 2.123 | 7,389 | - | | - | | 98,046 | 98,046 | 2.956 | 289,837 |
| 14 | ព្រៃវែង | - | | - | | - | | - | | 297,177 | 297,177 | 3.556 | 1,056,748 |
| 15 | ពោធិសាត់ | 363 | 363 | 1.647 | 598 | 1,392 | 1,392 | 2.400 | 3,341 | 145,175 | 145,175 | 3.799 | 551,483 |
| 16 | រតនគិរី | 10,042 | 10,042 | 1.797 | 18,044 | - | | - | | 30,844 | 30,333 | 2.453 | 74,404 |
| 17 | សៀមរាប | 1,590 | 1,590 | 2.403 | 3,820 | 2,865 | 2,865 | 2.721 | 7,795 | 190,055 | 187,475 | 2.608 | 488,903 |
| 18 | ព្រះសីហនុ | - | | - | | - | | - | | 11,174 | 11,174 | 3.302 | 36,896 |
| 19 | ស្ទឹងត្រែង | 1,370 | 1,370 | 2.556 | 3,502 | - | | - | | 27,336 | 27,172 | 2.750 | 74,724 |
| 20 | ស្វាយរៀង | - | | - | | - | | - | | 172,390 | 172,390 | 2.929 | 504,930 |
| 21 | តាកែវ | - | | - | | - | | - | | 213,576 | 213,576 | 3.430 | 732,667 |
| 22 | ឧត្តរមានជ័យ | 200 | 200 | 2.500 | 500 | - | | - | | 97,220 | 97,190 | 2.787 | 270,873 |
| 23 | កែប | - | | - | | - | | - | | 3,568 | 3,568 | 3.186 | 11,369 |
| 24 | ប៉ៃលិន | - | | - | | - | | - | | 6,990 | 6,990 | 3.200 | 22,368 |
| 25 | ត្បូងឃ្មុំ | - | | - | | - | | - | | 77,120 | 77,120 | 3.420 | 263,783 |
| សរុប | | **19,766** | **19,766** | **1.953** | **38,600** | **22,506** | **18,650** | **2.441** | **45,518** | **2,903,186** | **2,851,697** | **3.254** | **9,278,316** |
| តួលេខឆ្នាំមុន | | **20,683** | **20,683** | **1.992** | **41,210** | **33,448** | **33,448** | **2.203** | **73,681** | **2,806,623** | **2,676,840** | **3.108** | **8,319,366** |
| ប្រៀបធៀប | | **-917** | **-917** | **-0.040** | **-2,610** | **-10,942** | **-14,798** | **0.238** | **-28,163** | **96,563** | **174,857** | **0.146** | **958,950** |

# ផ្ទៃដីភ្ជួររាស់ និងដាំដុះដំណាំស្រូវរដូវប្រាំងឆ្នាំ ២០២១

ឧបសម្ព័ន្ធទី ៤

| ល.រ | ឈ្មោះស្រុក | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) | | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពង្រោះ | សរុប | |
| | | | | ហ.ត | % | ហ.ត | % | | | | | |
| 01 | បន្ទាយមានជ័យ | 22,000 | 50,511 | - | - | 50,511 | 100.00 | | | 50,511 | 50,511 | 229.60 |
| 02 | បាត់ដំបង | 18,800 | 43,356 | - | - | 43,356 | 100.00 | | | 43,356 | 43,356 | 230.62 |
| 03 | កំពង់ចាម | 42,000 | 45,812 | 4,257 | 9.29 | 41,555 | 90.71 | 10 | 110 | 45,702 | 45,812 | 109.08 |
| 04 | កំពង់ឆ្នាំង | 37,000 | 42,927 | | - | 42,927 | 100.00 | | | 42,927 | 42,927 | 116.02 |
| 05 | កំពង់ស្ពឺ | 450 | 561 | 3 | 0.53 | 558 | 99.47 | | | 561 | 561 | 124.67 |
| 06 | កំពង់ធំ | 40,000 | 76,956 | | - | 76,956 | 100.00 | | | 76,956 | 76,956 | 192.39 |
| 07 | កំពត | 8,220 | 9,237 | | - | 9,237 | 100.00 | | | 9,237 | 9,237 | 112.37 |
| 08 | កណ្តាល | 55,400 | 55,047 | | - | 55,047 | 100.00 | | | 55,047 | 55,047 | 99.36 |
| 09 | កោះកុង | | - | | | | | | | | - | - |
| 10 | ក្រចេះ | 14,000 | 14,176 | | - | 14,176 | 100.00 | 1 | 3 | 14,164 | 14,167 | 101.19 |
| 11 | មណ្ឌលគិរី | 100 | 137 | | - | 137 | 107.00 | | | 130 | 130 | 130.00 |
| 12 | ភ្នំពេញ | 460 | 515 | | - | 515 | 100.00 | | | 515 | 515 | 111.96 |
| 13 | ព្រះវិហារ | 120 | 22 | | - | 22 | 100.00 | | | 22 | 22 | 18.33 |
| 14 | ព្រៃវែង | 75,000 | 111,279 | | - | 111,279 | 100.00 | | | 111,279 | 111,279 | 148.37 |
| 15 | ពោធិសាត់ | 9,500 | 33,544 | | - | 33,544 | 100.00 | | | 33,544 | 33,544 | 353.09 |
| 16 | រតនគិរី | | - | | | | | | | | - | - |
| 17 | សៀមរាប | 22,585 | 23,285 | | - | 23,285 | 100.00 | | | 23,285 | 23,285 | 103.10 |
| 18 | ព្រះសីហនុ | | - | | | | | | | | - | - |
| 19 | ស្ទឹងត្រែង | | 52 | | | 52 | | | | 52 | 52 | - |
| 20 | ស្វាយរៀង | 20,500 | 21,513 | | - | 21,513 | 100.00 | | | 21,513 | 21,513 | 104.94 |
| 21 | តាកែវ | 80,000 | 107,377 | | - | 107,377 | 100.00 | | | 107,377 | 107,377 | 134.22 |
| 22 | ឧត្តរមានជ័យ | 140 | 167 | | - | 167 | 100.00 | | | 140 | 140 | 100.00 |
| 23 | កែប | 20 | 21 | | - | 21 | 100.00 | | | 21 | 21 | 105.00 |
| 24 | ប៉ៃលិន | 665 | 780 | | - | 780 | 100.00 | | | 780 | 780 | 117.29 |
| 25 | ត្បូងឃ្មុំ | 12,240 | 12,320 | | - | 12,320 | 100.00 | 15 | 125 | 12,195 | 12,320 | 100.65 |
| **សរុប** | | **459,200** | **649,595** | **4,260** | **0.66** | **645,335** | **99.34** | **26** | **238** | **649,314** | **649,552** | **141.45** |
| **តួលេខឆ្នាំមុន** | | **459,599** | **602,312** | **4,246** | **0.70** | **598,066** | **99.30** | **74** | **456** | **597,052** | **597,508** | **130.01** |
| **ប្រៀបធៀប** | | **(399)** | **47,283** | **14** | **-0.05** | **47,269** | **0.05** | **-48** | **-218** | **52,262** | **52,044** | **8.71** |

# វិមាណផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ ២០២១

ឧបសម្ព័ន្ធទី ៥

| ល.រ | រាជធានី-ខេត្ត | រដូវប្រាំង | | | | រដូវវស្សា | | | | សរុបប្រចាំឆ្នាំ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | ទិន្នផល (ត /ហ.ត) | បរិមាណផល (តោន) |
| 01 | បន្ទាយមានជយ័ | 50,511 | 47,511 | 4.429 | 210,428 | 264,905 | 235,652 | 3.379 | 796,257 | 315,416 | 283,163 | 3.555 | 1,006,685 |
| 02 | បាត់ដំបង | 43,356 | 43,356 | 4.121 | 178,673 | 397,628 | 381,270 | 3.503 | 1,335,703 | 440,984 | 424,626 | 3.566 | 1,514,376 |
| 03 | កំពង់ចាម | 45,812 | 45,812 | 4.032 | 184,703 | 102,179 | 102,179 | 3.515 | 359,157 | 147,991 | 147,991 | 3.675 | 543,860 |
| 04 | កំពង់ឆ្នាំង | 42,927 | 42,927 | 4.650 | 199,609 | 138,425 | 138,418 | 3.569 | 493,999 | 181,352 | 181,345 | 3.825 | 693,608 |
| 05 | កំពង់ស្ពឺ | 561 | 561 | 3.282 | 1,841 | 122,661 | 122,620 | 3.288 | 403,167 | 123,222 | 123,181 | 3.288 | 405,008 |
| 06 | កំពង់ធំ | 76,956 | 76,956 | 4.443 | 341,945 | 229,769 | 228,893 | 2.770 | 633,961 | 306,725 | 305,849 | 3.191 | 975,906 |
| 07 | កំពត | 9,237 | 9,237 | 5.000 | 46,185 | 152,468 | 152,468 | 3.219 | 490,759 | 161,705 | 161,705 | 3.321 | 536,944 |
| 08 | កណ្តាល | 55,047 | 55,047 | 4.369 | 240,483 | 39,890 | 39,434 | 3.594 | 141,742 | 94,937 | 94,481 | 4.046 | 382,225 |
| 09 | កោះកុង | - | | - | | 9,827 | 9,827 | 2.777 | 27,293 | 9,827 | 9,827 | 2.777 | 27,293 |
| 10 | ក្រចេះ | 14,167 | 13,600 | 4.419 | 60,100 | 40,443 | 40,373 | 2.839 | 114,629 | 54,610 | 53,973 | 3.237 | 174,729 |
| 11 | មណ្ឌលគិរី | 130 | 130 | 4.254 | 553 | 27,976 | 27,177 | 3.176 | 86,327 | 28,106 | 27,307 | 3.182 | 86,880 |
| 12 | ភ្នំពេញ | 515 | 515 | 3.458 | 1,781 | 6,344 | 6,000 | 2.723 | 16,337 | 6,859 | 6,515 | 2.781 | 18,118 |
| 13 | ព្រះវិហារ | 22 | 22 | 3.500 | 77 | 98,046 | 98,046 | 2.956 | 289,837 | 98,068 | 98,068 | 2.956 | 289,914 |
| 14 | ព្រៃវែង | 111,279 | 111,279 | 4.871 | 541,988 | 297,177 | 297,177 | 3.556 | 1,056,748 | 408,456 | 408,456 | 3.914 | 1,598,736 |
| 15 | ពោធិសាត់ | 33,544 | 33,544 | 4.496 | 150,816 | 145,175 | 145,175 | 3.799 | 551,483 | 178,719 | 178,719 | 3.930 | 702,299 |
| 16 | រតនគិរី | - | | - | | 30,844 | 30,333 | 2.453 | 74,404 | 30,844 | 30,333 | 2.453 | 74,404 |
| 17 | សៀមរាប | 23,285 | 23,285 | 3.646 | 84,908 | 190,055 | 187,475 | 2.608 | 488,903 | 213,340 | 210,760 | 2.723 | 573,811 |
| 18 | ព្រះសីហនុ | - | | - | | 11,174 | 11,174 | 3.302 | 36,896 | 11,174 | 11,174 | 3.302 | 36,896 |
| 19 | ស្ទឹងត្រែង | 52 | 52 | 3.404 | 177 | 27,336 | 27,172 | 2.750 | 74,724 | 27,388 | 27,224 | 2.751 | 74,901 |
| 20 | ស្វាយរៀង | 21,513 | 21,513 | 4.265 | 91,756 | 172,390 | 172,390 | 2.929 | 504,930 | 193,903 | 193,903 | 3.077 | 596,686 |
| 21 | តាកែវ | 107,377 | 107,377 | 5.005 | 537,385 | 213,576 | 213,576 | 3.430 | 732,667 | 320,953 | 320,953 | 3.957 | 1,270,052 |
| 22 | ឧត្តរមានជ័យ | 140 | 140 | 3.500 | 490 | 97,220 | 97,190 | 2.787 | 270,873 | 97,360 | 97,330 | 2.788 | 271,363 |
| 23 | កែប | 21 | 21 | 3.524 | 74 | 3,568 | 3,568 | 3.186 | 11,369 | 3,589 | 3,589 | 3.188 | 11,443 |
| 24 | ប៉ៃលិន | 780 | 780 | 3.071 | 2,395 | 6,990 | 6,990 | 3.200 | 22,368 | 7,770 | 7,770 | 3.187 | 24,763 |
| 25 | ត្បូងឃ្មុំ | 12,320 | 12,320 | 4.246 | 52,305 | 77,120 | 77,120 | 3.420 | 263,783 | 89,440 | 89,440 | 3.534 | 316,088 |
| **សរុប** | | **649,552** | **645,985** | **4.534** | **2,928,672** | **2,903,186** | **2,851,697** | **3.254** | **9,278,316** | **3,552,738** | **3,497,682** | **3.490** | **12,206,988** |
| **តួលេខឆ្នាំមុន** | | **597,508** | **592,128** | **4.418** | **2,616,253** | **2,806,623** | **2,676,840** | **3.108** | **8,319,366** | **3,404,131** | **3,268,968** | **3.345** | **10,935,619** |
| **ប្រៀបធៀប** | | **52,044** | **53,857** | **0.115** | **312,419** | **96,563** | **174,857** | **0.146** | **958,950** | **148,607** | **228,714** | **0.145** | **1,271,369** |

# តុល្យភាពស្បៀងតាមបណ្តារាជធានី-ខេត្តឆ្នាំ ២០២២

ឧបសម្ព័ន្ធទី ៦

| ល.រ | រាជធានី-ខេត្ត | ចំនួនប្រជាជន (នាក់) | បរិមាណផល តោន | ទុកពូជ និងបាត់បង់ពេលប្រមូលផល១៣% តោន | ស្រូវចំណីនៅសល់ (កាត់ចេញ១៣%) តោន | គិតជាអង្ករ ៦៤% តោន | តម្រូវការស្បៀងជាអង្ករ តោន | តុល្យភាពស្បៀង (អង្ករ) តោន | តុល្យភាពស្បៀង (ស្រូវ) តោន |
|---|---|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 920,026 | 1,006,685 | 130,869 | 875,816 | 560,522 | 131,564 | **428,958** | **670,247** |
| 02 | បាត់ដំបង | 1,025,229 | 1,514,376 | 196,869 | 1,317,507 | 843,204 | 146,608 | **696,596** | **1,088,431** |
| 03 | កំពង់ចាម | 925,111 | 543,860 | 70,702 | 473,158 | 302,821 | 132,291 | **170,530** | **266,453** |
| 04 | កំពង់ឆ្នាំង | 549,446 | 693,608 | 90,169 | 603,439 | 386,201 | 78,571 | **307,630** | **480,672** |
| 05 | កំពង់ស្ពឺ | 929,403 | 405,008 | 52,651 | 352,357 | 225,508 | 132,905 | **92,603** | **144,692** |
| 06 | កំពង់ធំ | 706,327 | 975,906 | 126,868 | 849,038 | 543,384 | 101,005 | **442,379** | **691,217** |
| 07 | កំពត | 608,106 | 536,944 | 69,803 | 467,141 | 298,970 | 86,959 | **212,011** | **331,267** |
| 08 | កណ្តាល | 1,240,324 | 382,225 | 49,689 | 332,536 | 212,823 | 177,366 | **35,457** | **55,402** |
| 09 | កោះកុង | 130,219 | 27,293 | 3,548 | 23,745 | 15,197 | 18,621 | **-3,424** | **-5,350** |
| 10 | ក្រចេះ | 394,574 | 174,729 | 22,715 | 152,014 | 97,289 | 56,424 | **40,865** | **63,852** |
| 11 | មណ្ឌលគិរី | 101,343 | 86,880 | 11,294 | 75,586 | 48,375 | 14,492 | **33,883** | **52,942** |
| 12 | ភ្នំពេញ | 2,566,303 | 18,118 | 2,355 | 15,763 | 10,088 | 366,981 | **-356,893** | **-557,645** |
| 13 | ព្រះវិហារ | 279,521 | 289,914 | 37,689 | 252,225 | 161,424 | 39,972 | **121,452** | **189,769** |
| 14 | ព្រៃវែង | 1,102,716 | 1,598,736 | 207,836 | 1,390,900 | 890,176 | 157,688 | **732,488** | **1,144,513** |
| 15 | ពោធិសាត់ | 433,492 | 702,299 | 91,299 | 611,000 | 391,040 | 61,989 | **329,051** | **514,142** |
| 16 | រតនគិរី | 237,144 | 74,404 | 9,673 | 64,731 | 41,428 | 33,912 | **7,516** | **11,744** |
| 17 | សៀមរាប | 1,059,475 | 573,811 | 74,595 | 499,216 | 319,498 | 151,505 | **167,993** | **262,489** |
| 18 | ព្រះសីហនុ | 336,845 | 36,896 | 4,796 | 32,100 | 20,544 | 48,169 | **-27,625** | **-43,164** |
| 19 | ស្ទឹងត្រែង | 181,770 | 74,901 | 9,737 | 65,164 | 41,705 | 25,993 | **15,712** | **24,550** |
| 20 | ស្វាយរៀង | 545,683 | 596,686 | 77,569 | 519,117 | 332,235 | 78,033 | **254,202** | **397,191** |
| 21 | តាកែវ | 931,814 | 1,270,052 | 165,107 | 1,104,945 | 707,165 | 133,249 | **573,916** | **896,744** |
| 22 | ឧត្តរមានជ័យ | 302,787 | 271,363 | 35,277 | 236,086 | 151,095 | 43,299 | **107,796** | **168,431** |
| 23 | កែប | 45,008 | 11,443 | 1,488 | 9,955 | 6,371 | 6,436 | **-65** | **-102** |
| 24 | ប៉ៃលិន | 77,687 | 24,763 | 3,219 | 21,544 | 13,788 | 11,109 | **2,679** | **4,186** |
| 25 | ត្បូងឃ្មុំ | 798,701 | 316,088 | 41,091 | 274,997 | 175,998 | 114,214 | **61,784** | **96,538** |
| សរុប | | **16,429,054** | **12,206,988** | **1,586,908** | **10,620,080** | **6,796,849** | **2,349,355** | **4,447,494** | **6,949,209** |
| តួលេខឆ្នាំមុន | | **16,075,409** | **10,935,619** | **1,421,632** | **9,513,987** | **6,088,953** | **2,298,786** | **3,790,167** | **5,922,136** |
| ប្រៀបធៀប | | **353,645** | **1,271,369** | **165,276** | **1,106,093** | **707,896** | **50,569** | **657,327** | **1,027,073** |

***កំណត់សម្គាល់*** ៖ ជំរឿនប្រជាជនឆ្នាំ២០១៩ និងការធ្វើចំណោលឆ្នាំ២០២២ របស់ក្រសួងផែនការ

# ផលិតផលស្រូវឆ្នាំ ២០២១ និងតុល្យភាពស្បៀងឆ្នាំ ២០២២

ឧបសម្ព័ន្ធទី ៧

| កំរិតកំណត់ | ឯកត្តា | រដូវប្រាំង | រដូវវស្សា | សរុប |
|---|---|---|---|---|
| ផែនការដាំដុះ | ហ.ត | 459,200 | 2,609,065 | **3,068,265** |
| ផ្ទៃដីអនុវត្ត | ហ.ត | 649,552 | 2,903,186 | **3,552,738** |
| ផ្ទៃដីខូចខាត | ហ.ត | 3,567 | 51,489 | **55,056** |
| ផ្ទៃដីប្រមូលផល | ហ.ត | 645,985 | 2,851,697 | **3,497,682** |
| ទិន្នផលមធ្យម | ត/ហ.ត | 4.534 | 3.254 | **3.490** |
| បរិមាណផល | តោន | 2,928,672 | 9,278,316 | **12,206,988** |

**<u>កំណត់សម្គាល់</u>**

- កាត់ចេញ ១៣ភាគរយ លើបរិមាណសរុបសំរាប់ទុកពូជ ចំណីសត្វ និងបាត់បង់ពេលប្រមូលផល 1,586,908 តោន
- ស្រូវចំណីនៅសល់ ក្រោយពីកាត់ចេញ (១៣%) 10,620,080 តោន
- សរុបស្បៀងដែលមាន គិតជាអង្ករ 6,796,849 តោន
- តម្រូវការស្បៀងមួយឆ្នាំ 2,349,355 តោន
- បរិមាណអង្ករលើស **4,447,494** តោន
- គិតជាស្រូវលើស **6,949,209** តោន

# ផលិតកម្មដំណាំស្រូវរយៈពេល ១០ ឆ្នាំ ២០១២-២០២១

ឧបសម្ព័ន្ធទី ៨

| ឆ្នាំ-កំរិតកំណត់ | ឯកតា | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | មធ្យមភាគ ១០ឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះប្រចាំឆ្នាំ | ហត | 3,007,545 | 3,052,420 | 3,055,507 | 3,051,412 | 3,118,160 | 3,206,523 | 3,335,929 | 3,328,846 | 3,404,131 | 3,552,738 | 3,211,321 |
| - ប្រាំង | ហត | 495,507 | 484,697 | 490,935 | 489,455 | 518,574 | 548,755 | 596,483 | 597,508 | 597,508 | 649,552 | 546,897 |
| - វស្សា | ហត | 2,512,038 | 2,567,723 | 2,564,572 | 2,561,957 | 2,599,586 | 2,657,768 | 2,739,446 | 2,731,338 | 2,806,623 | 2,903,186 | 2,664,424 |
| ផ្ទៃដីប្រមូលផលប្រចាំឆ្នាំ | ហត | 2,980,297 | 2,968,967 | 3,028,836 | 3,025,630 | 3,099,769 | 3,189,485 | 3,248,061 | 3,263,774 | 3,268,968 | 3,497,682 | 3,157,147 |
| - ប្រាំង | ហត | 495,465 | 483,446 | 490,860 | 489,455 | 518,514 | 547,848 | 593,747 | 592,128 | 592,128 | 645,985 | 544,958 |
